# ខុទ្ទកនិកាយគាថាធម្មបទ

## វគ្គទី ២៥-២៦

ប្រែ និងរៀបរៀងដោយ ភិក្ខុ សុវណ្ណជោតោ **លឹម ធន់**

**ខេត្តបាត់ដំបង ព.ស ២៥៥០**

# ២៥. ភិក្ខុវគ្គវណ្ណនា

១ ចក្ខុនា សំវរោ សាធុ សាធុ សោតេន សំវរោ
ឃានេន សំវរោ សាធុ សាធុ ជិវ្ហា សំវរោ
កាយេន សំវរោ សាធុ សាធុ វាចាយ សំវរោ
មនសា សំវរោ សាធុ សាធុ សព្វត្ថ សំវរោ
សព្វត្ថ សំវុតោ ភិក្ខុ សព្វទុក្ខា បមុច្ចតិ ។

ការសង្រួមភ្នែកប្រពៃ ការសង្រួមត្រចៀកប្រពៃ ការសង្រួមច្រមុះប្រពៃ ការសង្រួមអណ្ដាតប្រពៃ ការសង្រួមកាយប្រពៃ ការសង្រួមវាចាប្រពៃ ការសង្រួមចិត្តប្រពៃ ការសង្រួមទាំងអស់ប្រពៃ ភិក្ខុសង្រួមហើយក្នុងទ្វារទាំងអស់ តែងរួចស្រឡះចាកទុក្ខទាំងពួងបាន ។

២ ហត្ថសញ្ញតោ បាទសញ្ញតោ
វាចាយ សញ្ញតោ សញ្ញតុត្តមោ

អជ្ឈត្តរតោ សមាហិតោ
ឯកោ សន្តុសិតោ តមាហុ ភិក្ខុ ។

ជនណា សង្រួមដៃ សង្រួមជើង សង្រួមវាចា សង្រួមអត្តភាព ជាអ្នកត្រេកអរក្នុងការចម្រើនកម្មដ្ឋានដែលមានក្នុងខ្លួន ជាអ្នកមានចិត្តតម្កល់មាំ ជាអ្នកនៅឯកឯង តែងមានចិត្តត្រេកអរក្នុងធម៌ បណ្ឌិតទាំងឡាយ ហៅជននោះថា ភិក្ខុ ។

៣ យោ មុខសញ្ញតោ ភិក្ខុ មន្តភាណី អនុទ្ធតោ
អត្ថំ ធម្មញ្ច ទីបេតិ មធុរំ តស្ស ភាសិតំ ។

ភិក្ខុណា សង្រួមមាត់ ជាអ្នកពោលដោយបញ្ញា មានចិត្តមិនរាយមាយ សម្តែងអត្ថផង ធម៌ផងបាន ភាសិតរបស់ភិក្ខុនោះទើបឈ្មោះថា ពីរោះ ។

៤ ធម្មារាមោ ធម្មរតោ ធម្មំ អនុវិចិន្តយំ
ធម្មំ អនុស្សរំ ភិក្ខុ សទ្ធម្មា ន បរិហាយតិ ។

ភិក្ខុមានធម៌ជាទីត្រេកអរ ត្រេកអរហើយ

ក្នុងធម៌ ពិចារណាធម៌ រឭកធម៌រឿយៗ រមែង
មិនសាបសូន្យចាកព្រះសទ្ធម្មឡើយ ។

៥ សលាភំ នាតិមញ្ញេយ្យ នាញ្ញេសំ បិហយញ្ចរេ
អញ្ញេសំ បិហយំ ភិក្ខុ សមាធឹ នាធិគច្ឆតិ ។
អប្បលាភោបិ ចេ ភិក្ខុ សលាភំ នាតិមញ្ញតិ
តំ វេ ទេវា បសំសន្តិ សុទ្ធាជីវមតន្ទិតំ ។

ភិក្ខុ មិនគប្បីមើលងាយលាភរបស់ខ្លួន ( ដែលកើតឡើងដោយធម៌ ) មិនគប្បីប្រព្រឹត្តចង់បានលាភរបស់ភិក្ខុដទៃ បើចង់បានលាភរបស់ភិក្ខុដទៃ រមែងមិនបានសមាធិឡើយ ។

បើភិក្ខុសូម្បីមានលាភតិច មិនមើលងាយលាភរបស់ខ្លួន ទេវតា និងមនុស្សទាំងឡាយ តែងសរសើរភិក្ខុនោះឯង ដែលជាអ្នកព្យាយាមជាគ្រឿងអាស្រ័យរស់នៅ ដោយបរិសុទ្ធ ជាអ្នកមិនខ្ជិលច្រអូស ។

៦ សព្វសោ នាមរូបស្មឹ យស្ស នត្ថិ មមាយិតំ

អសតា ច ន សោចតិ ស វេ ភិក្ខូតិ វុច្ចតិ ។

បុគ្គលណា មិនមានសេចក្តីប្រកាន់ក្នុង នាម និងរូប ថាជារបស់អញ ដោយប្រការទាំង ពួង មួយទៀត បុគ្គលណា មិនសោកស្តាយ ព្រោះនាម និងរូបដែលមិនមាន បុគ្គលនោះឯង តថាគតហៅថា ភិក្ខុ ។

៧ មេត្តាវិហារី យោ ភិក្ខុ បសន្នោ ពុទ្ធសាសនេ
អធិគច្ឆេ បទំ សន្តំ សង្ខារូបសមំ សុខំ ។
សិញ្ច ភិក្ខុ ឥមំ នាវំ សិត្តា តេ លហុមេស្សតិ
ឆេត្វា រាគញ្ច ទោសញ្ច តតោ និព្វានមេហិសិ ។
បញ្ច ឆិន្ទេ បញ្ច ជហេ បញ្ច ឧត្តរិ ភាវយេ
បញ្ចសង្គាតិគោ ភិក្ខុ ឱឃតិណ្ណោតិ វុច្ចតិ ។
ឈាយ ភិក្ខុ មា ច បមាទោ
មា តេ កាមគុណេ ភមស្សុ ចិត្តំ
មា លោហគុឡំ គិលី បមត្តោ
មា កន្ទិ ទុក្ខមិទន្តិ ឌយ្ហមានោ ។

នត្ថិ ឈានំ អបញ្ញស្ស នត្ថិ បញ្ញា អឈាយិនោ
យម្ហិ ឈានញ្ច បញ្ញា ច ស វេ និព្វានសន្តិកេ ។
សុញ្ញាគារំ បវិដ្ឋស្ស សន្តចិត្តស្ស ភិក្ខុនោ
អមានុសី រតី ហោតិ សម្មា ធម្មំ វិបស្សតោ ។
យតោ យតោ សម្មសតិ ខន្ធានំ ឧទយព្វយំ
លភតិ បីតិបាមោជ្ជំ អមតំ តំ វិជានតំ ។
តត្រាយមាទិ ភវតិ ឥធ បញ្ញស្ស ភិក្ខុនោ
ឥន្ទ្រិយគុត្តិ សន្តុដ្ឋិ បាតិមោក្ខេ ច សំវរោ
មិត្តេ ភជស្សុ កល្យាណេ សុទ្ធាជីវេ អតន្ទិតេ ។
បដិសន្ថារវុត្យស្ស អាចារកុសលោ សិយ
តតោ បាមោជ្ជពហុលោ ទុក្ខស្សន្តំ ករិស្សសិ ។

ភិក្ខុណា នៅដោយអំណាចមេត្តា ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះ រមែងបានបទដ៏ស្ងប់ ជាទីរម្ងាប់នូវសង្ខារ នាំមកនូវសេចក្តីសុខ ។ ម្នាលភិក្ខុ អ្នកចូរស្តារទូក គឺអត្តភាពនេះ ទូកដែលអ្នកស្តារហើយ នឹងដល់ត្រើយឆាប់ អ្នក

កាត់រាគៈ និងទោសៈបានហើយ អំពីនោះនឹង
អាចដល់នូវព្រះនិព្វាន ។ ភិក្ខុ គប្បីកាត់
ឱរម្ភាគិយសំយោជនៈ ៥ ផង គប្បីលះបង់
ឧទ្ធម្ភាគិយសំយោជនៈ ៥ ផង គប្បីចម្រើន
ឥន្ទ្រិយ ៥ តទៅ ភិក្ខុកន្លងកិលេសជាគ្រឿង
ជំពាក់ ៥ ( រាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ )
បានហើយ ទើបតថាគតហៅថា អ្នកឆ្លងអន្លង់បាន ។
ម្នាលភិក្ខុ អ្នកចូរពិនិត្យផង ចូរជាអ្នកកុំប្រមាទ
ផង ចូរកុំវិលទៅរកកាមគុណឡើយ អ្នកចូរកុំ
ប្រមាទ ទំពាស៊ីនូវដុំលោហៈ កុំឲ្យជាអ្នកកាល
ភ្លើងឆេះហើយ កន្ទក់កន្ទេញថា នេះទុក្ខ ដូច្នេះ
ឡើយ ។ ការពិនិត្យមិនមានដល់បុគ្គលអ្នកមិន
មានប្រាជ្ញា ប្រាជ្ញាមិនមានដល់បុគ្គលអ្នកមិន
ពិនិត្យ ការពិនិត្យ និងប្រាជ្ញា មានក្នុងបុគ្គលណា
បុគ្គលនោះឯង ឈ្មោះថា ស្ថិតនៅក្នុងទីជិតនៃ
ព្រះនិព្វាន ។ សេចក្តីត្រេកអរដែលមិនមែនជា

របស់មនុស្ស រមែងមានដល់ភិក្ខុអ្នកចូលទៅកាន់ផ្ទះស្ងាត់ អ្នកមានចិត្តរម្ងាប់ អ្នកឃើញធម៌ដោយប្រពៃ ។ ភិក្ខុពិចារណាការកើតឡើងនិងការវិនាសខន្ធទាំងឡាយ ក្នុងកាលណា ក្នុងកាលនោះ ភិក្ខុនោះរមែងបានបីតិ និងបាមោជ្ជ បីតិ និងបាមោជ្ជនោះ ឈ្មោះថា ជាអមតធម៌របស់បណ្ឌិតអ្នកដឹងធម៌ទាំងឡាយ ។ គុណ ៣ ប្រការនេះ គឺការរក្សាឥន្ទ្រិយ ១ សេចក្ដីសន្ដោស ១ ការសង្រួមក្នុងបាតិមោក្ខ ១ ជាខាងដើមនៃព្រះនិព្វាននោះ តែងមានដល់ភិក្ខុអ្នកមានបញ្ញាក្នុងសាសនានេះ ( ម្នាលភិក្ខុ ) អ្នកចូរគប់រកកល្យាណមិត្ត អ្នកមានព្យាយាមជាគ្រឿងរស់ដោយបរិសុទ្ធ ជាអ្នកមិនខ្ជិលច្រអូស ។ ភិក្ខុគប្បីជាអ្នកប្រព្រឹត្តធ្វើបដិសណ្ឋារៈ គប្បីជាអ្នកឈ្លាសក្នុងអាចារៈ ព្រោះហេតុទាំង ២ នោះ អ្នកនឹងបានបាមោជ្ជច្រើន នឹងធ្វើទីបំផុត

ទុក្ខបាន ។

៨ វស្សិកា វិយបុប្ផានិ  បទ្ទវានិ បមុញ្ចតិ
ឯវំ រាគញ្ច ទោសញ្ច  វិប្បមុញ្ចេថ ភិក្ខវោ ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីជម្រុះរាគៈ និងទោសៈចេញ ដូចម្លិះជម្រុះម្លិះទាំងឡាយ ដែលស្វិតហើយ ដូច្នោះ ។

៩ សន្តកាយោ សន្តវាចោ  សន្តមនោ សុសមាហិតោ
វន្តលោកាមិសោ ភិក្ខុ  ឧបសន្តោតិ វុច្ចតិ ។

ភិក្ខុអ្នកមានកាយស្ងប់រម្ងាប់ហើយ មានវាចារម្ងាប់ហើយ មានចិត្តរម្ងាប់ហើយ មានចិត្តតម្កល់មាំហើយ មានអាមិសក្នុងលោក ខ្ជាក់ចោលហើយ ទើបតថាគតហៅថា អ្នកស្ងប់រម្ងាប់ ។

១០ អត្តនា ចោទយត្តានំ  បដិមំសេតមត្តនា
សោ អត្តគុត្តោ សតិមា  សុខំ ភិក្ខុ វិហាហិសិ ។
អត្តាហិ អត្តនោ នាថោ  អត្តនា ហិ អត្តនោ គតិ
តស្មា សញ្ញម អត្តានំ  អស្សំ ភទ្រំវ វាណិជោ ។

អ្នកចូរដាស់តឿនខ្លួនដោយខ្លួនឯង ចូរពិនិត្យខ្លួនដោយខ្លួនឯង ម្នាលភិក្ខុ អ្នកនោះបើមានស្មារតី រក្សាខ្លួនទុកហើយ នឹងនៅជាសុខ ។

មែនពិត ខ្លួនជាទីពឹងរបស់ខ្លួន ខ្លួនឯងជាគតិរបស់ខ្លួន ព្រោះហេតុនោះ អ្នកចូររវាំងខ្លួន ដូចពាណិជរវាំងសេះដ៏ល្អ ។

១១ បាមោជ្ជពហុលោ ភិក្ខុ បសន្នោ ពុទ្ធសាសនេ
អធិគច្ឆេ បទំ សន្តំ សង្ខារូបសមំ សុខំ ។

ភិក្ខុអ្នកក្រាស់ដោយសេចក្តីរីករាយ ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា រមែងបាននូវបទដ៏ស្ងប់ជាទីរម្ងាប់នូវសង្ខារ នាំមកនូវសេចក្តីសុខ ។

១២ យោ ហវេ ទហរោ ភិក្ខុ យុញ្ជតិ ពុទ្ធសាសនេ
សោមំ លោកំ បភាសេតិ អព្ភាមុត្តោវ ចន្ទិមា ។

ភិក្ខុណានៅកំលោះ ប្រឹងប្រែង ក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះរមែងញ៉ាំងលោកឲ្យភ្លឺបាន ដូចព្រះចន្ទដែលរះផុតអំពីពពក ។

# ២៥ ភិក្ខុវគ្គវណ្ណនា

## ១ រឿងភិក្ខុ ៥ រូប

*សេចក្ដីខាងដើម*

ព្រះសាស្តា កាលគង់នៅវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុ ៥ រូប ត្រាស់ព្រះធម្មទេសនានេះថា “**ចក្ខុនា សំវរោ សាធុ**” ជាដើម ។

## ភិក្ខុ ៥ រូបរក្សាទ្វារផ្សេងៗ គ្នា

បានឮថា បណ្តាភិក្ខុ ៥ រូបនោះ មួយរូបៗ រមែងរក្សាទ្វារទាំង ៥ មានចក្ខុទ្វារជាដើម មួយរូបទ្វារមួយប៉ុណ្ណោះ ។

ថ្ងៃមួយ ភិក្ខុទាំង ៥ រូបនោះប្រជុំគ្នាហើយ ជជែកគ្នាថា “ ខ្ញុំរមែងរក្សាទ្វារដែលរក្សាបានដោយកម្រ, ខ្ញុំរមែងរក្សាទ្វារដែលរក្សាបានដោយកម្រ ” ហើយពោលថា “ ពួកយើងទូលសួរព្រះសាស្តាហើយ នឹងដឹងនូវសេចក្តីនេះ”ទើបចូលទៅគាល់ព្រះសាស្តា ក្រាបទូលសួរថា “ បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គរក្សាទ្វារមានចក្ខុទ្វារជាដើមហើយ រមែងសម្គាល់ថា ទ្វារដែលខ្លួនរក្សានោះ ជាទ្វារដែលរក្សាបានដោយកម្រ, បណ្តាពួកខ្ញុំព្រះអង្គ អ្នកណាហ្ន៎ រមែងរក្សាទ្វារដែលរក្សាបានដោយកម្រ ?” ។

## ព្រះសាស្តាទ្រង់កែខៃការយល់ខុសរបស់ភិក្ខុ ៥ រូប

ព្រះសាស្តាមិនទ្រង់ញ៉ាំងភិក្ខុទាំងនោះ សូម្បីតែមួយរូបឲ្យតូចចិត្តឡើយ ហើយទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ទ្វារទាំងនោះសូម្បីទាំងអស់ ជារបស់ដែលរក្សាបានដោយកម្រពិត ៗ, ម្យ៉ាងទៀត ពួកអ្នកមិនសង្រួមទ្វារទាំង ៥ តែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ, សូម្បីក្នុងកាលមុន ក៏អ្នកទាំងឡាយមិនបានសង្រួមដែរ, អ្នកទាំងឡាយមិនប្រព្រឹត្តតាមឱវាទរបស់បណ្ឌិតទាំងឡាយ ដល់នូវការអស់ទៅនៃជីវិត ក៏ព្រោះទ្វារទាំងនោះ ដែលខ្លួនមិនបានសង្រួមនោះ" កាលភិក្ខុទាំងនោះទូលសួរថា "ក្នុងកាលណា ព្រះអង្គ ?" ក៏ទ្រង់ញ៉ាំងរឿងបញ្ចកិរុកជាតកឲ្យពិស្តារ ហើយត្រាស់ព្រះគាថាទាំងនោះថា ៖-

( ព្រះរាជាពោធិសត្វពោលថា )យើងមិនបានលុះ
ក្នុងអំណាចនៃពួកយក្ខិនីឡើយ ព្រោះមានសេចក្តី
ព្យាយាមដ៏មាំ ក្នុងឧបាយគ្រឿងណែនាំរបស់ព្រះ
បច្ចេកពុទ្ធ ជាអ្នកឈ្លាសផង ព្រោះភាពជាអ្នក
គ្របសង្កត់សេចក្តីខ្លាច នឹងសេចក្តីតក់ស្លុតផង

សុវត្ថិភាពចាកភ័យដ៏ធំនោះ មានដល់ខ្ញុំ ។

ដែលព្រះពោធិសត្វអ្នកបានទទួលការ អភិសេក ហើយ ក្នុងកាលរាជត្រកូលដល់នូវការអស់ទៅនៃជីវិត ព្រោះអំណាចនៃអារក្សទឹកទាំងឡាយ ទ្រង់គង់នៅលើរាជ-អាសនៈពួដ៏ក្រោមស្វេតច្ឆត្រ ទតមើលសិរីសម្បត្តិរបស់ព្រះអង្គហើយ ត្រាស់ថា "ដែលឈ្មោះថាសេចក្តីព្យាយាមនេះ សត្វទាំងឡាយគួរតែបំពេញ" ហើយទ្រង់បន្លឺឧទានឡើង ដោយអំណាចនៃសេចក្តីរីករាយ ទ្រង់ប្រជុំជាតកថា "សូម្បីកាលនោះ អ្នកទាំងឡាយជាជន ៥ នាក់ មានអាវុធក្នុងដៃ បោមរោមព្រះរាជាពោធិសត្វ ដែលស្តេចចេញទៅដើម្បីដណ្តើមយករាជសម្បត្តិក្នុងក្រុងតក្កសិលា ធ្វើទៅតាមផ្លូវមិនសង្រួមក្នុងអារម្មណ៍ទាំងឡាយ មានរូបារម្មណ៍ជាដើម ដែលយក្ខិនីទាំងឡាយនាំចូលមក ដោយអំណាចនៃទ្វារមានចក្ខុ-ទ្វារជាដើម ក្នុងចន្លោះផ្លូវ មិនប្រព្រឹត្តតាមឱវាទរបស់បណ្ឌិត សម្លឹងមើលយក្ខិនីនោះ ត្រូវយក្ខិនីទាំងឡាយទំពាស៊ី ដល់នូវការអស់ទៅនៃជីវិត, ចំណែកព្រះរាជាដែលទ្រង់សង្រួមក្នុង

អារម្មណ៍ទាំងនោះ មិនអើពើនិងនាងយក្ខិនីដែលមានភេទដូចជាទេវតា សូម្បីជាប់តាមទៅខាងក្រោយ ៗ ក៏ដោយ ក៏ស្តេចយាងទៅដល់ក្រុងតក្កសិលាដោយសិរីសួស្តី ហើយដល់កាលជាព្រះរាជា គឺតថាគតនេះឯង” ហើយត្រាស់ថា “ធម្មតាភិក្ខុ គួរសង្រួមទ្វារសូម្បីទាំងអស់, ព្រោះថា ភិក្ខុថាសង្រួមទ្វារទាំងនោះហើយ រមែងរួចផុតចាកទុក្ខទាំងពួងបាន” ដូច្នេះហើយ កាលនឹងទ្រង់សម្តែងធម៌ បានទ្រង់ភាសិតព្រះគាថាទាំងនេះថា ៖-

១ ចក្ខុនា សំវរោ សាធុ សាធុ សោតេន សំវរោ
ឃានេន សំវរោ សាធុ សាធុ ជិវ្ហា សំវរោ
កាយេន សំវរោ សាធុ សាធុ វាចាយ សំវរោ
មនសា សំវរោ សាធុ សាធុ សព្វត្ថ សំវរោ
សព្វត្ថ សំវុតោ ភិក្ខុ សព្វទុក្ខា បមុច្ចតិ ។

ការសង្រួមភ្នែកប្រពៃ ការសង្រួមត្រចៀកប្រពៃ ការសង្រួមច្រមុះប្រពៃ ការសង្រួមអណ្តាតប្រពៃ ការសង្រួមកាយប្រពៃ ការសង្រួមវាចា

ប្រពៃ ការសង្រួមចិត្តប្រពៃ ការសង្រួមទាំងអស់ប្រពៃ ភិក្ខុសង្រួមហើយក្នុងទ្វារទាំងអស់ តែងរួចស្រឡះចាកទុក្ខទាំងពួងបាន ។

## អធិប្បាយគាថា

គប្បីជ្រាបការវិនិច្ឆ័យក្នុងបទថា **ចក្ខុនា** ជាដើម ក្នុងព្រះគាថានោះ ដូចតទៅនេះ ៖-

ក៏កាលណា រូបារម្មណ៍មកកាន់គន្លងចក្ខុទ្វាររបស់ភិក្ខុ, ក្នុងកាលនោះ កាលភិក្ខុមិនត្រេកអរនិងអារម្មណ៍ដែលជាទីប្រាថ្នា មិនប្រទូស្តនិងអារម្មណ៍ដែលមិនជាទីប្រាថ្នា មិនញ៉ាំងមោហៈឲ្យកើតឡើង ក្នុងការសម្លឹងមើលនូវអារម្មណ៍ដែលមិនស្មើ, ការសង្រួម គឺការរារាំង បានដល់ការបិទ សំដៅដល់ការគ្រប់គ្រង ឈ្មោះថា ជាកិរិយាដែលភិក្ខុធ្វើហើយក្នុងទ្វារនោះ, ការសង្រួមចក្ខុទ្វារបែបនោះ របស់ភិក្ខុនោះ ជាគុណញ៉ាំងប្រយោជន៍ឲ្យសម្រេច ។ន័យសូម្បីក្នុងទ្វារដទៃមានសោតទ្វារជាដើម ក៏ដូច្នេះដែរ ។

ក៏ការសង្រួមឬការមិនសង្រួម រមែងមិនកើតក្នុងទ្វារទាំងឡាយ មានចក្ខុទ្វារជាដើមឡើយ, ប៉ុន្តែការសង្រួមឬការមិនសង្រួមនេះ រមែងមានក្នុងវិថីនៃជវនខាងមុខ, ពិតណាស់ក្នុងគ្រានោះ ការមិនសង្រួមកាលកើតឡើងជាអកុសលធម៌ ៥ យ៉ាងនេះគឺ "ការមិនជឿ ការមិនអត់ធន់ ការខ្ជិលច្រអូស ការវង្វេងភ្លេចសតិ ការមិនដឹង" រមែងមានក្នុងអកុសលវិថី។ ការសង្រួមកាលកើតឡើងជាកុសលធម៌ ៥ យ៉ាងនេះគឺ ការជឿ ១ ការអត់ធន់ ១ ការព្យាយាម ១ ការរលឹកបាន ១ការដឹង ១ " រមែងមានក្នុងកុសលវិថី ។

ក៏កាយបសាទក្តី ចោបនកាយក្តី រមែងបានក្នុងពីរបទនេះថា "**កាយេន សំវរោ**" ក៏ពាក្យថាបសាទកាយ និងចោ-បនកាយ សូម្បីទាំងពីរនោះ គឺកាយទ្វារនោះឯង ។ ក្នុងកាយទ្វារទាំងពីរនោះ ព្រះមានព្រះភាគត្រាស់ការសង្រួមនិងការមិនសង្រួមទុកក្នុងបសាទទ្វារ ។ ត្រាស់បាណាតិបាត អទិន្នាទាន និងមិច្ឆាចារដែលមានបសាទទ្វារនោះជាទីតាំងទុកក្នុងចោបនទ្វារ ។ ទ្វារនោះឈ្មោះថាកិក្ខុមិនសង្រួមហើយ ព្រោះ

អកុសលទាំងនោះ កើតឡើងក្នុងអកុសលវិថី ព្រមដោយបសាទទ្វារនិងចោបនទ្វារទាំងនោះ, ទ្វារនោះ ឈ្មោះថា ភិក្ខុនោះសង្រួមហើយ ព្រោះវិរតិទាំងឡាយ មានចេតនាជាគ្រឿងវៀរចាកបាណាតិបាតជាដើម កើតឡើងក្នុងកុសលវិថី

ចោបនវាចា ត្រាស់ទុកសូម្បីក្នុងបទពីរនេះថា "**សាធុ វាចាយ**" ទ្វារនោះឈ្មោះថាភិក្ខុមិនសង្រួមហើយ ព្រោះវចីទុច្ចរិតទាំងឡាយមានមុសាវាទជាដើម ដែលកើតឡើងព្រមដោយចោបនវាចានោះ, ឈ្មោះថា ភិក្ខុសង្រួមហើយ ព្រោះវិរតិទាំងឡាយមានចេតនាជាគ្រឿងវៀរចាកមុសាវាទជាដើម

មនោទុច្ចរិតទាំងឡាយមានអភិជ្ឈាជាដើម មួយអន្លើដោយចិត្តដទៃអំពីចិត្តដែលជាជវន រមែងមិនមានសូម្បីក្នុងពីរបទនេះថា " **មនសា សំវរោ** " ប៉ុន្តែទ្វារនោះ ឈ្មោះថាភិក្ខុមិនសង្រួម ព្រោះមនោទុច្ចរិតទាំងឡាយ មានអភិជ្ឈាជាដើមកើតឡើងក្នុងខណៈនៃជវនចិត្តក្នុងមនោទ្វារ, ឈ្មោះថាសង្រួមហើយ ព្រោះមនោសុចរិតទាំងឡាយមានអភិជ្ឈាជាដើម ដែលកើតឡើងក្នុងខណៈនៃជវនចិត្តក្នុងមនោទ្វារ ។

ពីរបទថា **សាធុ សព្វត្ថ** សេចក្ដីថា ការសង្រួមទ្វារទាំងពួងមានចក្ខុទ្វារជាដើមនោះ ជាគុណញុំាងប្រយោជន៍ឲ្យសម្រេច ។ ក៏ព្រះមានព្រះភាគទ្រង់សម្ដែងដែលភិក្ខុសង្រួម ៨ យ៉ាង និងទ្វារដែលភិក្ខុមិនសង្រួម ៨ យ៉ាងនោះ រមែងមិនផុតអំពីទុក្ខដែលមានវដ្ដៈជាមូលទេ, ចំណែកភិក្ខុអ្នកតាំងនៅក្នុងទ្វារដែលសង្រួង រមែងរួចផុតចាកទុក្ខទាំងពួងដែលមានវដ្ដៈជាមូល, ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា “ **សព្វត្ថ សំវុតោ ភិក្ខុ សព្វទុក្ខា បមុច្ចតិ** ” ។

ក្នុងកាលចប់ទេសនា ភិក្ខុ ៥ រូបនោះតាំងនៅក្នុងសោតាបត្តិផល, ទេសនាជាគុណជាតិមានប្រយោជន៍សូម្បីដល់មហាជនដែលប្រជុំគ្នាហើយ ។

រឿងភិក្ខុ ៥ រូប ចប់

## ១. រឿងភិក្ខុសម្លាប់ហង្ស

### សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកសម្លាប់ហង្សមួយរូប ត្រាស់ព្រះធម្មទេសនានេះថា " **ហត្ថសញ្ញតោ** " ជាដើម ។

### សម្លាញ់ពីរនាក់ចេញបួស

បានឮមកថា សម្លាញ់ពីរនាក់ដែលមានប្រក្រតីនៅក្នុងក្រុងសាវត្ថី បានបព្វជ្ជាឧបសម្បទាក្នុង ( សម្នាក់ ) ភិក្ខុទាំងឡាយហើយ ដោយច្រើនត្រាច់ទៅជាមួយគ្នា ។

ថ្ងៃមួយ ភិក្ខុពីររូបនោះទៅកាន់ស្ទឹងអចិរវតី ស្រង់ទឹកហើយ ហាលថ្ងៃ ឈរជជែកគ្នាអំពីសារាណីយកថា ។ ក្នុងខណៈនោះ មានហង្សពីរហើរមកតាមអាកាស ។

### ភិក្ខុមួយរូបប្រហារភ្នែកហង្សដោយដុំក្រួស

គ្រានោះ ភិក្ខុកំលោះមួយរូបចាប់ដុំក្រួស ហើយពោលថា " ខ្ញុំនឹងប្រហារភ្នែកហង្សមួយ " ភិក្ខុក្រៅនេះពោលថា " អ្នកនឹងមិនអាច " ។

ភិក្ខុរូបទី ១. ភ្នែកខាងនេះ ចូរលើកទុក, ខ្ញុំនឹងប្រហារភ្នែកខាងនោះ ។

ភិក្ខុរូបទី ២. សូម្បីភ្នែកខាងនេះ អ្នកក៏មិនអាចប្រហារបានដែរ ។

ភិក្ខុរូបទី ១.ពោលថា បើដូច្នោះ លោកចូររង់ចាំមើលចុះ លុះពោលដូច្នេះហើយ ក៏ចាប់ដុំក្រួសទី ២ គប់ទៅពីខាងក្រោយខ្នងហង្ស ។ ហង្សឮសំឡេងដុំក្រួសនោះក៏ងាកក្រោយមើល, ខណៈនោះ ភិក្ខុនោះចាប់ដុំក្រួសមួយដុំទៀត គប់ហង្សនោះចំភ្នែកខាងនាយ ញុំាងដុំក្រួសឲ្យចេញតាមភ្នែកខាងអាយ ។ ហង្សស្រែក វិលជុំវិញ (ប្រកាច់) ធ្លាក់ចុះមកក្បែរជើងភិក្ខុទាំងពីររូបនោះ ។

## ភិក្ខុទាំងឡាយតិះដៀលហើយ
## ក្រាបទូលរឿងនោះចំពោះព្រះសាស្ដា

ភិក្ខុទាំងឡាយ ឈរក្នុងទីនោះៗ ឃើញហើយ ក៏ពោលថា " អ្នកមានអាយុ អ្នកបួសក្នុងព្រះពុទ្ធសាសនា ហើយធ្វើបាណាតិបាត ( ឈ្មោះថា ) ធ្វើកម្មមិនសមគួរ " ហើយនាំភិក្ខុទាំងពីររូបនោះទៅគាល់ព្រះតថាគត ។

## ព្រះសាស្តាប្រទានឱវាទ

ព្រះសាស្តាត្រាស់សួរថា " ម្នាលភិក្ខុ បានឮថា អ្នកបានធ្វើបាណាតិបាតពិតមែនឬ ?" កាលភិក្ខុនោះក្រាបទូលថា " ព្រះករុណា ព្រះអង្គ " ទើបត្រាស់ថា " ម្នាលភិក្ខុ អ្នកបួសក្នុងព្រះសាសនា ដែលជាហេតុនាំសត្វចេញចាកទុក្ខបែបនេះហើយ ហេតុដូចម្តេច ទើបអ្នកធ្វើបាណាតិបាត ? បណ្ឌិតក្នុងកាលមុន កាលព្រះពុទ្ធមិនទាន់ទ្រង់ឧប្បត្តិ នៅគ្រប់គ្រងផ្ទះ វៀរសក្នុងអំពើទាំងឡាយសូម្បីមានប្រមាណតិច ចំណែកអ្នកបួសក្នុងព្រះពុទ្ធសាសនាបែបនេះ មិនបានធ្វើសេចក្តីវៀរសូម្បីតែបន្តិចបន្តួច " កាលភិក្ខុទាំងក្រាបទូលអារាធនាហើយ ក៏ទ្រង់នាំអតីតនិទាន មកត្រាស់ថា :-

## សីល ៥ ឈ្មោះថាគរុធម៌

“ ក្នុងអតីតកាល កាលព្រះបាទធនញ្ជ័យសោយរាជ-សម្បត្តិនៅក្នុងព្រះនគរ ឈ្មោះឥន្ទបត្តៈ ក្នុងដែនកុរុ, ព្រះពោធិសត្វបដិសន្ធិក្នុងគភ៌នៃព្រះអគ្គមហេសី របស់ព្រះរាជាអង្គនោះ លុះចម្រើនវ័យហើយ ក៏ទ្រង់រៀនសិល្បៈទាំងឡាយក្នុងក្រុងតក្កសិលា ត្រឡប់មកវិញ ត្រូវព្រះបិតាតែងតាំងជាឧបរាជ ក្រោយមក កាលព្រះបិតាសោយទិវង្គត បានទទួលរាជសម្បត្តិ ទ្រង់មិនប្រព្រឹត្តកន្លងរាជធម៌ទាំង ១០ ប្រការ [១] ទ្រង់សោយរាជសម្បត្តិដោយកុរុធម៌ ។ សីល ៥ ឈ្មោះថាកុរុធម៌ ព្រះពោធិសត្វទ្រង់រក្សាសីល ៥ នោះឲ្យបរិសុទ្ធ ។ ព្រះជននី ព្រះអគ្គមហេសីនៃព្រះពោធិសត្វផង ព្រះឧបរាជជាប្អូនប្រុសនៃព្រះពោធិសត្វផង ព្រាហ្មណ៍បុរោហិតផង អាមាត្យអ្នកកាន់ខ្សែផង សារថីផង សេដ្ឋីផង មហាអាមាត្យ

---

( ១ ) រាជធម៌ ១០ គឺ **ទានំ** ការឲ្យ ១ **សីលំ** សីល ១ **បរិច្ចាគំ** ការបរិច្ចាគ ១ **អាជ្ជវំ** ការពិចារណា ១ **មទ្ទវំ** កាពទន់ភ្លន់ ១ **តបំ** សេចក្តីព្យាយាម

១ **អក្កោធំ** ការមិនក្រោធ ១ **អវិហឹសា** ការមិនបៀតបៀន ១ **ខន្តិ** សេចក្តីអត់ធន់ ១ **អវិរោធនំ** ការមិនពិរោធ ។

អ្នករក្សាឃ្លាំងផង អ្នករក្សាទ្វារផង នាងវណ្ណទាសីជាស្រ្តីលម្អនគរផង រមែងរក្សាសីល ៥ ដូចព្រះពោធិសត្វ ដោយប្រការដូច្នេះ ។

## ដែនកាលិង្គៈមានគ្រោះរាំងភ្លៀង

កាលជនទាំង ១១ នាក់នោះ រក្សាកុរុធម៌យ៉ាងនោះ, កាលព្រះរាជាទ្រង់ព្រះនាមកាលិង្គៈ សោយរាជសម្បត្តិនៅក្នុងនគរទន្តបុរី ដែនកាលិង្គៈ ភ្លៀងមិនបង្អុរចុះក្នុងដែនរបស់ព្រះអង្គ ។ ក៏ដំរីឈ្មោះអញ្ជនវសភៈរបស់ព្រះពោធិសត្វនោះជាសត្វមានបុណ្យច្រើន ។ អ្នកដែនក្រាបទូលព្រះរាជាដោយការយល់ថា កាលនាំដំរីនោះមកហើយ ភ្លៀងនឹងបង្អុរចុះ ។

ព្រះរាជាទ្រង់បញ្ជូនពួកព្រាហ្មណ៍ទៅ ដើម្បីប្រយោជន៍ដល់ការនាំដំរីនោះមក ។ ព្រាហ្មណ៍ទាំងនោះទៅហើយ ទូលសូមដំរីអំពីព្រះពោធិសត្វ ។ ដើម្បីនឹងទ្រង់សម្តែងអាការ គឺ

ការសូមរបស់ព្រាហ្មណ៍ទាំងនោះ ព្រះសាស្តាក៏ត្រាស់កុរុធម្មជាតក ក្នុងតិកនិបាតដូច្នេះជាដើមថា :-

( ពួកព្រាហ្មណ៍ ក្រាបទូលថា ) បពិត្រព្រះជនាធិបតី យើងខ្ញុំទាំងឡាយ ដឹងច្បាស់នូវសទ្ធា និងសីលរបស់ព្រះអង្គ ហើយនឹងទទួលយកនូវដំរី មានសម្បុរប្រហាកសស្មើ ដោយផ្កាអញ្ជន ទៅកាន់សម្នាក់នៃព្រះបាទកលិង្គៈ ។

( ព្រះពោធិសត្វ ពោលថា ) ពួកសត្វដែលយើងចិញ្ចឹមដោយបាយក្តី មិនចិញ្ចឹមក្តី សត្វណាក្នុងជីវលោកនេះ ដើរសំដៅមករកយើង ពួកសត្វទាំងអស់នោះ យើងមិនបានឃាត់ឡើយ នេះជារបស់បុព្វាចារ្យ ( មាតាបិតារបស់យើង ) ។

ព្រាហ្មណ៍ទាំងឡាយ យើងឲ្យដំរីនេះ ដែលសមគួរដល់ព្រះរាជា ជាជំនិះរបស់ព្រះរាជា មានយសប្រដាប់តាក់តែងហើយ បំពាក់ហើយដោយបណ្តាញមាស ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ

ព្រមទាំងសារថី ( ចូរនាំ ) ទៅតាមប្រាថ្នាចុះ ។

ក៏កាលព្រាហ្មណ៍ទាំងនោះ នាំដំរីមកហើយ, ភ្លៀងនៅតែមិនបង្អុរចុះមក, ព្រះរាជាព្រះនាមកាលិង្គៈ ក៏ទ្រង់ព្រះតម្រិះថា “ ព្រះរាជាអង្គនោះទ្រង់រក្សាកុរុធម៌, ព្រោះដូច្នោះទើបភ្លៀងធ្លាក់ក្នុងដែនរបស់ព្រះអង្គ ” លុះទ្រង់ព្រះតម្រិះដូច្នេះហើយ ក៏ទ្រង់បញ្ជូនពួកព្រាហ្មណ៍ និងអាមាត្យទៅទៀតដោយព្រះតម្រាស់ថា “ ពួកអ្នកចូរចារឹកកុរុធម៌ដែលព្រះរាជាអង្គនោះរក្សាពួដ៏ផែនមាស ( ក្រាំងមាស ) ហើយនាំមក ” កាលព្រាហ្មណ៍ និងអាមាត្យទាំងនោះទៅទូលសូម, ជនទាំងនោះសូម្បីទាំងអស់ ចាប់តាំងអំពីព្រះរាជាជាដើមទៅ ធ្វើការរង្កៀសបន្តិចបន្តួចខ្វះៗ ក្នុងសីលទាំងឡាយរបស់ខ្លួន ហើយប្រកែកថា “ សីលរបស់ពួកយើងមិនបរិសុទ្ធ ត្រូវព្រាហ្មណ៍ និងអាមាត្យទាំងនោះអង្វរថា ការបែកធ្លាយនៃសីល រមែងមិនមានដោយហេតុមានប្រមាណប៉ុណ្ណេះទេ ” ទើបបានប្រាប់សីលរបស់ខ្លួនៗ ។

## ព្រះបាទកាលិង្គៈទ្រង់រក្សាកុរុធម៌ទើបភ្លៀងធ្លាក់

ព្រះបាទកាលិង្គៈ ទ្រង់ទតកុរុធម៌ដែលពួកព្រាហ្មណ៍និងអាមាត្យចារឹកព្ធដ៏ក្រាំងមាសហើយនាំមកនោះ ទ្រង់សមាទាន ហើយបំពេញឲ្យល្អ ទើបភ្លៀងបង្អុរចុះមកក្នុងដែនរបស់ព្រះអង្គ ។ ដែនបានក្សេមក្សាន្ត មានភិក្ខារកបានដោយងាយ

ព្រះសាស្តាលុះទ្រង់នាំអតីតនិទានមកហើយ ទ្រង់ប្រជុំជាតកថា :-

ស្រីលម្អក្រុងក្នុងកាលនោះ បានមកជានាងឧប្បលវណ្ណា, អ្នករក្សាទ្វារ បានមកជាភិក្ខុឈ្មោះបុណ្ណៈ, អាមាត្យអ្នកកាន់ខ្សែ បានមកជាកច្ចានភិក្ខុ, ហើយអាមាត្យអ្នករក្សាឃ្លាំង បានមកជាកោលិកៈ, សេដ្ឋីក្នុងកាលនោះ បានជាសារីបុត្រ, នាយសារថី បានជាអនុរុទ្ធ, ព្រាហ្មណ៍ បានមកជាកស្សបៈ, ឧបរាជ បានជានន្ទបណ្ឌិត ព្រះមហេសី បានជាមាតារបស់រាហុល, ព្រះជននី បានជាព្រះនាងមាយាទេវី , ព្រះបាទកុរុ បានជាព្រះពោធិសត្វ, ពួកអ្នកចូរចាំជាតកទុកដោយ

អាការយ៉ាងនេះចុះ ។

ដូច្នេះហើយ ត្រាស់ថា “ ម្នាលភិក្ខុ បណ្ឌិតក្នុងកាលមុន កាលសេចក្តីរង្កៀសស្ទើមានប្រមាណតិចកើតឡើងហើយ ធ្វើនូវការបែកធ្លាយនៃសីលរបស់ខ្លួន ឲ្យជាគ្រឿងរង្កៀសហើយ, ចំណែកអ្នក បួសក្នុងសាសនាព្រះពុទ្ធ អ្នកប្រាកដស្មើដោយតថាគតហើយ នៅធ្វើបាណាតិបាតទៀត ( ឈ្មោះថា ) បានធ្វើកម្មដ៏ធ្ងន់ក្រៃលែង, ធម្មតាភិក្ខុ គួរជាអ្នកសង្រួមដៃ ជើង និងវាចា ” ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា :-

**២ ហត្ថសញ្ញតោ បាទសញ្ញតោ**
**វាចាយ សញ្ញតោ សញ្ញតុត្តមោ**
**អជ្ឈត្តរតោ សមាហិតោ**
**ឯកោ សន្តុសិតោ តមាហុ ភិក្ខុំ ។**

ជនណា សង្រួមដៃ សង្រួមជើង សង្រួមវាចា សង្រួមអត្តភាព ជាអ្នកត្រេកអរក្នុងការចម្រើនកម្មដ្ឋានដែលមានក្នុងខ្លួន ជាអ្នកមានចិត្ត

តម្កល់មាំ ជាអ្នកនៅឯកឯង តែងមានចិត្តត្រេកអរក្នុងធម៌ បណ្ឌិតទាំងឡាយ ហៅជននោះថា ភិក្ខុ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **ហត្ថសញ្ញតោ** សេចក្ដីថា ឈ្មោះថាអ្នកមានដៃសង្រួមហើយ ព្រោះមិនមានកាយវិការទាំងឡាយ មានការប្រលែងដោយដៃជាដើម ឬមិនមានការប្រហារសត្វដទៃដោយដៃជាដើម ។

ន័យសូម្បីក្នុងបទទីពីរ ក៏ដូចន័យនេះ ។

ដែលឈ្មោះថាអ្នកមានវាចាសង្រួមហើយ ព្រោះមិនធ្វើទុច្ចរិត មានការនិយាយកុហកតាមវាចាជាដើម ។

បទថា **សញ្ញតុត្តមោ** គឺអ្នកមានអត្តសង្រួមហើយ, អធិប្បាយថា អ្នកមិនធ្វើអាការប្លែក មានកម្រើកកាយ ងក់ក្បាល និងញាក់ចិញ្ចើមជាដើម ។

**អជ្ឈត្តរតោ** សេចក្ដីថា ជាអ្នកត្រេកអរក្នុងការចំរើនកម្មដ្ឋានពោលគឺគោចរធម៌ដែលប្រព្រឹត្តទៅខាងក្នុង ។

បទថា **សមាហិតោ** គឺអ្នកមានចិត្តតម្កល់មាំហើយ ។

ពីរបទថា **ឯកោ សន្ទុសិតោ** សេចក្តីថា ជាអ្នកនៅឯកឯង តែងមានចិត្តត្រេកអរក្នុងធម៌ គឺមានចិត្តត្រេកអរហើយក្នុងអធិគមរបស់ខ្លួន ចាប់តាំងពីការប្រព្រឹត្តវិបស្សនាពិតណាស់ ព្រះសេក្ខបុគ្គលគ្រប់ជំពូក ចាប់ពីកល្យាណបុថុជ្ជនឡើងទៅ តែងតែត្រេកអរនិងអធិគមរបស់ខ្លួន ព្រោះហេតុនោះ ទើបឈ្មោះថាអ្នកសន្តោស, ចំណែកព្រះអរហន្តជាអ្នកត្រេកអរហើយដោយចំណែកមួយ, ព្រះមានព្រះភាគទ្រង់សំដៅយកព្រះអរហន្តនោះ ទើបត្រាស់ព្រះតម្រាស់នោះថា "**ឯកោ សន្ទុសិតោ**" ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

រឿងភិក្ខុសម្លាប់ហង្ស ចប់

## ៣.រឿងភិក្ខុឈ្មោះកោកាលិកៈ

### សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុឈ្មោះកោកាលិកៈ ត្រាស់ព្រះធម្មទេសនានេះថា "*យោ មុខសញ្ញតោ*" ជាដើម ។

### កោកាលិកៈកើតក្នុងនរកព្រោះជេរព្រះអគ្គសាវក

រឿងមានមកហើយក្នុងព្រះសូត្រថា " គ្រានោះ ភិក្ខុឈ្មោះកោកាលិកៈ បានចូលទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់ " ជាដើម, ចំណែកសេចក្ដីនៃរឿងនោះ បណ្ឌិតគប្បី

ជ្រាបតាមន័យដែលព្រះអដ្ឋកថាចារ្យ ពោលទុកហើយក្នុងអដ្ឋកថានោះចុះ ។

ក៏កាលព្រះកោកាលិកៈកើតក្នុងបទុមនរក, ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា “ឱ ! ភិក្ខុឈ្មោះកោកាលិកៈដល់នូវសេចក្ដីវិនាសហើយ ព្រោះអាស្រ័យមាត់របស់ខ្លួន, ក៏កាលលោកជេរព្រះអគ្គសាវកទាំងពីរនោះ ផែនដីបានបើកចន្លោះហើយ” ។

ព្រះសាស្ដាស្ដេចមកហើយត្រាស់សួរថា “ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយកថាអ្វី ?” កាលភិក្ខុទាំងឡាយក្រាបទូលថា “ បពិត្រព្រះអង្គដ៏ចម្រើនដោយកថាឈ្មោះនេះ ” ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុឈ្មោះកោកាលិកៈ វិនាសព្រោះអាស្រ័យមាត់របស់ខ្លួនក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏ទេ, សូម្បីក្នុងកាលមុន ភិក្ខុឈ្មោះកោកាលិកៈ ក៏វិនាសព្រោះអាស្រ័យមាត់របស់ខ្លួនដែរ កាលភិក្ខុទាំងឡាយ អ្នកប្រាថ្នានឹងស្ដាប់រឿងនោះអារាធនា

ហើយ ដើម្បីនឹងទ្រង់ប្រកាសរឿងនោះ បានទ្រង់នាំអតីតទាន មកត្រាស់ថា ៖-

## ហង្សពីរនាំអណ្ដើកដែលជាសម្លាញ់ទៅគុហាររបស់ខ្លួន

ក្នុងអតីតកាល មានអណ្ដើកមួយនៅក្នុងស្រះ ក្នុងហិមវន្តប្រទេស ។ កូនហង្សពីរត្រាច់ទៅដើម្បីរកស៊ី ធ្វើសេចក្ដីស្និទ្ធស្នាលជាមួយនិងអណ្ដើកនោះ ជាសត្វមានសេចក្ដីស្និទ្ធស្នាលយ៉ាងមាំ ថ្ងៃមួយ ហង្សទាំងពីរនោះសួរអណ្ដើកថា "ម្នាលសម្លាញ់ លំនៅរបស់ពួកយើងនៅក្នុងគុហាមាស លើផ្ទៃភ្នំឈ្មោះចិត្តកូដ ក្នុងហិមវន្តប្រទេស ជាប្រទេសដ៏មនោរម្យ, តើអ្នកឯងចង់ទៅទីនោះជាមួយនិងពួកយើងទេ ?"

អណ្ដើក. ខ្ញុំនឹងទៅដូចម្ដេចបាន ?

ហង្ស. ប្រសិនបើអ្នកឯងអាចរក្សាមាត់បាន ពួកយើងនឹងនាំអ្នកឯងទៅ ។

អណ្ដើក. ម្នាលសម្លាញ់ ខ្ញុំអាចរក្សាមាត់បាន, សូមអ្នកទាំងពីរនាំខ្ញុំទៅចុះ ។

ហង្សទាំងពីរពោលថា “ ប្រពៃហើយ ” ហើយឲ្យអណ្ដើកខាំកំណាត់ឈើមួយ ចំណែកខ្លួនខាំចុងកំណាត់ឈើទាំងពីរនោះ ហើយហើរទៅកាន់អាកាស ។

## អណ្ដើករបូតមាត់អំពីកំណាត់ឈើដែលខាំធ្លាក់ស្លាប់

ពួកក្មេងអ្នកស្រុក ឃើញហង្សនាំអណ្ដើកទៅយ៉ាងនោះ ក៏និយាយគ្នាថា “ហង្សពីរនាំអណ្ដើកទៅដោយកំណាត់ឈើ” អណ្ដើកឮដូច្នោះក៏តបថា “នែអាក្មេងប្រេតទាំងឡាយការដែលសម្លាញ់របស់យើងទាំងពីរ នាំយើងទៅវាមានប្រយោជន៍អ្វីដល់ពួកឯង ក្នុងរឿងនេះ” ក៏ប្រលែងកំណាត់ឈើអំពីទីដែលខ្លួនខាំ ក្នុងវេលាដល់ចំណែកខាងលើព្រះរាជនិវេសន៍ ក្នុងព្រះនគរពារាណសី ព្រោះការដែលហង្សទាំងពីរនោះជាសត្វមានល្បឿនដ៏រហ័ស ទើបធ្លាក់ចុះទៅក្នុងព្រះលានហ្លួងបែកជាពីរចំណែក ។

## ការនិយាយច្រើនមិនត្រូវកាលវេលាឲ្យទោស

ព្រះសាស្ដាលុះទ្រង់នាំអតីតទាននេះមកហើយ ទ្រង់ញ៉ាំងកច្ឆបជាតកក្នុងទុកនិបាតឲ្យពិស្ដារថា ៖-

អណ្ដើក កាលបើឈើខ្លួនពាំស៊ប់ហើយ ហា និយាយសម្លាប់នូវខ្លួនឯង ឈ្មោះថាសម្លាប់ដោយវាចារបស់ខ្លួន ។

បពិត្រព្រះអង្គមានព្យាយាមប្រសើរជាងជន ( ឯ បណ្ឌិតបុរស ) ឃើញនូវហេតុនេះហើយ មិនគប្បីបញ្ចេញវាចាជាកុសលឲ្យហួសវេលា ព្រះអង្គគង់នឹងទតឃើញអណ្ដើក ដែលដល់នូវសេចក្ដីវិនាសព្រោះតែនិយាយច្រើន ។

ហើយត្រាស់ថា “ ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុគប្បីជាអ្នកសង្រួមមាត់ ប្រព្រឹត្តស្មើ មិនរាយមាយ មានចិត្តស្ងប់ ” ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា ៖-

**២. យោ មុខសញ្ញតោ ភិក្ខុ មន្តភាណី អនុទ្ធតោ**
**អត្ថំ មុខសញ្ញតោ ភិក្ខុ មធុរំ តស្ស ភាសិត ។**

ភិក្ខុណា សង្រួមមាត់ ជាអ្នកពោលដោយបញ្ញា មានចិត្តមិនរាយមាយ សំដែងអត្ថផង ធម៌ផងបាន ភាសិតរបស់ភិក្ខុនោះទើបឈ្មោះថាពីរោះ ។

# អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **មុខសញ្ញតោ** សេចក្ដីថា ដែលឈ្មោះថា អ្នកសង្រួមមាត់ ព្រោះមិននិយាយពាក្យជាដើមថា " ឯងជាអ្នកមានជាតិអាក្រក់ ឯងជាមនុស្សទ្រុស្ត-សីល " ទៅកាន់ជនទាំងឡាយមានទាសៈនិងមនុស្សចណ្ឌាលជាដើម ។

បទថា **មន្តភាណី** សេចក្ដីថា បញ្ញា ព្រះមានព្រះភាគត្រាស់ហៅថា មន្តា, អ្នកមានប្រក្រតីនិយាយដោយបញ្ញា ។

បទថា **អនុទ្ធតោ** បានដល់ អ្នកមានចិត្តស្ងប់ហើយ ។

បាទព្រះគាថាថា **អត្ថំ ធម្មញ្ច ទីបេតិ** សេចក្ដីថា រមែងសម្ដែងអត្ថនៃភាសិត និងធម៌ គឺទេសនា ។

បទថា **មធុរំ** សេចក្ដីថា ភាសិតរបស់ភិក្ខុនោះ ទើបឈ្មោះថាពីរោះ ។

ចំណែកភិក្ខុណា ញុំាងអត្ថតែម្យ៉ាងឲ្យដល់ព្រម, មិនញុំាងព្រះបាលីឲ្យដល់ព្រម, ញុំាងព្រះបាលីតែប៉ុណ្ណោះឲ្យដល់ព្រម, មិនញុំាងអត្ថឲ្យដល់ព្រម, ឬក៏មិនញុំាងទាំងពីរយ៉ាង

ឲ្យដល់ព្រម, ភាសិតរបស់ភិក្ខុនោះ មិនឈ្មោះថាជាភាសិតដ៏ពីរោះទេ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

( រឿងភិក្ខុឈ្មោះកោកាលិកៈ ចប់ )

88888888888888888888

# ៨ រឿងព្រះធម្មារាមត្ថេរ

## សេចក្តីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ព្រះ-ធម្មារាមត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា “ **ធម្មារាមោ ធម្មរតោ** ” ជាដើម ។

ពួកភិក្ខុប្រឹក្សារឿងបរិនិព្វានរបស់ព្រះសាស្ដា

បានឮមកថា កាលព្រះសាស្ដាត្រាស់ប្រាប់ថា “ ការបរិនិព្វានរបស់តថាគតនឹងមានដោយកន្លងទៅ ៤ ខែទៀតចាប់តាំងពីថ្ងៃនេះទៅ ”, ភិក្ខុច្រើនពាន់រូបត្រាច់ចោមរោមព្រះសាស្ដា ។

បណ្ដាភិក្ខុទាំងនោះ ភិក្ខុជាបុថុជ្ជន មិនអាចនឹងទប់ទឹកភ្នែកបាន ។ ធម្មសង្វេគកើតឡើងដល់ភិក្ខុជាព្រះខីណាស្រពទាំងឡាយ ។ ភិក្ខុទាំងពួងប្រឹក្សាគ្នាថា “ យើងនឹងធ្វើដូចម្ដេចហ្ន៎ ” ដូច្នេះហើយ ក៏ត្រាច់ទៅដោយរួមគ្នាជាពួកៗ ។

ចំណែកភិក្ខុមួយរូប ឈ្មោះធម្មារាមៈ មិនចូលទៅកាន់សម្នាក់ភិក្ខុទាំងឡាយ, កាលភិក្ខុទាំងឡាយសួរថា “ អ្នកមានអាយុ អ្នកកើតអ្វី ?” មិនឆ្លើយតប ដោយគិតថា “ ឮថាព្រះសាស្ដានឹងបរិនិព្វានដោយកាលកន្លងទៅ ៤ ខែទៀត,

ចំណែកយើងជាអ្នកមានរាគៈមិនទាន់ទៅប្រាស កាលព្រះ-សាស្តាទ្រង់ព្រះជន្មនៅ យើងនឹងព្យាយាមដើម្បីឲ្យបានសម្រេចព្រះអរហត្ត ” ដូច្នេះហើយ ក៏ជាអ្នកតែម្នាក់ឯងប៉ុណ្ណោះ រមែងរំពឹង នឹក គិត រឭកដល់ធម៌ដែលព្រះសាស្តាទ្រង់សម្តែងហើយ ។ ភិក្ខុទាំងឡាយក្រាបទូល (រឿងនោះ) ចំពោះព្រះតថាគតថា “ បពិត្រព្រះអង្គ ព្រះធម្មារាមៈមិនបានធ្វើសេចក្តីស្នេហាក្នុងព្រះអង្គសូម្បីតែបន្តិចបន្តួច មិនធ្វើការប្រឹក្សាជាមួយនឹងពួកខ្ញុំព្រះអង្គសូម្បីតែបន្តិចបន្តួចថា “ អ្នកមានអាយុទាំងឡាយ បានឮថា ព្រះសាស្តានឹងបរិនិព្វាន, តើពួកយើងនឹងធ្វើដូចម្តេច ?” ។

ព្រះសាស្តាត្រាស់ឲ្យហៅព្រះធម្មារាមៈមកគាល់

ព្រះសាស្តាត្រាស់ឲ្យហៅលោកមកហើយ ត្រាស់សួរថា “ ម្នាលភិក្ខុ អ្នកបានធ្វើយ៉ាងនោះពិតមែនឬ ?” ។

ព្រះធម្មារាមៈ. ព្រះករុណា ព្រះអង្គ ។

ព្រះសាស្តា. ព្រោះហេតុអ្វី ?

ព្រះធម្មារាមៈ. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបាន ឮថា ព្រះអង្គនឹងបរិនិព្វានដោយកាលកន្លងទៅ ៤ ខែទៀត, ចំណែកខ្ញុំព្រះអង្គជាអ្នកមានរាគៈមិនទាន់ទៅប្រាស, កាល ព្រះអង្គទ្រង់ព្រះជន្មនៅនោះឯង ខ្ញុំព្រះអង្គនឹងព្យាយាមដើម្បី ឲ្យបានសម្រេចព្រះអរហត្ត ព្រោះហេតុនោះ ទើបខ្ញុំព្រះអង្គ រំពឹង នឹក គិតដល់ធម៌ដែលព្រះអង្គទ្រង់សម្ដែងហើយ ។

ព្រះសាស្ដាទ្រង់អនុមោទនា

ព្រះសាស្ដាទ្រង់ប្រទានសាធុការដល់លោកថា “ សាធុ សាធុ ” ហើយត្រាស់ថា “ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ ភិក្ខុណាស្រឡាញ់តថាគត គប្បីធ្វើដូចជាធម្មារាមភិក្ខុនេះចុះ, ពិតណាស់ ភិក្ខុណាបូជាដោយកម្រងផ្កា និងគ្រឿងក្រអូប ជាដើម មិនឈ្មោះថាបូជាតថាគតឡើយ, អ្នកបដិបត្តិធម៌ដ៏ សមគួរដល់ធម៌ប៉ុណ្ណោះ ទើបឈ្មោះថាបូជាតថាគត ”, ដូច្នេះ ហើយ ទ្រង់ត្រាស់ព្រះគាថានេះថា :-

**៤ ធម្មារាមោ ធម្មរតោ ធម្មំ អនុវិចិន្តយំ**
**ធម្មំ អនុស្សរំ ភិក្ខុ សទ្ធម្មា ន បរិហាយតិ ។**

ភិក្ខុមានធម៌ជាទីត្រេកអរ ត្រេកអរហើយ
ក្នុងធម៌ ពិចារណាធម៌ រឭកធម៌រឿយៗ រមែង
មិនសាបសូន្យចាកព្រះសទ្ធម្មឡើយ ។

## អធិប្បាយគាថា

គប្បីជ្រាបវិគ្គហៈក្នុងបទទាំងនោះថា ធម៌ គឺសមថៈ និងវិបស្សនា ជាទីត្រេកអររបស់ភិក្ខុនោះ ព្រោះអត្ថថា ជាទីនៅ ព្រោះហេតុនោះ ទើបឈ្មោះថាអ្នកមានធម៌ជាទីត្រេកអរ, ត្រេកអរហើយក្នុងធម៌នោះ ព្រោះហេតុនោះ ទើបឈ្មោះថាអ្នកត្រេកអរហើយក្នុងធម៌, ដែលឈ្មោះថាអ្នកពិចារណាធម៌ ព្រោះរឭកដល់ធម៌នោះរឿយៗ, អធិប្បាយថា អ្នកនឹកដល់ធម៌នោះ ។

បទថា **អនុស្សរំ** បានដល់ រឭកដល់ធម៌នោះឯង ។

បទថា **សទ្ធម្មា** សេចក្ដីថា ភិក្ខុនោះ រមែងសាបសូន្យចាកពោធិបក្ខិយធម៌ ៣៧ ប្រការ និងលោកុត្តរធម៌ ៩ ។

ក្នុងកាលចប់ទេសនា ភិក្ខុនោះតាំងនៅក្នុងព្រះអរហត្ត, ទេសនាបានជាគុណជាតិមានប្រយោជន៍ សូម្បីដល់បរិស័ទដែលប្រជុំគ្នាហើយ ដោយប្រការដូច្នេះ ។

( រឿងព្រះធម្មារាមត្ថេរ ចប់ )

8888888888888888888

# ៥ រឿងភិក្ខុអ្នកសេពគប់ពួកខុសមួយរូប

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធភិក្ខុអ្នកសេពគប់ភិក្ខុ ដែលជាបក្ខពួកអ្នកយល់ខុសមួយរូប ត្រាស់ព្រះធម្មទេសនានេះថា “ **សលាភំ នាតិមញ្ញេយ្យ** ” ជាដើម ។

## ភិក្ខុគប់រកភិក្ខុដែលជាបក្ខពួក ព្រះទេវទត្តព្រោះឃើញលាភ

បានឮថា ភិក្ខុដែលជាបក្ខពួកព្រះទេវទត្តមួយរូប ជាសម្លាញ់របស់ភិក្ខុរូបនោះ ។ ភិក្ខុដែលជាបក្ខពួករបស់ព្រះ-ទេវទត្តនោះ ឃើញភិក្ខុនោះត្រាច់ទៅបិណ្ឌបាតជាមួយភិក្ខុទាំងឡាយ ធ្វើភត្តកិច្ចហើយ ( ត្រឡប់ ) មក ក៏សួរថា “ នែ អាវុសោ អ្នកទៅណា ?” ។

ភិក្ខុដែលជាបក្ខពួកព្រះសាស្ដា. ខ្ញុំទៅកាន់ទីឈ្មោះឯណោះដើម្បីបិណ្ឌបាត ។

ភិក្ខុដែលជាបក្ខពួកព្រះទេវទត្ត. អ្នកបានបិណ្ឌបាតហើយឬ ?

ភិក្ខុដែលជាបក្ខពួកព្រះសាស្ដា. អើ ខ្ញុំបានហើយ ។

ភិក្ខុដែលជាបក្ខពួកព្រះទេវទត្ត. នៅទីនេះ ពួកខ្ញុំមានលាភ និងសក្ការៈច្រើន, អ្នកចូរនៅក្នុងទីនេះ ២-៣ ថ្ងៃចុះ ។

ភិក្ខុដែលជាបក្ខពួកព្រះសាស្ដានោះ នៅទីនោះ ២-៣ ថ្ងៃ តាមពាក្យរបស់ភិក្ខុនោះហើយ ក៏បានទៅកាន់លំនៅរបស់ខ្លួនវិញ ។

គ្រានោះ ភិក្ខុទាំងឡាយក្រាបទូលរឿងនោះចំពោះព្រះតថាគតថា “ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះបរិភោគលាភនិងសក្ការៈដែលកើតឡើងចំពោះព្រះទេវទត្ត, លោកជាបក្ខពួករបស់ព្រះទេវទត្ត ” ។

ព្រះសាស្ដា ត្រាស់ឲ្យហៅភិក្ខុនោះមកហើយ ត្រាស់សួរថា “ ម្នាលភិក្ខុ តើអ្នកបានធ្វើយ៉ាងនោះពិតមែនឬ ?” ។

ភិក្ខុ. ព្រះករុណា ព្រះអង្គ, ខ្ញុំព្រះអង្គអាស្រ័យភិក្ខុកំលោះមួយរូប បាននៅទីនោះ ២-៣ ថ្ងៃ , ក៏ប៉ុន្តែ ខ្ញុំព្រះអង្គមិនបានពេញចិត្តនឹងលទ្ធិរបស់ព្រះទេវទត្តទេ ។

## ភិក្ខុគួរត្រេកអរក្នុងលាភរបស់ខ្លួនប៉ុណ្ណោះ

គ្រានោះ ព្រះមានព្រះភាគត្រាស់ទៅកាន់ភិក្ខុនោះថា " ម្នាលភិក្ខុ អ្នកមិនពេញចិត្តនឹងលទ្ធិ ( របស់ព្រះទេវទត្ត ) នោះក៏ពិតមែនហើយ, ក៏ប៉ុន្តែ អ្នកបានត្រាច់ទៅជាមួយដូចជាពេញចិត្តនឹងលទ្ធិរបស់ជន ដែលអ្នកឃើញហើយដោយពិត, អ្នកបានធ្វើយ៉ាងនេះតែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏ទេ, សូម្បីក្នុងកាលមុន អ្នកក៏ជាបុគ្គលបែបនេះដែរ ", កាលភិក្ខុទាំង-ឡាយទូលអារាធនាថា " បពិត្រព្រះអង្គដ៏ចម្រើន ក្នុងកាលឥឡូវនេះ ពួកខ្ញុំព្រះអង្គឃើញភិក្ខុនេះដោយខ្លួនឯងហើយ, ប៉ុន្តែក្នុងកាលមុន ភិក្ខុនេះពេញចិត្តនឹងលទ្ធិរបស់បុគ្គលណា? សូមព្រះអង្គមេត្តាត្រាស់ប្រាប់ពួកខ្ញុំព្រះអង្គផង ", ទើបទ្រង់នាំអតីតនិទានមក ទ្រង់ញ៉ាំងមហិឡាមុខជាតកឲ្យពិស្តារថា :-

( អាមាត្យពោធិសត្វ ពោលថា ) ដំរីដ៏ឧត្តម

ឈ្មោះមហិឡាមុខៈ បានស្តាប់ពាក្យរបស់ចោរទាំងឡាយមុនហើយ ក៏ប្រព្រឹត្តតាម បានបោកសម្លាប់ ( ហ្មដំរី ) លុះបានស្តាប់ពាក្យពួកលោកអ្នកមានខ្លួនសង្រួមហើយ ក៏បានតាំងនៅក្នុងគុណគ្រប់យ៉ាង ។

ហើយត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុគប្បីជាអ្នកត្រេកអរនឹងលាភរបស់ខ្លួនប៉ុណ្ណោះ, ការប្រាថ្នាលាភរបស់អ្នកដទៃ មិនសមគួរឡើយ, ព្រោះឈាន វិបស្សនា មគ្គ និងផលទាំងឡាយ សូម្បីតែមួយ៉ាងក៏រមែងមិនកើតឡើងដល់ភិក្ខុអ្នកប្រាថ្នាលាភរបស់អ្នកដទៃ, ប៉ុន្តែគុណជាតិទាំងឡាយ មានឈានជាដើម រមែងកើតឡើងដល់ភិក្ខុអ្នកត្រេកអរនឹងលាភរបស់ខ្លួនប៉ុណ្ណោះ " ដូច្នេះហើយ កាលនឹងទ្រង់សម្តែងធម៌ បានទ្រង់ព្រះភាសិតព្រះគាថាទាំងនេះថា :-

**៥ សលាភំ នាតិមញ្ញេយ្យ នាញ្ញេសំ បិហយញ្ចរេ**
**អញ្ញេសំ បិហយំ ភិក្ខុ សមាធឹ នាធិគច្ឆតិ ។**
**អប្បលាភោបិ ចេ ភិក្ខុ សលាភំ នាតិមញ្ញតិ**

**តំ វេ ទេវា បសំសន្តិ សុទ្ធាជីវមតន្ទិតំ ។**

ភិក្ខុ មិនគប្បីមើលងាយលាភរបស់ខ្លួន ( ដែលកើតឡើងដោយធម៌ ) មិនគប្បីប្រព្រឹត្ត ចង់បានលាភរបស់ភិក្ខុដទៃ បើចង់បានលាភ របស់ភិក្ខុដទៃ រមែងមិនបានសមាធិឡើយ ។

បើភិក្ខុសូម្បីមានលាភតិច មិនមើល ងាយលាភរបស់ខ្លួន ទេវតា និងមនុស្សទាំង ឡាយ តែងសរសើរភិក្ខុនោះឯង ដែលជាអ្នក ព្យាយាមជាគ្រឿងអាស្រ័យរស់នៅ ដោយ បរិសុទ្ធ ជាអ្នកមិនខ្ជិលប្រអូស ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **សលាភំ** បានដល់ លាភ ដែលកើតឡើងដល់ខ្លួន ។ ពិតណាស់ ភិក្ខុណាវៀរចាកការ ត្រាច់ទៅតាមលំដាប់ផ្ទះ ចិញ្ចឹមជីវិតដោយការស្វែងរកមិន សមគួរ ភិក្ខុនោះឈ្មោះថា មើលងាយ គឺនឿយណាយ បាន

ដល់ ខ្ចីមឆ្អើមនូវលាភរបស់ខ្លួន, ព្រោះហេតុនោះ ភិក្ខុមិនគួរមើលងាយលាភរបស់ខ្លួន ដោយការមិនធ្វើយ៉ាងនោះ ។

ពីរបទថា **អញ្ញេសំ បិហយំ** មិនគប្បីប្រព្រឹត្តចង់បានលាភរបស់ភិក្ខុដទៃ ។

បាទព្រះគាថាថា **សមាធឹ នាធិគច្ឆតិ** សេចក្ដីថា បើចង់បានរបស់ភិក្ខុដទៃ ដល់នូវសេចក្ដីខ្វល់ខ្វាយក្នុងការធ្វើបរិក្ខារ មានចីវរជាដើមដល់ជនទាំងនោះ រមែងមិនបានអប្បនាសមាធិ ឬឧបចារសមាធិ ។

បាទព្រះគាថាថា **សលាភំ នាតិមញ្ញតិ** សេចក្ដីថា ភិក្ខុសូម្បីជាអ្នកមានលាភតិច កាលត្រាច់ទៅតាមលំដាប់ប្រកដោយលំដាប់នៃត្រកូលខ្ពស់ និងទាប ឈ្មោះថា មិនមើលងាយលាភរបស់ខ្លួន ។

បទថា **តំ វេ** ជាដើម សេចក្ដីថា ទេវតាទាំងឡាយរមែងសរសើរ គឺស្រឡាញ់ពេញចិត្តភិក្ខុនោះ គឺភិក្ខុបែបនោះឈ្មោះថាមានអាជីវៈបរិសុទ្ធ ព្រោះជាអ្នកមានជីវិតជាសារៈ

ឈ្មោះថាអ្នកមិនខ្ជិលច្រអូស ព្រោះជាអ្នកមិនរួញរា មិនខ្ជិលច្រអូសក្នុងការចិញ្ចឹមជីវិតដោយអាស្រ័យកម្លាំងស្មូង ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

( រឿងភិក្ខុគប់រកភិក្ខុដែលជាបក្ខពួកព្រះទេវទត្ត ចប់ )

8888888888888888888888888888888888888888888888

## ៦ រឿងព្រាហ្មណ៍ឈ្មោះបញ្ចគ្គទាយក

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ឈ្មោះបញ្ចគ្គទាយក ត្រាស់ព្រះធម្មទេសនានេះថា ***"សព្វសោ នាមរូបស្មឹ"*** ជាដើម ។

## ហេតុផលដែលព្រាហ្មណ៍មានឈ្មោះថាបញ្ចគ្គទាយក

បានឮថា ព្រាហ្មណ៍នោះតែងតែថ្វាយទានឈ្មោះខេត្តគ្គៈក្នុងកាលនៃស្រែដែលខ្ទួនជម្រះហើយ, ក្នុងកាលនៃលាន

( កាលជាទីធ្វើលាន ) ក៏ថ្វាយទានឈ្មោះខលគ្គៈ, ក្នុងកាលបញ្ជាន់ស្រូវ ក៏ថ្វាយទានឈ្មោះខលភណ្ឌគ្គៈ, ក្នុងកាលដាក់អង្ករក្នុងឆ្នាំង ក៏ថ្វាយទានឈ្មោះឧក្ខលិកគ្គៈ ក្នុងកាលដែលខ្ទងដួសបាយដាក់ក្នុងចាន ក៏ថ្វាយទានឈ្មោះបាជិគ្គៈ ព្រាហ្មណ៍តែងតែថ្វាយទានដ៏លើសទាំង ៥ យ៉ាងនេះ ។

ព្រាហ្មណ៍នោះ កាលដែលមិនទាន់ឲ្យទានដល់បដិគ្គាហកដែលមកដល់ហើយ រមែងមិនបរិភោគ ។ ព្រោះហេតុនោះ ទើបគាត់មានឈ្មោះថា " បញ្ចគ្គទាយក " ដូច្នេះឯង ។

## ព្រះសាស្តាស្តេចទៅប្រោសព្រាហ្មណ៍និងភរិយា

ព្រះសាស្តាទ្រង់ឃើញធម៌ដែលជាឧបនិស្ស័យនៃផលទាំង ៣ របស់ព្រាហ្មណ៍នោះ និងភរិយារបស់គាត់ ទើបស្តេចទៅក្នុងវេលាបរិភោគរបស់គាត់ ហើយទ្រង់ឈរក្បែរទ្វារ ។ ចំណែកព្រាហ្មណ៍នោះបែរមុខទៅក្នុងផ្ទះ អង្គុយបរិភោគក្បែរមាត់ទ្វារ, គាត់មិនឃើញព្រះសាស្តាដែលទ្រង់ឈរនៅក្បែរទ្វារ ។

ចំណែកកិរិយារបស់គាត់កំពុងបម្រើគាត់ ឃើញព្រះសាស្ដាក៏គិតថា “ ព្រាហ្មណ៍នេះថ្វាយទានដ៏លើសក្នុងឋានៈទាំង ៥ ( មុន ) ហើយ ទើបបរិភោគ, ក៏ពេលនេះ ព្រះ-សមណគោតមមកឈរនៅក្បែរទ្វារ, ប្រសិនបើព្រាហ្មណ៍ឃើញព្រះសមណគោតមហើយ

នឹងនាំភត្តរបស់ខ្លួនទៅថ្វាយ, យើងនឹងមិនអាចចម្អិនភត្តដើម្បីព្រាហ្មណ៍នេះម្ដងទៀតទេ ” ។ នាងគិតថា “ ព្រាហ្មណ៍នឹងមិនឃើញព្រះសមណគោតមដោយអាការយ៉ាងនេះ ” ទើបបែរខ្នងដាក់ព្រះសាស្ដា ឈរឱនចុះបាំងព្រះសាស្ដាអំពីខាងក្រោយព្រាហ្មណ៍ ដូចជាបាំងព្រះចន្ទពេញវង់ដោយបាតដៃដូច្នោះ ។ នាងព្រាហ្មណ៍បានឈរដោយអាការដូច្នោះ ក្រឡេកមើលព្រះសាស្ដាដោយកន្ទុយភ្នែក ដោយគិតថា “ ព្រះសាស្ដាស្ដេចទៅហើយ ឬនៅ ” ។

ព្រាហ្មណ៍ឃើញព្រះសាស្ដា

ព្រះសាស្ដាទ្រង់ឈរនៅក្នុងទីនោះឯង ។ ចំណែកនាងមិនបានពោលថា សូមព្រះអង្គមេត្តាស្ដេចទៅប្រោសសត្វខាង

មុខទៀតចុះ ” ព្រោះខ្លាចព្រាហ្មណ៍ឮ, ប៉ុន្តែនាងឱនទៅហើយ ខ្សឹបៗ ថា “ និមន្តទៅប្រោសសត្វខាងមុខទៀតចុះ ” ។

ព្រះសាស្តាទ្រង់គ្រវីព្រះសិរ្ស ដោយទ្រង់សម្តែងឲ្យដឹងថា “ តថាគតនឹងមិនទៅ ” កាលព្រះពុទ្ធជាគ្រូនៃសត្វលោកទ្រង់គ្រវីព្រះសិរ្ស ដោយទ្រង់សម្តែងឲ្យដឹងថា “ តថាគតនឹងមិនទៅ ” ( ដូច្នោះ ) នាងមិនអាចទប់សំណើចបាន ទើបសើចយ៉ាងខ្លាំង ។

គ្រានោះ ព្រះសាស្តាទ្រង់បញ្ចេញព្រះរស្មីចូលទៅកាន់ផ្ទះ ។ ចំណែកព្រាហ្មណ៍អង្គុយបែរខ្នងដាក់ព្រះសាស្តានោះ បានឮសំឡេងសើចរបស់នាងព្រាហ្មណីផង ក្រឡេកឃើញពន្លឺព្រះរស្មីមានពណ៌ ៦ ប្រការផង ក៏បានឃើញព្រះសាស្តា។

## ព្រាហ្មណ៍ថ្វាយកត្តចំពោះព្រះសាស្តា

ធម្មតា ព្រះពុទ្ធទាំងឡាយមិនទាន់ទ្រង់បង្ហាញព្រះអង្គដល់ជនទាំងឡាយអ្នកដល់ព្រមហើយដោយហេតុ ក្នុងស្រុកឬក្នុងព្រៃទេ រមែងមិនទ្រង់ចៀសចេញទៅ។ ចំណែកព្រាហ្មណ៍ឃើញព្រះសាស្តាហើយ ក៏ពោលថា “ នៃនាងដ៏ចម្រើន នាង

មិនប្រាប់ព្រះរាជបុត្រ ដែលស្ដេចមកឈរក្បែរទ្វារដល់យើង ដូច្នេះហើយ យើងជាបុគ្គលត្រូវនាងឲ្យវិនាសហើយ, នាងបាន ធ្វើកម្មដ៏ធ្ងន់ហើយ " ដូច្នេះហើយ ក៏កាន់យកភាជនភត្តដែល ខ្ទបរិភោគអស់ពាក់កណ្ដាលហើយ ទៅកាន់សម្នាក់ព្រះ-សាស្ដា ហើយក្រាបទូលថា " បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គថ្វាយទានដ៏លើសក្នុងឋានៈទាំង ៥ ហើយ ទើប បរិភោគ, ប៉ុន្ដែចំណែកភត្តពាក់កណ្ដាលប៉ុណ្ណោះ ដែលខ្ញុំព្រះ អង្គបំបែកត្រង់កណ្ដាលអំពីចំណែកនេះបរិភោគ, ចំណែកនៃ ភត្តមួយចំណែកនៅសល់ សូមព្រះអង្គទទួលយកចំណែកនេះ ជារបស់ព្រះអង្គចុះ " ។

## ព្រាហ្មណ៍ជ្រះថ្លានឹងព្រះតម្រាស់របស់ព្រះសាស្ដា

ព្រះសាស្ដាមិនត្រាស់ថា " តថាគតមិនត្រូវការភត្ត ដែលសល់អំពីអ្នកទេ " ត្រាស់ថា "ម្នាលព្រាហ្មណ៍ ភត្តដ៏ ថ្លៃថ្នូរក្ដី ភត្តដែលអ្នកបែងក្នុងទីពាក់កណ្ដាលហើយ បរិភោគ ក្ដី ជារបស់សមគួរដល់តថាគតទាំងអស់, សូម្បីដុំភត្តដែល ប្រព្រឹត្តទៅក្នុងកាលមុន ( បាយកក ) ក៏ជាវត្ថុសមគួរដល់

តថាគតដែរ, ម្នាលព្រាហ្មណ៍ ដ្បិតថា ពួកតថាគតជាអ្នកអាស្រ័យអាហារដែលអ្នកដទៃឲ្យចិញ្ចឹមជីវិត ដូចជាពួកប្រេត ” ហើយត្រាស់ព្រះគាថានេះថា ៖-

ភិក្ខុអ្នកអាស្រ័យអាហារដែលបុគ្គលដទៃឲ្យចិញ្ចឹម
ជីវិត បានដុំបាយឯណា អំពីចំណែកដ៏ថ្លៃក្តី អំពី
ចំណែកពាក់កណ្តាលក្តី អំពីចំណែកដ៏សេសសល់
ក្តី ភិក្ខុនោះជាអ្នកមិនគួរសរសើរដុំបាយនោះ, និង
មិនគួរតិះដៀល ហើយគប្បីធាន់ដុំបាយនោះ, ធីរ-
ជនទាំងឡាយ រមែងសរសើរភិក្ខុនោះថា ជាមុនី ។

ព្រាហ្មណ៍លុះបានស្តាប់ព្រះគាថានោះហើយ ក៏មានចិត្តជ្រះថ្លា ហើយគិតថា “ ឱ ! គួរអស្ចារ្យពិតមែនហ្ន៎, ព្រះរាជបុត្រអ្នកជាម្ចាស់នៃទ្វីប មិនបានត្រាស់ថា “ តថាគតមិនត្រូវការកត្តដែលសល់អំពីអ្នកទេ នៅត្រាស់យ៉ាងនោះទៀត” ហើយឈរនៅក្បែរទ្វារនោះឯង ទូលសួរបញ្ហាចំពោះព្រះសាស្តាថា “បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គត្រាស់ហៅសាវក

របស់ព្រះអង្គថា "ភិក្ខុដោយហេតុមានប្រមាណប៉ុន្មាន ? ឈ្មោះថាជាភិក្ខុ" ។

## បុគ្គលអ្នកមិនត្រេកអរមិនជាប់ជំពាក់និងនាមរូបឈ្មោះថាភិក្ខុ

ព្រះសាស្ដាទ្រង់ពិចារណាមើលថា "ធម្មទេសនាដូចម្ដេចហ្ន៎ ទើបជាគ្រឿងសប្បាយដល់ព្រាហ្មណ៍នេះ" ទ្រង់ព្រះតម្រិះថា "ជនទាំងពីរនេះ ក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាមថាកស្សប បានស្ដាប់ពាក្យរបស់ភិក្ខុទាំងឡាយអ្នកពោលថានាមរូប, ការដែលតថាគតមិនលះបង់នាមរូប ហើយសម្ដែងធម៌ដល់ជនទាំងពីរនោះ រមែងគួរ" ហើយទើបត្រាស់ថា "ម្នាលព្រាហ្មណ៍ បុគ្គលអ្នកមិនត្រេកអរ មិនជាប់ជំពាក់ មិនប្រកាន់មាំនូវនាមរូប ឈ្មោះថាភិក្ខុ" ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា ៖-

**៦ សព្វសោ នាមរូបស្មឹ យស្ស នត្ថិ មមាយិតំ**
**អសតា ច ន សោចតិ ស វេ ភិក្ខូតិ វុច្ចតិ ។**

បុគ្គលណា មិនមានសេចក្ដីប្រកាន់ក្នុង

នាម និងរូប ថាជារបស់អញ ដោយប្រការទាំង
ពួង មួយទៀត បុគ្គលណា មិនសោកស្តាយ
ព្រោះនាម និងរូបដែលមិនមាន បុគ្គលនោះឯង
តថាគតហៅថា ភិក្ខុ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **សព្វសោ** គឺក្នុងនាមរូប ដែលប្រព្រឹត្តទៅដោយអំណាចខន្ធ ៥ គឺនាមខន្ធ ៤ មាន វេទនាខន្ធជាដើម និងរូបក្ខន្ធ ។

បទថា **មមាយិតំ** សេចក្តីថា សេចក្តីប្រកាន់ថា យើង ឬថា របស់យើង មិនមានដល់បុគ្គលណា ។

បាទព្រះគាថាថា **អសតា ច ន សោចតិ** សេចក្តីថា កាលនាមរូបនោះអស់ទៅនិងសូន្យទៅ បុគ្គលណាមិនសោក សៅ គឺមិនក្តៅក្រហាយថា "រូបរបស់យើងអស់ទៅហើយ ។ល។ វិញ្ញាណរបស់យើងអស់ទៅហើយ គឺឃើញតាមការ ពិតថា នាមរូបដែលមានការអស់ទៅនិងសូន្យទៅជាធម្មតា នោះ បានអស់ទៅហើយ" ។

បទថា **ស វេ** ជាដើម សេចក្តីថា បុគ្គលនោះ គឺបុគ្គលបែបនោះ បានដល់ អ្នកវៀរចាកការប្រកាន់នាមរូប ថាជារបស់យើងក្តី អ្នកមិនសោកសៅចំពោះនាមរូបនោះក្តី ព្រះសាស្តាត្រាស់ហៅថា ភិក្ខុ ។

ក្នុងកាលចប់ទេសនា ព្រាហ្មណ៍និងព្រាហ្មណីតាំងនៅក្នុងព្រះអនាគាមិផល, ទេសនាជាគុណជាតិមានប្រយោជន៍សូម្បីដល់បរិស័ទដែលប្រជុំគ្នានោះ ។

រឿងព្រាហ្មណ៍ឈ្មោះបញ្ចគ្គទាយក ចប់

## ៧ រឿងភិក្ខុច្រើនរូប

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុច្រើនរូប ត្រាស់ធម្មទេសនានេះថា " **មេត្តាវិហារី** " ជាដើម ។

# ប្រវត្តិព្រះសោណកុដិកណ្ណៈ

សេចក្តីពិស្តារថា សម័យមួយ កាលព្រះមហាកច្ចានៈ អាស្រ័យកុររឃរនគរ ក្នុងអវន្តីជនបទ លើភ្នំឈ្មោះបវត្តៈ, ឧបាសកឈ្មោះសោណកុដិកណ្ណៈ ជ្រះថ្លានឹងធម្មកថារបស់ព្រះថេរៈ ប្រាថ្នានឹងបួសក្នុងសម្នាក់របស់ព្រះថេរៈ សូម្បីត្រូវព្រះថេរៈហាមអស់ ២ ដងថា " នៃសោណៈ ព្រហ្មចរិយៈមានកត្តូតែមួយពេល ដេកតែមួយពេល រហូតជីវិត ជាអំពើដែលបុគ្គលធ្វើបានដោយក្រ " ក៏ជាអ្នកកើតឧស្សាហ៍យ៉ាងខ្លាំងក្លាក្នុងការបព្វជ្ជា ក្នុងវារៈទី ៣ អង្វរព្រះថេរៈ បព្វជ្ជាហើយ ដោយកាលកន្លងទៅ ៣ ឆ្នាំ ទើបបានឧបសម្បទាព្រោះទក្ខិណាបថជនបទមានភិក្ខុតិច ជាអ្នកប្រាថ្នានឹងគាល់ព្រះសាស្តាក្នុងទីចំពោះព្រះភក្ត្រ ទើបថ្វាយបង្គំលាព្រះឧបជ្ឈាយ៍ ទទួលយកបណ្តាំដែលព្រះឧបជ្ឈាយ៍ឲ្យហើយទៅកាន់វត្តជេតពន ដល់វត្តជេតពនហើយ ចូលទៅថ្វាយបង្គំព្រះសាស្តា បានទទួលការបដិសណ្ឋារៈដែលព្រះសាស្តាទ្រង់ធ្វើហើយ ជាអ្នកមានសេនាសនៈ ដែលព្រះសាស្តាទ្រង់

អនុញ្ញាតហើយក្នុងព្រះគន្ធកុដិជាមួយតែម្តង ញុំាងរាត្រីចំណែក ច្រើនឲ្យកន្លងទៅខាងក្រៅ ( កណ្តាលវាល ) ហើយចូលទៅកាន់ព្រះគន្ធកុដិក្នុងវេលារាត្រី ញុំាងចំណែកនៃរាត្រីនោះឲ្យកន្លងទៅហើយ ក្នុងសេនាសនៈសម្រាប់ខ្លួន ក្នុងវេលាជិតភ្លឺ កាលដែលព្រះសាស្តាត្រាស់ឲ្យសូធ្យព្រះសូត្រ ក៏បានសូធ្យព្រះសូត្រទាំងអស់ ១៦ សូត្រ ជារបៀបសារភញ្ញ ដែលចាត់ជាអដ្ឋកវគ្គ ។

គ្រានោះ ព្រះមានព្រះភាគកាលនឹងទ្រង់អនុមោទនាឲ្យក្រៃលែង ទើបបានប្រទានសាធុការដល់លោកក្នុងវេលាចប់សរភញ្ញថា " ម្នាលភិក្ខុ ប្រពៃហើយ " ។

ភុម្មទេវតា នាគ និងគ្រុឌ បានឮសាធុការដែលព្រះ-សាស្តាទ្រង់ប្រទានហើយ ក៏បានឲ្យសាធុការដែរ, សំឡេងសាធុការបានមានក្នុងទីជាមួយគ្នា រហូតដល់ព្រហ្មលោកយ៉ាងនេះ ដោយប្រការដូច្នេះ ។

ក្នុងគ្រានោះ សូម្បីទេវតាដែលស្ថិតនៅក្នុងផ្ទះរបស់មហាឧបាសិកា អ្នកជាមាតារបស់ព្រះថេរៈ ក្នុងក្រុងកុររឃរ

នគរ ដែលនៅឆ្ងាយអំពីវត្តជេតពនប្រមាណ ១២០ យោជន៍ ក៏បានឲ្យសាធុការដោយសំឡេងដ៏លាន់ឮដែរ ។

គ្រានោះ មហាឧបាសិកា សួរទេវតានោះថា “ នរណាន៎ុះ ឲ្យសាធុការ ?” ។

ទេវតា. ម្នាលប្អូនស្រី ខ្ញុំ ។

មហាឧបាសិកា. អ្នកជានរណា ?

ទេវតា. ខ្ញុំជាទេវតា អាស្រ័យនៅក្នុងផ្ទះរបស់អ្នក ។

មហាឲ្យបាសិកា. កាលពីមុន ហេតុអ្វី អ្នកមិនឲ្យសាធុការដល់ខ្ញុំ ? ថ្ងៃនេះទើបឲ្យ ។

ទេវតា. ខ្ញុំមិនបានឲ្យសាធុការដល់អ្នកទេ ។

មហាឧបាសិកា. កាលបើដូច្នោះ អ្នកឲ្យសាធុការដល់នរណា ?

ទេវតា. ខ្ញុំឲ្យដល់ព្រះសោណកុដិកណ្ណត្ថេរ ជាបុត្ររបស់អ្នក ។

មហាឧបាសិកា. បុត្ររបស់ខ្ញុំធ្វើអ្វី ?

ទេវតា. ថ្ងៃនេះ បុត្ររបស់អ្នកនៅក្នុងព្រះគន្ធកុដិជាមួយព្រះសាស្ដា ហើយសម្ដែងធម៌ថ្វាយព្រះសាស្ដា, ព្រះ-សាស្ដាទ្រង់ព្រះសណ្ដាប់ធម៌នៃបុត្ររបស់អ្នក ហើយក៏ទ្រង់ជ្រះថ្លា ទើបបានប្រទានសាធុការ, ព្រោះហេតុនោះ សូម្បីខ្ញុំក៏ឲ្យសាធុការដល់ព្រះថេរៈនោះដែរ, ក៏ព្រោះទទួលសាធុការរបស់ព្រះសម្មាសម្ពុទ្ធ ទើបកើតសាធុការជាសំឡេងតែមួយចាប់តាំងអំពីភុម្មទេវា រហូតដល់ព្រហ្មលោក ។

មហាឧបាសិកា. នែអ្នកចម្រើន បុត្ររបស់ខ្ញុំសម្ដែងធម៌ថ្វាយព្រះសាស្ដា ឬក៏ព្រះសាស្ដាសម្ដែងធម៌ដល់បុត្ររបស់ខ្ញុំ ?

ទេវតា. បុត្ររបស់អ្នកសម្ដែងធម៌ថ្វាយព្រះសាស្ដា ។

កាលទេវតាពោលយ៉ាងនោះ, បីតិ ៥ ប្រការ កើតឡើងដល់ឧបាសិកា ផ្សាយទៅទូទាំងសរីរៈទាំងអស់ ។ គ្រានោះ មហាឧបាសិកានោះបានគិតយ៉ាងនេះថា “ ប្រសិនបើបុត្ររបស់យើងនៅក្នុងព្រះគន្ធកុដិជាមួយព្រះសាស្ដា ហើយនៅអាចសម្ដែងធម៌ថ្វាយព្រះសាស្ដាបាន, ក៏នឹងអាចសម្ដែង

ធម៌ដើម្បីយើងផងដែរ, យើងនឹងញុំាងបុគ្គលឲ្យស្តាប់ធម៌ ហើយស្តាប់ធម្មកថា ក្នុងកាលបុត្ររបស់យើងមកដល់ ”។

## ព្រះសោណៈទូលសូមពរ ៥ ប្រការអំពីព្រះសាស្តា

ចំណែកព្រះសោណត្ថេរ កាលព្រះសាស្តាទ្រង់ប្រទានសាធុការហើយ, ក៏គិតថា “ ពេលនេះ ជាពេលសមគួរក្រាបទូលបណ្តាំដែលព្រះឧបជ្ឈាយ៍ឲ្យមក ” ដូច្នេះហើយ ទើបទូលសូមពរ ៥ ប្រការ អំពីព្រះមានព្រះភាគ ចាប់តាំងពីការឧបសម្បទាដោយគណៈសង្ឃមានភិក្ខុទ្រទ្រង់វិន័យជាគម្រប់ ៥ ក្នុងជនបទទាំងឡាយដែលតាំងនៅជាយដែនហើយ នៅក្នុងសម្នាក់ព្រះសាស្តា ២-៣ ថ្ងៃប៉ុណ្ណោះ ថ្វាយបង្គំលាព្រះសាស្តាថា “ បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងទៅសួរសុខទុក្ខព្រះឧបជ្ឈាយ៍ ” បានចេញអំពីវត្តជេតពន ទៅកាន់សម្នាក់ព្រះឧបជ្ឈាយ៍ដោយលំដាប់ ។

ថ្ងៃស្អែកឡើង ព្រះថេរនាំព្រះសោណនោះត្រាច់ទៅបិណ្ឌបាត បានទៅដល់ទ្វារផ្ទះរបស់ឧបាសិកាជាមាតា ។

ចំណែកឧបាសិកានោះ ឃើញបុត្រហើយក៏ត្រេកអរ ថ្វាយហើយ អង្គាសដោយគោរពហើយសួរថា "នៃលោកកូន បានឮថា លោកកូននៅក្នុងព្រះគន្ធកុដិជាមួយនិង ព្រះសាស្តាហើយសម្តែងធម្មកថាថ្វាយព្រះសាស្តាពិតមែនឬ ?"

ព្រះសោណៈ. រឿងនេះ អ្នកណាប្រាប់ញោម ?

មហាឧបាសិកា. បពិត្រលោកកូន ទេវតាដែលនៅក្នុងផ្ទះនេះ ឲ្យសាធុការដោយសំឡេងដ៏លាន់ឮ, កាលញោមសួរថា អ្នកណានោះ ក៏ពោលថា ខ្ញុំ ហើយប្រាប់យ៉ាងនោះឯង, ព្រោះស្តាប់រឿងនោះ ញោមក៏បានគិតយ៉ាងនេះថា ប្រសិនបើបុត្ររបស់យើងសម្តែងធម្មកថាថ្វាយព្រះសាស្តាបាន, លោកក៏អាចសម្តែងធម៌ដល់យើងបានដែរ ។

គ្រានោះ មហាឧបាសិកាពោលទៅកាន់ព្រះសោណៈនោះថា "នៃលោកកូន លោកកូនសម្តែងធម៌ចំពោះព្រះភក្ត្រព្រះសាស្តាបាន, លោកកូនក៏អាចសម្តែងធម៌សូម្បីដល់ញោមបានដែរ, ក្នុងថ្ងៃឯណោះ ញោមនឹងប្រកាសឲ្យគេមក

ស្តាប់ធម៌ ហើយនឹងស្តាប់ធម៌របស់លោកកូន ” ព្រះសោណៈក៏ទទួលនិមន្ត ។

ឧបាសិកាគិតថា “ យើងថ្វាយទានចំពោះភិក្ខុសង្ឃ ធ្វើការបូជាហើយនឹងស្តាប់ធម្មកថានៃបុត្ររបស់យើង ” ទើបទុកទាសីម្នាក់ប៉ុណ្ណោះឲ្យនៅចាំផ្ទះ ហើយបាននាំយកបរិវារ-ជនទាំងអស់ទៅ ដើម្បីស្តាប់ធម្មកថារបស់បុត្រដែលនឹងឡើងកាន់ធម្មាសនៈដែលប្រដាប់តុបតែងហើយ ក្នុងមណ្ឌបដែលខ្ទនឲ្យគេសាងទុកខាងក្នុងព្រះនគរ ដើម្បីប្រយោជន៍ដល់ការស្តាប់ធម៌ សម្តែងធម៌ ។

## ពួកចោរចូលប្លន់ផ្ទះមហាឧបាសិកា

ក៏ក្នុងកាលនោះ ពួកចោរ ៩០០ ឃ្លាំមើលចន្លោះក្នុងផ្ទះរបស់ឧបាសិកានោះ ។ ក៏ផ្ទះរបស់ឧបាសិកានោះ ឡោមព័ទ្ធដោយកំពែង ៧ ជាន់ ប្រកបដោយខ្លោងទ្វារ ៧ ។ គេចងសុនខកាចៗ ទុកក្នុងទីនោះៗ គ្រប់ៗ ខ្លោងទ្វារ, មិនត្រឹមតែប៉ុណ្ណោះ គេជីកគូត្រង់ទីទឹកធ្លាក់អំពីជំបូលព្ធដ៏ខាងក្នុងផ្ទះហើយក៏ដាក់សំណពេញគូនោះ វេលាថ្ងៃ សំណនោះរលាយ

ដោយកម្ដៅថ្ងៃ ហាក់ដូចជាពុះហើយតាំងនៅ, វេលាយប់ សំណនោះកក ហាក់ដូចជាវត្ថុរឹង, គេកប់អន្ទប់ដែកដ៏ធំ តម្រៀបគ្នាក្នុងផ្ទៃនៃគូនោះ ដោយមិនមានចន្លោះ, ពួកចោរ ទាំងនោះមិនបានឱកាស ព្រោះអាស្រ័យការរក្សានេះ និង ព្រោះអាស្រ័យឧបាសិកានោះនៅខាងក្នុងផ្ទះ ថ្ងៃនោះដឹងថា ឧបាសិកានោះទៅស្ដាប់ធម៌ ក៏ជីកឧមង្គចូលទៅកាន់ផ្ទះ តាម ចំណែកខាងក្រោមគូដែលពេញដោយសំណ និងអន្ទប់ដែក នោះ ហើយបញ្ជូនមេចោរទៅកាន់សម្នាក់របស់ឲ្យឧបាសិកា នោះ ដោយប្រាប់ថា ប្រសិនបើឧបាសិកានោះ បានដឹងថា ពួកយើងចូលកាន់ផ្ទះរបស់គេហើយ ត្រឡប់មកកាន់ផ្ទះ, លោកចូរប្រហារឧបាសិកានោះឲ្យស្លាប់ដោយដាវ " ។ មេ ចោរនោះ បានទៅឈរនៅក្នុងសម្នាក់របស់ឧបាសិកានោះ ។

ចំណែកពួកចោរ អុជប្រទីបឲ្យបំភ្លឺខាងក្នុងផ្ទះ ហើយ បើកទ្វារបន្ទប់ដាក់កហាបណៈ ។ នាងទាសីឃើញចោរនោះ ហើយ ក៏ទៅកាន់សម្នាក់ឧបាសិកា ហើយប្រាប់ថា " បពិត្រ

នាងម្ចាស់ ចោរដ៏ច្រើនចូលទៅកាន់ផ្ទះ បើកទ្វារបន្ទប់ដាក់កហាបណៈហើយ ” ។

មហាឧបាសិកា. ពួកចោរចូរនាំយកកហាបណៈដែលខ្លួនឃើញទៅចុះ, យើងកំពុងស្តាប់ធម្មកថានៃបុត្ររបស់យើង, នាងកុំធ្វើឲ្យអន្តរាយដល់ការស្តាប់ធម៌របស់យើង, នាងចូរទៅផ្ទះចុះ ។

ចំណែកពួកចោរ ធ្វើបន្ទប់ដាក់កហាបណៈឲ្យទទេហើយ ក៏បើកបន្ទប់ដាក់ប្រាក់ ។ នាងទាសីនោះក៏ទៅប្រាប់ឧបាសិកាម្តងទៀត ។ ឧបាសិកានិយាយថា “ ពួកចោរចូរជញ្ជូនយកទ្រព្យដែលខ្លួនត្រូវការទៅចុះ, យើងកំពុងស្តាប់ធម្មកថានៃបុត្ររបស់យើង នាងកុំធ្វើឲ្យអន្តរាយដល់ការស្តាប់ធម៌របស់យើងឡើយ ” ហើយក៏ឲ្យនាងទាសីនោះទៅផ្ទះវិញទៀត ។

ពួកចោរធ្វើបន្ទប់ដាក់ប្រាក់ឲ្យទទេហើយ ក៏បើកបន្ទប់ដាក់មាស ។ នាងទាសីនោះក៏ទៅប្រាប់រឿងនោះដល់ឧបាសិកាទៀត ។

គ្រានោះ ឧបាសិកាហៅនាងទាសីមក ហើយនិយាយថា “ នែហាងដ៏ចម្រើន នាងមកកាន់សម្នាក់របស់យើងអស់ច្រើនដងហើយ សូម្បីយើងប្រាប់ថា ពួកចោរចូរយកទ្រព្យតាមការពេញចិត្តចុះ, ព្រោះយើងកំពុងស្តាប់ធម្មកថានៃបុត្ររបស់យើង, នាងកុំធ្វើឲ្យអន្តរាយដល់ការស្តាប់ធម៌របស់យើងក៏មិនអើពើនឹងពាក្យរបស់យើង ចុះឡើងៗ ដដែលៗ, ឥឡូវនេះ ប្រសិនបើនាងនឹងមកទៀត, យើងនឹងដឹងកិច្ចដែលគួរធ្វើចំពោះនាង, នាងចូរត្រឡប់ទៅផ្ទះចុះ ” លុះពោលដូច្នោះហើយក៏បញ្ជូននាងទាសីឲ្យត្រឡប់ទៅផ្ទះ ។

ធម៌រមែងរក្សាអ្នកប្រព្រឹត្តធម៌

មេចោរបានឮពាក្យរបស់ឧបាសិកានោះហើយ គិតថា “ កាលពួកយើងនាំទ្រព្យស្ត្រីបែបនេះទៅ រន្ទះបាញ់នឹងបាញ់បំបែកក្បាលរបស់ពួកយើង ” ដូច្នេះហើយ ក៏ទៅកាន់សម្នាក់ពួកចោរ ប្រាប់ថា “ អ្នកទាំងឡាយ ចូរជញ្ជូនយកទ្រព្យរបស់ឧបាសិកាទៅទុកកន្លែងដើមដោយរហ័ស ” ។ ចោរទាំងនោះ

ញុំាងបន្ទប់ដាក់កហាបណៈឲ្យពេញដោយកហាបណៈ ញុំាងបន្ទប់ប្រាក់ និងបន្ទប់មាសឲ្យពេញទៅដោយប្រាក់និងមាស។

បានឮថា ធម៌ រមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌ជាធម្មតា, ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា :-

ធម៌ រមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌, ធម៌ដែលបុគ្គលប្រព្រឹត្តល្អហើយ រមែងនាំសេចក្តីសុខមកឲ្យ, នេះជាអានិសង្សក្នុងធម៌ដែលបុគ្គលប្រព្រឹត្តល្អហើយ, អ្នកមានប្រក្រតីប្រព្រឹត្តធម៌ រមែងមិនទៅកាន់ទុគ្គតិ ។

ពួកចោរបានទៅឈរនៅក្នុងទីជាទីស្តាប់ធម៌ ។រីឯព្រះថេរសម្តែងធម៌ហើយ កាលរាត្រីភ្លឺច្បាស់ ក៏ចុះចាកអាសនៈ, ខណៈនោះមេចោរក្រាបចុះទៀបជើងរបស់ឧបាសិកា សូមទោសថា "ព្រះនាងម្ចាស់ មេត្តាអត់ទោសឲ្យខ្ញុំផងចុះ" ។

ឧបាសិកា. នៃអ្នកដ៏ចម្រើន តើមានបញ្ហាអ្វី ?

មេចោរ. ខ្ញុំចងអាឃាតចំពោះនាង ប្រាថ្នានឹងសម្លាប់នាង ទើបបានមកឈរនៅទីនេះ ។

ឧបាសិកា. បើដូច្នោះ ខ្ញុំអត់ទោសឲ្យ ។

## ពួកចោរជ្រះថ្លាសូមព្រះសោណៈបួស

សូម្បីពួកចោរដ៏សេស ក៏បានធ្វើដូច្នោះដែរ កាលឧបាសិកាពោលថា "នែអ្នកទាំងឡាយ ខ្ញុំអត់ទោសឲ្យ" ក៏ពោលថា "បពិត្រនាងម្ចាស់ ប្រសិនបើនាងអត់ទោសឲ្យពួកខ្ញុំ, សូមនាងញ៉ាំងពួកខ្ញុំឲ្យបានបព្វជ្ជាក្នុងសំណាក់បុត្ររបស់នាងផងចុះ" ។ ឧបាសិកានោះថ្វាយបង្គំបុត្រហើយ ពោលថា "បពិត្រលោកកូន ចោរទាំងនេះជ្រះថ្លានឹងគុណរបស់ញោម និងធម្មកថារបស់លោកកូន ក៏នាំគ្នាសូមបព្វជ្ជា, សូមលោកកូនបំបួសចោរទាំងនេះចុះ" ។

ព្រះថេរៈពោលថា "ប្រពៃហើយ" ហើយក៏ឲ្យកាត់ជាយសំពត់ដែលចោរទាំងនោះដណ្ដប់ ហើយឲ្យយកទៅជ្រលក់និងដីក្រហម ឲ្យចោរទាំងនោះបួសហើយ ឲ្យតាំងនៅក្នុងសីល ។ នៅពេលដែលចោរទាំងនោះឧបសម្បទាហើយ ព្រះថេរបានឲ្យកម្មដ្ឋានផ្សេង ៗ គ្នាដល់ភិក្ខុទាំងនោះ ។ ភិក្ខុ

៩០០ រូបនោះរៀនកម្មដ្ឋាន ៩ យ៉ាងផ្សេង ៗ គ្នាហើយនាំគ្នាឡើងកាន់ភ្នំមួយអន្លុយធ្វើសមណធម៌ក្រោមម្លប់ឈើនោះៗ។

ព្រះសាស្តា ទ្រង់គង់នៅក្នុងវត្តជេតពនមហាវិហារ ដែលមានចម្ងាយ ១២០ យោជន៍ ទ្រង់ពិចារណាមើលភិក្ខុទាំងនោះហើយ ទ្រង់កំណត់ព្រះធម្មទេសនាដោយអំណាចនៃការប្រព្រឹត្តរបស់ភិក្ខុទាំងនោះ ទ្រង់បញ្ចេញព្រះរស្មីទៅហាក់ដូចជាទ្រង់គង់នៅក្នុងទីចំពោះមុខ បានទ្រង់ភាសិតព្រះគាថាទាំងនេះថា ៖-

៧ មេត្តាវិហារី យោ ភិក្ខុ បសន្នោ ពុទ្ធសាសនេ
អធិគច្ឆេ បទំ សន្តំ សង្ខារូបសមំ សុខំ ។
សិញ្ច ភិក្ខុ ឥមំ នាវំ សិត្តា តេ លហុមេស្សតិ
ឆេត្វា រាគញ្ច ទោសញ្ច តតោ និព្វានមេហិសិ ។
បញ្ច ឆិន្ទេ បញ្ច ជហេ បញ្ច ឧត្តរិ ភាវយេ
បញ្ចសង្គាតិគោ ភិក្ខុ ឱឃតិណ្ណោតិ វុច្ចតិ ។
ឈាយ ភិក្ខុ មា ច បមាទោ
មា តេ កាមគុណេ ភមស្សុ ចិត្តំ

មា លោហគុឡំ គិលី បមត្តោ

មា តន្ទិ ទុក្ខមិទន្តិ ឌយ្ហមានោ ។

នត្ថិ ឈានំ អបញ្ញស្ស  នត្ថិ បញ្ញា អឈាយិនោ

យម្ហិ ឈានញ្ច បញ្ញា ច  ស វេ និព្វានសន្តិកេ ។

សុញ្ញាគារំ បវិដ្ឋស្ស  សន្តចិត្តស្ស ភិក្ខុនោ

អមានុសី រតី ហោតិ  សម្មា ធម្មំ វិបស្សតោ ។

យតោ យតោ សម្មសតិ  ខន្ធានំ ឧទយព្វយំ

លភតិ បីតិបាមោជ្ជំ  អមតំ តំ វិជានតំ ។

តត្រាយមាទិ ភវតិ  ឥធ បញ្ញស្ស ភិក្ខុនោ

ឥន្ទ្រិយគុត្តិ សន្តុដ្ឋិ  បាតិមោក្ខេ ច សំវរោ

មិត្តេ ភជស្សុ កល្យាណេ  សុទ្ធាជីវេ អតន្ទិតេ ។

បដិសន្ថារវុត្យស្ស  អាចារកុសលោ សិយ

តតោ បាមោជ្ជពហុលោ  ទុក្ខស្សន្តំ ករិស្សសិ ។

ភិក្ខុណា នៅដោយអំណាចមេត្តា ជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះ រមែងបានបទដ៏ស្ងប់ ជាទីរម្ងាប់នូវសង្ខារ នាំមកនូវសេចក្តីសុខ ។

ម្នាលភិក្ខុ អ្នកចូរស្តាប់ទុក គឺអត្តភាពនេះ ទុក ដែលអ្នកស្តាប់ហើយ នឹងដល់ត្រើយឆាប់ អ្នក កាត់រាគៈ និងទោសៈបានហើយ អំពីនោះនឹង អាចដល់នូវព្រះនិព្វាន ។ ភិក្ខុ គប្បីកាត់ ឱរម្ភាគិយសំយោជនៈ ៥ ផង គប្បីលះបង់ ឧទ្ធម្ភាគិយសំយោជនៈ ៥ ផង គប្បីចម្រើន ឥន្ទ្រិយ ៥ តទៅ ភិក្ខុកន្លងកិលេសជាគ្រឿង ជំពាក់ ៥ ( រាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ ) បានហើយ ទើបតថាគតហៅថា អ្នកឆ្លងអន្លង់បាន ។ ម្នាលភិក្ខុ អ្នកចូរពិនិត្យផង ចូរជាអ្នកកុំប្រមាទ ផង ចូរកុំវិលទៅរកកាមគុណឡើយ អ្នកចូរកុំ ប្រមាទ ទំពាស៊ីនូវដុំលោហៈ កុំឲ្យជាអ្នកកាល ភ្លើងឆេះហើយ កន្ទក់កន្ទេញថា នេះទុក្ខ ដូច្នេះ ឡើយ ។ ការពិនិត្យមិនមានដល់បុគ្គលអ្នកមិន មានប្រាជ្ញា ប្រាជ្ញាមិនមានដល់បុគ្គលអ្នកមិន ពិនិត្យ ការពិនិត្យ និងប្រាជ្ញា មានក្នុងបុគ្គលណា

បុគ្គលនោះឯង ឈ្មោះថា ស្ថិតនៅក្នុងទីជិតនៃព្រះនិព្វាន ។ សេចក្តីត្រេកអរដែលមិនមែនជារបស់មនុស្ស រមែងមានដល់ភិក្ខុអ្នកចូលទៅកាន់ផ្ទះស្ងាត់ អ្នកមានចិត្តរម្ងាប់ អ្នកឃើញធម៌ដោយប្រពៃ ។ ភិក្ខុពិចារណាការកើតឡើងនិងការវិនាសខន្ធទាំងឡាយ ក្នុងកាលណា ក្នុងកាលនោះ ភិក្ខុនោះរមែងបានបីតិ និងបាមោជ្ជ បីតិ និងបាមោជ្ជនោះ ឈ្មោះថា ជាអមតធម៌របស់បណ្ឌិតអ្នកដឹងធម៌ទាំងឡាយ ។ គុណ ៣ ប្រការនេះ គឺការរក្សាឥន្ទ្រិយ ១ សេចក្តីសន្តោស ១ ការសង្រួមក្នុងបាតិមោក្ខ ១ ជាខាងដើមនៃព្រះនិព្វាននោះ តែងមានដល់ភិក្ខុអ្នកមានបញ្ញាក្នុងសាសនានេះ ( ម្នាលភិក្ខុ ) អ្នកចូរគប់រកកល្យាណមិត្ត អ្នកមានព្យាយាមជាគ្រឿងរស់ដោយបរិសុទ្ធ ជាអ្នកមិនខ្ជិលច្រអូស ។ ភិក្ខុគប្បីជាអ្នកប្រព្រឹត្តធ្វើបដិសណ្ឋារៈ

គប្បីជាអ្នកឈ្លាសក្នុងអាចារៈ ព្រោះហេតុទាំង ២ នោះ អ្នកនឹងបានបាមោជ្ជច្រើន នឹងធ្វើទីបំផុតទុក្ខបាន ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **មេត្តាវិហារី** សេចក្ដីថា បុគ្គលអ្នកធ្វើកម្មក្នុងកម្មដ្ឋានដែលប្រកបដោយមេត្តាក្ដី អ្នកញ៉ាំងឈានពួក ៣ និងពួក ៤ ឲ្យកើតឡើងដោយអំណាចនៃមេត្តាហើយតាំងនៅក្ដី ឈ្មោះថា អ្នកមានប្រក្រតីនៅដោយមេត្តាពិត ៗ ។

ពាក្យថា **បសន្នោ** សេចក្ដីថា ក៏ភិក្ខុណាជាអ្នកជ្រះថ្លាហើយ, អធិប្បាយថា រមែងបណ្ដុះសេចក្ដីជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ។

ពីរបទថា **បទំ សន្តំ** នោះ ជាឈ្មោះនៃព្រះនិព្វាន ។ ពិតណាស់ ភិក្ខុបែបនោះ រមែងសម្រេចបាន ។ អធិប្បាយថា រមែងជួបប្រសព្វនូវព្រះនិព្វានដែលជាចំណែកនៃសេចក្ដីស្ងប់ ឈ្មោះថាជាទីចូលទៅស្ងប់សង្ខារ ព្រោះសង្ខារទាំងពួង

ជាសភាវៈស្ងប់ហើយ ដែលមានឈ្មោះថាថា សុខ ព្រោះជាសុខយ៉ាងក្រៃលែង ។

បាទព្រះគាថាថា **សិញ្ច ភិក្ខុ ឥមំ នាវំ** សេចក្ដីថា ម្នាលភិក្ខុ ចូរអ្នកស្ដារទូក គឺអត្តភាពនេះ ដែលមានទឹក គឺមិច្ឆាវិតក្កចេញ ។

បាទព្រះគាថាថា **សិត្តា តេ លហុមេស្សតិ** សេចក្ដីថា ដូចយ៉ាងថា ទូកដែលពេញប្រៀបដោយទឹកក្នុងមហាសមុទ្រ ជាទូកដែលគេស្ដារហើយ ព្រោះភាវៈនៃទឹកនោះជារបស់ដែលគេបិទប្រហោង ហើយស្ដារ ជាទូកស្រាល មិនលិចចុះក្នុងមហាសមុទ្រ រមែងស្ទុះទៅកាន់កំពង់បានឆាប់រហ័សយ៉ាងណា, ទូកគឺអត្តភាពរបស់អ្នកនេះ ក៏ពេញហើយដោយទឹក គឺមិច្ឆាវិតក្កដូច្នោះដែរ ដែលអ្នកស្ដារហើយ ព្រោះភាវៈនៃទឹក គឺមិច្ឆាវិតក្កដែលកើតឡើងហើយ ជារបស់ដែលអ្នកបិទប្រហោងទាំងឡាយ មានចក្ខុទ្វារជាដើម ដោយការសង្រួមស្ដារចេញហើយទើបស្រាល មិនលិចចុះក្នុងសង្សារវដ្ដ នឹងដល់ព្រះនិព្វាន ។

បទថា **ឆេត្វា** ជាដើម សេចក្ដីថា អ្នកគប្បីកាត់ចំណង គឺរាគៈ និងទោសៈ លុះកាត់ចំណងទាំងនោះបានហើយ នឹងសម្រេចព្រះអរហត្ត, អធិប្បាយថា ពេលនោះ គឺកាលក្រោយមក នឹងសម្រេចអនុបាទិសេសនិព្វាន ។

ពីរបទថា **បញ្ច ឆិន្ទេ** គឺគប្បីកាត់សំយោជនៈចំណែកខាងក្រោម ៥ យ៉ាង ដែលញ៉ាំងសត្វឲ្យដល់អបាយខាងក្រោម ដោយពួក ៣ នៃមគ្គខាងក្រោម ដូចបុរសកាត់ខ្សែដែលចងជើងដោយសស្ត្រាដូច្នោះ ។

ពីរបទថា **បញ្ច ជហេ** សេចក្ដីថា គប្បីលះបង់ គឺផ្ដាច់បោល, អធិប្បាយថា គប្បីកាត់សំយោជនៈខាងលើ ៥ យ៉ាង ដែលញ៉ាំងសត្វឲ្យដល់ទេវលោកជាន់ខ្ពស់ ដោយព្រះអរហត្តមគ្គ ដូចបុរសកាត់ខ្សែដែលចងពួដ៏កដូច្នោះ ។

បាទព្រះគាថាថា **បញ្ច ឧត្តរិ ភាវយេ** គឺគប្បីចម្រើនឥន្ទ្រិយ ៥ មានសទ្ធាជាដើមឲ្យច្រើន ដើម្បីប្រយោជន៍ដល់ការលះសំយោជនៈខាងលើ ។

បទថា **បញ្ចសង្គាតិគោ** សេចក្តីថា កាលបើដូច្នោះ ម្នាលភិក្ខុ អ្នកឈ្មោះថា កន្លងកិលេសជាគ្រឿងជាប់ជំពាក់ ៥ យ៉ាងបានហើយ ព្រោះឈានកន្លងកិលេសដែលជាគ្រឿងជាប់ជំពាក់ គឺរាគៈ ទោសៈ មោហៈ មានះ និងទិដ្ឋិ ៥ យ៉ាង ព្រះសាស្តាត្រាស់ហៅថា " អ្នកឆ្លងអន្លង់បាន ", អធិប្បាយថា ភិក្ខុនោះ ព្រះសាស្តាត្រាស់ហៅថា " អ្នកឆ្លងឱឃៈ ៤ បានដោយពិត " ។

ពីរបទថា **ឈាយ ភិក្ខុ** សេចក្តីថា ម្នាលភិក្ខុ ចូរអ្នកសម្លឹងមើលដោយអំណាចនៃឈាន ២ យ៉ាង ( អារម្មណូបនិជ្ឈាន និងលក្ខណូបនិជ្ឈាន ) ហើយឈ្មោះថា កុំប្រមាទ ព្រោះជាអ្នកមានប្រក្រតីមិនប្រមាទក្នុងកាយកម្មជាដើម ។

បទថា **ភមស្សុ** គឺចិត្តរបស់អ្នកចូរកុំវិលទៅរកកាមគុណ ៥ យ៉ាងឡើយ ។

បទថា **មា លោហគុឡំ** សេចក្តីថា ក៏ជនទាំងឡាយអ្នកប្រមាទហើយដោយអំណាចការធ្វេសប្រហែស មានការបណ្តែតបណ្តោយសតិជាលក្ខណៈ រមែងទំពាស៊ីដុំលោហៈ

ដ៏ក្ដៅក្នុងនរក, ព្រោះហេតុនោះ ទើបតថាគតពោលទៅកាន់អ្នក, អ្នកកុំជាអ្នកប្រមាទ ទំពាស៊ីដុំលោហ:, កុំជាអ្នកត្រូវភ្លើងឆេះរោលរាលក្នុងនរក ហើយកន្ទក់កន្ទេញថា " នេះទុក្ខ នេះទុក្ខដូច្នេះឡើយ " ។

ពីរបទថា **នត្ថិ ឈានំ** សេចក្ដីថា ឈ្មោះថា ឈានរមែងមិនមានដល់អ្នកមិនមានបញ្ញា ដោយបញ្ញាប្រកបដោយព្យាយាមជាគ្រឿងញុំាងឈានឲ្យកើតឡើង ។

ពីរបទថា **នត្ថិ បញ្ញា** សេចក្ដីថា បញ្ញាមានលក្ខណ: ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា " ភិក្ខុអ្នកមានចិត្តតាំងមាំហើយ រមែងដឹង រមែងឃើញតាមការពិត " រមែងមិនមានដល់បុគ្គលអ្នកមិនពិនិត្យ ។

បាទព្រះគាថាថា **យម្ហិ ឈានញ្ច បញ្ញា ច** សេចក្ដីថា ឈាន និងបញ្ញាសូម្បីទាំង ២ នេះមាននៅក្នុងបុគ្គលណា, បុគ្គលនោះឯង ឈ្មោះថា ឋិតនៅក្នុងទីជិតនៃព្រះនិព្វាន ។

បាទព្រះគាថាថា **សុញ្ញាគារំ បវិដ្ឋស្ស** គឺអ្នកអង្គុយដោយមិនលះបង់កម្មដ្ឋាន ដោយការធ្វើកម្មដ្ឋានទុកក្នុងចិត្តក្នុងឱកាសដ៏ស្ងាត់ណាមួយ ។

បទថា **សន្តចិត្តស្ស** គឺអ្នកមានចិត្តស្ងប់ហើយ ។

បទថា **សម្មា** ជាដើម សេចក្តីថា សេចក្តីត្រេកអរដែលមិនមែនជារបស់មនុស្ស ពោលគឺវិបស្សនាក្តី សេចក្តីត្រេកអរដែលជាទិព្វ ពោលគឺសមាបត្តិ ៨ ក្តី រមែងមាន, អធិប្បាយថា រមែងកើតឡើងដល់បុគ្គលអ្នកឃើញច្បាស់នូវធម៌ដោយហេតុ ដោយការណ៍ ។

បាទព្រះគាថាថា **យតោ យតោ សម្មសតិ** សេចក្តីថា ធ្វើកម្មក្នុងអារម្មណ៍ ៣៨ ប្រការ ដោយអាការណាៗ, គឺធ្វើកម្មក្នុងកាលទាំងឡាយ មានកាលមុនភត្តជាដើម ក្នុងកាលណាៗ ដែលខ្វនពេញចិត្តហើយ, ឬធ្វើកម្មក្នុងកម្មដ្ឋានដែលខ្វនពេញចិត្តហើយ ឈ្មោះថា រមែងពិចារណាឃើញ ។

បទថា **ឧទយព្វយំ** គឺនូវការកើតឡើងនៃខន្ធទាំង ៥ ដោយលក្ខណៈ ២៥ និងការវិនាសទៅនៃខន្ធ ៥ ដោយលក្ខណៈ ២៥ ដូចគ្នា ។

បទថា **បីតិបាមោជ្ជំ** គឺកាលពិចារណាការកើតឡើង និងការវិនាសទៅនៃខន្ធទាំងឡាយយ៉ាងនេះ ឈ្មោះថា រមែងបានបីតិនិងបាមោជ្ជក្នុងធម៌ ។

បទថា **អមតំ** សេចក្ដីថា កាលនាមរូបព្រមទាំងបច្ច័យជាសភាវៈប្រាកដឡើង បីតិនិងបាមោជ្ជដែលកើតឡើងហើយនោះ ឈ្មោះថា ជាអមតៈរបស់អ្នកដឹងច្បាស់ទាំងឡាយ គឺជារបស់បណ្ឌិតដោយពិត ព្រោះបីតិ និងបាមោជ្ជជាធម៌ដែលញ៉ាំងសត្វឲ្យដល់អមតមហានិព្វាន ។

បាទព្រះគាថាថា **តត្រាយមាទិ ភវតិ** គឺ នេះជាខាងដើម គឺបីតិ និងបាមោជ្ជនេះ ជាឋានៈមាននៅខាងដើមក្នុងអមតធម៌នោះ ។

ពីរបទថា **ឥធ បញ្ញស្ស** គឺមានដល់ភិក្ខុអ្នកមានបញ្ញាក្នុងសាសនានេះ ។ ឥឡូវនេះ ព្រះសាស្ដាកាលនឹងទ្រង់

សម្ដែងឋានៈដែលជាខាងដើម ដែលព្រះអង្គត្រាស់ថា “អាទិ” នោះ ទើបត្រាស់ពាក្យជាដើមថា “ **ឥន្ទ្រិយគុត្តិ** ” ពិតណាស់ បារិសុទ្ធិសីល ៤ ឈ្មោះថា ជាខាងដើម ។

ការសង្រួមឥន្ទ្រិយ ឈ្មោះថា **ឥន្ទ្រិយគុត្តិ** ក្នុងព្រះគាថានោះ ។ សេចក្ដីសន្ដោសចំពោះបច្ច័យ ៤ ឈ្មោះថា **សន្តុដ្ឋិ** ។ អាជីវបារិសុទ្ធិសីល និងបច្ចយសន្និស្សិតសីល ព្រះសាស្ដាត្រាស់ទុកដោយបទថា **សន្តុដ្ឋិ** នោះ ។

ភាពជាអ្នកធ្វើឲ្យបរិបូណ៌នូវសីលដ៏ប្រសើរបំផុត គឺ បាតិមោក្ខ ព្រះសាស្ដាត្រាស់ទុកដោយបទថា **បាតិមោក្ខេ** ។

បាទព្រះគាថាថា **មិត្តេ ភជស្សុ កល្យាណេ** សេចក្ដីថា អ្នកលះបង់សម្លាញ់ដែលមិនសមគួរ មានការងារលះបង់ហើយ ចូរសេព គឺចូរគប់រកកល្យាណមិត្ត អ្នកមានអាជីវៈដ៏បរិសុទ្ធ ព្រោះមានជីវិតប្រកបដោយសារៈ ឈ្មោះថា ជាអ្នកមិនខ្ជិលច្រអូស ព្រោះអាស្រ័យកម្លាំងស្មូងចិញ្ចឹមជីវិត ។

បាទព្រះគាថាថា **បដិសណ្ឋារវុត្យស្ស** គឺគប្បីជាអ្នកប្រព្រឹត្តបដិសណ្ឋារៈ, ព្រោះជាអ្នកដល់ព្រមដោយអាមិស-

ប្បដិសណ្ឋារៈ និងធម្មប្បដិសណ្ឋារៈ, អធិប្បាយថា គប្បីជាអ្នកធ្វើបដិសណ្ឋារៈ ។

បទថា **អាចារកុសលោ** សេចក្តីថា សូម្បីសីល ក៏ឈ្មោះថា មារយាទ សូម្បីវត្តបដិបត្តិក៏ឈ្មោះថា មារយាទដែរ, គប្បីជាអ្នកឆ្លាត, អធិប្បាយថា គប្បីជាអ្នកឈ្លាសវៃក្នុងមារយាទនោះ ។

បាទព្រះគាថាថា **តតោ បាមោជ្ជពហុលោ** សេចក្តីថា ព្រោះហេតុទាំង ២ នោះ អ្នកនឹងមានបាមោជ្ជច្រើន ព្រោះជាអ្នករីករាយក្នុងធម៌ ដែលកើតឡើងហើយអំពីការប្រព្រឹត្តបដិសណ្ឋារៈ និងអំពីភាពជាអ្នកឈ្លាសក្នុងមារយាទនោះ នឹងធ្វើទីបំផុតទុក្ខបាន ។

បណ្តាបទព្រះគាថាទាំងនេះ ដែលព្រះសាស្តាទ្រង់សម្តែងដោយអាការយ៉ាងនេះ កាលចប់ព្រះគាថាមួយៗ ភិក្ខុមួយរយៗ សម្រេចព្រះអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ លើអាសនៈដែលខ្លួនអង្គុយនោះឯង ហោះឡើងទៅកាន់វេហាស៍ ភិក្ខុទាំងនោះសូម្បីទាំងអស់ ឈានកន្លងផ្លូវ

កន្តារ ១២០ យោជន៍តាមផ្លូវអាកាសនោះឯង សរសើរព្រះសរីរៈដែលមានពណ៌ដូចមាសរបស់ព្រះតថាគត ហើយថ្វាយបង្គំព្រះបាទ ដូច្នេះឯង ។

( រឿងភិក្ខុច្រើនរូប ចប់ )

8888888888888888

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុប្រមាណ ៥០០ រូប ត្រាស់ព្រះធម្មទេសនានេះថា "**វស្សិកា វិយ បុប្ផានិ** " ជាដើម ។

បានឮថា ភិក្ខុទាំងនោះរៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្ដា បំពេញសមណធម៌ក្នុងព្រៃ ឃើញផ្កាម្លិះរីកនៅពេលព្រលឹម រោយចាកទងក្នុងវេលាល្ងាច ក៏នាំគ្នាព្យាយាមដោយគិតថា " ពួកយើងនឹងរួចផុតចាកកិលេសមានរាគៈជាដើម មុនផ្កាឈើទាំងឡាយរោយចាកទង " ។

## ភិក្ខុគួរព្យាយាមឲ្យផុតចាកវដ្ដទុក្ខ

ព្រះសាស្ដាទ្រង់ទតឃើញភិក្ខុទាំងនោះហើយត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុគប្បីព្យាយាយមដើម្បីផុតចាកវដ្ដទុក្ខឲ្យបាន ដូចផ្កាឈើដែលរោយចាកទងដូច្នោះ" ទង់គង់នៅឯព្រះគន្ធកុដិនោះឯង ទ្រង់ផ្សាយព្រះរស្មីទៅ ហើយត្រាស់ព្រះគាថានេះថា ៖-

**៨. វស្សិកា វិយ បុប្ផានិ មទ្ទវានិ បមុញ្ចតិ**

ឯវំ រាគញ្ច ទោសញ្ច   វិប្បមុញ្ចេថ ភិក្ខវោ ។
ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីជំរុះ
រាគនិងទោសចេញ   ដូចម្លិះជំរុះផ្កាទាំងឡាយ
ដែលស្វិតហើយ ដូច្នោះ ។

## អធិប្បាយគាថា

ម្លិះ ឈ្មោះថា **វស្សិកា** ក្នុងព្រះគាថានោះ ។

បទថា **មទ្ទវានិ** ប្រែថា ស្វិតហើយ ។

លោកអធិប្បាយពាក្យនេះទុកថា ៖-

"វល្លិ៍ម្លិះ រមែងជម្រុះ គឺរមែងពន្លែងផ្កាដែលរីកអំពីថ្ងៃម្សិល ក្នុងថ្ងៃស្អែកឡើង ជាផ្កាឈើចាស់ ឲ្យរោយចាកទង យ៉ាងណា, សូម្បីអ្នកទាំងឡាយ   ក៏គប្បីជម្រុះទោសទាំងឡាយ មានរាគជាដើមដូច្នោះដែរ" ។

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះសូម្បីទាំងអស់តាំងនៅក្នុងព្រះអរហត្ត ដូច្នេះឯង ។

រឿងភិក្ខុប្រមាណ ៥០០ រូប ចប់

## ៩ រឿងព្រះសន្តកាយត្ថេរ

### សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសន្តកាយត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា "**សន្តកាយោ**" ជាដើម ។

### ព្រះថេរធ្លាប់កើតជារាជសីហ៍

បានឮថា ការរពឹសដៃរពឹសជើងរបស់ព្រះថេររូបនោះ មិនបានមានហើយ ។ លោកជាអ្នកវៀរចាកការពត់កាយ ជាអ្នកមានអត្តភាពស្ងប់ ។

បានឮថា ព្រះថេររូបនោះមកអំពីកំណើតរាជសីហ៍ ។ បានឮថា រាជសីហ៍ទាំងឡាយ កាន់យកអាហារក្នុងថ្ងៃមួយហើយ ចូលទៅកាន់គុហាប្រាក់ គុហាមាស គុហាកែវមណី និងគុហាកែវប្រពាឡ គុហាណាមួយ ដេកលើលំអិតមនោ-សិលានិងហរិតាលសិលាអស់ ៧ ថ្ងៃ ថ្ងៃទី ៨ ក្រោកឡើងហើយ រមិលមើលនូវទីដែលខ្លួនដេកនោះ ប្រសិនបើលំអិតមនោសិលានិងហរិតាលសិលានោះរាត់រាយ ព្រោះកន្ទុយ

ត្រចៀក ឬជើងជាអវយវកម្រើក ក៏គិតថា "ការធ្វើដូច្នេះ មិនសមគួរដល់ជាតិនិងគោត្តរបស់ឯងទេ" ហើយក៏ដេកអត់អាហារ ៧ ថ្ងៃទៀត, ប៉ុន្តែបើលំអិតមនោសិលានិងហរិតា-សិលាមិនរាត់រាយទេ ក៏គិតថា "ការធ្វើដូច្នេះ ទើបសមគួរដល់ជាតិនិងគោត្ររបស់ឯង" ដូច្នេះហើយ ក៏ចេញចាកទីអាស្រ័យ ពត់កាយ ក្រឡេកមើលទិសទាំងឡាយ បន្លឺសីហនាទ ៣ ដង ហើយក៏ចេញទៅរកស៊ី ។ ភិក្ខុនេះមកហើយដោយកំណើតរាជសីហ៍បែបនោះ ។

ភិក្ខុទាំងឡាយ ឃើញមារយាទដ៏ប្រពៃប្រចាំកាយរបស់ព្រះថេររូបនោះ ក៏ក្រាបទូលព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុដូចជាព្រះសន្តកាយថេរនោះ ពួកខ្ញុំព្រះអង្គមិនធ្លាប់បានឃើញឡើយ, ក៏ការរពឹសដៃ រពឹសជើង ឬការពត់កាយរបស់ភិក្ខុនេះ ក្នុងទីដែលភិក្ខុនេះអង្គុយហើយ មិនមានឡើយ" ។

## ភិក្ខុគួរជាអ្នកស្ងប់

ព្រះសាស្តាទ្រង់ព្រះសណ្តាប់នូវពាក្យនោះហើយ ក៏ទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុ គប្បីជាអ្នកស្ងប់តាមទ្វារទាំងឡាយ មានកាយទ្វារជាដើមដោយពិត ដូចសន្តកាយថេរដូច្នោះ” ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា៖-

**៩ សន្តកាយោ សន្តវាចោ សន្តមនោ សុសមាហិតោ**
**វន្តលោកាមិសោ ភិក្ខុ ឧបសន្តោតិ វុច្ចតិ ។**

ភិក្ខុអ្នកមានកាយរម្ងាប់ហើយ មានវាចារម្ងាប់ហើយ មានចិត្តរម្ងាប់ហើយ មានចិត្តតម្កល់មាំហើយ មានអាមិសក្នុងលោក ខ្ជាក់ចោលហើយ ទើបតថាគតហៅថា អ្នកស្ងប់រម្ងាប់ ។

## អធិប្បាយថា

បណ្តាបទទាំងនោះ បទថា **សន្តកាយោ** ជាដើម សេចក្តីថា ដែលឈ្មោះថា អ្នកមានកាយស្ងប់ហើយ ព្រោះមិនមានកាយទុច្ចរិតទាំងឡាយ មានបាណាតិបាតជាដើម ។ ដែលឈ្មោះថា អ្នកមានវាចាស្ងប់ហើយ ព្រោះមិនមានវចីទុច្ចរិតទាំងឡាយ មានមុសាវាទជាដើម, ដែលឈ្មោះថា អ្នក

មានចិត្តស្ងប់ហើយ ព្រោះមិនមានមនោទុច្ចរិតទាំងឡាយមាន អភិជ្ឈាជាដើម, ដែលឈ្មោះថា អ្នកមានចិត្តតម្កល់មាំហើយ ព្រោះទ្វារទាំង ៣ មានកាយទ្វារជាដើមតម្កល់មាំហើយដោយល្អ, ដែលឈ្មោះថា អ្នកមានអាមិសក្នុងលោកខ្ជាក់ចោលហើយ ព្រោះអាមិសក្នុងលោកជារបស់ដែលខ្លួនខ្ជាក់ចោលហើយដោយមគ្គ ៤, ព្រះសាស្តាត្រាស់ហៅថា អ្នកស្ងប់ ព្រោះកិលេសទាំងឡាយ មានរាគជាដើមខាងក្នុងស្ងបរម្ងាប់ហើយ ។

ក្នុងកាលចប់ទេសនា ព្រះថេរនោះតាំងនៅក្នុងព្រះអរហត្ត ទេសនាជាគុណជាតិមានប្រយោជន៍សូម្បីដល់ជនដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

រឿងព្រះសន្តកាយថេរ ចប់

# ១០ រឿងនន្ទលកូជត្ថេរ

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ ព្រះនង្គលកូដត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា “ ***អត្តនា ចោទយត្តានំ*** ” ដូច្នេះជាដើម ។

## មនុស្សទុគ៌តបួសក្នុងព្រះពុទ្ធសាសនា

បានឮថា មនុស្សទុគ៌តម្នាក់ ស៊ីឈ្នួលគេចិញ្ចឹមជីវិត ។ ភិក្ខុមួយរូបឃើញមនុស្សទុគ៌តនោះ ស្លៀកក្រណាត់សម្ពត់ចាស់ លីនង្គ័លដើរទៅស្រែ ក៏សួរយ៉ាងនេះថា “ ម្នាលអ្នកដ៏ចម្រើន អ្នកបួសមិនប្រសើរជាងការរស់នៅយ៉ាងនេះទេឬ ?”

បុរសទុគ៌ត. បពិត្រលោកម្ចាស់ដ៏ចម្រើន អ្នកណាទៅនឹងឲ្យខ្ញុំព្រះករុណា ដែលជាអ្នករស់នៅយ៉ាងនេះបួសនោះ ។

ភិក្ខុ. ម្នាលអ្នកដ៏ចម្រើន ប្រសិនបើអ្នកចង់បួស អាត្មានឹងឲ្យអ្នកបួស ។

បុរសទុគ៌ត. “ ប្រពៃហើយលោកម្ចាស់, ប្រសិនបើលោកម្ចាស់ខ្ញុំបួស ខ្ញុំនឹងបួស ” ។

គ្រានោះ ព្រះថេរៈនាំបុរសទុគ៌តនោះទៅកាន់វត្តជេត-ពន ហើយឲ្យងូតទឹកដោយដៃរបស់ខ្លួន ឲ្យសម្រាកនៅក្នុងរោងហើយ បំបួស ឲ្យបុរសនោះទុកដាក់នង្គ័ល ព្រមទាំងក្រណាត់សម្ពត់ចាស់ ដែលខ្លួនស្លៀកលើមែកឈើ ជិតរោងនោះ ។ ក្នុងកាលឧបសម្បទាហើយ បុរសទុគ៌តនោះ បានប្រាកដនាមថា “ នង្គលកូដត្ថេរ ” ។

## ភិក្ខុមានឧបាយទូន្មានខ្លួនឯង រមែងរម្ងាប់សេចក្តីអផ្សុកបាន

ព្រះនង្គលកូដត្ថេរនោះ អាស្រ័យលាភសក្ការៈដែលកើតឡើងចំពោះព្រះពុទ្ធទាំងឡាយចិញ្ចឹមជីវិត សេចក្តីអផ្សុក

ក៏កើតឡើង កាលមិនអាចបន្ទោបង់សេចក្តីអផ្សុកបាន ក៏សម្រេចចិត្តថា “ ឥឡូវនេះ យើងនឹងមិនស្លៀកដណ្តប់សម្ពត់កាសាយៈទាំងឡាយដែលគេឲ្យដោយសទ្ធាទៀតទេ ” ដូច្នេះហើយ ក៏ទៅកាន់គល់ឈើ ទូន្មានខ្លួនដោយខ្លួនឯងថា នែបុគ្គលមិនមានហិរិ មិនមានសេចក្តីអៀនខ្មាស ឯងចង់សឹក ស្លៀកដណ្តប់ក្រណាត់សម្ពត់មួយផ្ទាំងនេះ ហើយស៊ីឈ្នួលគេចិញ្ចឹមជីវិតឬ ” ។ កាលលោកទូន្មានខ្លួនយ៉ាងនោះ ចិត្តជាធម្មជាតិស្រាល ( អស់ការអផ្សុក ) ។

លោកត្រឡប់មកវិញ កន្លងទៅបាន ២-៣ ថ្ងៃ ក៏អផ្សុកទៀត ទើបទូន្មានខ្លួនដោយឧបាយដូចមុន, លោកក៏ត្រឡប់ចិត្តបានទៀត ។ ពេលអផ្សុកលោកក៏ទៅកាន់ទីនោះហើយទូន្មានខ្លួនដោយទំនងនេះឯង ។

គ្រានោះ ភិក្ខុទាំងឡាយឃើញលោកទៅកាន់ទីនោះរឿយៗ ក៏សួរថា “ នែអាវុសោនន្តលកូជៈ ហេតុអ្វី ទើបអ្នកទៅកាន់ទីនោះ ?” ។

លោកឆ្លើយតបថា “ អ្នកដ៏មានអាយុទាំងឡាយ ខ្ញុំទៅកាន់សម្នាក់អាចារ្យរបស់ខ្ញុំ ” ដូច្នេះហើយ ២-៣ ថ្ងៃក្រោយមក ( ក៏ ) បានសម្រេចព្រះអរហត្ត ។

ភិក្ខុទាំងឡាយកាលទឹងធ្វើការចំអកចំអន់លោក ក៏បានពោលថា “ នែអាវុសោនន្ទលកុដ: ផ្លូវដែលជាទីត្រាច់ទៅរបស់អ្នកហាក់ដូចជាមិនមានស្នាម ប្រហែលជាអ្នកមិនទៅកាន់សម្នាក់អាចារ្យរបស់អ្នកទៀតទេដឹង ” ។

ព្រះថេរ:. បពិត្រអ្នកមានអាយុទាំងឡាយ យ៉ាងនោះហើយ, កាលកិលេសជាគ្រឿងជាប់ជំពាក់នៅមាន ខ្ញុំបានទៅកាន់ទីនោះ, ប៉ុន្តែឥឡូវនេះ កិលេសដែលជាគ្រឿងជាប់ជំពាក់នោះ ខ្ញុំកាត់បានហើយ ព្រោះហេតុនោះ ទើបខ្ញុំមិនទៅកាន់ទីនោះទៀត ។

ភិក្ខុទាំងឡាយ ស្តាប់ពាក្យនោះហើយ យល់ថា “ ភិក្ខុនេះពោលពាក្យមិនពិត ព្យាករព្រះអរហត្តផល ” ដូច្នេះហើយក៏ក្រាបទូលរឿងនោះចំពោះព្រះសាស្តា ។

## ភិក្ខុជាអ្នកទូន្មានខ្លួន

ព្រះសាស្ដាត្រាស់ថា “ ម្នាលភិក្ខុទាំងឡាយ នង្គល-
កូដៈបុត្ររបស់តថាគត ទូន្មានខ្លួនដោយខ្លួនឯងហើយ ទើប
ដល់នូវទីបំផុតនៃកិច្ចរបស់បព្វជិត ” ដូច្នេះហើយ កាលនឹង
ទ្រង់សម្ដែងធម៌ បានទ្រង់ភាសិតព្រះគាថាទាំងនេះថា :-

**១០ អត្តនា ចោទយត្តានំ បដិមំសេតមត្តនា**
**សោ អត្តគុត្តោ សតិមា សុខំ ភិក្ខុ វិហាហិសិ ។**
**អត្តាហិ អត្តនោ នាថោ អត្តា ហិ អត្តនោ គតិ**
**តស្មា សញ្ញម អត្តានំ អស្សំ ភទ្រំវ វាណិជោ ។**

អ្នកចូរដាស់តឿនខ្លួនដោយខ្លួនឯង ចូរ
ពិនិត្យខ្លួនដោយខ្លួនឯង ម្នាលភិក្ខុ អ្នកនោះបើ
មានស្មារតី រក្សាខ្លួនទុកហើយ នឹងនៅជាសុខ ។
មែនពិត ខ្លួនជាទីពឹងរបស់ខ្លួន ខ្លួនឯងជាគតិ
របស់ខ្លួន ព្រោះហេតុនោះ អ្នកចូររាំងខ្លួន ដូច
ពាណិជរាំងសេះដ៏ល្អ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **ពោទយត្តានំ** សេចក្ដីថា ចូរដាស់តឿនដោយខ្លួនឯង គឺចូរញ៉ាំងខ្លួនឲ្យដឹងខ្លួនដោយខ្លួនឯង ។

បទថា **បដិមំសេ** ចូរពិនិត្យខ្លួនដោយខ្លួនឯង ។

បទថា **សោ** ជាដើម សេចក្ដីថា ម្នាលភិក្ខុ អ្នកនោះកាលដាស់តឿន ពិនិត្យមើលខ្លួនយ៉ាងនោះហើយ, ជាអ្នកឈ្មោះថា គ្រប់គ្រងខ្លួនបាន ព្រោះជាអ្នកមានខ្លួនគ្រប់គ្រងហើយដោយខ្លួនឯង ដែលឈ្មោះថា អ្នកមានសតិ ព្រោះជាអ្នកមានសតិតាំងមាំហើយ នឹងរស់នៅសុខគ្រប់ឥរិយាបថ ។

បទថា **នាថោ** សេចក្ដីថា ជាទីពឹង គឺជាទីពុំនាក់អាស្រ័យ ( អ្នកដទៃណាទៅ គប្បីជាទីពឹងបាន ) ព្រោះបុគ្គលអាស្រ័យអត្តភាពរបស់អ្នកដទៃ មិនអាចធ្វើកុសលហើយមានសួគ៌ជាទីទៅខាងមុខ ឬជាអ្នកញ៉ាំងមគ្គឲ្យចម្រើនហើយ ធ្វើផលឲ្យជាក់ច្បាស់បាន, ព្រោះហេតុនោះ ទើបមានសេចក្ដីអធិប្បាយថា " អ្នកដទៃណាទៅ អាចជាទីពឹងបាន " ។

បទថា **តស្មា** ជាដើម សេចក្តីថា ខ្លួនជាគតិរបស់ខ្លួន គឺជាទីពុំនាក់អាស្រ័យ បានដល់ ជាសរណៈរបស់ខ្លួន ។

ឈ្មួញអាស្រ័យសេះដ៏ចម្រើន គឺសេះអាជានេយ្យនោះ ប្រាថ្នាលាភ ទើបការពារការត្រាច់ទៅក្នុងវិសមស្ថាន ( ទីមិនសមគួរ ) នៃសេះនោះ ងូតទឹកឲ្យសេះនោះ ឲ្យបរិភោគក្នុង ១ ថ្ងៃ ៣ ដង ឈ្មោះថា រមែងប្រុងប្រយ័ត្ន គឺគ្រប់គ្រងថែទាំយ៉ាងណា ចំពោះអ្នកទាំងឡាយក៏ដូច្នោះដែរ កាលការពារការកើតឡើងនៃអកុសលដែលមិនទាន់កើត កម្ចាត់បង់អកុសលដែលកើតឡើងហើយ ព្រោះការវង្វេងភ្លេចសតិ ( ក៏ ) ឈ្មោះថា ស្ងួនគ្រង គឺគ្រប់គ្រងខ្លួន ដូច្នោះដែរ, កាលអ្នកគ្រប់គ្រងខ្លួនបានយ៉ាងនេះ អ្នកនឹងសម្រេចគុណវិសេសទាំងដែលជាលោកិយ ទាំងដែលជាលោកុត្តរៈ ផ្តើមពីបឋមជ្ឈានជាដើមទៅ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

( រឿងព្រះនន្ទកូដត្ថេរ ចប់ )

888888888888888888888

# ១១ រឿងព្រះវក្កលិត្ថេរ

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធ ព្រះវក្កលិត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា “ **បាមោជ្ជ-ពហុលោ ភិក្ខុ** ” ដូច្នេះជាដើម ។

## អ្នកឃើញធម៌ឈ្មោះថាឃើញព្រះសាស្ដា

បានឮថា ព្រះវក្កលិត្ថេរនោះ កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថី ចម្រើនវ័យហើយ ឃើញព្រះតថាគត ស្ដេចចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត សម្លឹងមើលព្រះសរីរ-សម្បត្តិរបស់ព្រះសាស្ដាហើយ មិនឆ្អែតដោយការមើលព្រះសរីរសម្បត្តិ, ក៏សូមបព្វជ្ជាក្នុងសម្នាក់ព្រះសាស្ដា ដោយយល់ថា " យើងនឹងបានឃើញព្រះតថាគតអស់កាលជានិច្ច ដោយឧបាយនេះ " ដូច្នេះហើយ ក៏ឈរក្នុងទីដែលខ្លួនអាចមើលឃើញព្រះទសពលបាន, លះបង់កិច្ចវត្តទាំងឡាយ មានការស្វាធ្យាយ និងមនសិការក្នុងកម្មដ្ឋានជាដើម តាមតែមើលព្រះសាស្ដា ។

ព្រះសាស្ដា ទ្រង់រង់ចាំការចាស់ក្លានៃញាណរបស់លោក ទើបមិនត្រាស់អ្វីៗ ក្រោយមកទ្រង់ជ្រាបថា " ឥឡូវនេះ ញាណរបស់វក្កលិចាស់ក្លាហើយ " ទើបឲ្យឱវាទថា ម្នាលវក្កលិ ប្រយោជន៍អ្វីរបស់អ្នក ដោយការចាំមើលកាយស្អុយនេះ, " ម្នាលវក្កលិ បុគ្គលណាឃើញធម៌ បុគ្គលនោះ

ឈ្មោះថា ឃើញតថាគត, បុគ្គលណាឃើញតថាគត បុគ្គលនោះ ឈ្មោះថា ឃើញធម៌ ” ។

ព្រះវក្កលិនោះ សូម្បីព្រះសាស្ដាទ្រង់ទូន្មានយ៉ាងនោះ ក៏នៅតែមិនលះបង់ការមើលព្រះសាស្ដាក្នុងទីដទៃបាន ។

គ្រានោះ ព្រះសាស្ដាទ្រង់ព្រះតម្រិះថា “ ភិក្ខុនេះ មិនបានសេចក្ដីសង្វេគ នឹងមិនបានត្រាស់ដឹង ” កាលវស្សូបនាយិកាជិតចូលមកដល់ ក៏ស្ដេចទៅកាន់ក្រុងរាជគ្រឹះ ក្នុងថ្ងៃចូលវស្សា ព្រះសាស្ដាទ្រង់បណ្ដេញព្រះវក្កលិដោយព្រះតម្រាស់ថា “ ម្នាលវក្កលិ អ្នកចូរចៀសចេញទៅ ” ។ ព្រះវក្កលិគិតថា “ ព្រះសាស្ដាមិនត្រាស់ហៅយើង ” មិនអាចនឹងនៅក្នុងទីចំពោះព្រះភក្ត្រព្រះសាស្ដា អស់ត្រៃមាសបាន ទើបគិតថា “ ជីវិតនេះ មានប្រយោជន៍អ្វីចំពោះយើងទៀត, យើងនឹងលោតចុះអំពីភ្នំឲ្យស្លាប់ ” លុះគិតដូច្នេះហើយ ក៏ឡើងកាន់ភ្នំគិជ្ឈកូដ ។ ព្រះសាស្ដា ទ្រង់ជ្រាបនូវសេចក្ដីលំបាករបស់ព្រះវក្កលិនោះហើយ ក៏ទ្រង់ព្រះតម្រិះថា “ ភិក្ខុនេះ កាលមិនបានការលួងលោមអំពីសម្នាក់តថាគតនឹងញ៉ាំង

ធម៌ដែលជាឧបនិស្ស័យនៃមគ្គ និងផលទាំងឡាយឲ្យវិនាស”
ទើបទ្រង់ផ្សាយព្រះរស្មីទៅ ដើម្បីនឹងទ្រង់សម្តែងព្រះអង្គ (ឲ្យ
ប្រាកដ ) ។

គ្រានោះ សេចក្តីសោកដ៏ធំដល់ម៉្លោះ បាត់អស់ទៅ
ដំណាលគ្នានឹងការឃើញព្រះសាស្តា ។

ព្រះសាស្តា ដូចជាទេវតាដ៏វិសេស ញ៉ាំងស្រះដ៏ស្ងួត
ឲ្យពេញដោយទឹក ដើម្បីនឹងទ្រង់ញ៉ាំងបីតិ និងបាមោជ្ជដ៏មាន
កម្លាំងឲ្យកើតឡើងដល់ព្រះវក្កលិ ទើបត្រាស់ព្រះគាថានេះថា

**១១ បាមោជ្ជពហុលោ ភិក្ខុ បសន្នោ ពុទ្ធសាសនេ**
**អធិគច្ឆេ បទំ សន្តំ សង្ខារូបសមំ សុខំ ។**

ភិក្ខុអ្នកក្រាស់ដោយសេចក្តីរីករាយ ជ្រះ
ថ្លាក្នុងព្រះពុទ្ធសាសនា រមែងបាននូវបទដ៏ស្ងប់
ជាទីរម្ងាប់នូវសង្ខារ នាំមកនូវសេចក្តីសុខ ។

## អធិប្បាយគាថា

គប្បីជ្រាបសេចក្តីនៃព្រះគាថានោះថា :-

ភិក្ខុអ្នកច្រើនដោយបាមោជ្ជជាប្រក្រតី រមែងបណ្តុះសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធសាសនា, ភិក្ខុនោះជ្រះថ្លា ( ក្នុងព្រះពុទ្ធសាសនា ) ហើយយ៉ាងនោះ រមែងបាននូវបទដ៏ស្ងប់ គឺព្រះនិព្វានក្នុងព្រះពុទ្ធសាសនា ដែលមានឈ្មោះថា " សន្តិបទ ជាទីចូលទៅស្ងប់សង្ខារ ជាសុខ " ។

ព្រះសាស្តា លុះត្រាស់ព្រះគាថានេះហើយ ទ្រង់លាតព្រះហស្ត ហើយត្រាស់ព្រះគាថាទាំងនេះដល់ព្រះវក្កលិថា :-

ម្នាលវក្កលិ ចូរមក ចូរកុំខ្លាចឡើយ ចូរក្រឡេកមើលតថាគតចុះ, តថាគតនឹងស្រង់អ្នកឡើង ដូចអាចារ្យដំរីស្រង់ដំរីកុញ្ជរដែលលិចក្នុងភក់ដូច្នោះ ។
ម្នាលវក្កលិ ចូរមក ចូរអ្នកុំខ្លាចឡើយ អ្នកចូរក្រឡេកមើលតថាគតចុះ, តថាគតនឹងស្រង់អ្នកឡើង ដូចទេវតាដ៏វិសេសជួយព្រះចន្ទដែលត្រូវរាហូចាប់ដូច្នោះ ។

ព្រះវក្កលិ ញ៉ាំងបីតិដ៏មានកម្លាំងឲ្យកើតឡើងហើយ ដោយគំនិតថា " យើងបានឃើញព្រះទសពលហើយ "

ហើយព្រះសាស្ដាក៏ត្រាស់ហៅយើងថា “ ម្នាលវក្កលិ អ្នកចូរមក, ទើបគិតថា “ យើងនឹងទៅផ្លូវណាហ្ន៎ ?” កាលមិនឃើញផ្លូវទៅ ក៏ហោះឡើងទៅកាន់អាកាសក្នុងទីចំពោះព្រះ-កក្រ្តព្រះទសពល កាលជំហានជាដំបូងតាំងនៅលើភ្នំនោះឯង ក៏នឹកគិតដល់ព្រះគាថាដែលព្រះសាស្ដាត្រាស់ហើយ សង្កត់បីតិបានក្នុងអាកាសនោះ សម្រេចព្រះអរហត្ត ព្រមទាំងបដិ-សម្ភិទាទាំងឡាយ ថ្វាយបង្គំព្រះទសពលហើយ ចុះមកឈរក្នុងសម្នាក់ព្រះសាស្ដា ។

គ្រានោះ ព្រះសាស្ដាទ្រង់តាំងលោកទុកក្នុងតំណែងដ៏លើសជាងសាវកទាំងឡាយ អ្នកមានចិត្តស៊ប់ស្ងួនដោយសទ្ធា ( សទ្ធាធិមុត្ត ) ។

( រឿងវក្កលិត្ថេរ ចប់ )

## ១២ រឿងសុខសាមណេរ

### សេចក្ដីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តបុព្វារាម ទ្រង់ប្រារព្ធសុខសាមណេរ ត្រាស់ព្រះធម្មទេសនានេះថា " **យោ ហវេ** " ដូច្នេះជាដើម ។

# បុព្វកម្មរបស់ព្រះអនុរុទ្ធ

អនុបុព្វីកថាក្នុងរឿងនោះ ដូចតទៅនេះ :-

បានឮថាក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាមថាបទុមុត្តរៈ កុលបុត្រម្នាក់ ឃើញព្រះសាស្តាទ្រង់តែងតាំងភិក្ខុមួយរូបទុកក្នុងតំណែងជាឯតទគ្គផ្នែកខាងទិព្វចក្ខុ កណ្តាលបរិស័ទទាំង ៤ ប្រាថ្នាសម្បត្តិនោះ ទើបនិមន្តព្រះសាស្តា ថ្វាយទានចំពោះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ហើយប្រាថ្នាថា " បពិត្រព្រះអង្គដ៏ចម្រើន សូមខ្ញុំព្រះអង្គក៏គប្បីជាអ្នកប្រសើរជាងភិក្ខុទាំងឡាយផ្នែកខាងអ្នកមានទិព្វចក្ខុ ក្នុងព្រះសាសនានៃព្រះពុទ្ធមួយព្រះអង្គក្នុងអនាគតដែរ" ។

ព្រះសាស្តា ទ្រង់ពិចារណាមើលអស់មួយសែនកប្បទ្រង់ជ្រាប ការសម្រេចនៃសេចក្តីប្រាថ្នារបស់កុលបុត្រនោះហើយ ទើបទ្រង់ព្យាករណ៍ថា"ក្នុងទីបំផុតមួយសែនកប្បអំពី

កប្បនេះទៅ អ្នកនឹងមានឈ្មោះថាអនុរុទ្ធត្ថេរ ប្រសើរជាងភិក្ខុទាំងឡាយផ្នែកខាងអ្នកមានទិព្វចក្ខុ ក្នុងសាសនានៃព្រះពុទ្ធទ្រង់ព្រះនាមថាគោតម” កុលបុត្រនោះស្ដាប់ពាក្យព្យាករណ៍នោះហើយ ក៏សម្គាល់សម្បត្តិនោះថាដូចជាខ្ទនទឹងបានក្នុងថ្ងៃស្អែក, កាលព្រះសាស្ដាបរិនិព្វានហើយ, ក៏សួរភិក្ខុទាំងឡាយអំពីការបរិកម្មដើម្បីបានទិព្វចក្ខុ ភិក្ខុទាំងឡាយឲ្យធ្វើគោមច្រើនពាន់ដើម ដាក់ជុំវិញព្រះស្តូបមាសដែលមានកំពស់និងទំហំ ៧ យោជន៍ ហើយឲ្យបូជាព្រះស្តូបដោយប្រទីប ចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោកត្រាច់វង្កត់ទៅមកក្នុងទេវលោក និងមនុស្សលោកអស់មួយសែនកប្ប ក្នុងភទ្ទកប្បនេះ កើតក្នុងត្រកូលអ្នកក្រ ក្នុងក្រុងពារាណសី អាស្រ័យសុមនសេដ្ឋី ជាអ្នកជញ្ជូនស្មៅឲ្យសេដ្ឋីនោះចិញ្ចឹមជីវិត ។ បុរសនោះមានឈ្មោះថា “អន្នភារៈ” ។

ចំណែកសុមនសេដ្ឋីក៏ថ្វាយមហាទាន ក្នុងព្រះនគរនោះ អស់កាលជានិច្ច ។

សម័យថ្ងៃមួយ ព្រះបច្ចេកពុទ្ធព្រះនាមថាឧបរិដ្ឋៈ ចេញចាកនិរោធសមាបត្តិឯគន្ធមាទន៍ហើយ គិតថា "ថ្ងៃនេះ យើងនឹងសង្គ្រោះអ្នកណាហ្ន៎ ?" ទ្រង់ជ្រាបថា "ថ្ងៃនេះ ការដែលខ្ញុំសង្គ្រោះបុរសឈ្មោះអន្នភារៈ សមគួរណាស់, ក៏ឥឡូវនេះ គេកំពុងដឹកជញ្ជូនស្មៅអំពីព្រៃមកផ្ទះ" ដូច្នេះហើយ ក៏កាន់បាត្រនិងចីវរទៅដោយឫទ្ធិ ប្រាកដចំពោះមុខអន្នភារៈ ។ អន្នភារៈឃើញព្រះបច្ចេកពុទ្ធមានបាត្រទទេក្នុងព្រះហស្ថ ក៏សួរថា "បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់បានភិក្ខាខ្លះហើយឬ ?" កាលព្រះបច្ចេកពុទ្ធតបថា " អាត្មាភាពនឹងបាន អំពីអ្នកមានបុណ្យច្រើន " ក៏ប្រាប់ថា " បពិត្រលោកម្ចាស់ដ៏ចម្រើន បើដូច្នោះ សូមលោកម្ចាស់មេត្តារង់ចាំបន្តិចចុះ " ដូច្នេះហើយ ក៏បោះអម្រែកចោលនៅទីនោះ ហើយទៅកាន់ផ្ទះដោយរហ័ស សួរភរិយាថា "ម្នាលនាងដ៏ចម្រើនភត្តដែលនាងទុកសម្រាប់ខ្ញុំនោះមានដែរឬ ?" កាលភរិយាតបថា "បពិត្រនាយ មាន", ក៏ត្រឡប់មកដោយរហ័ស ទទួលយកបាត្ររបស់ព្រះបច្ចេកពុទ្ធទៅកាន់ផ្ទះដោយគិតថា កាលដែល

យើងប្រាថ្នានឹងឲ្យទាន ទេយ្យធម៌មិនមាន, កាលទេយ្យធម៌មាន យើងមិនបានបដិគ្គាហក ប៉ុន្តែថ្ងៃនេះបដិគ្គាហកក៏មាន ហើយទេយ្យធម៌របស់យើងក៏មាន, នេះជាលាភរបស់យើងហើយហ្ន៎ " ឲ្យករិយាដាក់កត្តុក្នុងបាត្រហើយ នាំត្រឡប់មកដាក់លើព្រះហស្តរបស់ព្រះបច្ចេកហើយប្រាថ្នាថា ៖-

ដោយអំណាចនៃទាន ភាពជាអ្នកទាល់ក្រ កុំបីមានដល់ខ្ញុំព្រះករុណាឡើយ, ពាក្យថា មិនមាន កុំបីមានដល់ខ្ញុំព្រះករុណាក្នុងភពតូច និងភពធំឡើយ ។

បពិត្រលោកម្ចាស់ដ៏ចម្រើន សូមឲ្យខ្ញុំព្រះករុណារួចផុតអំពីការចិញ្ចឹមជីវិតដ៏លំបាកយ៉ាងនេះ, សូមកុំឲ្យខ្ញុំព្រះ-ករុណាបានឮបទថា មិនមានឡើយ ។

ព្រះបច្ចេកពុទ្ធអនុមោទនាថា នៃអ្នកដ៏ចម្រើន សេចក្តីប្រាថ្នារបស់អ្នក ចូរសម្រេចតាមសេចក្តីប្រាថ្នាចុះ ដូច្នេះហើយក៏ចៀសចេញទៅ ។

ទេវតាដែលអាស្រ័យនៅពួដ៏ធត្រ របស់សុមនសេដ្ឋី ពោលថា

ឱ ! ទានដ៏ក្រៃលែង អន្នការបុរសបានតាំងទុក
ល្អហើយក្នុងព្រះបច្ចេកពុទ្ធព្រះនាមឧបរិដ្ឋ ។
ហើយបានឲ្យសាធុការអស់វារៈ ៣ ដង ។

គ្រានោះ សេដ្ឋីពោលទៅកាន់ទេវតានោះថា អ្នកមិនឃើញយើងឲ្យទានអស់កាលមានប្រមាណប៉ុណ្ណេះទេឬ ?

ទេវតា. ខ្ញុំមិនមែនប្រារព្ធទានរបស់លោក ហើយឲ្យសាធុការនោះទេ, ប៉ុន្តែសាធុការនេះ ខ្ញុំឲ្យប្រព្រឹត្តទៅហើយក៏ព្រោះសេចក្តីជ្រះថ្លាក្នុងបិណ្ឌបាត ដែលអន្នការៈថ្វាយហើយចំពោះព្រះបច្ចេកពុទ្ធ ។

សេដ្ឋីនោះគិតថា នែអ្នកដ៏ចម្រើន ហេតុគួរអស្ចារ្យណាស់ហ្ន៎, យើងថ្វាយទានអស់កាលប្រមាណប៉ុណ្ណេះ ក៏មិនអាចនឹងញ៉ាំងទេវតាឲ្យសាធុការបាន, អន្នការៈរស់នៅអាស្រ័យយើង ញ៉ាំងទេវតាឲ្យឲ្យសាធុការដោយបិណ្ឌបាតតែមួយប៉ុណ្ណោះបាន, យើងនឹងឲ្យវត្ថុដ៏សមគួរចំពោះទានរបស់

គេ ហើយធ្វើបិណ្ឌបាតនោះឲ្យជារបស់យើង ដូច្នេះហើយ ក៏ឲ្យគេហៅអន្នភារៈមកសួរថា នែអន្នភារៈ ថ្ងៃនេះឯងបានឲ្យអ្វីដល់អ្នកណាខ្លះ ?

អន្នភារៈ. បពិត្រសេដ្ឋី ថ្ងៃនេះ ខ្ញុំបានថ្វាយភត្តាហារចំពោះព្រះបច្ចេកពុទ្ធព្រះនាមឧបរិដ្ឋ ។

សេដ្ឋី. នែអន្នភារៈ បើដូច្នោះ អ្នកចូរកាន់យកកហាបណៈ ហើយឲ្យបិណ្ឌបាតនោះដល់ខ្ញុំចុះ ។

អន្នភារៈ. បពិត្រសេដ្ឋី ខ្ញុំជូនមិនបានទេ ។

សេដ្ឋីនោះតម្លើងថ្លៃរហូតដល់ពាន់នៃកហាបណៈ ។

ចំណែកអន្នភារៈ មិនបានជូនបិណ្ឌបាតនោះទៅសេដ្ឋីសូម្បីដោយទ្រព្យទាំងពាន់នៃកហាបណៈ ។

គ្រានោះ សេដ្ឋីពោលទៅកាន់អន្នភារៈថា នែអ្នកដ៏ចម្រើន រឿងនោះចូរលើកទុកសិនចុះ, ប្រសិនបើអ្នកមិនឲ្យបិណ្ឌបាតនោះដល់យើងទេ, អ្នកចូរកាន់យកទ្រព្យ ១០០០ ហើយឲ្យចំណែកបុណ្យដល់យើងចុះ ។

អន្ទការៈពោលថា ខ្ញុំប្រឹក្សាជាមួយនឹងលោកម្ចាស់ ហើយ នឹងដឹង ប្រញាប់ទៅទាន់ព្រះបច្ចេកពុទ្ធហើយសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន សុមនសេដ្ឋីឲ្យទ្រព្យ ១០០០ កហាបណៈ ហើយសូមចំណែកបុណ្យក្នុងបិណ្ឌបាតរបស់ខ្ញុំព្រះករុណា, តើខ្ញុំព្រះករុណាត្រូវធ្វើយ៉ាងណា ?

គ្រានោះ ព្រះបច្ចេកពុទ្ធបាននាំមកនូវឧបមាឲ្យអន្ទការៈបានយល់ថា ម្នាលបណ្ឌិត អ្នកគប្បីយល់តាមការឧបមារបស់អាត្មាភាពដូច្នេះចុះ ប្រទីបក្នុងផ្ទះមួយក្នុងស្រុកដែលមានត្រកូលមួយរយអាចភ្លឺឡើងបាន, ដោយពួកជនដ៏សេសញ៉ាំងប្រេងៈឲ្យទទឹកដោយប្រេងរបស់ខ្លួន ហើយទៅអុជចម្លងភ្លើងអំពីដួងប្រទីបដទៃយកមក, ពន្លឺនៃប្រទីបក្នុងកាលមុន បុគ្គលគប្បីពោលថា មាន ឬថា មិនមាន ។

អន្ទការៈ. បពិត្រលោកម្ចាស់ដ៏ចម្រើន ពន្លឺរមែងមានដ៏លើសលប់ក្រៃលែងជាងមុន ។

ព្រះបច្ចេកពុទ្ធ. ម្នាលបណ្ឌិត យ៉ាងនោះឯង បបរមួយបោយ ឬថា បាយមួយវែកក៏ដោយ ចូរលើកទុកសិនចុះ,

កាលបុគ្គលឲ្យចំណែកបុណ្យក្នុងបិណ្ឌបាតរបស់ខ្លួន ដល់ជនទាំងឡាយមានប្រមាណប៉ុន្មាន, ចំណែកបុណ្យប៉ុណ្ណោះរមែងចម្រើន, ក៏អ្នកបានឲ្យបិណ្ឌបាតមួយចំណែកប៉ុណ្ណោះ, ប៉ុន្តែកាលអ្នកចំណែកបុណ្យដល់សេដ្ឋី, បិណ្ឌបាត ឈ្មោះថា ពីរចំណែក មួយចំណែកជារបស់អ្នក មួយចំណែកជារបស់សេដ្ឋី ។

អន្នភារៈយល់ព្រមដោយពាក្យថា ប្រពៃហើយលោកម្ចាស់ ហើយថ្វាយបង្គំព្រះបច្ចេកពុទ្ធទៅកាន់សម្នាក់សេដ្ឋីពោលថា បពិត្រសេដ្ឋី សូមលោកទទួលយកចំណែកបុណ្យនេះចុះ ។

សេដ្ឋី. បើដូច្នោះ អ្នកចូរទទួលយកកហាបណៈទាំងនេះចុះ ។

អន្នភារៈ. ខ្ញុំមិនលក់បិណ្ឌបាតទេ, ខ្ញុំជូនចំណែកបុណ្យនេះដល់លោកដោយសទ្ធា ។

សេដ្ឋីពោលថា អ្នកឯងឲ្យចំណែកបុណ្យដល់យើងដោយសទ្ធា, ចំណែកយើងក៏បូជាគុណអ្នកដោយសទ្ធាដែរ

ដូច្នោះ ចូរទទួលយកកហាបណៈចុះ, មួយវិញទៀត ចាប់ពីពេលនេះទៅ អ្នកឯងមិនចាំបាច់ធ្វើការងារដោយដៃរបស់ខ្លួនទេ, ចូរសង់ផ្ទះក្បែរថ្នល់ចុះ, ហើយចូរកាន់យកវត្ថុគ្រប់យ៉ាងដែលអ្នកឯងត្រូវការអំពីសម្នាក់របស់ខ្ញុំ ។

ក៏បិណ្ឌបាត ដែលបុគ្គលប្រគេនចំពោះព្រះអរហន្តដែលទើបតែចេញអំពីនិរោធសមាបត្តិ រមែងឲ្យផលក្នុងថ្ងៃនោះតែម្តង, ព្រោះហេតុដូច្នោះ សូម្បីព្រះរាជាទ្រង់ព្រះ-សណ្តាប់នូវរឿងនោះហើយ ក៏ត្រាស់ឲ្យហៅអន្នភារៈមកហើយ ទ្រង់ទទួលយកចំណែកបុណ្យ ព្រះរាជទានភោគៈដ៏ច្រើន ហើយត្រាស់ឲ្យព្រះរាជទាននូវតំណែងជាសេដ្ឋីដល់អន្នភារៈ ។

## ប្រវត្តិព្រះអនុរុទ្ធ

អន្នភារៈនោះ ជាសម្លាញ់របស់សុមនសេដ្ឋី ធ្វើបុណ្យទាំងឡាយរហូតអស់ជីវិត ចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោក អន្ទោលទៅមកក្នុងទេវលោក និងមនុស្សលោក, ក្នុងពុទ្ធុប្បាទកាលនេះ បដិសន្ធិក្នុងសក្យត្រកូល ព្រះនាមថា

អមិតោទនៈ ក្នុងព្រះនគរកបិលពស្តុ ។ ព្រះញាតិទាំងឡាយ ទ្រង់ថ្វាយព្រះនាមព្រះកុមារនោះថា “ អនុរុទ្ធ ” ។ ព្រះកុមារនោះ ជាព្រះកនិដ្ឋភាតា ( អនុជ ) នៃសក្យមហានាម ជាព្រះឱរសរបស់ព្រះបាទមានៃព្រះសាស្តា ជាសុខុមាលជាតិ ជាអ្នកមានបុណ្យច្រើន ។

បានឮថា ថ្ងៃមួយ កាលក្សត្រទាំង ៦ អង្គលេងឃ្លី យកនំធ្វើជាគ្រឿងភ្នាល់, ព្រះអនុរុទ្ធចាញ់, ក៏បញ្ជូនដំណឹងទៅកាន់សម្នាក់ព្រះមាតាដើម្បីត្រូវការនំ ។ ព្រះមាតានោះញាំុថាសមាសមួយធំឲ្យពេញដោយនំហើយ បញ្ជូនទៅថ្វាយ ។ ព្រះអនុរុទ្ធសោយនំហើយ ទ្រង់លេងចាញ់ទៀត ក៏បញ្ជូនដំណឹងទៅដូច្នោះទៀត ។

កាលមនុស្សនាំនំមកយ៉ាងនេះអស់វារៈ ៣ ដង, ក្នុងវារៈទី ៤ ព្រះមាតាបញ្ជូនដំណឹងទៅថា “ ឥឡូវនេះ នំមិនមាន ” ព្រះអនុរុទ្ធ ទ្រង់ព្រះសណ្តាប់នូវពាក្យរបស់ព្រះមាតាហើយ ក៏សម្គាល់ថា “ នំដែលមានឈ្មោះថា មិនមាន នឹងមានក្នុងកាលឥឡូវនេះ ” ព្រោះបទថា “ មិនមាន ” ជាបទ

ដែលខ្លួនមិនធ្លាប់ឮពីមុនមក ទើបទ្រង់បញ្ជូនទៅដោយព្រះតម្រាស់ថា " អ្នកចូរទៅ ចូរនាំនំមិនមាននោះមក " ។

គ្រានោះ ព្រះមាតារបស់ព្រះកុមារនោះ កាលអ្នកបំរើទូលថា "បពិត្រព្រះម៉ែម្ចាស់ សូមព្រះម៉ែម្ចាស់ឲ្យ នំមិនមាននោះ" ក៏ទ្រង់ព្រះតម្រិះថា "បទថាមិនមានបុត្តរបស់យើងមិនធ្លាប់បានឮពីមុនមក, យើងគប្បីឲ្យគេដឹង ថានំមិនដោយពិធីណាហ្ន៎ ?" លុះទ្រង់ព្រះតម្រិះដូច្នេះ ហើយ ក៏ទ្រង់លាងថាសមាសហើយ បិទដោយថាសមួយទៀតបញ្ជូនទៅថា "នែអ្នកដ៏ចម្រើន អ្នកឯងចូរឲ្យថាស មាសនេះដល់បុត្តរបស់យើងចុះ" ។

គ្រានោះ ទេវតាទាំងឡាយអ្នករក្សាព្រះគនរ គិតថា "ព្រះអនុរុទ្ធកុមារនេះ ជាម្ចាស់របស់ពួកយើង ថ្វាយភត្តដែលជាចំណែករបស់ខ្លួន ចំពោះព្រះបច្ចេកពុទ្ធព្រះនាមថា ឧបរិដ្ឋៈក្នុងកាលដែលខ្លួនជាអ្នកជញ្ជូនស្មៅឈ្មោះអន្នភារៈ ហើយប្រាថ្នាថា សូមកុំឲ្យយើងបានឮពាក្យថា មិនមាន ។ ប្រសិនបើយើងដឹងរឿងនោះហើយ ព្រងើយកន្តើយមិនអើពើនោះ

សីរសះរបស់យើងនឹងបែកជា ៧ ចំរៀកមិនខាន” លុះគិតដូច្នេះហើយ ក៏ញ៉ាំងថាសមាសឲ្យពេញដោយនំទិព្វទាំងឡាយ ។ បុរសនោះនាំថាសមាសមកតកល់ទុកក្នុងសម្នាក់ក្សត្រទាំងនោះ ហើយគេចម្រប់ចេញ ។ ក្ខិននំទិព្វទាំងនោះផ្សាយទៅកាន់នគរទាំងមូល ។ ក៏កាលនំគ្រាន់តែក្សត្រទាំងនោះទ្រង់ដាក់ទៅក្នុងព្រះឱស្ឋភ្ជាម ក្លិននោះបានផ្សាយទៅកាន់សរសៃសម្រាប់ទទួលរសទាំង ៧ ពាន់ ។

ព្រះអនុរុទ្ធទ្រង់ព្រះតម្រិះថា “កាលមុនអំពីនេះ ព្រះមាតាប្រហែលជាមិនស្រឡាញ់យើងទេមើលទៅ ព្រោះក្នុងកាលដទៃ ព្រះមាតារបស់យើងនោះមិនដែលចៀននំមិនមានឲ្យយើងបរិភោគឡើយ” ។ ព្រះកុមារនោះទៅកាន់សម្នាក់ព្រះមាតាហើយ ទូលសួរយ៉ាងនេះថា “បពិត្រព្រះមាតា ខ្ញុំមិនជាទីស្រឡាញ់របស់អ្នកឬ ?” ។

មាតា. នែកូន កូនឯងនិយាយអ្វី ? កូនឯងជាទីស្រឡាញ់របស់មាតា សូម្បីជាងភ្នែកទាំងពីរ សូម្បីជាងសាច់បេះដូងរបស់មាតាទៅទៀត ។

អនុរុទ្ធ. បពិត្រមាតា ប្រសិនបើខ្ញុំជាទីស្រឡាញ់របស់មាតានោះ ហេតុអ្វី ក្នុងកាលមុន មាតាមិនប្រទាននំមិនមានបែបនេះឲ្យខ្ញុំ ។

ព្រះមាតារបស់ព្រះអនុរុទ្ធត្រាស់សួរបុរសនោះថា "នែអ្នកដ៏ចម្រើន អ្វីបានមាននៅក្នុងថាសឬ ?"

បុរសនោះទូលថា "បពិត្រព្រះម៉ែម្ចាស់ មាន, ថាសពេញទៅដោយនំទាំងឡាយ, នំបែបនេះខ្ញុំមិនដែលឃើញឡើយ" ។

ព្រះនាងទ្រង់ព្រះតម្រិះថា "បុត្ររបស់យើងបានធ្វើបុណ្យទុកហើយ, នំទិព្វនឹងជារបស់ដែលទេវតាទាំងឡាយបញ្ជូនទៅឲ្យបុត្ររបស់យើង" ។

ចំណែកព្រះអនុរុទ្ធ ក៏ទូលព្រះមាតាថា "បពិត្រម៉ែ នំបែបនេះ ខ្ញុំមិនដែលបានបរិភោគឡើយ, ចាប់ពីពេលនេះទៅសូមមាតាចៀននំមិនមាននេះប៉ុណ្ណោះឲ្យខ្ញុំបរិភោគ" ។

ចាប់ពីពេលនោះមក ព្រះនាងទ្រង់លាងថាសមាសបិទដោយថាសមាសមួយទៀតហើយ បញ្ជូនទៅ ( ឲ្យ )

នៅពេលដែលព្រះអនុរុទ្ធទូលថា បពិត្រម៉ែ ខ្ញុំចង់បរិភោគនំៗ ទេវតាទាំងឡាយតែងតែញ៉ាំងថាសឲ្យពេញ ( ដោយនំ ) ។ ព្រះកុមារនោះ កាលនៅក្នុងកណ្ដាលព្រះរាជវាំង មិនទ្រង់ជ្រាបនូវសេចក្ដីនៃបទថា "មិនមាន" សោយតែនំទិព្វដោយអាការយ៉ាងនេះ ។

ក៏កាលព្រះកុមារនៃសាក្យទាំងឡាយ បួសតាមលំដាប់ត្រកូល ដើម្បីជាបរិវានៃព្រះសាស្ដា ។ កាលព្រះមហានាមសាក្យៈត្រាស់ថា "នែប្អូនប្រុស ក្នុងត្រកូលរបស់ពួកយើងមិនទាន់មានអ្នកណាចេញបួសទេ ប្អូនឯងឬបងគួរតែបួស" ។ ព្រះអនុរុទ្ធត្រាស់ថា "បពិត្របងប្រុស ខ្ញុំជាសុខុមាលជាតិយ៉ាងក្រៃលែង មិនអាចបួសបានទេ" ។

មហានាម. បើដូច្នោះ ប្អូនឯងចូររៀនការងារចុះ បងនឹងបួស ។

អនុរុទ្ធ. ដែលឈ្មោះថាការងារនុ៎ះ ជាអ្វី ?

ពិតណាស់ ព្រះអនុរុទ្ធរមែងមិនដឹងសូម្បីទូវទីកើតឡើងនៃភត្តផង, នឹងដឹងការងារបានយ៉ាងណា ? ព្រោះហេតុនោះ ទើបត្រាស់សួរយ៉ាងនោះ ។

ថ្ងៃមួយ សាក្យ ៣ ព្រះអង្គគឺ អនុរុទ្ធ ភទ្ទិយៈ កិម្ពិលៈ ប្រឹក្សាគ្នាថា "ដែលឈ្មោះថាភត្ត កើតក្នុងទីណា ?" បណ្ដាសាក្យៈទាំង ៣ ព្រះអង្គនោះ កិម្ពិលៈត្រាស់ថា "ភត្តកើតក្នុងជង្រុក" ។ បានឮថា ថ្ងៃមួយព្រះកិម្ពិលៈនោះ បានឃើញគេបញ្ជូនស្រូវដាក់ជង្រុក, ព្រោះហេតុនោះ ទើបត្រាស់យ៉ាងនេះដោយសម្គាល់ថា "ភត្ត រមែងកើតឡើងអំពីជង្រុក" ។

គ្រានោះ ព្រះភទ្ទិយៈត្រាស់ទៅកាន់ព្រះកិម្ពិលៈថា "នៃអ្នកដ៏ចម្រើន អ្នកមិនទាន់ជ្រាបទេ" ដូច្នេះហើយ ត្រាស់ថា "ធម្មតាភត្ត រមែងកើតអំពីឆ្នាំង" ។ បានឮថា ថ្ងៃមួយព្រះភទ្ទិយៈនោះ ឃើញជនទាំងឡាយដួសភត្តអំពីឆ្នាំងហើយក៏បានធ្វើការសម្គាល់ថា "ភត្តនោះកើតអំពីឆ្នាំងនេះឯង", ព្រោះហេតុនោះ ទើបត្រាស់យ៉ាងនោះ ។

ព្រះអនុរុទ្ធត្រាស់ទៅសាក្យៈទាំងពីរនោះថា "សូម្បីអ្នកទាំងពីរក៏មិនទាន់ជ្រាប" ហើយត្រាស់ថា "ភត្តតែងកើតអំពីថាសមាសដ៏ធំ ដែលមានកំពស់មួយគក់" ។

បានឮថា ព្រះអនុរុទ្ធនោះមិនដែលឃើញគេបុកស្រូវ មិនធ្លាប់ឃើញគេចំអិនភត្ត, ឃើញតែភត្តដែលគេដួសដាក់ក្នុងថាសមាសហើយ តំដល់ទុកចំពោះព្រះភក្ត្រប៉ុណ្ណោះ, ព្រោះហេតុនោះ ទើបសម្គាល់ថា "ភត្តនោះ រមែងកើតអំពីថាសមាសនោះឯង, ព្រោះហេតុនោះ ទើបត្រាស់យ៉ាងនោះ។ កុលបុត្តអ្នកមានបុណ្យច្រើន កាលមិនដឹងសូម្បីនូវទីកើតឡើងនៃភត្តយ៉ាងនោះ នឹងដឹងការងារទាំងឡាយយ៉ាងណាបាន ។

ព្រះអនុរុទ្ធ ទ្រង់ព្រះសណ្ដាប់នូវការងារទាំងឡាយដែលព្រះមហានាមត្រាស់ប្រាប់ដោយន័យជាដើមថា "នែអនុរុទ្ធ ចូរមកណោះ បងនឹងបង្រៀននូវការងារក្នុងការនៅគ្រប់គ្រងផ្ទះដល់ឯង, អ្នកគ្រប់គ្រងផ្ទះ ចាំបាច់ត្រូវចាត់ចែងឲ្យគេភ្ជួរជាមុន" ដូច្នេះជាដើម ក៏ទ្រង់ព្រះតម្រិះថា ការងារ

នេះជាការកើតរមិនមានទីបំផុត សេចក្តីត្រូវការរបស់អញ ក៏មិនមានទីបំផុតដែរ លុះទ្រង់ព្រះតម្រិះដូច្នេះហើយ ក៏ទូលលាព្រះមាតាថា "បពិត្រព្រះមាតា ខ្ញុំមិនត្រូវការនៅគ្រប់គ្រងផ្ទះទេ" ហើយស្តេចចេញទៅមួយអន្លើដោយឱរសនៃសាក្យៈប្រាំព្រះអង្គ មានព្រះភទ្ទិយៈជាប្រធាន ចូលទៅគាល់ព្រះសាស្តាឯអនុបិយអម្ពវ័ន ហើយទ្រង់ព្រះផ្នួស, លុះទ្រង់ព្រះផ្នួសហើយ ព្រះអនុរុទ្ធជាអ្នកប្រតិបត្តិប្រពៃ ធ្វើឲ្យជាក់ច្បាស់នូវវិជ្ជា ៣ ដោយលំដាប់ គង់នៅលើអាសនៈតែមួយ អាចក្រឡេងមើលលោកធាតុមួយពាន់បានដោយទិព្វចក្ខុ ដូចផ្លែកន្ទួតព្រៃដែលបុគ្គលដាក់លើបាតដៃដូច្នោះ ហើយបន្លឺឧទានឡើងថា ៖-

> យើងអាចដឹងនូវខន្ធបញ្ចកៈ ដែលយើងធ្លាប់នៅអាស្រ័យហើយក្នុងកាលមុន, ទិព្វចក្ខុយើងក៏ជម្រះហើយ, យើងជាអ្នកបានវិជ្ជា ៣ ជាអ្នកដល់ហើយនូវឫទ្ធិ, ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ យើងបានធ្វើហើយ ។

ពិចារណាមើលថា "តើយើងបានកម្មអ្វីហ្ន៎ ? ទើបបាន សម្បត្តិនេះ" ជ្រាបបានថា "យើងបានតាំងសេចក្តីប្រាថ្នាទុក ទៀបបាទមូលព្រះពុទ្ធទ្រង់ព្រះនាមថាបទុមុត្តរៈ" ជ្រាបតទៅ ទៀតថា "យើងអន្ទោលទៅមកក្នុងសង្សារវដ្ត ក្នុងកាលមួយ នោះ បានអាស្រ័យសុមនសេដ្ឋី ក្នុងក្រុងពារាណសីចិញ្ចឹម ជីវិត ជាអ្នកមានឈ្មោះថា អន្នភារៈ" ដូច្នេះហើយ ពោលថា

> ក្នុងកាលមុន យើងជាបុរសឈ្មោះអន្នភារៈ ជាអ្នក
> កំសត់ ជាអ្នកនាំទៅនូវស្មៅ, យើងបានប្រគេនបិណ្ឌ-
> បាតចំពោះព្រះឧបរិដ្ឋបច្ចេកពុទ្ធ អ្នកដ៏មានយស ។

## ព្រះថេរលើកដល់សម្លាញ់ចាស់

គ្រានោះ ព្រះអនុរុទ្ធមានសេចក្តីត្រិះរិះដូច្នេះថា "សុមនសេដ្ឋីដែលជាសម្លាញ់របស់យើង ឲ្យកហាបណៈ ហើយកាន់យកចំណែកបុណ្យអំពីបិណ្ឌបាត ដែលយើង ប្រគេនចំពោះព្រះឧបរិដ្ឋបច្ចេកពុទ្ធ ក្នុងកាលនោះ, ឥឡូវនេះ កើតក្នុងទីណាហ្ន៎ ?" ពេលនោះ លោកបានឃើញសេដ្ឋីនោះ ថា "មានស្រុកមួយឈ្មោះមុណ្ឌៈនិគម នៅក្បែរជើងភ្នំ ក្នុង

ជនព្រៃដែលត្រូវភ្លើងឆេះ, ឧបាសកឈ្មោះមហាមុណ្ឌៈដែលមានប្រក្រតីនៅក្នុងមុណ្ឌនិគមនោះ មានបុត្តពីរនាក់ គឺមហាសុមនៈ ចូឡសុមនៈ, បណ្តាបុត្តទាំងពីរនោះ សុមនសេដ្ឋីជាចូឡសុមនៈ" លុះព្រះអនុរុទ្ធឃើញហើយ គិតថា "កាលយើងទៅកាន់ទីនោះ, តើមានប្រយោជន៍ ឬក៏មិនមាន ?" ព្រះអនុរុទ្ធលោកពិចារណាបានឃើញហេតុនេះថា "កាលយើងទៅកាន់ទីនោះ, ចូឡសុមនៈនោះមានអាយុ ៧ ខួបប៉ុណ្ណោះនឹងចេញបួស, ហើយនឹងសម្រេចព្រះអរហត្តក្នុងវេលាកោរសក់ហើយនោះឯង" លុះលោកឃើញដូច្នេះហើយ កាលរដូវភ្លៀងជិតចូលមកដល់ លោកក៏ទៅកាន់ទីនោះតាមអាកាសចុះក្បែរខ្លោងទ្វារស្រុក ។ ចំណែកមហាមុណ្ឌឧបាសក ក៏ជាអ្នកធ្លាប់ស្និទ្ធស្នាលនិងព្រះថេរក្នុងកាលមុនដែរ ។ ឧបាសកនោះឃើញព្រះថេរគ្រងចីវរក្នុងវេលាបិណ្ឌបាត ក៏ពោលទៅកាន់មហាសុមនៈជាបុត្តថា "នែមហាសុមនៈ លោកម្ចាស់អនុរុទ្ធរបស់យើងមកហើយ, កូនឯងចូរទៅទទួលបាត្ររបស់លោកឲ្យទាន់វេលាដែលអ្នកដទៃ មិនទាន់

ទទួលបាត្ររបស់លោកទៅ, ពុកនឹងឲ្យគេក្រាលអាសនៈ” មហាសុមនៈបានឆ្លើយយ៉ាងនោះ ។ ឧបាសកអង្គាសព្រះថេរ ខាងផ្ទះដោយគោរពហើយ ទទួលបដិញ្ញាដើម្បីត្រូវការដល់ ការចាំវស្សារហូតត្រៃមាស ។ ព្រះថេរក៏ទទួលនិមន្ត ។

គ្រានោះ ឧបាសកបដិបត្តិព្រះថេរនោះរហូតត្រៃមាស ដូចបដិបត្តិតែមួយថ្ងៃប៉ុណ្ណោះ ក្នុងថ្ងៃមហាបវារណា បាននាំ ត្រៃចីវរនិងអាហារវត្ថុទាំងឡាយ មានទឹកអំពៅ ប្រេង និង ប្បាយជាដើមមកតំកល់ទុកទៀបជើងព្រះថេរ ហើយប្រាប់ថា “បពិត្រលោកម្ចាស់ដ៏ចម្រើនសូមលោកម្ចាស់ទទួលយកចុះ”

## មិនទទួលវត្ថុត្រឡប់បានសាមណេរ

ព្រះថេរ. កុំឡើយឧបាសក សេចក្តីត្រូវការវត្ថុនេះ របស់អាត្មាភាព មិនមានទេ ។

ឧបាសក. បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជា វស្សាវាសិកលាភ ( គឺលាភកើតឡើងដល់អ្នកចាំវស្សា ), សូមលោកម្ចាស់ទទួលយកវត្ថុនេះចុះ ។

ព្រះថេរ. ឧបាសក កុំឡើយ ។

ឧបាសក. បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រោះហេតុអ្វី ទើបលោកម្ចាស់មិនទទួល ? ។

ព្រះថេរ. សូម្បីសាមណេរដែលជាកប្បិយការក ក្នុងសម្នាក់របស់អាត្មាភាពក៏មិនមាន ។

ឧបាសក. បពិត្រលោកម្ចាស់ដ៏ចម្រើន បើដូច្នោះមហាសុមនៈដែលជាបុត្តរបស់ខ្ញុំព្រះករុណានឹងជាសាមណេរ

ព្រះថេរ. ឧបាសក អាត្មាមិនត្រូវការមហាសុមនៈទេ។

ឧបាសក. បពិត្រលោកម្ចាស់ដ៏ចម្រើន បើដូច្នោះសូមលោកម្ចាស់បំបួសចូឡសុមនៈចុះ ។

ព្រះថេរ. ទទួលថា "ប្រពៃហើយ" ហើយបំបួសចូឡសុមនៈ ។ ចូឡសុមនៈនោះ បានសម្រេចព្រះអរហត្តក្នុងវេលាកោរសក់ហើយនោះឯង ។

ព្រះថេរ នៅទីនោះជាមួយនិងចូឡសុមនៈសាមណេរនោះប្រមាណកន្លះខែហើយ លាពួកញាតិរបស់លោកថា "ពួកអាត្មានឹងទៅគាល់ព្រះសាស្តា" ដូច្នេះហើយ បានទៅ

តាមអាកាស ចុះក្បែរកុដិដែលតាំងនៅក្នុងព្រៃ ក្នុងហិមវន្តប្រទេស ។

## ព្រះថេរប្រារព្ធសេចក្តីព្យាយាមជានិច្ច

ក៏ព្រះថេរនោះ តាមប្រក្រតីជាអ្នកប្រារព្ធសេចក្តីព្យាយាម, កាលលោកកំពុងចង្ក្រមនៅទីនោះ រាត្រីជំបូងនិងរាត្រីតមក ខ្យល់ក្នុងផ្ទៃបានកើតឡើងដល់លោក ។

គ្រានោះ សាមណេរឃើញលោកលំបាក ក៏សួរថា "បពិត្រលោកម្ចាស់ដ៏ចម្រើន តើលោកម្ចាស់កើតរោគអ្វី ? រោគអ្វីរមែងចាក់ដោតលោកម្ចាស់ ?

ព្រះថេរ. ខ្យល់ចាក់ដោតក្នុងផ្ទៃកើតឡើងដល់ខ្ញុំ ។

សាមណេរ. បពិត្រលោកម្ចាស់ដ៏ចម្រើន កាលអំពីមុន ខ្យល់ចាក់ដោតក្នុងផ្ទៃធ្លាប់កើតឡើងដល់លោកម្ចាស់ដែរឬ ?

ព្រះថេរ. អើ អ្នកមានអាយុ ធ្លាប់កើតដែរ ។

សាមណេរ. បពិត្រលោកម្ចាស់ តើសេចក្តីសប្បាយរមែងមានដោយភេសជ្ជៈអ្វី ?

ព្រះថេរ. ម្នាលអ្នកមានអាយុ កាលខ្ញុំបានទឹកផឹកអំពីអនោតត្តស្រះ សេចក្ដីសប្បាយរមែងមាន ។

សាមណេរ. បពិត្រលោកម្ចាស់ បើដូច្នោះខ្ញុំព្រះករុណានឹងនាំមកប្រគេន ។

ព្រះថេរ. ម្នាលសាមណេរ អ្នកនឹងអាចនាំមកឬ ?

សាមណេរ. ព្រះករុណា លោកម្ចាស់ ។

ព្រះថេរ. បើដូច្នោះ នាគរាជឈ្មោះបន្នកៈ ដែលនៅក្នុងអនោតត្តស្រះនោះស្គាល់ខ្ញុំ ។ អ្នកចូរប្រាប់នាគរាជនោះ ហើយនាំដបទឹកមួយដបមកដើម្បីប្រយោជន៍ដល់ការផ្សំថ្នាំ ។

សាមណេរទទួលយល់ព្រមដោយពាក្យថា "ប្រពៃហើយ លោកម្ចាស់" ហើយថ្វាយបង្គំព្រះឧបជ្ឈាយ៍ ហោះឡើងកាន់វេហាស៍ បានទៅកាន់ទីប្រមាណ ៥០០ យោជន៍ ។

## សាមណេរតទល់និងស្ដេចនាគ

ក៏ថ្ងៃនោះ នាគរាជមាននាគបរិវាររោមរោមហើយ ប្រាថ្នានឹងលេងទឹក ។ នាគរាជនោះ គ្រាន់តែឃើញសាមណេរនោះភ្លាម ក៏ក្រោធ ហើយគិតថា " សមណៈត្រងោលនេះ ដើរ

ធ្វើឲ្យធូលីដែលជាប់នឹងបាតជើង ហុយមកលើក្បាលយើង, សមណៈត្រងោលនេះមកដើម្បីត្រូវការទឹកផឹកអនោតត្តស្រះ ឥឡូវនេះ យើងនឹងមិនឲ្យទឹកផឹកដល់សមណៈត្រងោលនេះ” ដូច្នេះហើយ ដេកបិទអនោតត្តស្រះដែលមានប្រមាណ ៥០ យោជន៍ពពា ដូចបុគ្គលបិទថ្នាំងបាយដោយថាសដ៏ធំដូច្នោះ ។

សាមណេរ គ្រាន់តែឃើញអាការរបស់នាគរាជនោះភ្លាម ក៏ដឹងថា “ នាគរាជនេះក្រោធហើយ ” ទើបពោលគាថានេះថា :-

“ ម្នាលនាគរាជ អ្នកមានតេជៈដ៏ខ្លាំងក្លា មានកម្លាំងច្រើន ចូរស្តាប់ ( ពាក្យ ) របស់អាត្មា, ចូរឲ្យក្អមដ៏ពេញដោយទឹកផឹកដល់អាត្មា, អាត្មាជាអ្នកមកហើយ ដើម្បីប្រយោជន៍ដល់ទឹកសម្រាប់ផ្សំថ្នាំ ” ។

នាគរាជស្តាប់គាថានោះហើយ ពោលគាថានេះថា :-

“ ស្ទឹងធំឈ្មោះគង្គា នៅខាងទិសបូព៌ា រមែងហូរទៅកាន់មហាសមុទ្រ, លោកចូរនាំយកទឹកផឹក

អំពីស្ទឹងគង្គានោះទៅចុះ ” ។

សាមណេរស្តាប់ពាក្យនោះហើយ គិតថា “ ស្តេចនាគនេះនឹងមិនឲ្យតាមសេចក្តីប្រាថ្នារបស់ខ្លួន, យើងនឹងគំរាមកំហែងធ្វើឲ្យវាដឹងនូវអានុភាពដ៏ធំ នឹងគ្របសង្កត់ស្តេចនាគនេះហើយ នាំទឹកផឹកទៅ ” ដូច្នេះហើយ ពោលថា “ មហារាជ ព្រះឧបជ្ឈាយ៍ឲ្យអាត្មានាំទឹកអំពីអនោតត្តស្រះប៉ុណ្ណោះ, ព្រោះហេតុនោះ ទើបអាត្មានាំយកទឹកអំពីស្រះនេះប៉ុណ្ណោះទៅ, អ្នកចូរចៀសចេញទៅ ចូរកុំហាមឃាត់អាត្មាឡើយ ” ដូច្នេះហើយ ពោលគាថានេះថា :-

“ អាត្មាត្រូវការតែទឹកផឹកអំពីអនោតត្តស្រះ
នេះប៉ុណ្ណោះ, អាត្មាត្រូវការទឹកផឹកនេះប៉ុណ្ណោះ,
ម្នាលនាគរាជ ប្រសិនបើកម្លាំង និងសេចក្តី
ក្លាហានរបស់អ្នកមាន, អ្នកចូរហាមឃាត់ចុះ ។

គ្រានោះ នាគរាជពោលទៅកាន់សាមណេរនោះថា :-

“ នែ សាមណេរ ប្រសិនបើសេចក្តីព្យាយាម
ដែលបុគ្គលគប្បីឈានកន្លងសម្រាប់បុរស របស់

លោកមាន, ខ្ញុំត្រេកអរក្រៃលែងណាស់ លោកចូរ
នាំទឹករបស់ខ្ញុំទៅចុះ " ។

គ្រានោះ ឆ្លើយតបនឹងនាគរាជនោះថា " មហារាជ អាត្មានឹងនាំទៅយ៉ាងនោះ, កាលស្ដេចនាគពោលថា " កាល លោកម្ចាស់អាចកាន់យកបាន ក៏ចូរនាំយកទៅចុះ " ទទួល ប្ដេជ្ញាអស់ ៣ ដងថា " បើដូច្នោះ អ្នកចូរដឹងចុះ " ហើយគិត ថា " ការដែលយើងសម្ដែងអានុភាពនៃព្រះពុទ្ធសាសនា ហើយទើបនាំទៅ គួរ " បានទៅកាន់សម្នាក់ទេវតាដែលស្ថិត នៅក្នុងអាកាសមុន ។ ទេវតាទាំងនោះមកថ្វាយបង្គំហើយ ពោលថា " បពិត្រលោកម្ចាស់ដ៏ចម្រើន មានការណ៍អ្វី ?" ។

សាមណេរពោលថា " សង្គ្រាមរបស់អាត្មាជាមួយនឹង ស្ដេចនាគឈ្មោះបន្ទុកៈនឹងមានលើខ្នងអនោតត្តស្រះនេះ, អ្នក ទាំងឡាយចូរទៅកាន់ទីនោះ មើលការឈ្នះនិងការចាញ់ " ។ សាមណេរនោះចូលទៅរកលោកបាលទាំងបួន និងសក្កទេវ-រាជ សុយាមទេវរាជ សន្ដុសិតទេវរាជ សុនិម្មិតទេវរាជ និង វសវត្តីទេវរាជ ហើយប្រាប់សេចក្ដីនោះដោយទំនងនោះឯង។

តអំពីនោះទៅ សាមណេរទៅដោយលំដាប់ រហូតដល់ព្រហ្មលោក កាលដែលព្រហ្មទាំងឡាយក្នុងទីនោះៗ មកថ្វាយបង្គំហើយ សួរថា "បពិត្រលោកម្ចាស់ដ៏ចម្រើន មានការណ៍អ្វី ?" ក៏ប្រាប់សេចក្ដីនោះ ។

សាមណេរនោះត្រាច់ទៅប្រាប់គ្រប់ទៀកន្លែង អស់កាលមួយរំពេចប៉ុណ្ណោះ វៀរលែងតែអសញ្ញីសត្វ និងអរូបព្រហ្មដោយអាការយ៉ាងនេះ ។

ចំណែកទេវតាគ្រប់ៗ ជំពូក ស្ដាប់ពាក្យរបស់លោកហើយ ប្រជុំគ្នាពេញអាកាសរកចន្លោះគ្មាន លើខ្នងអនោតត្តស្រះ ដូចលម្អិតនំដែលបុគ្គលដាក់ក្នុងនាឡិ ដូច្នោះ ។

## សាមណេរអញ្ជើញទេវតាមកមើលចម្បាំង

កាលពួកទេវតាប្រជុំគ្នាហើយ, សាមណេរឈរនៅលើអាកាស ពោលទៅកាន់ស្ដេចនាគថា :-

" ម្នាលនាគរាជ អ្នកមានតេជះដ៏ខ្លាំងក្លា មានកម្លាំងច្រើន ចូរស្ដាប់ ( ពាក្យ ) របស់អាត្មា, ចូរឲ្យក្អមដ៏ពេញដោយទឹកផឹកដល់អាត្មា, អាត្មាជា

អ្នកមកហើយ ដើម្បីប្រយោជន៍ដល់ទឹកសម្រាប់ផ្សំថ្នាំ " ។

លំដាប់នោះ ស្តេចនាគពោលទៅកាន់សាមណេរថា :-

" នៃ សាមណេរ ប្រសិនបើសេចក្តីព្យាយាមដែលបុគ្គលគប្បីឈានកន្លងសម្រាប់បុរស របស់លោកមាន, ខ្ញុំត្រេកអរក្រៃលែងណាស់ លោកចូរនាំទឹករបស់ខ្ញុំទៅចុះ " ។

សាមណេរនោះទទួលការប្តេជ្ញារបស់នាគរាជអស់ ៣ ដងហើយ ឈរនៅលើអាកាសនោះឯង និម្មិតអត្តភាពជាព្រហ្មប្រមាណ ១២ យោជន៍ ហើយចុះចាកអាកាស ជាន់លើពពារបស់ស្តេចនាគ សង្កត់ឲ្យមានមុខចុះក្រោម ។ ក្នុងខណៈនោះឯង កាលសាមណេរជាន់ពពាស្តេចនាគនោះក្លាម ផ្ទាំងពពាបានរួញចូលប្រមាណប៉ុនវែក ដូចស្បែកស្រស់ដែលបុរសមានកម្លាំងជាន់ហើយដូច្នោះ ។

ខ្សែទឹកប្រមាណប៉ុនដើមត្នោត បានខ្ទាតឡើងក្នុងទីដែលផុតចាកពពាទាំងឡាយរបស់នាគរាជ ។

សាមណេរ ញុំាងជូទឹកផឹកឲ្យពេញនៅលើអាកាស នោះឯង ។ ពួកទេវតាបានឲ្យសាធុការ ។

## ស្តេចនាគចាញ់សាមណេរ

ស្តេចនាគនោះអៀនខ្មាស ក្រោធខឹងសាមណេរ ។ ភ្នែកទាំងពីររបស់នាគរាជនោះមានពណ៌ដូចផ្កាច្បា ។ ស្តេចនាគនោះគិតថា "សមណៈត្រងោលនេះឲ្យពួកទេព្តាប្រជុំគ្នាហើយ កាន់យកទឹកផឹក ញុំាងយើងឲ្យខ្មាស, យើងនឹងចាប់សមណៈត្រងោលនេះដាក់ដៃចូលទៅក្នុងមាត់ហើយ ប្របាច់សាច់បេះដូងសមណៈនេះ, ឬនឹងចាប់ជើងសមណៈនេះបោះទៅខាងនាយស្ទឹងគង្គា" លុះគិតដូច្នេះហើយ ក៏តាមទៅដោយរហ័ស ។ សូម្បីដេញតាមសាមណេរដោយរហ័យយ៉ាងណាក៏ដោយ ក៏តាមមិនទាន់សាមណេរដែរ ។

សាមណេរមកដល់កន្លែងហើយ ដាក់ទឹកផឹកលើព្រះហស្តព្រះឧបជ្ឈាយ៍ហើយប្រាប់ថា "បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់និមន្តឆាន់ទឹក" ។

## ស្តេចនាគនិយាយកុហកប៉ុន្តែសាមណេរ

## មិននិយាយកុហក

ចំណែកស្តេចនាគ មកតាមក្រោយសាមណេរហើយ ប្រាប់ព្រះអនុរុទ្ធថា "បពិត្រលោកម្ចាស់ដ៏ចម្រើន សាមណេរ កាន់យកទឹកដែលខ្ញុំព្រះករុណាមិនទាន់ឲ្យមក, សូមលោកម្ចាស់កុំឆាន់" ។

ព្រះថេរៈសួរថា "ម្នាលសាមណេរ ពិតមែនឬ ?

សាមណេរ. បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកនិមន្តឆាន់ចុះ, ទឹកដែលខ្ញុំព្រះករុណានាំមកនេះ ស្តេចនាគឲ្យខ្ញុំព្រះករុណាហើយ ។

ព្រះថេរៈជ្រាបថា " ការពោលពាក្យកុហករបស់សាម-ណេរអ្នកជាខីណាស្រព រមែងមិនមាន" ទើបឆាន់ទឹកនោះ ។ អាពាធរបស់លោកក៏ស្ងប់ខណៈនោះឯង ។

ស្តេចនាគពោលទៅកាន់ព្រះថេរៈទៀតថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំម្ចាស់ត្រូវសាមណេរធ្វើឲ្យខ្មាសពួកទេវតាហើយ ខ្ញុំម្ចាស់នឹងពុះបេះដូងសាមណេរនេះ , ឬនឹងចាប់ជើងហើយបោះទៅខាងនាយនៃស្ទឹងគង្គា ។

ព្រះថេរៈពោលថា " បពិត្រមហារាជ សាមណេរនេះ មានអានុភាពច្រើន អ្នកមិនអាចទប់ទល់នឹងសាមណេរបាន ទេ , អ្នកចូរឲ្យសាមណេរនោះអត់ទោសឲ្យ ហើយត្រឡប់ទៅវិញចុះ " ។

## ស្ដេចនាគសូមខមាទោសសាមណេរ

ស្ដេចនាគនោះ ដឹងអានុភាពរបស់សាមណេរដោយខ្លួនឯងដែរ, ប៉ុន្តែនៅជាប់តាមមក ព្រោះសេចក្ដីខ្មាស ។

គ្រានោះ ស្ដេចនាគឲ្យសាមណេរនោះអត់ទោសតាមពាក្យរបស់ព្រះថេរៈហើយ ដើម្បីជាសេចក្ដីស្និទ្ធស្នាលដោយភាពជាមិត្រជាមួយនិងសាមណេរ ទើបពោលថា "ចាប់អំពីពេលនេះទៅ កាលសេចក្ដីត្រូវការដោយទឹកក្នុងអនោតត្តស្រះមាន, កិច្ចដោយការមកនៃលោកម្ចាស់ រមែងមិនមាន សូមលោកម្ចាស់បញ្ជូនដំណឹងទៅឲ្យខ្ញុំព្រះករុណា, ខ្ញុំព្រះ-ករុណានឹងនាំទឹកមកប្រគេន" លុះពោលដូច្នេះហើយ ក៏ចៀសចេញទៅ, សូម្បីព្រះថេរៈក៏សាមណេរទៅដែរ ។

ព្រះសាស្តាទ្រង់ជ្រាបការមកនៃព្រះថេរៈហើយ ទ្រង់គង់ទតការមកនៃព្រះថេរៈលើប្រាសាទរបស់មិគារមាតា ។

ចំណែកពួកភិក្ខុឃើញព្រះថេរៈនិមន្តមក ក៏ក្រោកឡើងទៅទទួលបាត្រនិងចីវរ ។

## ពួកភិក្ខុលេងនិងសាមណេរ

គ្រានោះ ភិក្ខុពួកខ្លះចាប់សាមណេរត្រង់ក្បាលខ្លះត្រចៀកទាំង ២ ខ្លះ ភិក្ខុអង្គខ្លះចាប់ដៃអង្រួនបណ្តើរ ពោលបណ្តើរថា " ម្នាលសាមណេរ អ្នកមិនអផ្សុកទេឬ " ។

ព្រះសាស្តា ទ្រង់ទតឃើញអំពើរបស់ភិក្ខុទាំងនោះហើយ ទ្រង់ព្រះតម្រិះថា " កម្មរបស់ភិក្ខុទាំងនេះធ្ងន់ណាស់ហ្ន៎, ភិក្ខុទាំងនេះ ចាប់សាមណេរដូចចាប់អាសិរពិសត្រង់-ក, ពួកភិក្ខុទាំងនេះមិនដឹងអានុភាពរបស់សាមណេរទេ, ថ្ងៃនេះការដែលតថាគត ញុំាងគុណរបស់សុមនសាមណេរឲ្យប្រាកដ រមែងសមគួរ " ។ សូម្បីព្រះថេរៈ ក៏មកថ្វាយបង្គំព្រះសាស្តាហើយ គង់នៅក្នុងទីនោះដែរ ។

## ព្រះសាស្តាទ្រង់ញុំាងគុណ

## របស់សាមណេរឲ្យប្រាកដ

ព្រះសាស្ដា ទ្រង់ធ្វើបដិសណ្ឋារៈជាមួយនឹងព្រះថេរៈ ហើយ ត្រាស់ហៅព្រះអានន្ទត្ថេរមកថា “ ម្នាលអានន្ទ តថាគតប្រាថ្នាលាងជើងទាំងពីរ ដោយទឹកក្នុងអនោតត្តស្រះ អ្នកចូរក្រុមដល់ពួកសាមណេរ ហើយឲ្យនាំទឹកមកចុះ ” ។

ព្រះថេរៈ ឲ្យសាមណេរប្រមាណ ៥០០ ក្នុងវិហារ ប្រជុំគ្នា ។

បណ្ដាសាមណេរទាំងនោះ សុមនសាមណេរជា សាមណេរថ្មីជាងសាមណេរទាំងអស់ ។ ព្រះថេរៈពោលទៅ កាន់សាមណេរចាស់ជាងគេបង្អស់ថា “ ម្នាលសាមណេរ ព្រះសាស្ដាមានព្រះបំណងនឹងលាងព្រះបាទទាំងពីរ ដោយ ទឹកក្នុងអនោតត្តស្រះ, អ្នកចូរកាន់យកក្អមទឹកទៅនាំទឹកមក ចុះ ”។ សាមណេរនោះមិនប្រាថ្នា ដោយពោលថា “ បពិត្រ លោកម្ចាស់ដ៏ចម្រើន ខ្ញុំមិនអាច ”។ ព្រះថេរៈសួរសាមណេរ ទាំងឡាយដ៏សេសដោយលំដាប់ ។ សូម្បីសាមណេរទាំង នោះ ក៏ប្រកែកដូចគ្នា ។

មានពាក្យសួរថា “ ក៏បណ្ដាសាមណេរទាំងនេះ សាមណេរជាព្រះខីណាស្រេព មិនមានឬ ?” ។

ឆ្លើយថា “ មាន ។ ប៉ុន្តែ សាមណេរទាំង នោះប្រកែក មិនព្រមទៅ ដោយគិតឃើញថា “ កម្រងផ្កានេះ ព្រះសាស្ដា មិនទ្រង់ចងទុកដើម្បីពួកយើងទេ ព្រះអង្គទ្រង់ចងទុកដើម្បី សុមនសាមណេរតែមួយរូបប៉ុណ្ណោះ ។

ទីបំផុត កាលវារៈដល់សុមនសាមណេរ ព្រះថេរៈ ពោលថា “ ម្នាលសាមណេរ ព្រះសាស្ដាមានព្រះបំណង លាងព្រះបាទទាំងពីរដោយទឹកក្នុងអនោតត្តស្រះ, ដូច្នេះ អ្នក កាន់យកក្អមទឹកទៅនាំទឹកនោះមក ” សុមនសាមណេរនោះ ពោលថា “ប្រសិនបើព្រះសាស្ដាទ្រង់ឲ្យនាំមក, ខ្ញុំនឹងនាំមក” ដូច្នេះហើយ ថ្វាយបង្គំព្រះសាស្ដា ក្រាបទូលថា “ បពិត្រ ព្រះអង្គដ៏ចម្រើន បានឮថា ព្រះអង្គឲ្យខ្ញុំព្រះអង្គនាំទឹកអំពី អនោតត្តស្រះមកឬ ?” ។

ព្រះសាស្ដា ត្រាស់ថា “ ម្នាលសុមនៈ ពិតហើយ ”។

សុមនសាមណេរនោះ យកដៃចាប់ក្អមធំមួយ ដែលអាចដាក់ទឹកបាន ៦០ ក្អម បណ្ដាក្អមសម្រាប់សេនាសនៈ ដែលជំដោយមាសទាំងដុំ ដែលមហាឧបាសិកាវិសាខាឲ្យគេធ្វើប្រគេន កាន់ទៅដោយគិតថា “ សេចក្ដីត្រូវការរបស់យើងដោយក្អមដែលយើងដាក់លើចង្កួយស្មា រមែងមិនមាន ” ហោះឡើងទៅកាន់វេហាស៍ មានមុខឆ្ពោះទៅកាន់ហិមវន្ត-ប្រទេស ដោយរហ័ស ។

នាគរាជឃើញសាមណេរអំពីចម្ងាយ ក៏ក្រោកឡើងទៅទទួលក្អមដោយស្មា ហើយពោលថា “ បពិត្រលោកម្ចាស់ដ៏ចម្រើន កាលអ្នកបម្រើដូចជាខ្ញុំព្រះករុណាមាន ហេតុអ្វី ទើបលោកម្ចាស់និមន្តមកដោយខ្លួនឯងយ៉ាងនេះ, កាលលោកម្ចាស់ត្រូវការទឹក ហេតុអ្វី លោកម្ចាស់មិនបញ្ជូនដំណឹងមក ” ដូច្នេះហើយ យកក្អមដងទឹកខ្លួនឯង ហើយពោលថា “ និមន្តលោកម្ចាស់លុបលាងមុខសិនចុះ ខ្ញុំម្ចាស់នឹងនាំទៅដោយខ្លួនឯង ” ។ សាមណេរពោលថា “ បពិត្រមហារាជអ្នកចូរឈប់ចុះ, អាត្មាជាអ្នកដែលព្រះសម្មាសម្ពុទ្ធប្រើឲ្យមក”

ដូច្នេះហើយ ឲ្យនាគរាជត្រឡប់ហើយ ចាប់កណ្ដាប់មាត់ក្អម ដោយដៃ ហោះមកតាមអាកាស ។

គ្រានោះ ព្រះសាស្ដាទ្រង់ក្រឡេកឃើញសាមណេរ ដែលកំពុងមក ក៏ត្រាស់ហៅពួកភិក្ខុមកហើយ ត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរមើលដំណើររបស់សាមណេរនោះចុះ, សាមណេរនោះមានដំណើរល្អដូចស្ដេចហង្សដ៏ពួអាកាសដូច្នោះ " ។

ចំណែកសាមណេរនោះដាក់ក្អមទឹកហើយ ថ្វាយបង្គំព្រះសាស្ដា រួចហើយឈរក្នុងទីដ៏សមគួរមួយ ។

គ្រានោះ ព្រះសាស្ដាត្រាស់ទៅកាន់សាមណេរនោះថា "ម្នាលសុមនៈ អ្នកមានអាយុប៉ុន្មាន ? សាមណេរក្រាបទូលថា " បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានអាយុ ៧ ឆ្នាំ "។

ព្រះសាស្ដាត្រាស់ថា " ម្នាលសុមនៈ បើដូច្នោះ ចាប់ពីថ្ងៃទៅ អ្នកចូរជាភិក្ខុចុះ " ដូច្នេះហើយបានប្រទានទាយជ្ជ-ឧបសម្បទា ។

បានឮថា សាមណេរអ្នកមានអាយុ ៧ ឆ្នាំ មាន ២ រូបប៉ុណ្ណោះ បានឧបសម្បទា គឺសុមនសាមណេរនេះមួយរូប សោបាកសាមណេរមួយរូប កាលសុមនសាមណេរនោះ ឧបសម្បទាហើយយ៉ាងនោះ ពួកភិក្ខុសន្ទនាគ្នាក្នុងរោងធម៌ថា " អ្នកមានអាយុទាំងឡាយ ហេតុគួរអស្ចារ្យណាស់ហ្ន៎ អានុភាពរបស់សាមណេរតូចយ៉ាងនេះ អានុភាពបែបនេះ ពួកយើងមិនធ្លាប់ឃើញហើយអំពីកាលមុន " ។ សម្បត្តិរមែងសម្រេចដល់ក្មេងៗ បាន

ព្រះសាស្ដាស្ដេចមកហើយ ត្រាស់សួរថា " ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសន្ទនាគ្នាអំពីរឿងអ្វីហ្ន៎ ?" កាលភិក្ខុទាំងនោះក្រាបទូលថា " អំពីរឿងឈ្មោះនេះ ព្រះអង្គ " ក៏ត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនារបស់តថាគត បុគ្គលសូម្បីនៅក្មេងក៏ដោយ ឲ្យតែបតិបត្តិប្រពៃហើយ រមែងបានសម្បត្តិបែបនេះដូចគ្នា " កាលនឹងទ្រង់សម្ដែងធម៌ ទើបត្រាស់ព្រះគាថានេះថា :-

**១២ យោ ហវេ ទហរោ ភិក្ខុ យុញ្ជតិ ពុទ្ធសាសនេ**

**សោមំ លោកំ បភាសេតិ អព្ភាមុត្តោវ ចន្ទិមា ។**

ភិក្ខុណានៅកំលោះ ប្រឹងប្រែង ក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះរមែងញុំាងលោកឲ្យភ្លឺបាន ដូចព្រះចន្ទដែលរះផុតអំពីពពក ។

# អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **យុញ្ជតិ** ប្រឹងប្រែង គឺព្យាយាម ។

បទថា **បភាសេតិ** ជាដើម សេចក្ដីថា ភិក្ខុនោះរមែងញុំាងលោក មានខន្ធលោកជាដើមឲ្យភ្លឺបាន គឺធ្វើឲ្យមានពន្លឺភ្លឺស្វាងតែមួយដោយញាណ ដែលសម្បយុត្តជាមួយនឹងអរហត្តមគ្គរបស់ខ្លួន ។ ដូចព្រះចន្ទដែលរះផុតហើយអំពីគ្រឿងបិទបាំង មានពពកជាដើមដូច្នោះ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។៚

( រឿងសុមនសាមណេរ ចប់ )

ភិក្ខុវណ្ណនា ចប់

វគ្គទី ២៥ ចប់

8888888888888

# ២៦ ព្រាហ្មណវគ្គវណ្ណនា

១ ឆិន្ទ សោតំ បរក្កម្ម កាមេ បនូទ ព្រាហ្មណ

សង្ខារានំ ខយំ ញត្វា អកតញ្ញូសិ ព្រាហ្មណ ។

ម្នាលព្រាហ្មណ៍ អ្នកប្រឹងកាត់តណ្ហាដូចខ្សែទឹក ចូរបន្ទោបង់កាមទាំងឡាយ ម្នាលព្រាហ្មណ៍ អ្នកស្គាល់ច្បាស់នូវការអស់សង្ខារទាំងឡាយហើយ ឈ្មោះថា ជាអ្នកដឹងនូវព្រះ

និព្វានដែលបច្ច័យតាក់តែងមិនបាន ។

២ យទា ទ្វយេសុ ធម្មេសុ  បារគូ ហោតិ ព្រាហ្មណោ
អថស្ស សព្វេ សំយោគា  អត្ថំ គច្ឆន្តិ ជានតោ ។

កាលណា ព្រាហ្មណ៍អ្នកដល់ត្រើយ ក្នុងធម៌ពីរប្រការ គឺសមថធម៌ និងវិបស្សនាធម៌ ក្នុងកាលនោះ  កិលេសគ្រឿងប្រកបសត្វទុកទាំងអស់របស់ព្រាហ្មណ៍ អ្នកដឹងនោះ រមែងដល់នូវការតាំងនៅមិនបាន ។

៣ យស្ស បារំ អបារំ វា  បារាបារំ ន វិជ្ជតិ
វីតទ្ទរំ វិសញ្ញុត្តំ  តមហំ ព្រូមិ ព្រាហ្មណំ ។

ត្រើយក្តី ទីមិនមានត្រើយក្តី ត្រើយ និងមិនមែនត្រើយក្តី មិនមានដល់បុគ្គលណា ( ការប្រកាន់អាយតនៈមិនមានដល់បុគ្គលណា ) តថាគតហៅបុគ្គលនោះ  ដែលជាអ្នកមានសេចក្តីក្រវល់ក្រវាយអស់ហើយ  ជាអ្នកប្រាសចាកកិលេស ថាជាព្រាហ្មណ៍ ។

៤ ឈាយឹ វិរជមាសីនំ     កតកិច្ចំ អនាសវំ
ឧត្តមត្ថំ អនុប្បត្តំ     តមហំ ព្រូមិ ព្រាហ្មណំ ។

តថាគតហៅបុគ្គលអ្នកចម្រើនឈាន មាន
ធូលី គឺកាមអស់ហើយ អ្នកអង្គុយនៅឯកឯង
អ្នកមានសោឡសកិច្ចធ្វើស្រេចហើយ មិនមាន
អាសវៈ ដល់នូវប្រយោជន៍ដ៏ខ្ពង់ខ្ពស់ ដោយ
លំដាប់ហើយនោះ ថាជាព្រាហ្មណ៍ ។

៥ ទិវា តបតិ អាទិច្ចោ     រត្តិមាភាតិ ចន្ទិមា
សន្នទ្ធោ ខត្តិយោ តបតិ ឈាយី តបតិ ព្រាហ្មណោ
អថ សព្វមហោរត្តឹ     ពុទ្ធោ តបតិ តេជសា ។

ព្រះអាទិត្យរុងរឿងក្នុងវេលាថ្ងៃ ព្រះចន្ទ
រុងរឿងក្នុងវេលាយប់ ក្សត្រទ្រង់ប្រដាប់ពេញ
យសហើយ រមែងរុងរឿង សមណព្រាហ្មណ៍
អ្នកមានឈាន រមែងរុងរឿង ឯព្រះសម្ពុទ្ធ
រមែងរុងរឿងដោយតេជះ ទាំងយប់ ទាំងថ្ងៃ ។

៦ ពាហិតបាបោ ហិ ព្រាហ្មណោ

សមចរិយា សមណោតិ វុច្ចតិ
បព្វាជយមត្តនោ មលំ
តស្មា បព្វជិតោតិ វុច្ចតិ ។
អ្នកដែលមានបាបបន្សាត់ហើយ ឈ្មោះ
ថា ព្រាហ្មណ៍ អ្នកដែលតថាគត ហៅថា
សមណៈ ព្រោះការប្រព្រឹត្តរម្ងាប់ អ្នកដែល
បណ្តេញមន្ទិលនៃខ្លួន ហេតុនោះទើបតថាគត
ហៅថា បព្វជិត ។

៧ ន ព្រាហ្មណស្ស បហរេយ្យ នាស្ស មុញ្ចេថ ព្រាហ្មណោ
ធិ ព្រាហ្មណស្ស ហន្តារំ តតោ ធិ យស្ស មុញ្ចតិ ។
ន ព្រាហ្មណស្សេតទកិញ្ចិ សេយ្យោ
យទានិសេធោ មនសោ បិយេហិ
យតោ យតោ ហឹសមនោ និវត្តតិ
តតោ តតោ សម្មតិមេវ ទុក្ខំ ។
ព្រាហ្មណ៍ មិនគប្បីប្រហារព្រាហ្មណ៍ទេ
( ចំណែក ) ព្រាហ្មណ៍ ( ដែលត្រូវគេប្រហារ

ហើយ )  គប្បីចងពៀរចំពោះព្រាហ្មណ៍នោះ តថាគតតិះដៀលព្រាហ្មណ៍  ដែលប្រហារព្រាហ្មណ៍  ព្រាហ្មណ៍ណា  ចងពៀរចំពោះព្រាហ្មណ៍នោះ តថាគតតិះដៀលព្រាហ្មណ៍នោះក្រៃលែងជាងនោះទៅទៀត ។  ការហាមឃាត់ចិត្តចាកអារម្មណ៍ជាទីស្រឡាញ់ របស់ព្រាហ្មណ៍នោះ មិនមែនប្រសើរបន្តិចបន្តួចទេ ចិត្តដែលគិតបៀតបៀនគេ ងាកចេញចាកវត្ថុណាៗ សេចក្តីទុក្ខព្រោះវត្ថុនោះៗ ក៏រម្ងាប់ទៅបាន ។

***៨ យស្ស កាយេន វាចាយ មនសា នត្ថិ ទុក្កតំ***
***សំវុតំ តីហិ ឋានេហិ  តមហំ ព្រូមិ ព្រាហ្មណំ ។***

អំពើអាក្រក់  ដោយទ្វារកាយ  ទ្វារវាចាទ្វារចិត្ត  របស់បុគ្គលណា  មិនមានទេ  តថាគតហៅបុគ្គល ដែលបានសង្រួមដោយឋានទាំង ៣ នោះ ថាជាព្រាហ្មណ៍ ។

***៩ យម្ហា ធម្មំ វិជានេយ្យ សម្មាសម្ពុទ្ធទេសិតំ***

សក្កច្ចំ តំ នមស្សេយ្យ អគ្គិហុត្តំវ ព្រាហ្មណោ ។

បុគ្គលចេះធម៌អាថ៌ ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងហើយ អំពីសម្នាក់គ្រូណា គប្បីនមស្ការគ្រូនោះ ដោយគោរព ដូចព្រាហ្មណ៍ដែលគោរពការបូជាភ្លើង ដូច្នោះដែរ ។

១០ ន ជដាហិ ន គោត្តេហិ ន ជច្ចា ហោតិ ព្រាហ្មណោ
យម្ហិ សច្ចញ្ច ធម្មោ ច សោ សុចី សោ ច ព្រាហ្មណោ ។

បុគ្គលដែលឈ្មោះថា ព្រាហ្មណ៍ព្រោះផ្នួងសក់ ក៏មិនមែន ព្រោះគោត្រ ក៏មិនមែន ព្រោះជាតិ ក៏មិនមែន សច្ចៈផង ធម៌ផង មានក្នុងបុគ្គលណា បុគ្គលនោះឈ្មោះថា អ្នកស្អាតផង បុគ្គលនោះឈ្មោះថា ព្រាហ្មណ៍ផង ។

១១ កិន្តេ ជដាហិ ទុម្មេធ កិន្តេ អជិនសាដិយា
អព្ភន្តរន្តេ គហនំ ពាហិរំ បរិមជ្ជសិ ។

នៃអ្នកអប្បប្រាជ្ញាអើយ អ្នកមានប្រ-យោជន៍អ្វី ដោយការទុកផ្នួងសក់ អ្នកមាន

ប្រយោជន៍អ្វី ដោយការទ្រទ្រង់សំពត់ស្បែក
ឃ្លា បើសន្ដានខាងក្នុងរបស់អ្នក ស៊ីងសាំញ៉ាំ
ដោយរាគាទិក្កិលេស អ្នកឈ្មោះថា ដុសខាត់
តែខាងក្រៅទេ ។

១២ បំសុកូលធរំ ជន្តុំ    កិសន្ធមនិសន្ថតំ
ឯកំ វនស្មឹ ឈាយន្តិ  តមហំ ព្រូមិ ព្រាហ្មណំ ។

តថាគតហៅ  បុគ្គលអ្នកទ្រទ្រង់សំពត់
បំសុកូល  មានកាយស្គម  មានខ្លួនរវាមដោយ
សរសៃ ជាបុគ្គលឯកឯង ចម្រើនឈានក្នុងព្រៃ
នោះ ថាជាព្រាហ្មណ៍ ។

១៣ ន ចាហំ ព្រាហ្មណំ ព្រូមិ យោនិជំ មត្តិសម្ភវំ
ភោវាទី នាម សោ ហោតិ ស វេ ហោតិ កិញ្ចនោ
អកិញ្ចនំ អនាទានំ    តមហំ ព្រូមិ ព្រាហ្មណំ ។

តថាគតនឹងហៅអ្នកកើត អំពីកំណើត អ្នកកើត
ក្នុងផ្ទៃនៃព្រាហ្មណីជាមាតា ថាជាព្រាហ្មណ៍ ក៏ទេ
បុគ្គលនោះគ្រាន់តែបាននាមថា  ភោវាទី ( អ្នក

ពោលថាចម្រើន ) ព្រោះបុគ្គលនោះឯង ជាអ្នក
មានកិលេសគ្រឿងកង្វល់នៅឡើយ តថាគត
ហៅបុគ្គលអ្នកមិនមានកិលេសគ្រឿងកង្វល់ អ្នក
មិនមានសេចក្ដីប្រកាន់មាំនោះឯង ថាជាព្រាហ្មណ៍ ។

**១៤ សព្វសំ យោជនំ ឆេត្វា យោ វេ ន បរិតស្សតិ**
**សង្គាតិគំ វិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា កាត់សំយោជនៈទាំងអស់បាន
មិនតក់ស្លុត តថាគតហៅបុគ្គលនោះ ដែលគ្មាន
កិលេសជាគ្រឿងចំពាក់ អ្នករួចស្រឡះចាក
កិលេស ថាជាព្រាហ្មណ៍ ។

**១៥ ឆេត្វា នទ្ធឹ វរត្តញ្ច សន្ទានំ សហានុក្កមំ**
**ឧក្ខិត្តបលិឃំ ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគតហៅបុគ្គលដែលកាត់សេចក្ដីក្រោធ
ដូចព្រួរផង កាត់តណ្ហា ដូចព្រ័ត្រផង កាត់ទិដ្ឋិ
៦២ ដូចទឹក ព្រមទាំងអនុស័យ ដូចអ្នកដើរ
តាមផង អ្នកមានអវិជ្ជា ដូចសសរខឿន ដក

បោលហើយ អ្នកត្រាស់ដឹងសច្ចៈ ៤ នោះឯង
ថាជាព្រាហ្មណ៍ ។

**១៦ អក្កោសំ វធពន្ធញ្ច អទុដ្ឋោ យោ តតិក្ខតិ**
**ខន្តីពលំ ពលានីកំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា មិនប្រទូស្ត អត់សង្កត់ពាក្យជេរ
ផង ការបៀតបៀន និងការចងផងបាន ទើប
តថាគតហៅបុគ្គលដែលមានខន្តីជាពលៈ មាន
ខន្តីជាវេហ៍ពលនោះឯង ថាជាព្រាហ្មណ៍ ។

**១៧ អក្កោធនំ វតវន្តំ សីលវន្តំ អនុស្សទំ**
**ទន្តំ អន្តិមសារីរំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគតហៅបុគ្គល ដែលមិនមានសេចក្តី
ក្រោធ មានធុតង្គវត្ត មានចតុប្បារិសុទ្ធិសីល
មិនមានតណ្ហាគ្រៀងប៉ោងចិត្ត មានឥន្ទ្រិយ
ទូន្មានហើយ មានសរីរៈឋិតនៅ ក្នុងទីបំផុត
នោះ ថាជាព្រាហ្មណ៍ ។

**១៨ បោក្ខរបត្តេវ អារគ្គេរិវ សាសបោ**

យោ វេ ន លិម្បតិ កាមេសុ  តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា មានចិត្តមិនបានជាប់នៅ ក្នុងកាមទាំងឡាយ ដូចទឹកលើស្លឹកឈូក ឬដូចគ្រាប់ស្ពៃលើចុងដែលស្រួច  តថាគតហៅបុគ្គល ថាជាព្រាហ្មណ៍ ។

១៩ យោ ទុក្ខស្ស បជានាតិ  ឥធេវ ខយមត្តនោ
បន្នភារំ វិសញ្ញុត្តំ  តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា ក្នុងសាសនានេះឯង ដឹងច្បាស់នូវការអស់ទុក្ខរបស់ខ្លួន  តថាគតហៅបុគ្គលនោះ ដែលមានខន្ធភារៈ ដាក់ចុះហើយ ដែលរួចស្រឡះចាកកិលេសទាំងឡាយ ថាជាព្រាហ្មណ៍។

២០ គម្ភីរបញ្ញំ មេធាវី  មគ្គាមគ្គស្ស កោវិទំ
ឧត្តមត្ថំ អនុប្បត្តំ  តមហំ ព្រូមិ ព្រាហ្មណំ ។

តថាគតហៅ បុគ្គលអ្នកប្រាជ្ញាជ្រៅ មានប្រាជ្ញាជាគ្រឿងទម្លាយកិលេស  អ្នកឈ្លាសក្នុងផ្លូវ និងមិនមែនផ្លូវ បានសម្រេចប្រ-

យោជន៍ដ៏ខ្ពង់ខ្ពស់នោះ ថាជាព្រាហ្មណ៍ ។

**២១ អសំសដ្ឋំ គហដ្ឋេហិ អនាគារេហិ ចូភយំ**
**អនោកសារី អប្បិច្ឆំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគតហៅបុគ្គល ដែលមិនច្រឡំ ដោយជនទាំងឡាយ ២ ពួក គឺគ្រហស្ថ ១ បព្វជិត ១ ជាអ្នកត្រាច់ទៅដោយមិនមានសេចក្ដីអាល័យ មានសេចក្ដីប្រាថ្នាតិចនោះ ថាជាព្រាហ្មណ៍ ។

**២២ និធាយ ទណ្ឌំ ភូតេសុ តសេសុ ថាវរេសុ ច**
**យោ ន ហន្តិ ន ឃាតេតិ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា ដាក់ចុះនូវអាជ្ញា ក្នុងសត្វទាំងឡាយ ដែលនៅតក់ស្លុតក្ដី ដែលមាំមួន គឺមិនតក់ស្លុតក្ដី មិនបៀតបៀនដោយខ្លួនឯង មិនប្រើគេឲ្យបៀតបៀន តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

**២៣ អវិរុទ្ធំ វិរុទ្ធេសុ អត្តទណ្ឌេសុ និព្វុតំ**
**សាទានេសុ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគតហៅបុគ្គលអ្នកដែលមិនខឹង ចំពោះពួកជនដែលខឹងហើយ អ្នករំលត់ចំពោះពួកជនដែលមានអាជ្ញាក្នុងខ្លួន អ្នកមិនមានសេចក្តីប្រកាន់ចំពោះពួកជន ដែលមានសេចក្តីប្រកាន់នោះ ថាជាព្រាហ្មណ៍ ។

២៤ យស្ស រាគោ ច ទោសោ ច មានោ មោក្ខោ ច បាតិតោ
សាសបោរិ អារគ្គា តមហំ ព្រូមិ ព្រាហ្មណំ ។

រាគៈ ទោសៈ មានះ និងមក្ខៈ ដែលបុគ្គលណាជម្រុះចេញហើយ ដូចគ្រាប់ស្ពៃដែលជ្រុះចុះ អំពីចុងដែកស្រួច តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

២៥ អក្កកសំ វិញ្ញាបនី គិរំ សច្ចំ ឧទីរយេ
យាយ នាភិសជេ កញ្ចិ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា ពោលពាក្យមិនអាក្រក់ ពាក្យជាហេតុឲ្យដឹងសេចក្តីបាន ជាពាក្យពិត ជាពាក្យដែលមិនធ្វើអ្នកណា ឲ្យទាស់ចិត្ត តថាគតហៅបុគ្គលនោះថាជាព្រាហ្មណ៍ ។

២៦ យោធ ទីឃំ វ រស្សំ វា អណុំ ថូលំ សុភាសុភំ
លោកេ អទិន្នំ នាទិយតិ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា មិនយករបស់វែង ឬខ្លី តូច ឬធំ
អាក្រក់ ឬល្អ ដែលគេមិនបានឲ្យហើយក្នុងលោក
នេះ តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

២៧ អាសា យស្ស ន វិជ្ជន្តិ អស្មឹ លោកេ បរម្ហិ ច
និរាសយំ វិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា មិនមានសេចក្តីប្រាថ្នាក្នុងលោក
នេះផង ក្នុងលោកខាងមុខផង តថាគតហៅបុគ្គល
នោះ ដែលមិនមានសេចក្តីប្រាថ្នា ដែលផុតស្រឡះ
ចាកកិលេស ថាជាព្រាហ្មណ៍ ។

២៨ យស្សាលយា ន វិជ្ជន្តិ អញ្ញាយ អកថង្កថី
អមតោគធំ អនុប្បត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

អ្នកណា មិនមានសេចក្តីអាល័យ គឺតណ្ហា
មិនមានសេចក្តីសង្ស័យក្នុងអ្វីសោះ ព្រោះដឹង
ច្បាស់ធម៌ តថាគតហៅបុគ្គលនោះ ដែលមាន

ចិត្តចុះស៊ប់កាន់ព្រះនិព្វាន ដែលមានព្រះអរហត្ត-
ផលដល់ហើយ ដោយលំដាប់ ថាជាព្រាហ្មណ៍ ។

**២៩ យោធ បុញ្ញញ្ច បាបញ្ច ឧភោ សង្គំ ឧបច្ចគា**
**អសោកំ វិរជំ សុទ្ធំ  តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា ក្នុងលោកនេះ លះបង់បុណ្យ និងបាបទាំង ២ និងកិលេសជាគ្រឿងចំពាក់ ( មានរាគៈជាដើម ) ចេញហើយ តថាគតហៅបុគ្គលនោះ ដែលជាអ្នកមិនមានសេចក្តីសោក មានធូលី គឺកិលេសអស់ហើយ ជាអ្នកបរិសុទ្ធ ថាជាព្រាហ្មណ៍ ។

**៣០ ចន្ទំវ វិមលំ សុទ្ធំ  វិប្បសន្នមនាវិលំ**
**នន្ទិភវបរិក្ខីណំ  តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគតហៅបុគ្គល ដែលមិនមានសេចក្តីសៅហ្មង ដូចព្រះចន្ទប្រាសចាកមន្ទិល ជាអ្នកបរិសុទ្ធ មានចិត្តជ្រះថ្លា មិនកករល្អក់ អស់សេចក្តីត្រេកអរក្នុងភពហើយនោះ ថាជាព្រាហ្មណ៍ ។

យោមំ បលិបថំ ទុគ្គំ  សំសារំ មោហមច្ចគា
តិណ្ណោ បារគតោ ឈាយី អនេជោ អកថង្កថី
អនុបាទាយ និព្វុតោ  តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា កន្លងផ្លូវ គឺរាគៈ និងភក់ដែលគេឆ្លងបានដោយកម្រ គឺកិលេស និងសង្សារវដ្ដ និងមោហៈទាំងនេះបាន  ជាអ្នកឆ្លងអន្លង់ទាំង ៤ បានដល់ត្រើយ គឺព្រះនិព្វាន  ជាអ្នកមានឈាន  មិនញាប់ញ័រដោយតណ្ហា   មិនមានសេចក្ដីសង្ស័យមិនប្រកាន់មាំ ជាអ្នករលត់កិលេសហើយ តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

៣២ យោធ កាមេ បហន្ត្វាន អនាគារោ បរិព្វជេ
កាមភវបរិក្ខីណំ    តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា ក្នុងលោកនេះ បានលះបង់កាមទាំងឡាយ ជាអ្នកមិនមានផ្ទះ គេចចេញចាក

កាមបាន តថាគតហៅបុគ្គលនោះ ដែលអស់កាមភពហើយ ថាជាព្រាហ្មណ៍ ។

**៣៣ យោធ តណ្ហំ បហន្ត្វាន អនាគារោ បរិព្វជេ តណ្ហាភវបរិក្ខីណំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា ក្នុងលោកនេះ បានលះបង់តណ្ហាហើយ ជាអ្នកមិនមានផ្ទះ គេចចេញចាកតណ្ហាបាន តថាគតហៅបុគ្គល ដែលអស់តណ្ហា និងភពហើយនោះ ថាជាព្រាហ្មណ៍ ។

**៣៤ ហិត្វា មានុសកំ យោគំ ទិព្វំ យោគំ ឧបច្ចគា សព្វយោគវិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា លះកិលេសជាគ្រឿងប្រកបដែលជារបស់មនុស្ស កន្លងកិលេសជាគ្រឿងប្រកប ដែលជារបស់ទិព្វបានហើយ តថាគតហៅបុគ្គល ដែលផុតស្រឡះ ចាកកិលេសជាគ្រឿងប្រកបទាំងពួងនោះ ថាជាព្រាហ្មណ៍ ។

**៣៥ ហិត្វា រតឹ អរតិញ្ច សីតិភូតំ និរូបធឹ**

*សព្វលោកាតិគំ វីរំ  តមហំ ព្រូមិ ព្រាហ្មណំ ។*

តថាគតហៅបុគ្គល ដែលលះបង់សេចក្ដី

ត្រេកអរក្នុងកាមគុណ  និងមិនត្រេកអរក្នុង

កិរិយានៅក្នុងព្រៃ  ជាអ្នកមានចិត្តត្រជាក់  មិន

មានឧបក្កិលេស  គ្របសង្កត់លោកទាំងពួង

មានសេចក្ដីព្យាយាមនោះ ថាជាព្រាហ្មណ៍ ។

៣៦ *ចុតឹ យោ វេទិ សត្តានំ  ឧបបត្តិញ្ចសព្វសោ*

*អសត្តំ សុគតឹ ពុទ្ធំ  តមហំ ព្រូមិ ព្រាហ្មណំ ។*

*យស្ស គតឹ ន ជានន្តិ  ទេវា គន្ធព្វមានុសា*

*ខីណាសវំ អរហន្តំ  តមហំ ព្រូមិ ព្រាហ្មណំ ។*

បុគ្គលណា  ដឹងច្បាស់ចុតិ  និងបដិសន្ធិ

របស់ពួកសត្វ ដោយអាការទាំងពួងបាន តថា-

គតហៅបុគ្គល ដែលជាអ្នកមិនជាប់នៅក្នុងកាម

អ្នកមានដំណើរល្អ ដោយសេចក្ដីប្រតិបត្តិ អ្នក

ត្រាស់ដឹងនូវសច្ចៈ ៤ នោះ ថាជាព្រាហ្មណ៍ ។

ទេវតា គន្ធព្វ និងពួងមនុស្សទាំងឡាយ មិនដឹង

គតិរបស់បុគ្គលណា តថាគតហៅបុគ្គល ដែលជាអ្នកមានអាសវៈអស់ហើយ ជាព្រះអរហន្ត នោះ ថាជាព្រាហ្មណ៍ ។

**៣៧ យស្ស បុរេ ច បច្ឆា ច មជ្ឈេ ច នត្ថិ កិញ្ចនំ**
**អកិញ្ចនំ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា មិនមានសេចក្ដីកង្វល់ ក្នុងកាលមុនផង ក្នុងកាលជាខាងក្រោយផង ក្នុងកាលជាកណ្ដាលផង តថាគតហៅបុគ្គល ដែលជាអ្នកមិនមានកង្វល់ មិនមានសេចក្ដីប្រកាន់នោះ ថាជាព្រាហ្មណ៍ ។

**៣៨ ឧសភំ បវរំ វីរំ មហេសឹ វិជិតាវិនំ**
**អនេជំ ន្ហាតកំ ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគតហៅវីរបុរស អ្នកអង់អាច អ្នកប្រសើរ អ្នកស្វែងរកគុណដ៏ធំ ឈ្នះមារ មិនមានកិលេសជាគ្រឿងញាប់ញ័រ ងូតលាងកិលេស ត្រាស់ដឹងសច្ចៈនោះ ថាជាព្រាហ្មណ៍ ។

**៣៩ ពុទ្ធេនិវាសំ យោ វេទិ សគ្គាបាយញ្ច បស្សតិ**

អថោ ជាតិក្ខយំ បត្តោ អភិញ្ញា វោសិតោ មុនិ
សព្វវោសិតវោសានំ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា ដឹងច្បាស់ខន្ធបញ្ចកៈ ដែលខ្លួនធ្លាប់នៅអាស្រ័យ ក្នុងកាលមុនផង ឃើញច្បាស់ឋានសួគ៌ និងអបាយភូមិផង មួយទៀត បានសម្រេចធម៌ជាគ្រឿងអស់ជាតិ ជាអ្នកប្រាជ្ញ ស្រេចកិច្ចហើយ ព្រោះអភិញ្ញា តថាគតហៅបុគ្គល ដែលជាអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ ចប់សព្វគ្រប់ហើយនោះ ថាជាព្រាហ្មណ៍ ។

# ២៦ ព្រាហ្មណវគ្គវណ្ណនា

## ១ រឿងព្រាហ្មណ៍អ្នកច្រើនដោយសេចក្ដីជ្រះថ្លា

### *សេចក្ដីខាងដើម*

*ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍អ្នកច្រើនដោយសេចក្ដីជ្រះថ្លា ត្រាស់ព្រះធម្មទេសនានេះថា “ **ឆិន្ទ សោតំ បរក្កម្ម** ” ជាដើម ។*

## ពួកភិក្ខុវៀសវាងទះរបស់ព្រាហ្មណ៍

បានឮថា ព្រាហ្មណ៍នោះស្ដាប់ធម្មទេសនារបស់ព្រះមានព្រះភាគហើយ មានចិត្តជ្រះថ្លា តាំងផ្ដើមនូវនិច្ចភត្តដើម្បីភិក្ខុប្រមាណ ១៦ រូប ទុកក្នុងផ្ទះរបស់ខ្លួន ទទួលបាត្រក្នុងពេលដែលភិក្ខុទាំងឡាយមកហើយ ពោលថា "សូមព្រះអរហន្តដ៏ចម្រើន ចូរមក, សូមព្រះអរហន្តដ៏ចម្រើន និមន្តគង់" កាលពោលនូវពាក្យណាមួយ ក៏ពោលពាក្យប្រកបដោយវាទះថាព្រះអរហន្តប៉ុណ្ណោះ ។ បណ្ដាភិក្ខុទាំងនោះ ពួកភិក្ខុដែលជាបុថុជ្ជនគិតគ្នាថា "ព្រាហ្មណ៍នេះ តែងសម្គាល់ពួកយើងថាជាព្រះអរហន្ត" ពួកភិក្ខុដែលជាព្រះអរហន្តក៏គិតថា "ព្រាហ្មណ៍នេះ រមែងដឹងពួកយើងថាជាព្រះខីណាស្រព" ភិក្ខុទាំងអស់នោះ វៀសពាក្យរបស់ព្រាហ្មណ៍យ៉ាងនេះ ទើបមិនទៅកាន់ផ្ទះរបស់ព្រាហ្មណ៍នោះ ។ ព្រាហ្មណ៍នោះកើតទុក្ខចិត្តហើយគិតថា "ព្រោះហេតុអ្វីហ្ន៎ ? ទើបលោកម្ចាស់ទាំងឡាយ មិននិមន្តមកផ្ទះយើង" លុះគិតដូច្នេះហើយក៏ទៅកាន់វិហារថ្វាយបង្គំព្រះសាស្ដា ក្រាបទូលសេចក្ដីនោះ។

## មិនជាអាបត្តិព្រោះមិនត្រេកអរចំពោះវាទៈនោះ

ព្រះសាស្តា ត្រាស់ហៅភិក្ខុទាំងឡាយមកហើយ ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ តើសេចក្តីនោះជាយ៉ាងណា" កាលភិក្ខុទាំងនោះក្រាបទូលសេចក្តីនោះហើយ, ទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ក៏អ្នកទាំងឡាយត្រេកអរនិងវាទៈថា ជាព្រះអរហន្តឬ ?" ។

ពួកភិក្ខុ. បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គមិនមានត្រេកអរទេ ។

ព្រះសាស្តា. បើដូច្នោះ, ពាក្យនោះ ជាពាក្យពោលដោយសេចក្តីជ្រះថ្លារបស់មនុស្សទាំងឡាយប៉ុណ្ណោះ, ភិក្ខុទាំងឡាយ មិនជាអាបត្តិព្រោះការពោលដោយសេចក្តីជ្រះថ្លាទេ, មួយវិញទៀត សេចក្តីស្រឡាញ់ព្រះអរហន្តទាំងឡាយរបស់ព្រាហ្មណ៍ មានប្រមាណក្រៃលែង, ហេតុនោះ សូម្បីពួកអ្នកកាត់ក្រសែតណ្ហាហើយសម្រេចព្រះអរហន្តនោះ គួរ" ដូច្នេះហើយ កាលនឹងទ្រង់សម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖-

**១ ឆិន្ទ សោតំ បរក្កម្ម កាមេ បនូទ ព្រាហ្មណ**
**សង្ខារានំ ខយំ ញត្វា អកតញ្ញូសិ ព្រាហ្មណ ។**

ម្នាលព្រាហ្មណ៍ អ្នកប្រឹងកាត់តណ្ហាដូចខ្សែទឹក ចូរបន្ទោបង់កាមទាំងឡាយ ម្នាលព្រាហ្មណ៍ អ្នកស្គាល់ច្បាស់នូវការអស់សង្ខារទាំងឡាយហើយ ឈ្មោះថា ជាអ្នកដឹងនូវព្រះនិព្វានដែលបច្ច័យតាក់តែងមិនបាន ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **បរក្កម្ម** ជាដើម សេចក្ដីថា ដែលឈ្មោះថា ក្រសែតណ្ហា នរណា ៗ មិនអាចដើម្បីនឹងកាត់បានដោយសេចក្ដីព្យាយាមមានប្រមាណតិច, ហេតុនោះ អ្នកចូរព្យាយាមកាត់ខ្សែនោះ ដោយសេចក្ដីព្យាយាមដ៏ធំ ដែលប្រកបជាមួយនិងញាណ គឺចូរបន្ទោបង់ បានដល់ ចូរបញ្ចេញកាមទាំងពីរចេញចុះ ។

ពាក្យថា **ព្រាហ្មណ៍** នោះ ជាពាក្យហៅព្រះខីណាស្រពទាំងឡាយ ។

បទថា **សន្ធាភនំ** សេចក្តីថា ដឹងនូវកិរិយាអស់ទៅនៃខន្ធ ៥ ។

បទថា **អកតញ្ញូ** សេចក្តីថា កាលបើដូច្នោះ អ្នកឈ្មោះថា អកតញ្ញូ ព្រោះដឹងនូវព្រះនិព្វានដែលបុគ្គលធ្វើមិនដោយវត្ថុធាតុទាំងឡាយ មានមាសជាដើម ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

រឿងព្រាហ្មណ៍អ្នកច្រើនដោយសេចក្តីជ្រះថ្លា ចប់

## ២.រឿងភិក្ខុច្រើនរូប

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុច្រើនរូប ត្រាស់ធម៌ទេសនានេះថា “ **យទា ទ្វយេសុ ធម្មេសុ** ” ជាដើម ។

## ព្រះសារីបុត្រទូលសួរបញ្ហាដើម្បីពួកភិក្ខុ

ថ្ងៃមួយ ភិក្ខុដែលនៅក្នុងទិសប្រមាណ ៣០ រូប មកថ្វាយបង្គំព្រះសាស្តា ហើយអង្គុយក្នុងដ៏សមគួរ ។ ព្រះ-

សារីបុត្តត្ថេរ ឃើញធម៌ដែលជាឧបនិស្ស័យនៃព្រះអរហត្ត របស់ភិក្ខុទាំងនោះហើយ ចូលទៅគាល់ព្រះសាស្ដា ទូលសួរបញ្ហានេះថា “ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយដែលព្រះអង្គត្រាស់ហៅថា ធម៌ ២ ប្រការៗ ដូច្នេះ, ធម៌ ២ ប្រការនោះ តើដូចម្ដេច ?” ។

គ្រានោះ ព្រះសាស្ដាត្រាស់ទៅកាន់ព្រះសារីបុត្រថា “ ម្នាលសារីបុត្រ សមថៈ និងវិបស្សនា ហៅថា ធម៌ ២ ប្រការ ” ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា :-

**២ យទា ទ្វយេសុ ធម្មេសុ បារគូ ហោតិ ព្រាហ្មណោ**
**អថស្ស សព្វេ សំយោគា អត្ថំ គច្ឆន្តិ ជានតោ ។**

កាលណា ព្រាហ្មណ៍អ្នកដល់ត្រើយ ក្នុងធម៌ពីរប្រការ គឺសមថធម៌ និងវិបស្សនាធម៌ ក្នុងកាលនោះ កិលេសគ្រឿងប្រកបសត្វទុកទាំងអស់របស់ព្រាហ្មណ៍ អ្នកដឹងនោះ រមែងដល់នូវការតាំងនៅមិនបាន ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **យទា** ជាដើម សេចក្ដីថា ក្នុងកាលណាព្រះខីណាស្រពអ្នកដល់ត្រើយ ក្នុងធម៌ គឺសមថៈ និងវិបស្សនា ដែលតាំងនៅក្នុងចំណែកទាំង ២ ដោយអំណាចនៃការដល់នូវត្រើយ គឺអភិញ្ញាជាដើម, ក្នុងកាលនោះកិលេសជាគ្រឿងប្រកបទាំងឡាយ មានកិលេសគ្រឿងប្រកប គឺកាមជាដើមទាំងពួង ដែលអាចប្រកបទុកក្នុងវដ្ដៈរបស់ព្រះខីណា-ស្រពនោះ អ្នកដឹងយ៉ាងនោះ រមែងដល់នូវការតាំងនៅមិនបាន គឺអស់ទៅ ។

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះសូម្បីទាំងអស់តាំងនៅក្នុងព្រះអរហត្ត ។ល។

( រឿងភិក្ខុច្រើនរូប ចប់ )

# ៣ រឿងមារ

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមារ ត្រាស់ព្រះធម្មទេសនានេះថា “ **យស្ស បារំ អបារំ វា** ” ជាដើម ។

## មានបន្ទំខ្ទូនទូលសួររឿងត្រើយ

បានឮថា ថ្ងៃមួយ មានក្មេងខ្ទួនជាបុរសម្នាក់ចូលទៅគាល់ព្រះសាស្តា ហើយទូលសួរថា "បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលព្រះអង្គត្រាស់ថា ត្រើយៗ, អ្វីហ្ន៎ ឈ្មោះថាត្រើយនុ៎ះ ?" ។

ព្រះសាស្តាទ្រង់ជ្រាបថា " នេះជាមារ " ទើបត្រាស់ថា "ម្នាលមារអ្នកមានចិត្តបាប ប្រយោជន៍អ្វីរបស់អ្នកដោយត្រើយ, ត្រើយនោះ អ្នកមានរាគៈទៅប្រាសហើយទាំងឡាយគប្បីដល់ " ដូច្នេះហើយ ត្រាស់ធម្មទេសនានេះថា :-

**៣ យស្ស បារំ អបារំ វា បារាបារំ ន វិជ្ជតិ**
**វីតទ្ទរំ វិសញ្ញុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។**

ត្រើយក្តី ទីមិនមានត្រើយក្តី ត្រើយ និងមិនមែនត្រើយក្តី មិនមានដល់បុគ្គលណា ( ការប្រកាន់អាយតនៈមិនមានដល់បុគ្គលណា ) តថាគតហៅបុគ្គលនោះ ដែលជាអ្នកមានសេចក្តីក្រវល់ក្រវាយអស់ហើយ ជាអ្នកប្រាសចាកកិលេស ថាជាព្រាហ្មណ៍ ។

# អធិប្បាយគាថា

អាយតនៈខាងក្នុង ៦ ឈ្មោះថា **បារំ** ក្នុងព្រះគាថានោះ ។ អាយតនៈខាងក្រៅ ៦ ឈ្មោះថា **អបារំ** ។ អាយតនៈទាំង ២ នោះ ឈ្មោះថា **បារាបារំ** ។

បទថា **ន វិជ្ជតិ** សេចក្ដីថា ត្រើយ និងមិនមែនត្រើយទាំងអស់នោះ មិនមានដល់អ្នកណា ព្រោះមិនមានការប្រកាន់ថា " យើង " ឬថា " របស់យើង ", តថាគតហៅអ្នក គឺអ្នកដែលមានសេចក្ដីក្រវល់ក្រវាយទៅប្រាសហើយ ព្រោះទៅប្រាសនៃសេចក្ដីក្រវល់ក្រវាយ គឺកិលេសទាំងឡាយ អ្នកប្រាសចាកកិលេសទាំងពួងបានហើយថា ជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយ-ផលទាំងឡាយ មានសោតាបត្តិផលជាដើម ។l๛

( រឿងមារ ចប់ )

# ៨ រឿងព្រាហ្មណ៍ម្នាក់

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា “ **ឈាយឹ** ” ជាដើម ។

## ព្រាហ្មណ៍ទូលសួររឿងព្រាហ្មណ៍ចំពោះព្រះសាស្ដា

បានឮថា ព្រាហ្មណ៍នោះគិតថា “ ព្រះសាស្តាត្រាស់ហៅសាវករបស់ព្រះអង្គថា ព្រាហ្មណ៍, ចំណែកយើងជាព្រាហ្មណ៍ដោយជាតិ និងគោត្រ, ការដែលព្រះអង្គត្រាស់ហៅយើងដូច្នោះដែរ គួរ ”, ព្រាហ្មណ៍នោះចូលទៅគាល់ព្រះ-សាស្តា ទូលសួរសេចក្តីនោះ ។

ព្រះសាស្តាត្រាស់ថា “ តថាគតមិនហៅបុគ្គលថាព្រាហ្មណ៍ ដោយហេតុត្រឹមតែជាតិ និងគោត្រប៉ុណ្ណោះទេ, ប៉ុន្តែ តថាគតហៅបុគ្គលអ្នកសម្រេចប្រយោជន៍ដ៏ខ្ពង់ខ្ពស់បំផុតប៉ុណ្ណោះ ( ថាជាព្រាហ្មណ៍ ) ដូច្នេះហើយ ត្រាស់ព្រះ-គាថានេះថា :-

**៤ ឈាយឹ វិរជមាសីនំ កតកិច្ចំ អនាសវំ**
**ឧត្តមត្ថំ អនុប្បត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគតហៅបុគ្គលអ្នកចម្រើនឈាន មាន
ធូលី គឺកាមអស់ហើយ អ្នកអង្គុយនៅឯកឯង
អ្នកមានសោឡសកិច្ចធ្វើស្រេចហើយ មិនមាន
អាសវៈ ដល់នូវប្រយោជន៍ដ៏ខ្ពង់ខ្ពស់ ដោយ

លំដាប់ហើយនោះ ថាជាព្រាហ្មណ៍ ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **ឈាយឹ** ជាដើម សេចក្តីថា តថាគតហៅបុគ្គលអ្នកសម្លឹងដោយឈាន ២ យ៉ាង អ្នកប្រាសចាកធូលី ដោយធូលីគឺកាម នៅតែម្នាក់ឯងក្នុងព្រៃ ឈ្មោះថា អ្នកមានកិច្ចធ្វើស្រេចហើយ ព្រោះកិច្ច ១៦ យ៉ាង ខ្លួនបានធ្វើដោយមគ្គ ៤ ហើយ ឈ្មោះថា មិនមានអាសវៈ ព្រោះមិនមានអាសវៈទាំងឡាយ សម្រេចប្រយោជន៍ដ៏ខ្ពង់ខ្ពស់ គឺព្រះអរហត្តហើយ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ព្រាហ្មណ៍នោះ តាំងនៅក្នុងសោតាបត្តិផល ទេសនាបានជាប្រយោជន៍សូម្បីដល់ជនអ្នកមកប្រជុំគ្នាហើយ ៚

( រឿងព្រាហ្មណ៍ម្នាក់ ចប់ )

# ៥ រឿងព្រះអានន្ទត្ថេរ

## *សេចក្តីខាងដើម*

*ព្រះសាស្តា កាលគង់នៅក្នុងប្រាសាទរបស់ឧបាសិកាឈ្មោះមិគារមាតា ទ្រង់ប្រារព្ធព្រះអានន្ទត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា “ **ទិវា តបតិ អាទិច្ចោ** ” ជាដើម ។*

# រស្មីនៃវត្ថុ ៥ យ៉ាងផ្សេងគ្នា

បានឮថា ក្នុងថ្ងៃមហាបវារណា ព្រះបាទបសេនទិ-កោសលទ្រង់ប្រដាប់គ្រឿងរាជឥស្សរិយាកណ្ឌទាំងពួង ទ្រង់កាន់យកវត្ថុទាំងឡាយ មានគ្រឿងក្រអូបជាដើម ស្តេចទៅកាន់វិហារ ។

ក្នុងខណៈនោះ ព្រះកាឡុទាយិត្ថេរគង់ចូលឈានក្នុងទីបំផុតបរិស័ទ ។ ក៏ពាក្យថា កាឡុទាយិត្ថេរ នុ៎ះ ជាឈ្មោះរបស់ព្រះថេរៈនោះឯង ។ សរីរៈ ( របស់លោក ) មានពណ៌ដូចមាស ។ ក៏ក្នុងខណៈនោះព្រះចន្ទកំពុងរះឡើង, ព្រះ-អាទិត្យកំពុងអស្តង្គត ។

ព្រះអានន្ទត្ថេរ សម្លឹងមើលរស្មីព្រះអាទិត្យដែលកំពុងអស្តង្គត និងព្រះចន្ទដែលកំពុងរះឡើង ហើយសម្លឹងមើលសរីរោភាសរបស់ព្រះរាជា សរីរោភាសរបស់ព្រះថេរៈ និងព្រះសរីរោភាសរបស់ព្រះតថាគត ។ បណ្តាជនទាំងនោះព្រះសាស្តារមែងរុងរឿងកន្លងរស្មីទាំងពួង ។ ព្រះថេរៈថ្វាយបង្គំព្រះសាស្តាហើយ ក្រាបទូលថា “ ថ្ងៃនេះ កាលខ្ញុំព្រះអង្គ

សម្លឹងមើលរស្មីទាំងនេះ, ព្រះរស្មីរបស់ព្រះអង្គប៉ុណ្ណោះរមែង ជាទីគាប់ចិត្តរបស់ខ្ញុំព្រះអង្គ, ព្រោះថា ព្រះសរីរៈរបស់ព្រះ-អង្គ រមែងរុងរឿងកន្លងរស្មីទាំងពួង " ។

គ្រានោះ ព្រះសាស្តា ត្រាស់ទៅកាន់ព្រះអានន្ទថា " ម្នាលអានន្ទ ធម្មតាព្រះអាទិត្យរមែងរុងរឿងក្នុងវេលាថ្ងៃ, ព្រះចន្ទរមែងរុងរឿងក្នុងវេលាយប់, ព្រះរាជារមែងរុងរឿងក្នុងវេលាទ្រង់ប្រដាប់ហើយប៉ុណ្ណោះ, ព្រះខីណាស្រព លះបង់ការប្រឡូកប្រឡំដោយពួក រមែងរុងរឿងខាងក្នុងសមាបត្តិប៉ុណ្ណោះ, ចំណែកព្រះពុទ្ធ រមែងរុងរឿងដោយតេជៈ ៥ យ៉ាង ទាំងក្នុងពេលយប់ ទាំងក្នុងពេលថ្ងៃ " ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា :-

**៥ ទិវា តបតិ អាទិច្ចោ រត្តិមាភាតិ ចន្ទិមា**
**សន្នទ្ធោ ខត្តិយោ តបតិ ឈាយី តបតិ ព្រាហ្មណោ**
**អថ សព្វមហោរត្តឹ ពុទ្ធោ តបតិ តេជសា ។**

ព្រះអាទិត្យរុងរឿងក្នុងវេលាថ្ងៃ ព្រះចន្ទ
រុងរឿងក្នុងវេលាយប់ ក្សត្រទ្រង់ប្រដាប់ពេញ

យសហើយ រមែងរុងរឿង សមណព្រាហ្មណ៍
អ្នកមានឈាន រមែងរុងរឿង ឯព្រះសម្ពុទ្ធ
រមែងរុងរឿងដោយតេជះ ទាំងយប់ ទាំងថ្ងៃ ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ ពីរបទថា **ទិវា តបតិ** សេចក្តីថា ព្រះអាទិត្យរមែងរុងរឿងក្នុងវេលាថ្ងៃប៉ុណ្ណោះ, ប៉ុន្តែសូម្បីផ្លូវដែលព្រះអាទិត្យនោះទៅ រមែងមិនប្រាកដក្នុងវេលាយប់ ។

បទថា **ចន្ទិមា** សេចក្តីថា សូម្បីព្រះចន្ទដែលផុតចាកមន្ទិល មានពពកជាដើម ក៏រុងរឿងតែក្នុងវេលាយប់ប៉ុណ្ណោះ មិនរុងរឿងក្នុងវេលាថ្ងៃ ។

បទថា **សន្នទ្ធោ** សេចក្តីថា ព្រះរាជាដែលទ្រង់ប្រដាប់ដោយអាភរណៈទាំងពួង ដ៏វិចិត្រដោយមាស និងកែវមណី ដែលសេនាមានអង្គ ៤ ចោមរោមហើយ រមែងរុងរឿង, ដែលទ្រង់បិតនៅដោយភេទជាអ្នកដែលបុគ្គលដទៃមិនស្គាល់ ( បន្លំភេទ ) រមែងមិនរុងរឿង ។

បទថា **ឈាយី** សេចក្តីថា ចំណែកព្រះខីណាស្រព លះបង់ពួកគណៈហើយ អន្តុយស្ញឹងស្ញាធី រមែងរុងរឿង ។

បទថា **តេជសា** សេចក្តីថា ចំណែកព្រះសម្មាសម្ពុទ្ធ ទ្រង់គ្របសង្កត់តេជៈនៃការទ្រុស្តសីល ដោយតេជៈនៃសីល តេជៈនៃអំពើអាក្រក់ ដោយតេជៈនៃអំពើល្អ តេជៈនៃអវិជ្ជា ដោយតេជៈនៃបញ្ញា តេជៈនៃអំពើដែលមិនមែនជាបុណ្យ ដោយតេជៈនៃបុណ្យ តេជៈនៃអធម៌ ដោយតេជៈនៃធម៌ រមែងរុងរឿងដោយតេជៈ ៥ យ៉ាងនេះ រហូតអស់កាលជានិច្ច ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយ-ផលទាំងឡាយ មានសោតាបត្តិផលជាដើម ៕

( រឿងព្រះអានន្ទត្ថេរ ចប់ )

## ៦ រឿងបព្វជិតមួយរូប

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបព្វជិតមួយរូប ត្រាស់ព្រះធម្មទេសនានេះថា “**ពាហិតបាបោ** ជាដើម ។

## ព្រាហ្មណ៍បួសក្រៅព្រះពុទ្ធសាសនា

បានឮថា ព្រាហ្មណ៍ម្នាក់បួសក្រៅព្រះពុទ្ធសាសនា ហើយគិតថា “ ព្រះសមណគោតមតែងហៅសាវ័ករបស់ព្រះថា បព្វជិត, ចំណែកយើងក៏ជាបព្វជិត, ការដែលព្រះអង្គហៅយើងយ៉ាងនោះដែរ ក៏គួរ ” លុះគិតដូច្នេះហើយ ក៏ចូលទៅគាល់ព្រះសាស្តា ទូលសួរសេចក្តីនោះ ។

ព្រះសាស្តាត្រាស់ថា “ តថាគតមិនហៅថា បព្វជិតដោយហេតុត្រឹមតែប៉ុណ្ណោះទេ, ចំណែកបុគ្គលអ្នកឈ្មោះថាជាបព្វជិត ព្រោះមន្ទិលគឺកិលេសទាំងឡាយខ្លួនវៀរបានដាច់ស្រឡះហើយ ” ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា ៈ-

**៦ ពាហិតបាបោ ហិ ព្រាហ្មណោ**
**សមចរិយា សមណោតិ វុច្ចតិ**

**បព្វាជយមត្តនោ មលំ**
**តស្មា បព្វជិតោតិ វុច្ចតិ ។**

អ្នកដែលមានបាបបន្សាត់ហើយ ឈ្មោះថា ព្រាហ្មណ៍ អ្នកដែលតថាគត ហៅថា សមណៈ ព្រោះការប្រព្រឹត្តរម្ងាប់ អ្នកដែលបណ្តេញមន្ទិលនៃខ្លួន ហេតុនោះទើបតថាគត ហៅថា បព្វជិត ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **សមចរិយាយ** គឺព្រោះការប្រព្រឹត្តរម្ងាប់នូវអកុសលធម៌ទាំងពួង ។

បទថា **តស្មា** សេចក្តីថា បុគ្គលដែលព្រះសាស្តាត្រាស់ហៅថា ព្រាហ្មណ៍ ព្រោះជាអ្នកមានបាបបន្សាត់ហើយ បុគ្គលដែលព្រះសាស្តាត្រាស់ហៅថា សមណៈ ព្រោះប្រព្រឹត្តស្ងប់នូវអកុសលធម៌ទាំងឡាយ, ហេតុនោះ បុគ្គលបញ្ចេញ គឺកំចាត់មន្ទិលមានរាគៈជាដើមរបស់ខ្លួន, សូម្បី

បុគ្គលនោះ ក៏ព្រះសាស្តាត្រាស់ហៅថា បណ្ឌិត ព្រោះការបញ្ចេញនោះ ។

ក្នុងកាលចប់ទេសនា បណ្ឌិតនោះតាំងនៅក្នុងសោតាបត្តិផល, ទេសនាបានជាគុណជាតិមានប្រយោជន៍សូម្បីដល់ជនអ្នកប្រជុំគ្នាហើយ ។៚

( រឿងបណ្ឌិតមួយរូប ចប់ )

# ៧ រឿងព្រះសារីបុត្រ

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសារីបុត្រ ត្រាស់ព្រះធម្មទេសនានេះថា “ **ន ព្រាហ្មណស្ស** ” ជាដើម ។

## ព្រះថេរៈត្រូវព្រាហ្មណ៍វាយ

បានឮថា មនុស្សជាច្រើននៅក្នុងទីមួយ ពោលគុណរបស់ព្រះថេរៈថា “ឱ គួរឲ្យសរសើរក្រៃពេកណាស់ លោកម្ចាស់របស់ពួកយើង ប្រកបហើយដោយកម្លាំងគឺខន្តិ, កាលជនដទៃជេរក្ដី ប្រហារក្ដី សូម្បីហេតុត្រឹមតែសេចក្ដីក្រោធ ក៏មិនមាន ” ។

គ្រានោះ ព្រាហ្មណ៍មិច្ឆាទិដ្ឋិម្នាក់សួរថា “ បុគ្គលណាមិនចេះខឹង ” ។

ពួកមនុស្ស. ព្រះថេរៈរបស់ពួកយើង ។

ព្រាហ្មណ៍.     បុគ្គលដែលញុំាងព្រះថេរៈរបស់ឯងឲ្យក្រោធ មិនមានទេដឹង ?

ពួកមនុស្ស. ម្នាលព្រាហ្មណ៍ សេចក្តីនោះ មិនដូច្នោះទេ ។

ព្រាហ្មណ៍. បើដូច្នោះ យើងនឹងញុំាងលោកឲ្យក្រោធ។

ពួកមនុស្ស.   ប្រសិនបើអ្នកអាច,   អ្នកចូរញុំាងព្រះថេរៈឲ្យក្រោធចុះ ។

ព្រាហ្មណ៍នោះគិតថា " ណ្ហើយចុះ, យើងនឹងដឹងកិច្ចដែលគួរធ្វើ " ដូច្នេះហើយ ឃើញព្រះថេរៈចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត   ក៏ដើរទៅអំពីខាងក្រោយ   ប្រហារខ្នងព្រះថេរៈដោយបាទដៃយ៉ាងខ្លាំង ។

ព្រះថេរៈមិនបានយកចិត្តនិងការប្រហារនោះ   គិតតែនិមន្តទៅ   ។ សេចក្តីក្តៅក្រហាយកើតឡើងក្នុងសរីរៈរបស់ព្រាហ្មណ៍ទាំងអស់ ។

ព្រាហ្មណ៍នោះគិតថា " លោកម្ចាស់ដ៏ចម្រើនបរិបូណ៌ដោយគុណ " ដូច្នេះហើយ ក្រាបចុះទៀបព្រះបាទរបស់ព្រះ

ថេរៈ ហើយសូមទោសព្រះថេរៈថា “ បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់អត់ទោសឲ្យខ្ញុំព្រះករុណាផង” កាលព្រះថេរៈសួរថា “ម្នាលព្រាហ្មណ៍ តើមានបញ្ហាអ្វី ? ហេតុអ្វី ទើបអ្នកសូមទោសអាត្មា ?” ក៏ប្រាប់ថា “ខ្ញុំប្រហារលោកម្ចាស់ដើម្បីសាកល្បងមើល” ។

ព្រះថេរៈពោលថា “ណ្ហើយចុះ ព្រាហ្មណ៍ អាត្មាអត់ទោសឲ្យ” ។ ព្រាហ្មណ៍ក៏ពោលថា “បពិត្រលោកម្ចាស់ដ៏ចម្រើន ប្រសិនបើលោកម្ចាស់អត់ទោសឲ្យខ្ញុំព្រះករុណាសោត សូមលោកម្ចាស់ទទួលភិក្ខាក្នុងផ្ទះរបស់ខ្ញុំព្រះករុណាចុះ” ដូច្នេះហើយ បានទទួកយកបាត្ររបស់ព្រះថេរៈ ។

ចំណែកព្រះថេរៈឲ្យបាត្រទៅព្រាហ្មណ៍, ព្រាហ្មណ៍ក៏នាំព្រះថេរៈទៅផ្ទះអង្គាសដោយគោរព ។

ពួកមនុស្សក្រោធហើយ ម្នាក់ ៗ ក៏គិតថា “លោកម្ចាស់របស់ពួកយើងជាអ្នកមិនមាន ត្រូវព្រាហ្មណ៍នេះប្រហារហើយ, ការផុតចាកកំណាត់ឈើមិនមានដល់ព្រាហ្មណ៍នោះ, ពួកយើងនឹងសម្លាប់វាចោលក្នុងទីនេះ”

ដូច្នេះហើយ មានដុំដីនិងកំណាត់ឈើជាដើមក្នុងដៃ បានឈរជុំវិញទ្វារផ្ទះរបស់ព្រាហ្មណ៍ ។

ព្រះថេរៈក្រោកឡើងដើរទៅបានឲ្យបាត្រទៅព្រាហ្មណ៍

ពួកមនុស្សឃើញព្រាហ្មណ៍នោះ ដើរទៅជាមួយនិងព្រះថេរៈ ក៏ពោលថា "បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ទទួលយកបាត្ររបស់លោកម្ចាស់ ហើយព្រាហ្មណ៍ត្រឡប់ទៅវិញចុះ" ព្រះថេរៈពោលថា "ម្នាលឧបាសក នេះមានរឿងអ្វី ?" ។

ពួកមនុស្ស. ព្រាហ្មណ៍ប្រហារលោកម្ចាស់, ពួកខ្ញុំនឹងដឹងកិច្ចដែលគួរចំពោះគេ ។

ព្រះថេរៈ. អ្នកទាំងឡាយត្រូវព្រាហ្មណ៍នេះឬ ? ឬក៏អាត្មាត្រូវព្រាហ្មណ៍នេះប្រហារ ។

ពួកមនុស្ស. លោកម្ចាស់ត្រូវព្រាហ្មណ៍នេះប្រហារ ។

ព្រះថេរៈពោលថា "ព្រាហ្មណ៍នោះប្រហារអាត្មាហើយ ( ប៉ុន្តែ ) បានសូមទោសអាត្មាហើយ, អ្នកទាំងឡាយ

ចូរទៅវិញចុះ” បញ្ជូនពួកមនុស្សទៅហើយ ឲ្យព្រាហ្មណ៍ត្រឡប់ទៅផ្ទះ និមន្តទៅកាន់វិហារវិញ ។

ភិក្ខុទាំងឡាយលើកទោសថា “ កម្មហ្នឹងឈ្មោះអ្វី ? ព្រះសារីបុត្តត្រូវព្រាហ្មណ៍ណាប្រហារហើយ នៅទទួលភិក្ខក្នុងផ្ទះរបស់ព្រាហ្មណ៍នោះទៀត, ចាប់តាំងពីពេលដែលព្រះថេរៈត្រូវព្រាហ្មណ៍នោះប្រហារហើយ តអំពីនេះទៅ គេនឹងមិនអៀនខ្មាស ( នឹងមិនរអែង ) ចំពោះជនណាៗ, នឹងដើរវាយភិក្ខុដ៏សេស ” ។

## ព្រាហ្មណ៍មិនគួរប្រហារព្រាហ្មណ៍

ព្រះសាស្ដាស្ដេចមកហើយ ត្រាស់សួរថា “ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយកថាអ្វីហ្ន៎ ?” កាលភិក្ខុទាំងនោះក្រាបទូលថា “ ដោយកថាឈ្មោះនេះ ” ហើយ, ត្រាស់ថា “ ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ៍ឈ្មោះថាប្រហារព្រាហ្មណ៍ រមែងមិនមាន, ប៉ុន្តែសមណព្រាហ្មណ៍ត្រូវព្រាហ្មណ៍ជាគ្រហស្ថប្រហារ រមែងមាន, ឈ្មោះថា សេចក្ដីក្រោធនោះរមែងដកឡើងបានដោយអនាគាមិមគ្គ ” ដូច្នេះ

ហើយ កាលទឹងទ្រង់សម្តែងធម៌ បានទ្រង់ភាសិតព្រះគាថាទាំងនេះថា :-

៧ ន ព្រាហ្មណស្ស បហរេយ្យ នាស្ស មុញ្ចេថ ព្រាហ្មណោ
ធិ ព្រាហ្មណស្ស ហន្តារំ តតោ ធិ យស្ស មុញ្ចតិ ។
ន ព្រាហ្មណស្សេតទកិញ្ចិ សេយ្យោ
យទានិសេធោ មនសោ បិយេហិ
យតោ យតោ ហឹសមនោ និវត្តតិ
តតោ តតោ សម្មតិមេវ ទុក្ខំ ។

ព្រាហ្មណ៍ មិនគប្បីប្រហារព្រាហ្មណ៍ទេ ( ចំណែក ) ព្រាហ្មណ៍ ( ដែលត្រូវគេប្រហារហើយ ) គប្បីចងពៀរចំពោះព្រាហ្មណ៍នោះ តថាគតតិះដៀលព្រាហ្មណ៍ ដែលប្រហារព្រាហ្មណ៍ ព្រាហ្មណ៍ណា ចងពៀរចំពោះព្រាហ្មណ៍នោះ តថាគតតិះដៀលព្រាហ្មណ៍នោះក្រៃលែងជាងនោះទៅទៀត ។ ការហាមឃាត់ចិត្តចាកអារម្មណ៍ជាទីស្រឡាញ់ របស់ព្រាហ្មណ៍

នោះ មិនមែនប្រសើរបន្តិចបន្តួចទេ ចិត្តដែលគិតបៀតបៀនគេ ងាកចេញចាកវត្ថុណាៗ សេចក្តីទុក្ខព្រោះវត្ថុនោះៗ ក៏រម្ងាប់ទៅបាន ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **បហរេយ្យ** សេចក្តីថា ព្រាហ្មណ៍ជាខីណាស្រពដឹងថា " យើងជា ( ព្រះខីណាស្រព )" មិនគួរប្រហារព្រាហ្មណ៍ជាខីណាស្រព ឬព្រាហ្មណ៍ដទៃ ។

បទថា **នាស្ស មុញ្ចេថ** ព្រាហ្មណ៍ខីណាស្រពនោះត្រូវគេប្រហារហើយ មិនគួរចងពៀរចំពោះបុគ្គលអ្នកប្រហារនោះ គឺមិនគួរធ្វើសេចក្តីក្រោធចំពោះព្រាហ្មណ៍នោះ ។

បទថា **ធិ ព្រាហ្មណស្ស** សេចក្តីថា តថាគតរមែងតិះដៀលព្រាហ្មណ៍ដែលប្រហារព្រាហ្មណ៍ជាខីណាស្រព ។

បទថា **តតោ ធិ** សេចក្តីថា ក៏បុគ្គលណា ប្រហារតបបុគ្គលអ្នកប្រហារ ឈ្មោះថា ចងពៀរចំពោះបុគ្គលអ្នកប្រហារ

នោះ, គឺជាគតិះដៀលអ្នកចងពៀរនោះ ក្រៃលែងជាងអ្នកប្រហារនោះទៀត ។

បទថា **ឯតទកិញ្ចិ សេយ្យោ** សេចក្ដីថា ការមិនជេរតបបុគ្គលអ្នកជេរ ឬការមិនប្រហារតបបុគ្គលអ្នកប្រហាររបស់ព្រះខីណាស្រពណា, ការមិនជេរតប ឬការមិនប្រហារតបនោះ មិនមែនប្រសើរបន្តិចបន្តួចទេ គឺមិនមែនប្រសើរដែលមានប្រមាណតិច ដល់ព្រាហ្មណ៍ជាព្រះខីណាស្រពនោះ, ពិតណាស់ រមែងជាការប្រសើរដែលមានប្រមាណដ៏ក្រៃលែង ។

បាទព្រះគាថាថា **យទានិសេធោ មនសោ បិយេហិ** សេចក្ដីថា ក៏ការកើតឡើងនៃសេចក្ដីក្រោធ, ឈ្មោះថា អារម្មណ៍ជាទីស្រឡាញ់នៃចិត្ត របស់បុគ្គលអ្នកច្រើនទៅដោយសេចក្ដីក្រោធ, ក៏បុគ្គលអ្នកច្រើនទៅដោយសេចក្ដីក្រោធនោះធ្វើខុសចំពោះមាតាបិតាក្ដី ចំពោះព្រះពុទ្ធជាដើមក្ដី ក៏ព្រោះអាស្រ័យអារម្មណ៍ជាទីស្រឡាញ់នៃចិត្តនោះទាំងអស់, ហេតុនោះ ការហាមឃាត់ចិត្តចាកអារម្មណ៍ដែលជាទីស្រឡាញ់

ទាំងនោះ គឺគ្របសង្កត់ចិត្តដែលកើតឡើង ដោយអំណាចនៃសេចក្តីក្រោធ របស់បុគ្គលអ្នកច្រើនដោយសេចក្តីក្រោធនោះ ការហាមឃាត់នោះ មិនមែនជាការប្រសើរបន្តិចបន្តួចទេ ។

ចិត្តដែលសម្បយុត្តដោយសេចក្តីក្រោធ ឈ្មោះថា **ហីសមនោ,** ចិត្តដែលសម្បយុត្តដោយសេចក្តីក្រោធរបស់បុគ្គលនោះ កាលត្រូវដកឡើងដោយអនាគាមិមគ្គ ឈ្មោះថាងាកចេញចេញចាកវត្ថុណាៗ ។

ពីរបទថា **តតោ តតោ** សេចក្តីថា វដ្តទុក្ខសូម្បីទាំងអស់ រមែងត្រឡប់ចាកវត្ថុនោះៗ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។៚

( រឿងព្រះសារីបុត្តត្ថេរ ចប់ )

# ៨ រឿងព្រះនាងមហាបជាបតីគោតមី

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះនាងមហាបជាបតីគោតមី ត្រាស់ព្រះធម្មទេសនានេះថា “ *យស្ស កាយេន* ” ជាដើម ។

## ព្រះសាស្តាទ្រង់បញ្ញត្តគរុធម៌ ៨

សេចក្ដីពិស្ដារថា ព្រះនាងបជាបតីគោតមីព្រមដោយបរិវារទទួលគរុធម៌ ៨ ប្រការ [(១)] ដែលព្រះមានព្រះភាគទ្រង់បញ្ញត្តិហើយ ក្នុងកាលដែលរឿងមិនទាន់កើតឡើង ដូចបុរសអ្នកមានជាតិជាអ្នកប្រដាប់ទទួលកម្រងផ្កាដោយសិរសា បានឧបសម្បទាហើយ ។ ឧបជ្ឈាយ៍ ឬអាចារ្យដទៃរបស់ព្រះនាងមិនមាន ។ ក្នុងសម័យដទៃ ភិក្ខុទាំងឡាយសន្ទនាគ្នា ប្រារព្ធព្រះថេរីអ្នកឧបសម្បទាហើយយ៉ាងនោះថា “ អាចារ្យ ឬឧបជ្ឈាយ៍របស់ព្រះនាងមហាបជាបតីគោតមី រមែងមិនប្រាកដ,

( ១ ) ភិក្ខុនីសូម្បីឧបសម្បទាបាន ១០០ ហើយក៏ដោយ ក៏ត្រូវតែថ្វាយបង្គំ ក្រោក ទទួល ធ្វើអញ្ជលិកម្ម សាមីចិកម្ម ចំពោះភិក្ខុដែលទើបនឹងបានឧបសម្បទាក្នុងថ្ងៃនោះ ១, ភិក្ខុនីមិនត្រូវនៅចាំវស្សាក្នុងអាវាសដែលគ្មានភិក្ខុឡើយ ១, ភិក្ខុនី ត្រូវប្រាថ្នាធម៌ពីរប្រការ គឺសួរឧបោសថ ចូលទៅស្ដាប់ឱវាទអំពីសម្នាក់ភិក្ខុសង្ឃរាល់កន្លះខែ ១, ភិក្ខុនីនៅចាំវស្សារួចហើយត្រូវបវារណាក្នុងសម្នាក់សង្ឃទាំង ២ ពួក ១, ត្រូវគរុកាបត្តិហើយ គប្បីប្រព្រឹត្តបក្ខមានត្តក្នុងសម្នាក់សង្ឃទាំង ២ ពួក ១, ត្រូវជួយស្វែងរកឧបសម្បទាក្នុងសម្នាក់សង្ឃទាំងពីរពួកដល់សិក្ខាមានាដែល បានសិក្សាសិក្ខាក្នុងធម៌ទាំង ៦ ប្រការគ្រប់ ២ ឆ្នាំហើយ ១, មិនត្រូវជេរ មិនត្រូវប្រទេចភិក្ខុដោយបរិយាយណាមួយឡើយ ១, តាំងពីថ្ងៃដែលបានឧបសម្បទានេះទៅត្រូវតែស្ដាប់បង្គាប់ភិក្ខុ ឯភិក្ខុមិនត្រូវស្ដាប់បង្គាប់ភិក្ខុនីវិញទេ ១ ។

ព្រះនាងកាន់យកសំពត់កាសាយៈទាំងឡាយ ដោយដៃរបស់ខ្លួន ។

លុះពេលយ៉ាងនោះហើយ ភិក្ខុនីទាំងឡាយរង្កៀសរមែងមិនធ្វើឧបោសថ មិនធ្វើបវារណារួមជាមួយនឹងព្រះនាង ភិក្ខុនីទាំងនោះក្រាបទូលសេចក្តីនោះចំពោះព្រះសាស្តា ។

បុគ្គលដែលគួរហៅថាព្រាហ្មណ៍

ព្រះសាស្តា ទ្រង់ព្រះសណ្តាប់ពាក្យរបស់ភិក្ខុនីទាំងនោះហើយ ក៏ត្រាស់ថា " គរុធម៌ ៨ ប្រការ តថាគតឲ្យព្រះនាងបជាបតីគោតមីហើយ, ដូច្នេះ តថាគតជាអាចារ្យ ជាឧបជ្ឈាយ៍របស់ព្រះនាង, ឈ្មោះថា ការរង្កៀសចំពោះព្រះខីណាស្រពទាំងឡាយ អ្នកវៀរចាកទុច្ចរិតទាំងឡាយ អ្នកទាំងឡាយមិនគួរធ្វើឡើយ " ដូច្នេះហើយ កាលនឹងទ្រង់សម្តែងព្រះធម៌ទេសនា ទើបត្រាស់គាថានេះថា :-

**៨ យស្ស កាយេន វាចាយ មនសា នត្ថិ ទុក្កតំ**
**សំវុតំ តីហិ ឋានេហិ តមហំ ព្រូមិ ព្រាហ្មណំ ។**

អំពើអាក្រក់ ដោយទ្វារកាយ ទ្វារវាចា

ទ្វារចិត្ត របស់បុគ្គលណា មិនមានទេ តថាគត ហៅបុគ្គល ដែលបានសង្រួមដោយឋានទាំង ៣ នោះ ថាជាព្រាហ្មណ៍ ។

អធិប្បាយគាថា

កម្មមានទោស គឺមានទុក្ខជាកម្រៃ ដែលញ៉ាំងសត្វឲ្យទៅកាន់អបាយ ឈ្មោះថា **ទុក្កតំ** ក្នុងព្រះគាថានោះ ។

ពីរបទថា **តីហិ ឋានេហិ** សេចក្តីថា តថាគតហៅបុគ្គលអ្នកមានទ្វារបិទហើយ ដើម្បីហាមឃាត់ការចូលទៅនៃទុច្ចរិតជាដើម ដោយហេតុ ៣ មានកាយជាដើមទាំងនោះថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ៕

## ៩ រឿងព្រះសារីបុត្តត្ថេរ

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសារីបុត្តត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា “ **យម្ហា យម្ហា ធម្មំ វិជានេយ្យ** ” ជាដើម ។

## ព្រះសារីបុត្តគោរពព្រះអស្សជិអ្នកជាអាចារ្យ

បានឮថា ព្រះសារីបុត្តនោះ ចាប់ពីពេលដែលលោកស្តាប់ធម៌ក្នុងសម្នាក់ព្រះអស្សជិ ហើយបានសម្រេចសោតាបត្តិផលមក ពេលដែលលោកបានដឹងថា ព្រះថេរៈនៅក្នុងទិសណា” ក៏ផ្គងអញ្ជលីទៅទិសនោះ សឹងបែរព្រះសិរសៈទៅកាន់ទិសនោះ ។

ភិក្ខុទាំងឡាយពោលថា “ព្រះសារីបុត្តជាមនុស្សមិច្ឆាទិដ្ឋិ ដល់ពេលនេះហើយ នៅតែនមស្ការទិសទាំងឡាយទៀត” ដូច្នេះហើយ ក្រាបទូលរឿងនោះចំពោះព្រះតថាគត ។

ព្រះសាស្តាត្រាស់ឲ្យហៅព្រះថេរៈមកហើយ ត្រាស់សួរថា “ម្នាលសារីបុត្ត បានឮថា អ្នកតែងតែនមស្ការនូវទិសទាំងឡាយពិតមែនឬ ?” កាលព្រះថេរៈក្រាបទូលថា “បពិត្រព្រះអង្គ មានតែព្រះអង្គមួយព្រះអង្គប៉ុណ្ណោះ រមែង

ទ្រង់ជ្រាបថា ខ្ញុំព្រះអង្គនមស្សការទិសទាំងឡាយ ឬក៏មិននមស្សការទាំងឡាយ ?" ដូច្នេះហើយ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ សារីបុត្តមិននមស្សការទិសទាំងឡាយទេ, ប៉ុន្តែព្រោះសារីបុត្តស្តាប់ធម៌អំពីសម្នាក់អស្សជិត្ថេរ ហើយបានសម្រេចសោតាបត្តិផល ទើបដេកបែរសីរសៈទៅខាងទិសអាចារ្យរបស់ខ្លួន, ដ្បិតថា ភិក្ខុអាស្រ័យអាចារ្យណា រមែងដឹងនូវធម៌, ភិក្ខុនោះគប្បីនមស្សការអាចារ្យនោះដោយគោរពដូចព្រាហ្មណ៍គោរពភ្លើងដូច្នោះ" ដូច្នេះហើយ កាលនឹងទ្រង់សម្តែងព្រះធម៌ ទើបត្រាស់ព្រះគាថានេះថា ៖-

## អធិប្បាយគាថា

**៩ យម្ហា ធម្មំ វិជានេយ្យ សម្មាសម្ពុទ្ធទេសិតំ**
**សក្កច្ចំ តំ នមស្សេយ្យ អគ្គិហុត្តំវ ព្រាហ្មណោ ។**

បុគ្គលចេះធម៌អាថ៌ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងហើយ អំពីសម្នាក់គ្រូណា គប្បីនមស្ការគ្រូនោះ ដោយគោរព ដូចព្រាហ្មណ៍ដែលគោរពការបូជាភ្លើង ដូច្នោះដែរ ។

បណ្ដាបទទាំងនោះ បទថា **អគ្គិហុត្តំ វ** សេចក្ដីថា បុគ្គលដឹងច្បាស់នូវធម៌ដែលព្រះតថាគត ទ្រង់សំដែងហើយ អំពីសំណាក់គ្រូណា, គប្បីនមស្ការគ្រូនោះដោយគោរព ដូចព្រាហ្មណ៍ដែលគោរពការបូជាភ្លើង ដោយការបំរើដោយល្អ និងដោយកិច្ចទាំងឡាយមានអញ្ជលីកម្មជាដើមដូច្នោះដែរ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

រឿងព្រះសារីបុត្តត្ថេរ ចប់

## ១០ រឿងព្រាហ្មណ៍ជដិល

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធជដិលម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា “**ន ជដាហិ**” ជាដើម ។

## ជដិលចង់ឲ្យព្រះសាស្តាត្រាស់ហៅខ្លួនថាជាព្រាហ្មណ៍

បានឮថា ជដិលព្រាហ្មណ៍នោះគិតថា “យើងជាអ្នកកើតដោយល្អហើយ ទាំងខាងមាតា ទាំងខាងបិតា កើតក្នុងត្រកូលព្រាហ្មណ៍, ប្រសិនបើព្រះសមណគោតមត្រាស់ហៅសាវករបស់ព្រះអង្គថា ព្រាហ្មណ៍, ការដែលព្រះអង្គត្រាស់ហៅយើងយ៉ាងនោះដែរ ក៏គួរ” ដូច្នេះហើយ ក៏ចូលទៅកាន់សម្នាក់ព្រះសាស្តា ក្រាបទូលសួរសេចក្តីនោះ ។

## លក្ខណៈរបស់ព្រាហ្មណ៍

គ្រានោះ ព្រះសាស្តាទៅកាន់ព្រាហ្មណ៍នោះថា “ម្នាលព្រាហ្មណ៍ តថាគតមិនហៅថា ព្រាហ្មណ៍ដោយហេតុត្រឹមតែជដា ដោយហេតុត្រឹមតែជាតិនិងគោត្រទេ, ប៉ុន្តែតថាគតហៅ

អ្នកត្រាស់ដឹងសច្ចធម៌ហើយប៉ុណ្ណោះថា "ជាព្រាហ្មណ៍" ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា ៖-

**១០ ន ជដាហិ ន គោត្តេហិ ន ជច្ចា ហោតិ ព្រាហ្មណោ**
**យម្ហិ សច្ចញ្ច ធម្មោ ច សោ សុចី សោ ច ព្រាហ្មណោ ។**

បុគ្គលដែលឈ្មោះថា ព្រាហ្មណ៍ព្រោះផ្នួងសក់ក៏មិនមែន ព្រោះគោត្រ ក៏មិនមែន ព្រោះជាតិ ក៏មិនមែន សច្ចៈផង ធម៌ផង មានក្នុងបុគ្គលណា បុគ្គលនោះឈ្មោះថា អ្នកស្អាតផង បុគ្គលនោះឈ្មោះថា ព្រាហ្មណ៍ផង ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **សច្ចំ** ជាដើម សេចក្ដីថា សច្ចញ្ញាណដែលចាក់ធ្លុះនូវសច្ចៈ ៤ យ៉ាង ដោយអាការ ១៦ ហើយតាំងនៅ និងលោកុត្តរធម៌ ៩ មានក្នុងបុគ្គលណា, បុគ្គលនោះជាអ្នកស្អាត និងជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

រឿងជដិលព្រាហ្មណ៍ ចប់

# ១១ រឿងព្រាហ្មណ៍អ្នកនិយាយកុហក

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅឯកូដាគារសាលា ទ្រង់ប្រារព្ធព្រាហ្មណ៍អ្នកកុហកម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា " **កិន្តេ** " ជាដើម ។

បានឮថា ព្រាហ្មណ៍នោះឡើងដើមថ្ងាន់មួយដើមដែលក្បែរទ្វារព្រះនគរវេសាលី យកជើងទាំងពីរតោងមែកថ្ងាន់សំយុងក្បាលចុះហើយ ពោលថា "អ្នកទាំងឡាយចូរឲ្យគោក្រហម ១០០ ដល់យើង ចូរឲ្យកហាបណៈទាំងឡាយដល់យើង ចូរឲ្យស្រ្តីបំរើដល់យើង, ប្រសិនបើអ្នកទាំងឡាយមិនឲ្យទេ, យើងនឹងទម្លាក់ខ្លួនចុះអំពីដើមឈើនេះឲ្យស្លាប់ នឹងធ្វើព្រះនគរមិនឲ្យជាព្រះនគរ"ភិក្ខុទាំងឡាយឃើញព្រាហ្មណ៍នោះ ក្នុងកាលជាទីស្តេចចូលទៅកាន់នគរនៃព្រះតថាគតដែលពួកភិក្ខុចោមរោមហើយ សូម្បីក្នុងកាលដែលស្តេច

បេញអំពីនគរ ភិក្ខុទាំងឡាយក៏ឃើញព្រាហ្មណ៍នោះសំយុង ក្បាលចុះដូច្នោះដែរ ។

ចំណែកអ្នកនគរក៏គិតថា“ព្រាហ្មណ៍នេះសំយុងក្បាល ចុះយ៉ាងនេះ តាំងអំពីព្រឹក គេនឹងធ្លាក់ស្លាប់ហើយ ធ្វើព្រះ នគរមិនឲ្យជាព្រះនគរ” ខ្លាចការវិនាសទៅនៃព្រះនគរ ទើប យលព្រមថា “ពួកយើងនឹងឲ្យវត្ថុគ្រប់យ៉ាងដែលព្រាហ្មណ៍ នោះសូម” លុះគិតដូច្នោះហើយ ក៏បានឲ្យវត្ថុគ្រប់យ៉ាងទៅ ព្រាហ្មណ៍ ។ ព្រាហ្មណ៍បានទទួលយកវត្ថុគ្រប់យ៉ាងហើយ ចៀសចេញទៅ ។

ភិក្ខុទាំងឡាយ ឃើញព្រាហ្មណ៍ដើរទៅមានអាការដូច មេគោជិតឧបចារវិហារ ចាំបាន ក៏សួរថា “ម្នាលព្រាហ្មណ៍ អ្នកបានវត្ថុតាមសេចក្ដីប្រាថ្នាហើយឬ ?” បានស្ដាប់ថា “ព្រះ ករុណា លោកម្ចាស់” ទើបក្រាបទូលរឿងនោះចំពោះព្រះ សាស្ដាខាងក្នុងវិហារ ។

## ព្រះសាស្ដាត្រាស់បុព្វកម្មរបស់ព្រាហ្មណ៍

ព្រះសាស្ដាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ៍នោះជាចោរឆបោកអ្នកដទៃតែក្នុងកាលនេះប៉ុណ្ណោះ ក៏ទេ, សូម្បីក្នុងកាលមុន ក៏ជាចោរឆបោកអ្នកដទៃដែរ, ក៏ពេលនេះព្រាហ្មណ៍នោះកុហកឆបោកជនពាលបាន, ប៉ុន្តែក្នុងកាលនោះមិនអាចកុហកឆបោកបណ្ឌិតទាំងឡាយបាន" ដូច្នេះហើយ កាលដែលភិក្ខុទាំងនោះក្រាបទូលអារាធនាហើយ ក៏ទ្រង់នាំអតីតទានមក ( ត្រាស់ ) ថា ៖-

ក្នុងអតីតកាល មានតាបសអ្នកកុហកម្នាក់ នៅក្នុងកាសិកគ្រាម ។ ហើយត្រកូលដែលបំរើតាបសនោះ តែងតែឲ្យចំណែកមួយអំពីវត្ថុដែលបុគ្គលគប្បីទំពាស៊ី និងវត្ថុដែលបុគ្គលគប្បីបរិភោគ ដែលកើតឡើងក្នុងវេលាថ្ងៃដល់តាបសនោះ ដូចឲ្យដល់បុត្ររបស់ខ្លួន, ទុកដាក់ចំណែកដែលកើតឡើងក្នុងវេលាល្ងាចជូនតាបសនោះក្នុងថ្ងៃទីពីរ ។

ថ្ងៃមួយ ត្រកូលនោះបានសាច់ទន្សងក្នុងវេលាល្ងាចចំអិនឲ្យល្អហើយ ដួសមួយចំណែកទុកដើម្បីជូនតាបសនោះក្នុងថ្ងៃទីពីរ ។ តាបសនោះបរិភោគសាច់ទន្សងនោះភ្លាម ក៏

ត្រូវចំណានក្នុងរស្សរូបរីតហើយ សួរថា “នៃអ្នកទាំងឡាយ សាច់នេះ ជាសាច់អ្វី ?” បានដឹងថា “សាច់ទន្សង” ដូច្នេះ ហើយ ក៏ត្រាច់ទៅដើម្បីភិក្ខា ទទួលយកទឹកដោះស្រស ទឹកដោះជូរ និងគ្រឿងហឹរជាដើម ទៅកាន់បណ្ណសាលាហើយទុកដាក់ក្នុងទីដ៏សមគួរមួយ ។

ក៏ស្តេចទន្សងនៅក្នុងជំបូកមួយ ដែលនៅមិនឆ្ងាយអំពីបណ្ណសាលានោះ ។ ស្តេចទន្សងនោះតែងតែមកថ្វាយបង្គំតាបសនោះតាមកាលដ៏សមគួរ ។

ក៏ក្នុងថ្ងៃនោះ តាបសនោះគិតថា “យើងនឹងសម្លាប់ទន្សងនោះ” ដូច្នេះហើយ លាកដំបងទុកហើយ អង្គុយធ្វើដូចជាលក់នៅក្បែរជំបូកនោះ ។

ទន្សងចេញចាកជំបូកហើយ មកកាន់សម្នាក់តាបស កំណត់អាការបានហើយ ក៏ត្រឡប់អំពីទីនោះដោយគិតថា “ថ្ងៃនេះ យើងមិនពេញចិត្តនិងអាការរបស់អាចារ្យ” ។

តាបសដឹងថាទន្សងនោះត្រឡប់ទៅដូច្នោះ ក៏ទាញដំបងគ្រវែងទៅ ប្រាថ្នានឹងសម្លាប់ទន្សងនោះ ។ ដំបងនោះ

ផ្ទាតខុសទៅ ។ ទន្សោងចូលទៅកាន់ដំបូលហើយ អើតក្បាល
ចេញអំពីដំបូកហើយ ក្រឡេងមើលផ្លូវដែលខ្លួនមក ពោល
ទៅកាន់តាបសថា ៖-

ខ្ញុំស្មានអ្នកថាជាសមណៈ បានចូលទៅរកអ្នក
ជាអ្នកមិនសង្រួម អ្នកនោះប្រហារខ្ញុំដោយដំបង
ដូចមនុស្សមិនមែនជាសមណៈដែរ ។
ម្នាលតាបសកម្ញៅ ប្រយោជន៍អ្វីដោយផ្នួងសក់
របស់អ្នក ប្រយោជន៍អ្វីដោយស្បែកខ្លាឃ្មុំរបស់
អ្នក ខាងក្នុងរបស់អ្នកសាំញាំដោយកិលេស អ្នក
ដុសរំលីងតែសរីរៈខាងក្រៅ ។

គ្រានោះ តាបសដើម្បីនឹងល្បួងទន្សោងនោះ ដោយវត្ថុ
នៃខ្លួន បើពោលយ៉ាងនេះ ៖-

នែទន្សោង ឯងចូរមកណេះ
ឯងត្រឡប់មកវិញ ចូរបរិភោគបាយស្រូវសាលីចុះ
ប្រេងនិងអម្បិលរបស់អញក៏មាន ដីប្លីរបស់អញក៏
មានច្រើន ។

ទន្ទ្រងស្ដាប់ពាក្យនោះហើយ ពោលតបថា "លោកពោលដោយប្រការណាៗ, ការដែលយើងជាអ្នកមានសេចក្ដីប្រាថ្នានឹងរត់ទៅ រមែងមានដោយប្រការនោះៗដែរ" ដូច្នេះហើយ ពោលគាថានេះថា ៈ-

ខ្ញុំនោះនឹងចូលទៅរកដំបូកដំរៅ
១០០ ជួរបុរសយ៉ាងក្រៃលែង ថ្វីបើអ្នកឯងមាន
ប្រេងនិងអម្បិល ដីប្ចីរបស់អ្នកមិនជាប្រយោជន៍
ដល់ខ្ញុំឡើយ ។

លុះពោលយ៉ាងនោះហើយ ក៏ពោលថា "យើងបានសម្គាល់លោកថា ជាសមណៈអស់កាលមានប្រមាណប៉ុណ្ណោះ, ឥឡូវនេះ លោកត្រូវវែងដំបងទៅ ព្រោះប្រាថ្នានឹងសម្លាប់ខ្ញុំ, ដូច្នោះ លោកមិនមែនជាសមណៈចាប់ពីពេលនោះមក, ប្រយោជន៍អ្វីដោយជដាទាំងឡាយរបស់បុគ្គលអ្នកមានបញ្ញាត្រូវទោសប្រទូស្តហើយដូចជាអ្នក, ប្រយោជន៍អ្វីដោយការគ្រងដណ្ដប់ស្បែកខ្លាឃ្មុំទាំងក្រចក ។ ដ្បិតថា

ខាងក្នុងរបស់អ្នកសាំញាំដោយកិលេសខ្លាំងណាស់, អ្នកបោសរំលីងតែខាងក្រៅប៉ុណ្ណោះ" ។

ព្រះសាស្តា លុះទ្រង់នាំអតីតនិទាននេះមកហើយ ទ្រង់ត្រាស់ថា "ព្រាហ្មណ៍នេះ បានជាតាបសកុហកក្នុងកាលនោះ, ចំណែកស្តេចទន្សង បានជាតថាគតនេះឯង" ដូច្នេះ ហើយទ្រង់ប្រមូលជាតក កាលនឹងទ្រង់សម្តែងហេតុដែលតាបសនោះ ត្រូវទន្សងដ៏ឈ្លាសវៃគ្របសង្កត់ក្នុងកាលនោះ ទើបត្រាស់ព្រះគាថានេះថា ៖-

១១ កិន្តេ ជដាហិ ទុម្មេធ កិន្តេ អជិនសាដិយា
អព្ភន្តរន្តេ គហនំ ពហិរំ បរិមជ្ជសិ ។

នែអ្នកអប្បប្រាជ្ញាអើយ អ្នកមានប្រយោជន៍អ្វី ដោយការទុកជ្ជដសក់ អ្នកមានប្រយោជន៍អ្វី ដោយការទ្រទ្រង់សំពត់ស្បែកខ្លា បើសន្តានខាងក្នុងរបស់អ្នក សឹងសាំញាំដោយរាគាទិក្កិលេស អ្នកឈ្មោះថា ដុសខាត់តែខាងក្រៅទេ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ ពីរបទថា **កិន្តេ ជដាហិ** សេចក្ដីថា នៃបុគ្គលអ្នកអប្បបញ្ញាអើយ ប្រយោជន៍អ្វីដោយជដាទាំងនេះ សូម្បីអ្នកចងដោយល្អហើយ និងដោយសំពត់សាជកដែលធ្វើដោយស្បែកខ្លាឃ្មុំព្រមទាំងក្រចក ដែលអ្នកស្លៀកដណ្ដប់នោះ ។

បទថា **អព្ភន្តរំ** សេចក្ដីថា ខាងក្នុងសន្ដានរបស់អ្នកសាំញាំទៅដោយកិលេសមានរាគៈជាដើម, អ្នកដុសខាត់តែខាងក្រៅប៉ុណ្ណោះ ដូចជាអាចម៍ដំរី អាចម៍សេះដូច្នោះ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិជាដើម ។

រឿងកុហកព្រាហ្មណ៍ ចប់

## ១២ រឿងនាងកិសាគោតមី

### សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងកិសាគោតមី ត្រាស់ព្រះធម្មទេសនានេះថា **“បំសុកូលធរំ”** ជាដើម ។

### នាងគោតមីឃើញសក្កទេវរាជ

បានឮថា ក្នុងកាលនោះសក្កទេវរាជចូលទៅគាល់ព្រះសាស្ដា មួយអន្លើដោយទេវបរិស័ទ ក្នុងកាលជាទីបំផុតនៃ

បឋមយាម ថ្វាយបង្គំហើយ ទ្រង់គង់ស្តាប់សារាណីយធម៌ក្នុងទីដ៏សមគួរមួយ ។

ក្នុងខណៈនោះ នាងកិសាគោតមីគិតថា "យើងនឹងគាល់ព្រះសាស្តា" ហោះមកតាមអាកាស ឃើញសក្កទេវរាជក៏ត្រឡប់ទៅវិញ សក្កទេវរាជទ្រង់ទតឃើញនាងដែលថ្វាយបង្គំព្រះសាស្តាហើយ ត្រឡប់ទៅវិញ ក៏ទូលសួរព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនីនោះឈ្មោះអ្វី ? គ្រាន់តែក្រឡេកឃើញខ្ញុំព្រះអង្គភ្លាម ក៏ត្រឡប់ទៅវិញ"

## នាងកិសាគោតមីជាកំពូលផ្នែក ខាងទ្រទ្រង់សំពត់បង្សុកូល

ព្រះសាស្តាត្រាស់ថា "មហាបពិត្រ ភិក្ខុនីនោះ ឈ្មោះកិសាគោតមី ជាធិតារបស់តថាគត ជាកំពូលនៃព្រះថេរីអ្នកទ្រទ្រង់សំពត់បង្សុកូលទាំងឡាយ" ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា ៖-

**១២ បំសុកូលធរំ ជន្តុំ កិសន្ធមនិសន្ថតំ**
**ឯកំ វនស្មឹ ឈាយន្តំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគតហៅ បុគ្គលអ្នកទ្រទ្រង់សំពត់
បំសុកូល មានកាយស្គម មានខ្លួនរវាមដោយ
សរសៃ ជាបុគ្គលឯកឯង ចម្រើនឈានក្នុងព្រៃ
នោះ ថាជាព្រាហ្មណ៍ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **កិសំ** សេចក្ដីថា ក៏ជនទាំងឡាយអ្នកទ្រទ្រង់សំពត់បង្សុកូល ញ៉ាំងបដិបទាដែលសមគួរដល់ខ្លួនឲ្យពេញ រមែងជាអ្នកមានសាច់និងលោហិតតិច និងជាអ្នកមានខ្លួនរវាមដោយសរសៃ, ហេតុនោះ ទើបព្រះសាស្ដាត្រាស់យ៉ាងនោះ ។

ពីរបទថា **ឯកំ វនស្មឹ** សេចក្ដីថា តថាគតហៅបុគ្គលតែឯកឯង ចម្រើនឈានក្នុងទីស្ងាត់នោះថា ជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

រឿងកិសាគោតមី ចប់

## ១៣ រឿងព្រាហ្មណ៍ម្នាក់

### សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា “ **ន ចាហំ** ” ជាដើម ។

## ព្រាហ្មណ៍ចូលគាល់ព្រះសាស្ដា

បានឮថា ព្រាហ្មណ៍នោះគិតថា "ព្រះសមណគោតម ត្រាស់ហៅសាវកទាំងឡាយរបស់ព្រះអង្គថា ព្រាហ្មណ៍, ចំណែកយើងក៏ជាអ្នកកើតក្នុងកំណើតព្រាហ្មណ៍ដែរ, ការដែលព្រះអង្គត្រាស់ហៅយើងយ៉ាងនោះដែរ រមែងគួរ" ដូច្នេះហើយ ចូលទៅគាល់ព្រះសាស្ដា ទូលសួរសេចក្ដីនោះ ។

## លក្ខណៈរបស់ព្រាហ្មណ៍

គ្រានោះ ព្រះសាស្ដាត្រាស់ទៅកាន់ព្រាហ្មណ៍នោះថា "ម្នាលព្រាហ្មណ៍ តថាគតមិនហៅថា ព្រាហ្មណ៍ ដោយហេតុត្រឹមតែកើតក្នុងកំណើតព្រាហ្មណ៍ប៉ុណ្ណោះទេ, ចំណែកបុគ្គលណាមិនមានកិលេសជាគ្រឿងកង្វល់ មិនប្រកាន់មាំ, តថាគតហៅអ្នកនោះថា ជាព្រាហ្មណ៍" ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា ៖-

**១៣ ន ចាហំ ព្រាហ្មណំ ព្រូមិ យោនិជំ មត្តិសម្ភវំ**
**ភោវាទី នាម សោ ហោតិ ស វេ ហោតិ កិញ្ចនោ**
**អកិញ្ចនំ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគតនឹងហៅអ្នកកើត អំពីកំណើត អ្នកកើតក្នុងផ្ទៃនៃព្រាហ្មណីជាមាតា ថាជាព្រាហ្មណ៍ ក៏ទេ បុគ្គលនោះគ្រាន់តែបាននាមថា ភោវាទី ( អ្នកពោលថាចម្រើន ) ព្រោះបុគ្គលនោះឯង ជាអ្នកមានកិលេសគ្រឿងកង្វល់នៅឡើយ តថាគតហៅបុគ្គលអ្នកមិនមានកិលេសគ្រឿងកង្វល់ អ្នកមិនមានសេចក្តីប្រកាន់មាំនោះឯង ថាជាព្រាហ្មណ៍ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **យោនិជំ** សេចក្តីថា អ្នកកើតអំពីកំណើត ។

បទថា **ភោវាទី** សេចក្តីថា ក៏បុគ្គលនោះគេតែងពោលថា "អ្នកចម្រើន អ្នកចម្រើន" ក្នុងកាលទាំងឡាយ មានកាលជាទីហៅគ្នាជាដើម រមែងជាអ្នកមានឈ្មោះថា ភោវាទី, បុគ្គលនោះឯង ជាអ្នកនៅមានកិលេសជាគ្រឿងកង្វល់ទាំងឡាយ មានរាគៈជាដើម, ប៉ុន្តែតថាគតហៅបុគ្គលអ្នកមិនមាន

កិលេសជាគ្រឿងទាំងឡាយ មានរាគៈជាដើម អ្នកមិនប្រកាន់មាំដោយឧបាទាន ៤ ថា ជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ព្រាហ្មណ៍នោះបានសម្រេចសោតាបត្តិផល ។ ទេសនាបានជាកថាមានប្រយោជន៍សូម្បីដល់មហាជនដែលមកប្រជុំគ្នាក្នុងទីនោះ ។

រឿងព្រាហ្មណ៍ម្នាក់ ចប់

## ១៤ រឿងឧគ្គសេន

### សេចក្ដីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសេដ្ឋីបុត្រឈ្មោះឧគ្គសេន ត្រាស់ព្រះធម្មទេសនានេះថា **“សព្វសញ្ញោជនំ”** ជាដើម ។

## ព្រះអរហន្តរមែងមិនខ្លាច

រឿងខ្ញុំម្ចាស់ឲ្យពិស្តារហើយ ក្នុងអដ្ឋកថានៃព្រះគាថាថា **“មុញ្ច បុរេ មុញ្ច បច្ឆតោ”** ជាដើមនោះឯង ។

ក៏ក្នុងកាលនោះ ព្រះសាស្តា កាលភិក្ខុទាំងឡាយក្រាបទូលថា “បពិត្រព្រះអង្គដ៏ចម្រើន ព្រះឧគ្គសេនតែងតែពោលថា យើងមិនខ្លាច, ប្រហែលជាព្យាករណ៍ ( ពោលអួត ) ព្រះអរហត្តផលដោយពាក្យមិនពិតទេដឹង”, ទើបទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ បុគ្គលដូចជាបុត្តរបស់តថាគត ដែលមានសំយោជនៈកាត់ផ្តាច់បានហើយ រមែងមិនខ្លាចឡើយ” ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា ៖-

**១៤ សព្វសំ យោជនំ ឆេត្វា យោ វេ ន បរិតស្សតិ**
**សង្គាតិគំ វិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា កាត់សំយោជនៈទាំងអស់បាន
មិនតក់ស្លុត តថាគតហៅបុគ្គលនោះ ដែលគ្មាន

កិលេសជាគ្រឿងចំពាក់ អ្នករួចស្រឡះចាក
កិលេស ថាជាព្រាហ្មណ៍ ។

**អធិប្បាយគាថា**

បណ្ដាបទទាំងនោះ បទថា **សព្វសញ្ញោជនំ** បានដល់សំយោជនៈ ១០ យ៉ាង ។

បទថា **ន បរិតស្សតិ** បានដល់ រមែងតក់ស្លុតព្រោះតណ្ហា ។

បទថា **តម្ហំ** កាត់បទជា **តំ អហំ** សេចក្ដីថា តថាគតហៅបុគ្គលនោះ ដែលជាអ្នកគ្មានកិលេសគ្រឿងចំពាក់ ព្រោះកិលេសគ្រឿងចំពាក់ទាំងឡាយ មានរាគៈជាដើម ឈានកន្លងបានហើយ អ្នករួចស្រឡះហើយ ព្រោះមិនមានយោគៈ ៤ ថា ជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

រឿងឧគ្គសេន ចប់

**១៥ រឿងព្រាហ្មណ៍ពីរនាក់**

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ ២ នាក់ ត្រាស់ព្រះធម្មទេសនានេះថា "**ឆេត្វា នទ្ធឹ** ជាដើម ។

## ព្រាហ្មណ៍ពីរនាក់យកគោជល់គ្នា

បានឮថា ព្រាហ្មណ៍ទាំងពីរនាក់នោះ ព្រាហ្មណ៍ម្នាក់មានគោឈ្មោះថា ចូឡរោហិត, ម្នាក់ទៀតមានគោឈ្មោះថា មហារោហិត ។

ថ្ងៃមួយ ព្រាហ្មណ៍ទាំងពីររូបនោះជជែកគ្នាថា "គោរបស់អ្នកមានកម្លាំងខ្លាំងជាង ឬក៏គោរបស់យើងមានកម្លាំងជាង" ដូច្នេះហើយ ម្នាក់ៗពោលថា "ប្រយោជន៍អ្វីដោយការជជែកគ្នារបស់យើងទាំងពីររូបនោះ, យើងឲ្យគោជល់គ្នាហើយ នឹងដឹង" ញ៉ាំងរទេះឲ្យពេញដោយដីខ្សាច់នាឆ្នេរស្ទឹងអចិរវតី ហើយទឹមគោ ។

គ្រានោះ ភិក្ខុទាំងឡាយក៏បានទៅកាន់ទីនោះ ដើម្បីផ្ទុតទឹក ។ ព្រាហ្មណ៍ទាំងពីររូបនោះបរទេះទៅ ។ រទេះបានឈប់នៅស្ងៀម, ពួរនិងព្រ័ត្រទាំងឡាយបានដាច់ ។

ភិក្ខុទាំងឡាយឃើញហើយ ទៅកាន់វិហារ ក្រាបទូលសេចក្ដីនោះចំពោះព្រះសាស្ដា ។

## គួរកាត់ពួរនិងព្រ័ត្តខាងក្នុង

ព្រះសាស្ដាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ពួរនិងព្រ័ត្រនោះជារបស់ខាងក្រៅទេ, បុគ្គលណាក៏ដោយ ក៏កាត់ពួរនិងព្រ័ត្រទាំងនោះបានដែរ, ចំណែកភិក្ខុណាកាត់ពួរ គឺសេចក្ដីក្រោធ និងព្រ័ត្តគឺតណ្ហាដែលប្រព្រឹត្តទៅខាងក្នុងគួរ" ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា ៖-

**១៥ ឆេត្វា នទ្ធឹ វរត្តញ្ច សន្ទានំ សហនុក្កមំ**
**ឧក្ខិត្តបលិឃំ ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគតហៅបុគ្គលដែលកាត់សេចក្ដីក្រោធ
ដូចពួរផង កាត់តណ្ហា ដូចព្រ័ត្រផង កាត់ទិដ្ឋិ
៦២ ដូចទឹក ព្រមទាំងអនុស័យ ដូចអ្នកដើរ

តាមផង អ្នកមានអវិជ្ជា ដូចសសរខឿន ដក
បោលហើយ អ្នកត្រាស់ដឹងសច្ចៈ ៤ នោះឯង
ថាជាព្រាហ្មណ៍ ។

**អធិប្បាយគាថា**

បណ្ដាបទទាំងនោះ បទថា **នទ្ធឹ** បានដល់ សេចក្ដីក្រោធដែលប្រព្រឹត្តទៅដោយការៈជាគ្រឿងរួបរឹត ។

បទថា **វរត្តំ** បានដល់ តណ្ហាដែលប្រព្រឹត្តដោយការៈជាគ្រឿងចង ។

បាទព្រះគាថាថា **សន្ទានំ សហានុក្កមំ** ជាដើម សេចក្ដីថា តថាគតហៅបុគ្គលអ្នកកាត់ទីតគឺទិដ្ឋិ ៦២ ដែលប្រកបដោយខ្សែគឺអនុស័យទាំងអស់នេះហើយឋិតនៅ អ្នកដែលមានគន្លឹះដកចេញហើយ ព្រោះគន្លឹះគឺអវិជ្ជាជាធម្មជាតដែលខ្ទនដកឡើងហើយ អ្នកដែលត្រាស់ដឹងហើយ ព្រោះត្រាស់ដឹងសច្ចៈទាំង ៤ នោះថា ជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ភិក្ខុ ៥០០ រូបបានសម្រេចព្រះអរហត្តផល ។ ទេសនាបានជាកថាមានប្រយោជន៍សូម្បីដល់មហាជនដែលប្រជុំគ្នានៅទីនោះ ។

រឿងព្រាហ្មណ៍ពីររូប ចប់

## ១៦ រឿងអក្កោសកភារទ្វាជព្រាហ្មណ៍

### សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធអក្កោសកភារទ្វាជព្រាហ្មណ៍ ត្រាស់ព្រះធម្មទេសនានេះថា "**អក្កោសំ**" ជាដើម ។

### នាងធនញ្ជានីត្រូវជេរ

សេចក្តីពិស្តារថា នាងព្រាហ្មណីឈ្មោះធនញ្ជានីដែលជាភរិយារបស់ភារទ្វាជព្រាហ្មណ៍ ជាបងប្រុសរបស់អក្កោសកភារទ្វាជព្រាហ្មណ៍ ជាសោតាបន្ន។ នាងធនញ្ជានីនោះ កណ្តាស់ក្តី ក្អកក្តី ភ្លាត់មាត់ក្តី តែងតែបន្លឺឧទានថា "**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** (វីកិរិយានមស្សការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មាន

ព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃ ចំពោះព្រះអង្គ ឥតគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ)" ។

ថ្ងៃមួយ ក្នុងវេលាអង្គាសពួកព្រាហ្មណ៍ នាងភ្លាត់មាត់ហើយ បន្លឺវាចាឡើងយ៉ាងនោះឯង ដោយសំឡេងដ៏ខ្លាំង ។

ព្រាហ្មណ៍ក្រោធហើយ ពោលថា "នែស្រីចង្រៃ នាងភ្លាត់មាត់ទីណាមួយហើយ តែងពោលសរសើរព្រះសមណៈត្រងោលនោះយ៉ាងនេះគ្រប់ទីកន្លែង" ដូច្នេះហើយ ពោលថា "នែស្រីចង្រៃ ឥឡូវនេះយើងនឹងទៅលើកវាទៈចំពោះសាស្ដារបស់នាង" ។

គ្រានោះ នាងក៏ពោលទៅកាន់ព្រាហ្មណ៍នោះថា "នែព្រាហ្មណ៍ សូមលោកអញ្ជើញទៅចុះ, ខ្ញុំមិនដែលឃើញបុគ្គលអ្នកអាចលើកវាទៈចំពោះព្រះមានព្រះភាគអង្គនោះបានឡើយព្រាហ្មណ៍ចុះ ប្រសិនបើលោកចូលទៅហើយ សូមលោកទូលសួរបញ្ហាចំពោះព្រះមានព្រះភាគចុះ" ព្រាហ្មណ៍នោះទៅកាន់សម្នាក់ព្រះមានព្រះភាគហើយ មិនថ្វាយបង្គំព្រះ

មានព្រះភាគទេ បានឈរនៅក្នុងទីដ៏សមគួរមួយ, កាលនឹងទូលសួរបញ្ហា ទើបពោលគាថានេះថា ៖-

បុគ្គលសម្លាប់អ្វីបាន ទើបដេកនៅជាសុខ សម្លាប់អ្វីបាន ទើបមិនសោក បពិត្រព្រះគោតម ព្រះអង្គគាប់ព្រះហឫទ័យ ចំពោះការសម្លាប់ធម៌ឯង តើធម៌អ្វី ? ។

គ្រានោះ ព្រះសាស្ដា កាលនឹងទ្រង់ព្យាករណ៍បញ្ហារបស់ព្រាហ្មណ៍នោះ ទើបត្រាស់ព្រះគាថានេះថា ៖-

បុគ្គលសម្លាប់សេចក្ដីក្រោធបាន ទើបដេកនៅជាសុខ សម្លាប់សេចក្ដីក្រោធបាន ទើបមិនសោក ម្នាលព្រាហ្មណ៍ ព្រះអរិយៈទាំងឡាយ តែងសរសើរការសម្លាប់សេចក្ដីក្រោធ ដែលមានគល់ជាពិស មានចុងដ៏ផ្អែម លុះតែសម្លាប់សេចក្ដីក្រោធនោះបាន ទើបមិនសោក ។

ព្រាហ្មណ៍ ៤ នាក់បានសម្រេចព្រះអរហត្តផល

ព្រាហ្មណ៍នោះជ្រះថ្លាចំពោះព្រះសាស្ដា បួសហើយបានសម្រេចព្រះអរហត្ត ។

គ្រានោះ អក្កោសកភារទ្វាជព្រាហ្មណ៍ដែលជាប្អូនប្រុសរបស់ភារទ្វាជព្រាហ្មណ៍នោះ បានស្ដាប់ថា "បងប្រុសរបស់ខ្ញុំបួសហើយ"ក៏ក្រោធ ទើបមកជេរព្រះសាស្ដាដោយវាចាដ៏អាក្រក់ ដែលមិនមែនជាវាចារបស់សប្បុរស ។

សូម្បីព្រាហ្មណ៍នោះ ក៏ត្រូវព្រះសាស្ដាធ្វើឲ្យយលព្រម ដោយពាក្យប្រៀបធៀបទៅនិងការឲ្យវត្ថុទាំងឡាយមានរបស់ដែលគួរទំពាស៊ីជាដើមដល់ភ្ញៀវទាំងឡាយ ជ្រះថ្លាចំពោះព្រះសាស្ដា បួសហើយបានសម្រេចព្រះអរហត្ត ។

ប្អូនប្រុសរបស់ភារទ្វាជព្រាហ្មណ៍ ដទៃពីររូបទៀតគឺសុន្ទរិកភារទ្វាជៈ ១ ពិលង្គិកភារទ្វាជៈ ១ ( នាំគ្នា ) ជេរព្រះសាស្ដាដែរ ត្រូវព្រះសាស្ដាទ្រង់ណែនាំ បួសហើយបានសម្រេចព្រះអរហត្ត ។

ក្រោយមក នៅថ្ងៃមួយ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា "អ្នកមានអាយុទាំងឡាយ គុណរបស់ព្រះពុទ្ធ

គួរឲ្យអស្ចារ្យពិតមែនហ្ន៎ ! កាលព្រាហ្មណ៍ជាបងប្អូនទាំង ៤ ជេរ, ក៏ព្រះសាស្តាមិនត្រាស់អ្វី ៗ ត្រឡប់បានជាទីពឹងនៃព្រាហ្មណ៍ទាំងនោះវិញ" ។

## ព្រះសាស្តាជាទីពឹងរបស់មហាជន

ព្រះសាស្តា ស្តេចមកហើយត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយកថាអ្វីហ្ន៎ ?" កាលភិក្ខុទាំងនោះក្រាបទូលថា "ដោយកថាឈ្មោះនេះ ព្រះអង្គ" ក៏ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ តថាគតមិនប្រទូស្តចំពោះបុគ្គលដែលប្រទូស្ត ព្រោះតថាគតប្រកបដោយកម្លាំងគឺខន្តិ រមែងបានជាទីពឹងនៃមហាជនដោយពិត ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា ៖-

**១៦ អក្កោសំ វធពន្ធញ្ច អទុដ្ឋោ យោ តតិក្ខតិ**
**ខន្តីពលំ ពលានីកំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា មិនប្រទូស្ត អត់សង្កត់ពាក្យជេរ
ផង ការបៀតបៀន និងការចងផងបាន ទើប
តថាគតហៅបុគ្គលដែលមានខន្តីជាពលៈ មាន

ខន្តីជាវេហ៍ពលនោះឯង ថាជាព្រាហ្មណ៍ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **អទុដ្ឋោ** ជាដើម សេចក្ដីថា បុគ្គលណាជាអ្នកមានចិត្តមិនក្រោធ គ្របសង្កត់ពាក្យជេរ និងពាក្យបរិភាស ដោយអក្កោសវត្ថុ ១០ និងការប្រហារដោយបាតដៃជាដើម និងការចងដោយចំណងទាំងឡាយមានខ្នោះជាដើម, តថាគតហៅបុគ្គលនោះ គឺបុគ្គលបែបនោះដែលឈ្មោះថាមានកម្លាំងគឺខន្តី ព្រោះជាអ្នកប្រកបដោយកម្លាំងគឺខន្តិ បុគ្គលដែលមានឈ្មោះថា អ្នកមានកងពលគឺខន្តី ព្រោះជាអ្នកប្រកបដោយកម្លាំងគឺខន្តី ដែលកើតឡើងជាកងពលដោយកិរិយាកើតឡើងរឿយៗ នោះថាជាព្រាហ្មណ៍។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

រឿងអក្កោសកភារទ្វាជព្រាហ្មណ៍ ចប់

## ១៧ រឿងព្រះសារីបុត្តត្ថេរ

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសារីបុត្តត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា “**អក្កោធនំ**” ជាដើម ។

## ព្រះថេរៈលះបង់ទ្រព្យចេញបួស

បានឮថា ក្នុងកាលនោះព្រះថេរៈត្រាច់ទៅបិណ្ឌបាតជាមួយនិងភិក្ខុ ៥០០ រូប បានទៅកាន់ទ្វារផ្ទះរបស់មាតា ក្នុងស្រុកនាលកៈ ។

គ្រានោះ មាតារបស់លោកនិមន្តលោកឲ្យគង់ក្នុងផ្ទះ ហើយអង្គាស រួចជេរថា "នែលោកកូន លោកកូនឯងមិនបានរបស់ទំពាស៊ីដ៏ជាដែល និងទឹកបាយដ៏ជាដែល ក៏សមគួរនឹងបរិភោគទឹកបាយដែលគេបរិភោគហើយ ជាប់និងខ្នងវែកក្នុងផ្ទះបុគ្គលដទៃ, លោកកូនលះបង់ទ្រព្យ ៨០ កោដិហើយចេញបួស, ខ្ញុំម្ចាស់ជាស្ត្រីត្រូវលោកឲ្យវិនាសហើយ, ឥឡូវនេះ លោកចូរបរិភោគចុះ" ។ នាងប្រគេនភត្តភិក្ខុទាំងឡាយបណ្ដើរ ពោលបណ្ដើរថា "បុត្តរបស់ខ្ញុំម្ចាស់ត្រូវលោកម្ចាស់ទាំងឡាយ ធ្វើឲ្យជាអ្នកបំរើខ្លួនហើយ, ឥឡូវនេះ លោកម្ចាស់ទាំងឡាយចូរបរិភោគចុះ" ព្រះថេរៈទទួលភិក្ខាហើយនិមន្តទៅកាន់វិហារវិញ ។

គ្រានោះ រាហុលសួរនាំព្រះសាស្ដាដោយបិណ្ឌបាត ។ ពេលនោះ ព្រះសាស្ដាត្រាស់ទៅកាន់រាហុលថា "ម្នាលរាហុល ពួកអ្នកទៅកាន់ទីណា ?" ។

ព្រះរាហុល. បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គទៅកាន់ស្រុកលោកយាយ ។

ព្រះសាស្ដា. ក៏ឧបជ្ឈាយ៍របស់អ្នក ត្រូវលោកយាយពោលយ៉ាងណាខ្លះ ?

ព្រះរាហុល. បពិត្រព្រះអង្គដ៏ចម្រើន ឧបជ្ឈាយ៍របស់ខ្ញុំព្រះអង្គ ត្រូវលោកយាយជេរ ។

ព្រះសាស្ដា. ឧបជ្ឈាយ៍របស់អ្នកត្រូវយាយជេរដូចម្ដេចខ្លះ ?

ព្រះរាហុល. ពោលពាក្យឈ្មោះនេះ ព្រះអង្គ ។

ព្រះសាស្ដា. ចំណែកឧបជ្ឈាយ៍របស់អ្នកពោលយ៉ាងណាដែរ ?

ព្រះរាហុល. បពិត្រព្រះអង្គដ៏ចម្រើន ឧបជ្ឈាយ៍របស់ខ្ញុំព្រះអង្គមិនបានពោលពាក្យអ្វីឡើយ ។

## ភិក្ខុទាំងឡាយសរសើរព្រះថេរៈ

ភិក្ខុទាំងឡាយស្តាប់ពាក្យនោះហើយ ក៏សន្ទនាគ្នាក្នុងធម្មសភាថា "អ្នកមានអាយុទាំងឡាយ គុណទាំងឡាយរបស់ព្រះសារីបុត្តគួរឲ្យអស្ចារ្យពិតមែនហ្ន៎ ! កាលមាតារបស់លោកជេរយ៉ាងនោះហើយ ហេតុសូម្បីត្រឹមតែសេចក្តីក្រោធ ក៏មិនមាន" ។

ព្រះសាស្តាស្តេចមកហើយ ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយអង្គុយសន្ទនាគ្នាអំពីកថាអ្វីហ្ន៎ ?" កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន អំពីកថាឈ្មោះនេះ ។ ទើបត្រាស់ថា "ភិក្ខុទាំងឡាយ ធម្មតាព្រះខីណាស្រពទាំងឡាយមិនក្រោធឡើយ" ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា ៖-

**១៧ អក្កោធនំ វតវន្តំ សីលវន្តំ អនុស្សទំ**
**ទន្តំ អន្តិមសារីរំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគតហៅបុគ្គល ដែលមិនមានសេចក្តី
ក្រោធ មានធុតង្គវត្ត មានចតុប្បារិសុទ្ធិសីល

មិនមានតណ្ហាគ្រឿងប៉ោងចិត្ត មានឥន្ទ្រិយ
ទូន្មានហើយ មានសរីរៈឋិតនៅ ក្នុងទីបំផុត
នោះ ថាជាព្រាហ្មណ៍ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **វត្តវន្តំ** ជាដើម សេចក្តីថា តថាគតហៅអ្នកប្រកបដោយវត្តគឺធុតង្គ អ្នកមានសីលដោយបារិសុទ្ធសីល ៤ បុគ្គលដែលមានឈ្មោះថាមិនមានតណ្ហាគ្រឿងប៉ោងឡើង ព្រោះមិនមានគ្រឿងប៉ោងឡើងគឺតណ្ហា បុគ្គលដែលមានឈ្មោះថាទូន្មានហើយ ព្រោះទូន្មានឥន្ទ្រិយ ៦ បុគ្គលដែលមានឈ្មោះថា មានសរីរៈឋិតនៅក្នុងទីបំផុត ព្រោះមានអត្តភាពឋិតនៅក្នុងទីបំផុនោះ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

រឿងព្រះសារីបុត្តត្ថេរ ចប់

## ១៨ រឿងព្រះនាងឧប្បលវណ្ណាថេរី

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះនាងឧប្បលវណ្ណាថេរី ត្រាស់ព្រះធម្មទេសនានេះថា “**វារិបោក្ខរបត្តេវ**” ជាដើម

## មហាជនយល់ថាព្រះខីណាស្រពត្រេកអរនិងកាមសុខ

រឿងខ្ញុំម្ចាស់ឲ្យពិស្តារហើយ ក្នុងអដ្ឋកថានៃព្រះគាថាថា “**មធុវា មញ្ញតី ពាលោ**” ជាដើម ។

ពិតណាស់ ក្នុងវណ្ណនានៃព្រះគាថានោះខ្ញុំម្ចាស់ពោលដូច្នេះថា “ក្នុងសម័យដទៃទៀត មហាជនសន្ទនាគ្នាក្នុងរោងធម៌ថា “សូម្បីព្រះខីណាស្រពទាំងឡាយ ក៏នៅសេពកាម, នឹងមិនសេពដូចម្តេច ? ព្រោះព្រះខីណាស្រពទាំងនោះ មិនមែនជាឈើពុក មិនមែនជាដំបូកឯណា ជាអ្នកមានសាច់និងសរីរៈដ៏ស្រស់ថ្លានៅឡើយ, ហេតុនោះ សូម្បីព្រះខីណា-ស្រពទាំងនោះ ក៏នៅត្រេកអរនិងកាមសុខដែរ” ។

## ព្រះខីណាស្រពមិនជាប់ក្នុងកាម

ព្រះសាស្តាស្តេចមកហើយ ត្រាស់សួរថា “ភិក្ខុទាំងឡាយ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយកថាអ្វីហ្ន៎ ?”

កាលភិក្ខុទាំងនោះក្រាបទូលថា "ម្នាលភិក្ខុទាំងឡាយ ព្រះខីណាស្រពទាំងឡាយ រមែងមិនត្រេកអរនិងកាមសុខ មិនសេពកាមឡើយ, ដូចដំណក់ទឹកដែលធ្លាក់លើស្លឹកឈូកមិនជាប់ មិនដក់នៅ, រមែងរមៀលធ្លាក់ទៅយ៉ាងណា,ម្យ៉ាងទៀត ដូចគ្រាប់ស្ពៃ រមែងមិនជាប់ មិនតាំងនៅលើដែកស្រួចរមែងរមៀលធ្លាក់ទៅយ៉ាងណា, សូម្បីកាមទាំងពីរយ៉ាង ក៏រមែងជាប់ មិនតាំងនៅក្នុងចិត្តរបស់ព្រះខីណាស្រព ដូច្នោះដែរ" ដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ទើបត្រាស់ព្រះគាថាក្នុងព្រាហ្មណវគ្គនេះថា ៖-

**១៨ បោក្ខរបត្តេវ អារគ្គេរិវ សាសបោ**
**យោ វេ ន លិម្បតិ កាមេសុ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា មានចិត្តមិនបានជាប់នៅ ក្នុង
កាមទាំងឡាយ ដូចទឹកលើស្លឹកឈូក ឬដូច
គ្រាប់ស្ពៃលើចុងដែកស្រួច តថាគតហៅ
បុគ្គលនោះ ថាជាព្រាហ្មណ៍ ។

**អធិប្បាយគាថា**

បណ្ដាបទទាំងនោះ បទថា **យោ ន លិម្បតិ** ជាដើម សេចក្ដីថា បុគ្គលណាមានចិត្តមិនជាប់នៅក្នុងកាមសុខទាំងពីរយ៉ាង គឺមិនតាំងនៅក្នុងកាមនោះយ៉ាងនេះ, តថាគតហៅបុគ្គលនោះថា ជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

រឿងព្រះនាងឧប្បលវណ្ណាថេរី ចប់

## ១៩ រឿងព្រាហ្មណ៍មួយរូប

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍មួយរូប ត្រាស់ព្រះធម្មទេសនានេះថា "**យោ ទុក្ខស្ស**" ជាដើម ។

## ទាសរបស់ព្រាហ្មណ៍លួចរត់ទៅបួស

បានឮថា ទាសម្នាក់របស់ព្រាហ្មណ៍នោះ កាលសិក្ខាបទដែលព្រះមានព្រះភាគមិនទាន់បានបញ្ញត្តិ លួចរត់ទៅបួសបានសម្រេចព្រះអរហត្ត ។ ព្រាហ្មណ៍ស្វែងរកដែរ ប៉ុន្តែស្វែងរកឃើញ ថ្ងៃមួយព្រាហ្មណ៍បានឃើញភិក្ខុនោះនិមន្តទៅបិណ្ឌបាតជាមួយនិងព្រះមានព្រះភាគត្រង់ចន្លោះទ្វារ ចាប់ទាញចីវរយ៉ាងមាំ ។ ព្រះសាស្ដាស្ដេចត្រឡប់មក ត្រាស់សួរថា "ម្នាលព្រាហ្មណ៍ តើមានបញ្ហាអ្វី ?" ។

ព្រាហ្មណ៍. បពិត្រព្រះគោតមដ៏ចម្រើន ( ភិក្ខុនេះ ) ជាទាសរបស់ខ្ញុំព្រះអង្គ ។

ព្រះសាស្តា. ម្នាលព្រាហ្មណ៍ ភិក្ខុនោះជាអ្នកមានភារៈដាក់ចុះហើយ ។

កាលព្រះសាស្តាត្រាស់ថា "ជាអ្នកមានភារៈដាក់ចុះហើយ" ព្រាហ្មណ៍ដឹងបានថា "ជាព្រះអរហន្ត" កាលព្រាហ្មណ៍ក្រាបទូលសួរបញ្ជាក់ទៀតថា "យ៉ាងនោះឬ ? ព្រះគោតមដ៏ចម្រើន" ។

ព្រះសាស្តាត្រាស់ថា "ត្រឹមត្រូវហើយ ព្រាហ្មណ៍ ភិក្ខុនោះជាអ្នកមានភារៈដាក់ចុះហើយ" ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា ៖-

**១៩ យោ ទុក្ខស្ស បជានាតិ ឥធេវ ខយមត្តនោ**
**បន្នភារំ វិសញ្ញុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា ក្នុងសាសនានេះឯង ដឹងច្បាស់
នូវការអស់ទុក្ខរបស់ខ្លួន តថាគតហៅបុគ្គល
នោះ ដែលមានខន្ធភារៈ ដាក់ចុះហើយ ដែល
រួចស្រឡះចាកកិលេសទាំងឡាយ ថាជាព្រាហ្មណ៍។

**អធិប្បាយគាថា**

បណ្ដាបទទាំងនោះ បទថា **ទុក្ខស្ស** បានដល់ ខន្ធទុក្ខ បទថា **បន្នភារំ** ជាដើម សេចក្ដីថា តថាគតហៅអ្នកមានភារៈគឺខន្ធដាក់ចុះហើយ អ្នករួចស្រឡះចាកយោគៈ ៤ ឬកិលេសទាំងឡាយនោះថា ជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ព្រាហ្មណ៍នោះតាំងនៅក្នុងសោតាបត្តិផល ។ ទេសនាបានកថាមានប្រយោជន៍សូម្បីដល់មហាជនដែលមកប្រជុំគ្នានៅទីនោះ ។

រឿងព្រាហ្មណ៍មួយរូប ចប់

# ២០ រឿងខេមាភិក្ខុនី

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅលើភ្នំគិជ្ឈកូដ ទ្រង់ប្រារព្ធខេមាភិក្ខុនី ត្រាស់ព្រះធម្មទេសនានេះថា **“គម្ភីរបញ្ញំ”** ជាដើម ។

## ខេមាភិក្ខុនីជួបសក្កទេវរាជ

បានឮថា ថ្ងៃមួយ សក្កទេវរាជាស្ដេចមកកាន់ទេវបរិ-ស័ទក្នុងចន្លោះបឋមយាម ទ្រង់គង់សណ្ដាប់ព្រះធម្មកថាដែលសម្ដែងអំពីសារាណីយធម៌ក្នុងសម្នាក់ព្រះសាស្ដា ។

គ្រានោះ ខេមាភិក្ខុនីមកដោយបំណងថា “នឹងគាល់ព្រះសាស្ដា” ឃើញសក្កទេវរាជហើយ ឈរនៅលើអាកាសនោះឯង ថ្វាយបង្គំព្រះសាស្ដាហើយ ក៏ត្រឡប់ទៅវិញ ។

សក្កទេវរាជទតឃើញព្រះនាងខេមាហើយ ទូលសួរថា "បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនីនោះឈ្មោះអ្វី ? មកឈរនៅលើអាកាស ថ្វាយបង្គំហើយ ត្រឡប់ទៅវិញ" ។

## លក្ខណៈរបស់ព្រាហ្មណ៍ក្នុងព្រះពុទ្ធសាសនា

ព្រះសាស្តាត្រាស់ថា "មហាបពិត្រ ភិក្ខុនីនោះ ជាធិតារបស់តថាគត ឈ្មោះខេមា ជាអ្នកមានបញ្ញា ឈ្លាសវៃក្នុងផ្លូវនិងមិនមែនផ្លូវ" ដូច្នេះហើយ ត្រាស់ព្រះគាថានេះថាៈ-

**២០ គម្ភីរបញ្ញំ មេធាវី មគ្គាមគ្គស្ស កោវិទំ**
**ឧត្តមត្ថំ អនុប្បត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគតហៅ បុគ្គលអ្នកមានប្រាជ្ញាជ្រៅ
មានប្រាជ្ញាជាគ្រឿងទម្លាយកិលេស អ្នកឈ្លាស
ក្នុងផ្លូវនិងមិនមែនផ្លូវ បានសម្រេចប្រយោជន៍
ដ៏ខ្ពង់ខ្ពស់នោះ ថាជាព្រាហ្មណ៍ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **គម្ភីរបញ្ញំ** ជាដើម សេចក្តីថា តថាគតហៅបុគ្គលអ្នកប្រកបដោយបញ្ញា ដែលប្រព្រឹត្ត

ទៅក្នុងធម៌ទាំងឡាយ មានខន្ធជាដើមដ៏ជ្រាលជ្រៅ ជាអ្នកប្រាជ្ញ ប្រកបដោយបញ្ញាដ៏រុងរឿងក្នុងធម៌ ឈ្មោះថាអ្នកឈ្លាសក្នុងផ្លូវនិងមិនមែនផ្លូវ ព្រោះជាអ្នកឈ្លាសវៃក្នុងផ្លូវនិងមិនមែនផ្លូវយ៉ាងនេះ គឺនេះជាផ្លូវទុគ្គតិ, នេះជាផ្លូវសុគតិ, នេះផ្លូវនៃព្រះនិព្វាន, នេះមិនមែនផ្លូវ, អ្នកសម្រេចប្រយោជន៍ដ៏ខ្ពង់ខ្ពស់ ពោលគឺព្រះអរហត្តនោះថា ជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

រឿងខេមាភិក្ខុនី ចប់

## ២១ រឿងព្រះតិស្សត្ថេរអ្នកមានប្រក្រតីនៅក្នុងញកភ្នំ

### *សេចក្តីខាងដើម*

*ព្រះសាស្តា កាលគង់នៅក្នុវត្តជេតពន ទ្រង់ប្រារព្ធព្រះតិស្សត្ថេរ អ្នកមានប្រក្រតីនៅក្នុងញកភ្នំ ត្រាស់ព្រះធម្មទេសនានេះថា " **អសំសដ្ឋំ** " ដូច្នេះជាដើម ។*

*ទេវតាខ្លាចអ្នកមានសីលបរិសុទ្ធ*

*បានឮថា ព្រះថេរៈរូបនោះរៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តាហើយ ចូលទៅកាន់ព្រៃ រកមើលសេនាសនៈដែលជាទីសប្បាយ ដល់ញកភ្នំមួយ, ក្នុងពេលដែលលោកទៅដល់ទីនោះ ចិត្តរបស់លោកជាធម្មជាតិមានអារម្មណ៍មូលតែមួយ ។*

លោកគិតថា “ កាលបើយើងនៅទីនេះ នឹងអាចញ៉ាំងកិច្ចនៃបព្វជិតឲ្យសម្រេចបាន ” ។

ទេវតាដែលអាស្រ័យនៅក្នុងញកភ្នំនោះគិតថា “ ភិក្ខុអ្នកមានសីលមកហើយ, ការដែលយើងនៅក្នុងទីមួយជាមួយនឹងភិក្ខុនេះ រមែងលំបាក, ក៏ភិក្ខុនេះនឹងនៅក្នុងទីនេះអស់មួយរាត្រីប៉ុណ្ណោះ នឹងទៅហើយ ” ទើបនាំទាំងឡាយចេញទៅ ។

ថ្ងៃស្អែកឡើង ព្រះថេរៈចូលទៅកាន់គោចរគ្រាមអំពីព្រលឹម ដើម្បីបិណ្ឌបាត ។

គ្រានោះ ឧបាសិកាមួយរូបឃើញព្រះថេរៈហើយ មានចិត្តស្រឡាញ់ព្រះថេរៈដូចជាកូនហើយ និមន្តឲ្យគង់ក្នុងផ្ទះ ឲ្យឆាន់ហើយ អារាធនាដើម្បីប្រយោជន៍ដល់ការអាស្រ័យខ្លួនអស់ត្រៃមាស ។ ចំណែកព្រះថេរៈក៏ទទួល ដោយគិតថា “ យើងអាស្រ័យឧបាសិកានេះហើយ នឹងអាចធ្វើការរលាស់ខ្លួនចេញចាកភពបាន ” ដូច្នេះហើយ បានទៅកាន់គុហានោះ ។

ទេវតាឃើញព្រះថេរៈកំពុងនិមន្តមក ក៏គិតថា “ ព្រះថេរៈនេះប្រហែលជាមានអ្នកណានិមន្តទុកដោយពិត, លោកគង់នឹងទៅថ្ងៃស្អែក ឬថាក្នុងថ្ងៃខានស្អែក ” ។

## ទេវតាគិតរកឧបាយដើម្បីឲ្យភិក្ខុចេញចាកអំពីទីនោះ

កាលវេលាប្រមាណកន្លះខែ កន្លងទៅហើយយ៉ាងនេះ, ទេវតាក៏គិតថា “ ភិក្ខុនេះ ប្រាកដជានៅក្នុងទីនេះអស់វជ្ជូវស្សានេះ, ក៏ការដែលយើងនិងបុត្រតូចៗ ទាំងឡាយ នៅក្នុងទីមួយជាមួយនឹងអ្នកមានសីល ជាការធ្វើបានដោយក្រ, ម្យ៉ាងទៀត យើងមិនអាចនឹងពោលទៅកាន់ភិក្ខុនេះថា “ លោកចូរចៀសចេញទៅ ដូច្នេះបានឡើយ, តើការភ្លាំងភ្លាត់ក្នុងសីលរបស់ភិក្ខុនេះមានដែរឬហ្ន៎ ” ដូច្នេះហើយ រកមើលដោយទិព្វចក្ខុ ក៏មិនឃើញការភ្លាំងភ្លាត់ក្នុងសីលរបស់ព្រះថេរៈ តាំងពីពេលឧបសម្បទា ក៏គិតថា “ សីលរបស់លោកបរិសុទ្ធ, យើងនឹងធ្វើនូវអំពើអ្វីមួយ ដើម្បីនឹងញ៉ាំងទោសឲ្យកើតឡើងដល់លោក ” ដូច្នេះហើយ ក៏ចូលសណ្ឋិតក្នុងសរីរៈបុត្រច្បងរបស់ឧបាសិកា ក្នុងត្រកូលឧបដ្ឋាក មួលក, ធ្វើឲ្យក្អែកទាំង

២ លៀនចេញ, ទឹកមាត់ហូរចេញចាកមាត់ ។ ឧបាសិកាឃើញកូនមានអាការដូច្នោះ ក៏ស្រែកថា “ នេះជាអ្វី ” ។

គ្រានោះ ទេវតាមានរូបមិនប្រាកដ ពោលទៅកាន់ឧបាសិកានោះយ៉ាងនេះថា “ បុត្រនោះយើងចាប់ទុកហើយ, យើងមិនត្រូវការសូម្បីពលីកម្ម, ប៉ុន្តែ នាងចូរសូមវល្លិ៍ឈើអែមអំពីព្រះថេរៈដែលជាជីតុនរបស់នាង យកទៅស្ងូឲ្យទៅជាប្រេងហើយ ចូរឲ្យបុត្ររបស់នាងដោយវិធីបន្តក់ចុះ, កាលធ្វើយ៉ាងនេះ យើងនឹងលែងបុត្ររបស់នាង ” ។

ឧបាសិកា. បុត្រនោះវិនាស ឬស្លាប់ក៏ដោយចុះ, ខ្ញុំមិនអាចនឹងសូមឈើអែមអំពីព្រះថេរៈបានទេ ។

ទេវតា. ប្រសិនបើនាងមិនសូមឈើអែមអំពីព្រះថេរៈទេ, នាងចូរពោលដើម្បីឲ្យព្រះថេរៈដាក់លម្អិតនៃជរហិង្គុរតាមប្រមុះបុត្ររបស់នាងចុះ ។

ឧបាសិកា. ខ្ញុំមិនអាចពោលសូម្បីនូវពាក្យយ៉ាងនេះ ។

ទេវតា. បើដូច្នោះ នាងចូរស្រោចទឹកសម្រាប់លាងជើងព្រះថេរៈនោះលើក្បាលបុត្ររបស់នាងចុះ ។

ឧបាសិកាពោលថា “ ខ្ញុំអាចធ្វើដូច្នេះបាន ” និមន្តព្រះថេរៈអ្នកមកតាមវេលាឲ្យគង់ហើយ ប្រគេនយាគូ និងរបស់ទំពាស៊ី លាងជើងព្រះថេរៈក្នុងចន្លោះកត្ត ត្រងយកទឹកទុកហើយ ប្រាប់ព្រះថេរៈឲ្យដឹងថា ខ្ញុំព្រះករុណានឹងស្រោចទឹកនេះលើក្បាលក្មេង ” កាលព្រះថេរៈអនុញ្ញាតថា “ ចូរស្រោចចុះ ” ក៏បានធ្វើយ៉ាងនោះ ។ ទេវតាលែងក្មេងនោះក្នុងខណៈនោះឯង ហើយទៅឈរនៅក្បែរទ្វារគុហា ។

ចំណែកព្រះថេរៈ វេលាស្រេចភត្តកិច្ច ក្រោកចាកអាសនៈស្វាធ្យាយអាការ ៣២ ព្រោះលោកជាអ្នកមិនលះបង់កម្មដ្ឋាន ហើយចៀសចេញទៅ ។

លុះពេលដែលព្រះថេរៈទៅដល់គុហា ទេវតានោះពោលទៅកាន់ព្រះថេរៈថា “នែមហាពេទ្យ លោកកុំចូលមកទីនេះ” ។ ព្រះថេរៈឈរនៅទីនោះហើយ សួរថា “នែអ្នកដ៏ចម្រើន អ្នកជានរណា ?”

ទេវតា. ខ្ញុំម្ចាស់ជាទេវតាអាស្រ័យនៅទីនេះ ។

ព្រះថេរៈគិតថា តើយើងមានបានធ្វើវេជ្ជកម្មដែរទេ ? ដូច្នេះហើយ ពិចារណាមើលចាប់តាំងអំពីកាលឧបសម្បទាមក មិនឃើញភាពសៅហ្មង ឬការស្នាមជាំនៃសីលរបស់ខ្លួន ទើបពោលថា "អាត្មាមិនឃើញទីកន្លែងដែលអាត្មាធ្វើវេជ្ជកម្មឡើយ, អ្នកពោលយ៉ាងនេះ ព្រោះហេតុអ្វី ?"

ទេវតា. លោកម្ចាស់មិនឃើញឬ ?

ព្រះថេរៈ. អើ អាត្មាមិនឃើញទេ ។

ទេវតា. បើដូច្នោះ ខ្ញុំម្ចាស់នឹងប្រាប់លោកម្ចាស់ ។

ព្រះថេរៈ. ប្រាប់មកចុះ ។

ទេវតា. ការពោលក្នុងកាលឆ្ងាយចូរលើកទុកសិនចុះ, ថ្ងៃនេះ លោកម្ចាស់ស្រោចទឹកសម្រាប់លាងជើងលើក្បាលបុត្ររបស់ឧបដ្ឋាកដែលត្រូវអមនុស្សចូលឬ ឬក៏មិនមែនទេ ?

ព្រះថេរៈ. អើ អាត្មាបានស្រោចពិតមែន ។

ទេវតា. នោះជាអ្វី ? លោកម្ចាស់មិនឃើញទេឬ ?

ព្រះថេរៈ. អ្នកពោលសំដៅយកហេតុនោះឬ ?

ទេវតា. ព្រះករុណា លោកម្ចាស់ ខ្ញុំម្ចាស់ពោលសំដៅយកហេតុនោះឯង ។

## អ្នកមានសីលបរិសុទ្ធមិនក្តៅក្រហាយចិត្ត

ព្រះថេរៈគិតថា "ឱហ្ន៎ ! យើងបានតំកល់ខ្លួនទុកដោយប្រពៃហើយ, យើងបានធ្វើកិច្ចដ៏សមគួរដល់សាសនាហើយ, សូម្បីតែទេវតាក៏រកមើលមិនភាពសៅហ្មង ឬការស្នាមជាំនៃចតុបារិសុទ្ធសីលរបស់យើងដែរ បានឃើញត្រឹមតែទឹកលាងជើង ដែលយើងស្រោចហើយលើក្បាលទារកប៉ុណ្ណោះ" ។ បិតិដ៏មានកម្លាំងព្រោះប្រារព្ធសីលកើតឡើងហើយដល់ព្រះថេរៈ, ព្រះថេរៈគ្របសង្កត់បីតិដ៏មានកម្លាំងនោះទុកហើយ ឈរនៅស្ងៀម មិនធ្វើការលើកជើងឡើងបានសម្រេចព្រះអរហត្តក្នុងទីនោះឯង ហើយពោលថា "អ្នកប្រទូស្តសមណៈអ្នកបរិសុទ្ធដូចជាយើង, អ្នកកុំនៅក្នុងព្រៃនេះ, អ្នកចូរចៀសចេញទៅ" កាលនឹងទូន្មានទេវតានោះ ក៏បន្លឺឧទាននេះថា ៖-

ធម៌ជាគ្រឿងរបស់អាត្មាស្អាតទេតើ, អ្នកកុំប្រទូស្ត

អាត្មាដែលជាអ្នកមិនមានមន្ទិល អ្នកមានតប អ្នកបរិសុទ្ធហើយ, អ្នកចូរចៀសចេញអំពីព្រៃនេះចុះ ។

ព្រះថេរៈនៅទីនោះអស់ត្រៃមាស ចេញវស្សាហើយទៅកាន់សម្នាក់ព្រះសាស្ដា ត្រូវភិក្ខុទាំងឡាយសួរថា "នែអ្នកមានអាយុ កិច្ចរបស់បព្វជិតលោកឲ្យសម្រេចដល់ទីបំផុតហើយឬ ?" ក៏ប្រាប់រឿងនោះទាំងអស់ ចាប់ផ្ដើមពីការចូលវស្សាក្នុងគុហានោះ ដល់ភិក្ខុទាំងឡាយ, កាលភិក្ខុទាំងឡាយពោលថា "ម្នាលអាវុសោ អ្នកត្រូវទេវតាពោលពាក្យយ៉ាងនោះហើយ មិនក្រោធឬ ?" ពោលថា "ខ្ញុំមិនក្រោធទេ" ។

ភិក្ខុទាំងឡាយ ក្រាបទូលរឿងនោះចំពោះព្រះតថាគតថា " បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះព្យាករណ៍អរហត្តផល, សូម្បីត្រូវទេវតាពោលពាក្យយ៉ាងនោះហើយ នៅពោលថា "យើងមិនក្រោធ" ។

## លក្ខណៈរបស់ព្រាហ្មណ៍ក្នុងព្រះពុទ្ធសាសនា

ព្រះសាស្តា ទ្រង់ព្រះសណ្តាប់ពាក្យរបស់ភិក្ខុទាំងនោះហើយ ត្រាស់ថា “ ម្នាលភិក្ខុទាំងឡាយ បុត្ររបស់តថាគតរមែងមិនក្រោធឡើយ, ព្រោះការជាប់ជំពាក់និងពួកគ្រហស្ថ ឬពួកបព្វជិតទាំងឡាយ រមែងមិនមានដល់បុត្ររបស់តថាគត បុត្ររបស់តថាគតនោះ មិនជាប់ជំពាក់ ប្រាថ្នាតិច សន្តោស” ដូច្នេះហើយ កាលនឹងទ្រង់សម្តែងធម៌ បានត្រាស់ព្រះគាថានេះថា ៖-

**២១ អសំសដ្ឋំ គហដ្ឋេហិ អនាគារេហិ ចូភយំ**
**អនោកសារឹ អប្បិច្ឆំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគតហៅបុគ្គល ដែលមិនច្រឡំ ដោយ
ជនទាំងឡាយ ២ ពួក គឺគ្រហស្ថ ១ បព្វជិត ១
ជាអ្នកត្រាច់ទៅដោយមិនមានសេចក្តីអាល័យ
មានសេចក្តីប្រាថ្នាតិចនោះ ថាជាព្រាហ្មណ៍ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **អសំសដ្ឋំ** សេចក្តីថា ដែលឈ្មោះថា អ្នកមិនជាប់ជំពាក់ ព្រោះមិនមានការជាប់ជំ-

ពាក់ដោយការមើល ការស្តាប់ ការសន្ទនា ការបរិភោគ និង ជាប់ជំពាក់ដោយកាយ ។

បទថា **ឧភយំ** បានដល់ អ្នកមិនប្រឡូកប្រឡំដោយ ជន ២ ពួកគឺ គ្រហស្ថ ១ បព្វជិត ១ ។

បទថា **អនោកសារី** បានដល់ អ្នកត្រាច់ទៅដោយមិន មានសេចក្តីអាល័យ ។ អធិប្បាយថា តថាគតហៅបុគ្គល នោះ គឺបុគ្គលបែបនោះថា ជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយ ផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

រឿងព្រះតស្សត្ថេរអ្នកមានប្រក្រតីនៅក្នុងញកភ្នំ ចប់

## ២២ រឿងភិក្ខុមួយរូប

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប ត្រាស់ព្រះធម្មទេសនានេះថា “**និធាយ**”ជាដើម ។

## ភិក្ខុដើរផ្លូវរួមជាមួយនឹងស្ត្រី សូម្បីមិនដឹងក៏មានទោស

បានឮថា ភិក្ខុនោះរៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តាហើយ ព្យាយាមនៅក្នុងព្រៃ បានសម្រេចព្រះអរហត្តហើយគិតថា “ យើងនឹងក្រាបទូលគុណដែលខ្លួនបានហើយចំពោះព្រះសាស្តា ” ទើបចេញចាកព្រៃនោះ ។

គ្រានោះ ស្ត្រីម្នាក់នៅក្នុងស្រុកមួយ ឈ្លោះនឹងស្វាមី, កាលស្វាមីនោះចេញទៅខាងក្រៅ, គិតថា “ យើងនឹងទៅកាន់ផ្ទះនៃត្រកូល ” ទើបធ្វើដំណើរទៅ ជួបភិក្ខុនោះតាមផ្លូវ ក៏គិតថា “ យើងនឹងអាស្រ័យព្រះថេរៈនេះ ” លុះគិតដូច្នោះហើយ ក៏ដើរជាប់តាមអំពីខាងក្រោយៗ ។ ប៉ុន្តែព្រះថេរៈមិនឃើញនាង ។

គ្រានោះ ស្វាមីរបស់នាងមកផ្ទះវិញ មិនឃើញនាង ក៏គិតថា “ នាងនឹងទៅកាន់ផ្ទះនៃត្រកូលហើយ ” ជាប់តាមទៅឃើញនាងហើយ គិតថា ស្ត្រីនេះតែម្នាក់មិនអាចដើរឆ្លងព្រៃនេះបានទេ, នាងអាស្រ័យបុគ្គលណាហ្ន៎ ទើបឆ្លងព្រៃនេះបាន គិតដូច្នេះហើយ រកមើលឃើញព្រះថេរៈហើយ គិតថា “ ព្រះថេរៈនេះនឹងជាអ្នកនាំស្ត្រីនេះចេញទៅ ” លុះគិតដូច្នេះហើយ ក៏គំរាមព្រះថេរៈ ។

គ្រានោះ ស្ត្រីនោះក៏ពោលទៅកាន់ស្វាមីនោះថា លោកម្ចាស់ដ៏ចម្រើននេះ មិនបានឃើញ មិនបានហៅខ្ញុំឡើយ, លោកកុំពោលពាក្យអ្វីៗ ទៅកាន់លោកដ៏ចម្រើននេះឡើយ ។

## ព្រះថេរៈត្រូវស្វាមីរបស់ស្ត្រីនោះវាយតែមិនក្រោធ

ស្វាមីរបស់ស្ត្រីនោះ មានសេចក្តីក្រោធកើតឡើងថា “ នាងមិនប្រាប់បុគ្គលអ្នកនាំនាងទៅដល់យើងឬ ? យើងនឹងធ្វើកម្មដ៏សមគួរដល់ភិក្ខុនេះ ( ជំនួស ) នាង ” ។ ដោយការចងអាឃាតក្នុងស្ត្រី ក៏វាយព្រះថេរៈ ហើយស្ត្រីនោះត្រឡប់ទៅវិញ ។

សរីរៈទាំងអស់របស់ព្រះថេរៈហើមគ្រប់កន្លែងៗកាល ព្រះថេរៈនោះមកដល់វិហារ ភិក្ខុទាំងឡាយនាំគ្នាប្របាច់ដៃ ប្របាច់ជើងប្រគេនព្រះថេរៈ ឃើញពកនោះហើយ សួរថា “បពិត្រលោកម្ចាស់ដ៏ចម្រើន ហេតុអ្វីសរីរៈរបស់លោកម្ចាស់ មានពកច្រើនម្ល៉េះ?ព្រះថេរៈប្រាប់រឿងនោះដល់ភិក្ខុទាំងនោះៗ

គ្រានោះ ពួកភិក្ខុសួរព្រះថេរៈថា “ បពិត្រលោកម្ចាស់ ដ៏ចម្រើន កាលបុរសនោះប្រហារលោកម្ចាស់យ៉ាងនោះ, លោកម្ចាស់បានពោលពាក្យអ្វី ? ឬសេចក្តីក្រោធមានកើត ឡើងដល់លោកម្ចាស់ទេ ?” ព្រះថេរៈពោលថា “ អ្នកមាន អាយុទាំងឡាយ សេចក្តីក្រោធមិនបានកើតឡើងដល់ខ្ញុំទេ ”ៗ

ភិក្ខុទាំងនោះ ទៅកាន់សម្នាក់ព្រះសាស្តា ក្រាបទូល រឿងនោះហើយ ក្រាបទូលថា “ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុ នោះ ត្រូវខ្ញុំព្រះអង្គទាំងឡាយសួរថា សេចក្តីក្រោធមានកើត ឡើងដល់លោកម្ចាស់ទេ លោកពោលថា អ្នកមានអាយុទាំង ឡាយ សេចក្តីក្រោធមិនបានកើតឡើងដល់ខ្ញុំទេ, ភិក្ខុនោះ ពោលពាក្យមិនពិត ព្យាករអរហត្តផល ” ៗ

ព្រះខីណាស្រពសូម្បីត្រូវវាយក៏មិនក្រោធ

ព្រះសាស្តា ទ្រង់ព្រះសណ្តាប់ពាក្យរបស់ភិក្ខុទាំងនោះហើយ ត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ ធម្មតាព្រះខីណាស្រពទាំងឡាយ អ្នកមានអាជ្ញាដាក់ចុះហើយ, ព្រះខីណាស្រពទាំងនោះ រមែងមិនក្រោធចំពោះបុគ្គលណាឡើយ សូម្បីអ្នកប្រហារ " ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា :-

**២២ និធាយ ទណ្ឌំ ភូតេសុ តសេសុ ថាវរេសុ ច**
**យោ ន ហន្តិ ន ឃាតេតិ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា ដាក់ចុះនូវអាជ្ញា ក្នុងសត្វទាំងឡាយ ដែលនៅតក់ស្លុតក្តី ដែលមាំមួន គឺមិនតក់ស្លុតក្តី មិនបៀតបៀនដោយខ្លួនឯង មិនប្រើគេឲ្យបៀតបៀន តថាគតហៅបុគ្គលនោះថាជាព្រាហ្មណ៍ ។

## <u>អធិប្បាយគាថា</u>

បណ្តាបទទាំងនោះ បទថា **និធាយ** បានដល់ ដាក់ហើយ គឺដាក់ចុះហើយ ។

ពីរបទថា **តសេសុ ថាវរេសុ ច** សេចក្ដីថា បុគ្គល ដែលឈ្មោះថាតក់ស្លុត ព្រោះតក់ស្លុតដោយអំណាចនៃតណ្ហា ហើយបុគ្គលដែលឈ្មោះថា មាំមួន ព្រោះជាអ្នកមាំមួនដោយ ការមិនមានតណ្ហា ។

ពីរបទថា **យោ ន ហន្តិ** ជាដើម សេចក្ដីថា បុគ្គល ដែលមានឈ្មោះថាមានអាជ្ញាដាក់ចុះហើយ ព្រោះជាអ្នកមាន បដិឃៈទៅប្រាសហើយក្នុងសត្វទាំងពួងយ៉ាងនេះ រមែងមិន សម្លាប់ដោយខ្លួនឯង មិនប្រើគេឲ្យសម្លាប់នូវសត្វណាៗ, តថាគតហៅអ្នកនោះថា ជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយ- ផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

( រឿងភិក្ខុមួយរូប ចប់ )

## ២៣ រឿងសាមណេរ

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសាមណេរទាំងឡាយ ត្រាស់ព្រះធម្មទេសនានេះថា “ **អវិរុទ្ធំ** ” ជាដើម ។

## ព្រាហ្មណីខូចចិត្តព្រោះបានសាមណេរតូច

បានឮថា ព្រាហ្មណីម្នាក់ ចាត់ចែងឧទ្ទេសភត្តទុកដើម្បីភិក្ខុ ៤ រូប ហើយពោលទៅកាន់ព្រាហ្មណ៍ថា “ បពិត្រអ្នកជាម្ចាស់ លោកចូរទៅកាន់វិហារហើយ ចូររើសយកព្រាហ្មណ៍ចាស់ៗ ៤ រូបមក ” ។ ព្រាហ្មណ៍នោះទៅកាន់វិហារហើយពោលថា “ បពិត្រលោកម្ចាស់ទាំងឡាយ សូមលោកម្ចាស់ទាំងឡាយឲ្យព្រាហ្មណ៍ចាស់ៗ ៤ រូបដល់ខ្ញុំ ” ។

សាមណេរអ្នកជាខីណាស្រព ៤ រូប ដែលមានអាយុ ៧ ឆ្នាំ គឺ “ សង្កិច្ចសាមណេរ, បណ្ឌិតសាមណេរ, សោបាកសាមណេរ, រេវតសាមណេរ ” ដល់ហើយដល់ព្រាហ្មណ៍នោះ ។

ព្រាហ្មណី រៀបចំអាសនៈទាំងឡាយដែលមានតម្លៃច្រើនទុក ឃើញសាមណេរហើយ ក្រោធ ធ្វើសំឡេង តដៈ តដៈ ដូចអំបិលដែលគេដាក់ទៅក្នុងចង្ក្រានភ្លើង ពោលថា " លោកទៅកាន់វិហារហើយ នាំក្មេង ៤ នាក់សូម្បីត្រឹមតែជាចៅរបស់ខ្លួនក៏មិនសមគួរផងមកកាន់ផ្ទះ " លុះពោលដូច្នោះហើយ ក៏មិនឲ្យសាមណេរទាំងនោះគង់លើអាសនៈទាំងនោះ ដាក់តាំងក្នុងទីទាប ហើយពោលថា " លោកទាំងឡាយចូរអង្គុយលើតាំងទាំងនោះចុះ " ពោលថា " ព្រាហ្មណ៍លោកចូរទៅ ចូររើសព្រាហ្មណ៍ចាស់ៗ ហើយនាំមក " ។ សូម្បីអគ្គសាវកទាំងពីរក៏មិនពេញចិត្តព្រាហ្មណី

ព្រាហ្មណ៍ទៅកាន់វិហារ ឃើញព្រះសារីបុត្តត្ថេរហើយនិមន្តថា " មកចុះលោកម្ចាស់, យើងនឹងទៅកាន់ផ្ទះរបស់យើង " ដូច្នេះហើយ នាំព្រះថេរៈទៅកាន់ផ្ទះ ។ ព្រះថេរៈមកដល់ផ្ទះព្រាហ្មណ៍ ឃើញសាមណេរទាំងឡាយហើយ សួរថា " ព្រាហ្មណ៍ទាំងនេះបានភត្តហើយឬ ?" កាលព្រាហ្មណ៍ឆ្លើយថា " មិនទាន់បានទេ " ក៏ដឹងថា ភត្តដែលព្រាហ្មណីតាក់តែង

ហើយនោះ ដើម្បីព្រាហ្មណ៍ ៤ រូបនេះតែប៉ុណ្ណោះ ពោលថា " ម្នាលព្រាហ្មណ៍ អ្នកចូរឲ្យបាត្រមកអាត្មាវិញ " ទទួលយកបាត្រហើយ ចៀសចេញទៅ ។

ចំណែកព្រាហ្មណីសួរថា " ព្រាហ្មណ៍នេះពោលដូចម្តេច ?" កាលព្រាហ្មណ៍ប្រាប់ថា " លោកប្រាប់ថា ការដែលព្រាហ្មណ៍អ្នកអង្គុយទាំងនោះបាន ទើបគួរ ចូរឲ្យបាត្រមកអាត្មា, ទទួលយកបាត្ររបស់ខ្លួនហើយ ចៀសចេញទៅ " ក៏ពោលថា ព្រះថេរៈនោះប្រហែលជាមិនប្រាថ្នានឹងឆាន់, លោកចូរប្រញាប់ទៅរកមើលព្រាហ្មណ៍ដទៃ ហើយនាំមក " ។

ព្រាហ្មណ៍ទៅឃើញព្រះមហាមោគ្គល្លាន ក៏ពោលពាក្យ ដូចកាលដែលខ្លួនពោលទៅកាន់ព្រះសារីបុត្តដូច្នោះ ហើយនាំព្រះមហាមោគ្គល្លានមកកាន់ផ្ទះ ។

ចំណែកព្រះមហាមោគ្គល្លាន ឃើញសាមណេរទាំងបួនអង្គនោះហើយក៏ពោលដូចព្រះសារីបុត្តដែរ ទទួលយកបាត្រហើយចៀសចេញទៅ ។

គ្រានោះ ព្រាហ្មណីពោលទៅកាន់ព្រាហ្មណ៍នោះថា "ព្រាហ្មណ៍ទាំងនោះជាអ្នកមិនប្រាថ្នានឹងឆាន់ហើយមើលទៅ? លោកចូរទៅកាន់រោងសូត្ររបស់ព្រាហ្មណ៍ នាំព្រាហ្មណ៍ចាស់ៗម្នាក់មក" ។

ចំណែកសាមណេរទាំង ៤ អង្គនោះ មិនបានអ្វីឆាន់តាំងអំពីព្រលឹម ត្រូវសេចក្ដីស្រេកឃ្លានគ្របសង្កត់ ក៏គង់នៅស្ងៀម ។

## សក្កទេវរាជក្លែងធ្វើជាព្រាហ្មណ៍ចាស់ មកទូន្មានព្រាហ្មណី

គ្រានោះ អាសនៈរបស់សក្កទេវរាជសម្ដែងអាការក្ដៅដោយអំណាចគុណរបស់សាមណេរទាំងនោះ។ សក្កទេវរាជពិចារណាមើល ក៏ជ្រាបថា សាមណេរទាំងនោះអត់អាហារតាំងអំពីព្រលឹមម្ល៉េះ ទ្រង់ព្រះតម្រិះថា " ការដែលយើងទៅកាន់ទីនោះ គួរ " ទើប ( ក្លែង ) ធ្វើជាព្រាហ្មណ៍ចាស់គ្រាំគ្រាដោយជរា អង្គុយលើអាសនៈដ៏ប្រសើររបស់ព្រាហ្មណ៍ទាំងឡាយ ក្នុងរោងសូត្ររបស់ព្រាហ្មណ៍នោះ ។ ព្រាហ្មណ៍គ្រាន់

តែឃើញសក្កទេវរាជក្លាម ក៏គិតថា “ លើកនេះព្រាហ្មណី របស់យើងប្រាជកជាពេញចិត្តហើយ ” ពោលទៅកាន់សក្ក-ទេវរាជថា “មកចុះលោក, ពួកយើងនឹងទៅកាន់ផ្ទះ” បាននាំសក្កទេវរាជទៅកាន់ផ្ទះ ។

ព្រាហ្មណី គ្រាន់តែឃើញសក្កទេវរាជក្លាម មានចិត្តត្រេកអរ ក្រាលកម្រាលលើអាសនៈ ២ ជាន់ ក្នុងទីមួយ ហើយពោលថា “ បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកអង្គុយលើអាសនៈនេះចុះ ” ។

សក្កទេវរាជស្ដេចចូលទៅកាន់ផ្ទះថ្វាយបង្គំសាមណេរទាំង ៤ រូប ដោយបញ្ចង្គប្រតិស្ឋាន ហើយគង់លើអាសនៈខាងចុងអាសនៈរបស់សាមណេរទាំងនោះ ។

គ្រានោះ ព្រាហ្មណីឃើញអាការរបស់សក្កទេវរាជក៏ពោលទៅកាន់ព្រហ្មណ៍ថា “ ព្រាហ្មណ៍ដែលលោកនាំមកមុននោះយ៉ាប់ហើយ, ឥឡូវនេះ លោកនាំព្រាហ្មណ៍ធ្លូតបែបនេះមកទៀត, ព្រាហ្មណ៍នោះថ្វាយបង្គំសាមណេរដូចជាចៅរបស់ខ្លួន, ប្រយោជន៍អ្វីដោយព្រាហ្មណ៍នេះ, លោកចូរបណ្ដេញ

ព្រាហ្មណ៍នេះចេញអំពីផ្ទះទៅ " ។ សក្កព្រាហ្មណ៍នោះ ត្រូវព្រាហ្មណីចាប់ក ចាប់ត្រចៀក ចាប់ក្លៀក ទាញចេញអំពីផ្ទះ ប៉ុន្តែមិនធ្វើសូម្បីតែការក្រោកឡើង ។

គ្រានោះ ព្រាហ្មណីពោលទៅកាន់ព្រាហ្មណ៍ដែលជាស្វាមីថា " បពិត្រព្រាហ្មណ៍ លោកចូរមក, ចូរចាប់ដៃម្ខាង ខ្ញុំនឹងចាប់ដៃម្ខាង " ។ ប្តី និងប្រពន្ធទាំងពីរនាក់ចាប់ដៃទាំងពីរ ហើយវាយខ្នង ជួយគ្នាទាញសក្កទេវរាជទៅក្រៅផ្ទះ ។

ចំណែកសក្កទេវរាជ ក៏គង់ក្នុងទីដែលព្រះអង្គគង់នោះឯង រលាស់ព្រះហស្ត ។ ប្រពន្ធនិងប្តីទាំងពីរនាក់នោះត្រឡប់មកឃើញសក្កទេវរាជគង់ក្នុងទីដដែល ក៏ស្រែកដោយការខ្លាច ។

ក្នុងខណៈនោះ សក្កទេវរាជធ្វើឲ្យប្រពន្ធ និងប្តីទាំង ២ នាក់នោះដឹងថា ព្រះអង្គជាសក្កទេវរាជ ។

គ្រានោះ ប្តីប្រពន្ធទាំង ២ នាក់ប្រគេនអាហារដល់សាមណេរទាំងនោះ ។ ក៏ជនទាំង ៥ រូបទទួលអាហារហើយ សាមណេរមួយរូបទម្លុះមណ្ឌលនៃហោជាងចេញទៅ, មួយរូប

ទម្ពុះចំណែកខាងមុខនៃដំបូលចេញទៅ, មួយរូបទម្ពុះចំណែកខាងក្រោយនៃដំបូលចេញទៅ, មួយរូបមុជចុះក្នុងផែនដីចេញទៅ, ចំណែកសក្កទេវរាជ ក៏ស្តេចចេញទៅតាមផ្លូវមួយ, ជនទាំង ៥ នាក់បានទៅកាន់ទីទាំង ៥ ដោយប្រការដូច្នេះ ។ ពួកសាមណេរជំណាលរឿងដែលត្រូវព្រាហ្មណីធ្វើបាប

បានឮថា ផ្ទះនោះមានឈ្មោះថា ជាផ្ទះមានប្រហោង ៥ ចាប់តាំងពីពេលនោះមក ។ ពេលដែលសាមណេរទៅកាន់វិហារ ភិក្ខុទាំងឡាយ សួរសាមណេរទាំងនោះថា " ម្នាលសាមណេរ ផ្ទះរបស់ព្រាហ្មណ៍ប្រាកដដូចម្តេចខ្លះ ?" ។

ពួកសាមណេរ. បពិត្រលោកម្ចាស់ទាំងឡាយ សូមលោកម្ចាស់ទាំងឡាយកុំសួរពួកខ្ញុំ, ចាប់តាំងអំពីកាលដែលព្រាហ្មណីឃើញពួកខ្ញុំហើយ ព្រាហ្មណីនោះជាស្ត្រីត្រូវសេចក្តីក្រោធគ្របសង្កត់ មិនឲ្យពួកខ្ញុំអង្គុយលើអាសនៈដែលខ្លួនតាក់តែងហើយ ហើយថែមទាំងពោលថា បពិត្រព្រាហ្មណ៍លោកចូរទៅនាំព្រាហ្មណ៍ចាស់ៗ មកឲ្យឆាប់, ឧបជ្ឈាយ៍របស់ពួកខ្ញុំមកឃើញពួកខ្ញុំហើយ ពោលថា ការដែលព្រាហ្មណ៍

ទាំងបាន ( អាហារមុន ) គួរ, ទទួលយកបាត្រមកហើយ ត្រឡប់ទៅវិញ, កាលនាងព្រាហ្មណីពោលថា “ បពិត្រព្រាហ្មណ៍ លោកចូរទៅនាំព្រាហ្មណ៍ចាស់ៗ ដទៃមក, ព្រាហ្មណ៍នាំព្រះមហាមោគ្គល្លានត្ថេរមក, លោកឃើញពួកខ្ញុំហើយ ក៏ពោលពាក្យដូចឧបជ្ឈាយ៍របស់ពួកខ្ញុំដែរ ហើយត្រឡប់ទៅវិញ ។ ពេលនោះ ព្រាហ្មណីពោលថា បពិត្រព្រាហ្មណ៍ ព្រាហ្មណ៍ទាំងនេះជាអ្នកមិនប្រាថ្នានឹងឆាន់, លោកចូរទៅ, ចូរនាំព្រាហ្មណ៍ចាស់ម្នាក់អំពីរោងសូត្ររបស់ព្រាហ្មណ៍មកចុះ ហើយបញ្ជូនព្រាហ្មណ៍ទៅ, ព្រាហ្មណ៍នោះទៅកាន់រោងសូត្រនោះហើយ នាំសក្កទេវរាជដែលស្តេចមកដោយភេទជាព្រាហ្មណ៍មក, កាលសក្កទេវរាជស្តេចមកដល់ផ្ទះ ប្តីប្រពន្ធទាំងពីរនាក់ក៏ប្រគេនអាហារដល់ពួកខ្ញុំ ។

ភិក្ខុទាំងឡាយ. ពួកអ្នកមិនក្រោធនឹងព្រាហ្មណីដែលធ្វើយ៉ាងនោះទេឬ ?

សាមណេរ. ពួកខ្ញុំមិនក្រោធទេ ។

ភិក្ខុទាំងឡាយ ស្តាប់ពាក្យនោះហើយ ក្រាបទូលព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន សាមណេរទាំងនេះពោលពាក្យមិនពិតថា ពួកខ្ញុំមិនក្រោធទេ ព្យាករអរហត្តផល ។

ព្រះសាស្តាត្រាស់ថា “ ម្នាលភិក្ខុទាំងឡាយ ធម្មតាព្រះខីណាស្រពទាំងឡាយ រមែងមិនក្រោធចំពោះជនទាំង-ឡាយ សូម្បីជនដែលក្រោធហើយឡើយ ” ដូច្នេះហើយត្រាស់ព្រះគាថានេះថា :-

**២៣ អវិរុទ្ធំ វិរុទ្ធេសុ អត្តទណ្ឌេសុ និព្វុតំ**
**សាទានេសុ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគតហៅបុគ្គលអ្នកដែលមិនខឹង ចំពោះពួកជនដែលខឹងហើយ អ្នករំលត់ចំពោះពួកជនដែលមានអាជ្ញាក្នុងខ្លួន អ្នកមិនមានសេចក្តីប្រកាន់ចំពោះពួកជន ដែលមានសេចក្តីប្រកាន់នោះ ថាជាព្រាហ្មណ៍ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **អវិរុទ្ធំ** ជាដើម សេចក្ដីថា តថាគតរមែងហៅបុគ្គលនោះ គឺបុគ្គលបែបនោះ បុគ្គលដែលឈ្មោះថា មិនក្រោធ ព្រោះមិនមានអាឃាតចំពោះពួកលោកិយមហាជន សូម្បីអ្នកដែលក្រោធហើយ ដោយអំណាចនៃអាឃាត ។ បុគ្គលដែលឈ្មោះថា រំលត់បានហើយ គឺអ្នកមានអាជ្ញាដាក់ចុះហើយចំពោះជនទាំងឡាយ បុគ្គលដែលឈ្មោះថា មានអាជ្ញាក្នុងខ្លួន ព្រោះជាអ្នកមិនវៀរចាកការប្រហារជនដទៃ ក្នុងកាលដំបង ឬសស្ត្រាមិនមាននៅក្នុងដៃ, បុគ្គលដែលឈ្មោះថា មិនប្រកាន់ ព្រោះមិនប្រកាន់មាំចំពោះជនទាំងឡាយ បុគ្គលដែលឈ្មោះថា ប្រកាន់មាំ ព្រោះប្រកាន់ខន្ធទាំង ៥ ថា " យើង " ថា " របស់យើង " ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ល។

( រឿងសាមណេរ ចប់ )

# ២៨ រឿងព្រះមហាបន្ថកត្ថេរ

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តវេឡុវន ទ្រង់ប្រារព្ធព្រះមហាមហាបន្ថកត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា “**យស្ស រាគោ ច**” ជាដើម ។

## មហាបន្ថកបណ្ដេញប្អូនប្រុសចេញអំពីវិហារ

សេចក្ដីពិស្ដារថាមហាបន្ថកៈនោះបណ្ដេញចូឡបន្ថកៈអ្នកមិនអាចធ្វើ ( ទន្ទេញ ) គាថាមួយគាថាឲ្យចាំស្ទាត

ដោយកាលបួនខែចេញអំពីវិហារដោយពាក្យថា "អ្នកជាអ្នកអភ័ព្វក្នុងព្រះសាសនានេះ ទាំងជាអ្នកសាបសូន្យហើយចាកកោគៈរបស់គ្រហស្ថទៀត, ប្រយោជន៍អ្វីរបស់អ្នកដោយការនៅក្នុងវិហារនេះ, អ្នកចូរចេញអំពីវិហារនេះទៅ, ហើយបិទទ្វារ" ។

ភិក្ខុទាំងឡាយសន្ទនាគ្នាថា "ម្នាលអាវុសោទាំងឡាយ កម្មឈ្មោះនេះព្រះមហាបន្ថកៈបានធ្វើហើយ, សេចក្តីក្រោធប្រហែលជាកើតឡើងសូម្បីដល់ព្រះខីណាស្រព" ។

ព្រះសាស្តាស្តេចមកហើយ ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយកថាអ្វីហ្ន៎ ?" កាលភិក្ខុទាំងនោះក្រាបទូលថា "ដោយកថាឈ្មោះនេះ ព្រះអង្គ" ទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ កិលេសទាំងឡាយមានរាគៈជាដើម រមែងមិនមានដល់ព្រះខីណាស្រពទាំងឡាយឡើយ, ប៉ុន្តែបុត្តរបស់តថាគតធ្វើកម្មនោះ ព្រោះខ្លួនជាអ្នកប្រាថ្នាអត្ថ និងប្រាថ្នាធម៌ជាខាងមុខ" ដូច្នេះហើយត្រាស់ព្រះគាថានេះថា ៖-

២៤ យស្ស រាគោ ច ទោសោ ច មានោ មក្ខោ ច បាតិតោ
សាសបោរិវ អារគ្គា តមហំ ព្រូមិ ព្រាហ្មណំ ។

រាគៈ ទោសៈ មានះ និងមក្ខៈ ដែលបុគ្គលណា ជម្រុះចេញហើយ ដូចគ្រាប់ស្ពៃដែលជ្រុះចុះ អំពីចុង ដែកស្រួច តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **អារគ្គា** ជាដើម សេចក្ដីថា កិលេសទាំងឡាយមានរាគៈជាដើម និងមក្ខៈការលុបលាង គុណអ្នកដទៃជាលក្ខណៈ ដែលបុគ្គលណាធ្វើឲ្យជ្រុះហើយ ដូចគ្រាប់ស្ពៃដែលជ្រុះអំពីចុងដែកស្រួចដូច្នោះ, កិលេសទាំង នោះ រមែងមិនតាំងនៅក្នុងចិត្ត ដូចគ្រាប់ស្ពៃមិនជាប់នៅលើ ចុងដែកស្រួចដូច្នោះ, តថាគតហៅបុគ្គលនោះថាជាព្រាហ្មណ៍

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយ ផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

រឿងព្រះមហាបន្ថកត្ថេរ ចប់

# ២៥ រឿងព្រះបិលិន្ទវច្ឆត្ថេរ

## សេចក្តីខាងដើម

*ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រះបិលិន្ទវច្ឆត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **“អក្កកសំ”** ជាដើម ។*

## ព្រះបិលិន្ទវច្ឆៈប្រើវាទៈថា មនុស្សថោកទាបរហូតជាប់មាត់

បានឮថា ព្រះបិលិន្ទវច្ឆៈនោះ ពោលពាក្យជាដើមថា "មនុស្សថោកទាប ចូរមក, មនុស្សថោកទាប ចូរទៅ" តែង តែហៅគ្រហស្ថព្រមទាំងបព្វជិត ដោយវាទៈថាមនុស្សថោក ទាបជានិច្ច ។

ក្រោយមក ភិក្ខុជាច្រើនក្រាបទូលព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះបិលិន្ទវច្ឆៈតែងតែហៅភិក្ខុទាំង ឡាយ ដោយវាទៈថាមនុស្សថោកទាប" ។

ព្រះសាស្តាត្រាស់ឲ្យហៅលោកមកហើយ ត្រាស់សួរ ថា "ម្នាលបិលិន្ទវច្ឆៈ បានឮថា អ្នកតែងតែហៅភិក្ខុទាំង ឡាយ ដោយវាទៈថាមនុស្សថោកទាបពិតមែនឬ ?" កាល លោកក្រាបទូលថា "ព្រះករុណា ព្រះអង្គ" ទើបទ្រង់ធ្វើ បុព្វេនិវាសរបស់ព្រះបិលិន្ទវច្ឆៈនោះ ទុកក្នុងព្រះហឫទ័យ ហើយត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំលើក ទោសភិក្ខុឈ្មោះបិលិន្ទវច្ឆៈនេះឡើយ, ម្នាលភិក្ខុទាំងឡាយ បិលិន្ទវច្ឆៈមិនបានហៅភិក្ខុទាំងឡាយ ដោយវាទៈថាមនុស្ស ថោកទាបដោយទោសៈទេ, ម្នាលភិក្ខុទាំងឡាយ ៥០០ ជាតិ

របស់ភិក្ខុឈ្មោះបិលិន្ទវច្ឆៈនេះមិនប្រទូស្តប្រទូស្តគ្នា, ទាំងអស់នោះកើតហើយក្នុងត្រកូលព្រាហ្មណ៍ក្នុងខាងក្រោយ, វាទៈថាមនុស្សថោកទាប មនុស្សចង្រៃនោះ បិលិន្ទវច្ឆៈធ្លាប់សន្សំមកអស់កាលយូរហើយ, ពាក្យជាគ្រឿងខាំងខប់ចំពោះជនដទៃ ដែលជាពាក្យដ៏ទ្រគោះគ្រោតគ្រាត ជាពាក្យមិនពិរោះត្រចៀក រមែងមិនមានដល់ព្រះខីណាស្រព, ដ្បិតថា បុគ្គលរបស់តថាគតពោលពាក្យយ៉ាងនោះ ដោយអំណាចនៃការធ្លាប់" កាលនឹងទ្រង់សម្តែងធម៌ បានត្រាស់ព្រះគាថានេះថា

**២៥ អកក្កសំ វិញ្ញាបនឹ គិរំ សច្ចំ ឧទីរយេ**
**យាយ នាភិសជេ កញ្ចិ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា ពោលពាក្យមិនអាក្រក់ ពាក្យជាហេតុឲ្យដឹងសេចក្តីបាន ជាពាក្យពិត ជាពាក្យដែលមិនធ្វើអ្នកណា ឲ្យទាស់ចិត្ត តថាគតហៅបុគ្គលនោះថាជាព្រាហ្មណ៍ ។

## អធិប្បាយគាថា

បណ្ដាបទទាំនោះ បទថា **អក្កកសំ** បានដល់ ពាក្យមិនគ្រោតគ្រាត មិនអាក្រក់ ។

បទថា **វិញ្ញាបនី** បានដល់ ឲ្យដឹងសេចក្ដីបាន ។

បទថា **សច្ចំ** បានដល់ ជាពាក្យពិត ។

បទថា **នាភិសជេ** ជាដើម សេចក្ដីថា បុគ្គលមិនគប្បីញ៉ាំងបុគ្គលដទៃឲ្យទាស់ចិត្ត ដោយអំណាចនៃការធ្វើឲ្យគេក្រោធដោយពាក្យឯណាមួយឡើយ, ធម្មតាព្រះខីណាស្រពគប្បីពោលពាក្យបែបនោះឯង, ហេតុនោះ ទើបតថាគតហៅបុគ្គលនោះថា ជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ៕

( រឿងព្រះបិលិន្ទវច្ឆត្ថេរ ចប់ )

# ២៦ រឿងភិក្ខុមួយរូប

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប ត្រាស់ព្រះធម្មទេសនានេះថា “ **យោគ ទីឃំ** ” ជាដើម ។

# ព្រះខីណាស្រពកាន់យករបស់អ្នកដទៃ
# ដោយបង្សុកូលសញ្ញា

បានឮថា ព្រាហ្មណ៍មិច្ឆាទិដ្ឋិម្នាក់ដែលមានប្រក្រតីនៅក្នុងក្រុងសាវត្ថី ដោះសំពត់សាដកសម្រាប់ដណ្តប់ចេញ ព្រោះខ្លាចក្អិនខ្លួន ដាក់ក្នុងចំណែកម្ខាង អង្គុយបែរមុខទៅខាងក្រៅទ្វារ ។

គ្រានោះ ព្រះខីណាស្រពមួយរូបធ្វើភត្តកិច្ចហើយ ដើរទៅកាន់វិហារ ឃើញសំពត់សាដកនោះហើយ រកមើលខាងនេះខាងនោះ កាលមិនឃើញនរណាៗ ក៏ធ្វើទុក្នុងចិត្តថា " សំពត់សាដកនេះមិនមានម្ចាស់ " អធិដ្ឋានជាសំពត់បង្សុកូលហើយ កាន់យក ។

គ្រានោះ ព្រាហ្មណ៍ឃើញកិរិយារបស់ព្រះខីណាស្រពនោះហើយ ជេរបណ្តើរដើរចូលទៅរកព្រះខីណាស្រពបណ្តើរ ហើយពោលថា " ម្នាលសមណៈត្រងោល អ្នកកាន់យកសំពត់សាដករបស់ខ្ញុំធ្វើអ្វី ?" ។

ព្រះឧទីណាស្រេព. ម្នាលព្រាហ្មណ៍ នុ៎ះជាសំពត់សាដក របស់អ្នកឬ ?

ព្រាហ្មណ៍. អើ សមណះ ។

ព្រះឧទីណាស្រេពពោលថា “ អាត្មាមិនឃើញអ្នកណាម្នាក់ ទើបអាត្មាកាន់យកសំពត់សាដកនោះដោយសញ្ញាថាជាសំពត់បង្សុកូល, អ្នកចូរទទួលយកសំពត់សាដកនោះទៅវិញចុះ ” ឲ្យ ( សំពត់សាដក ) ដល់ព្រាហ្មណ៍នោះហើយទៅកាន់វិហារ ប្រាប់សេចក្តីនោះដល់ភិក្ខុទាំងឡាយ ។

គ្រានោះ ភិក្ខុទាំងឡាយស្តាប់ពាក្យរបស់ព្រះឧទីណា-ស្រេពនោះហើយ កាលទឹងចំអកឲ្យព្រះឧទីណាស្រេពនោះ ក៏បានពោលថា “ ម្នាលអាវុសោ សំពត់សាដកនោះវែង ឬក៏ខ្លី គ្រោតគ្រាត ឬក៏ល្អិត ?” ។

ព្រះឧទីណាស្រេពពោលថា “ ម្នាលអ្នកមានអាយុទាំងឡាយ សំពត់សាដកវែង ឬខ្លី គ្រោតគ្រាត ឬល្អិត ចូរលើកទុកសិនចុះ, សេចក្តីអាល័យសំពត់សាដកនោះរបស់ខ្ញុំមិនមាន ខ្ញុំកាន់យកដោយសម្គាល់ថាសំពត់បង្សុកូល ” ។

ភិក្ខុទាំងឡាយស្តាប់ពាក្យនោះហើយ ក្រាបទូលព្រះ-សាស្តាថា " បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនោះពោលពាក្យមិនពិត ព្យាករព្រះអរហត្តផល " ។

## ព្រះខីណាស្រពមិនកាន់យករបស់អ្នកដទៃ ដោយចេតនាលួច

ព្រះសាស្តាត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះពោលពាក្យពិត, ធម្មតាព្រះខីណាស្រពទាំងឡាយ រមែងមិនកាន់យករបស់អ្នកដទៃ " ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**២៦ យោធ ទីឃំ វ រស្សំ វា អណុំ ថូលំ សុភាសុភំ**
**លោកេ អទិន្នំ នាទិយតិ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា មិនយករបស់វែង ឬខ្លី តូច ឬធំ
អាក្រក់ ឬល្អ ដែលគេមិនបានឲ្យហើយក្នុងលោក
នេះ តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

## អធិប្បាយគាថា

គប្បីជ្រាបសេចក្តីនៃព្រះគាថានោះ ដូច្នេះ :-

ពាក្យថា បុគ្គលណា មិនកាន់យករបស់វែង ឬខ្លី បណ្តាវត្ថុទាំងឡាយ មានសំពត់សាដក និងគ្រឿងប្រដាប់ជាដើម តូច ឬធំ បណ្តាវត្ថុទាំងឡាយ មានកែវមណី និងកែវមុក្តាជាដើម អាក្រក់ ឬល្អ ដោយអំណាចនៃវត្ថុដែលមានតម្លៃច្រើន ឬតម្លៃតិច ដែលអ្នកដទៃហួងហែងហើយក្នុងលោកនេះ, តថាគតហៅបុគ្គលនោះថា ជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ៕

( រឿងភិក្ខុមួយរូប ចប់ )

## ២៧ រឿងព្រះសារីបុត្តត្ថេរ

### សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសារីបុត្រ ត្រាស់ព្រះធម្មទេសនានេះថា “**អាសា យស្ស**” ជាដើម ។

## ពួកភិក្ខុយល់ថាព្រះសារីបុត្រនៅមានតណ្ហា

បានឮថា ព្រះថេរៈនោះមានភិក្ខុប្រមាណ ៥០០ ជាបរិវារ ទៅកាន់វិហារមួយក្នុងជនបទ ហើយចាំវស្សានៅទីនោះ

មនុស្សទាំងឡាយ ឃើញព្រះថេរៈហើយ ត្រៀមសំពត់ចំណាំវស្សាទុកយ៉ាងច្រើន ។ ព្រះថេរៈបវារណាហើយ កាលមិនទាន់បានទទួលសំពត់ចំណាំវស្សា, កាលនឹងទៅកាន់សម្នាក់ព្រះសាស្តា បានផ្តាំភិក្ខុទាំងឡាយថា “ កាលសំពត់ចំណាំវស្សាដែលមនុស្សទាំងឡាយ នាំមកហើយដើម្បីភិក្ខុកំលោះនិងសាមណេរទាំងឡាយ ពួកអ្នកទទួលហើយបញ្ជូនទៅឲ្យខ្ញុំ ឬទទួលទុកហើយគប្បីបញ្ជូនដំណឹងទៅប្រាប់ខ្ញុំ ” ព្រះថេរៈនោះ លុះផ្តាំយ៉ាងនេះហើយ ក៏ទៅកាន់សម្នាក់ព្រះសាស្តា ។

ភិក្ខុទាំងឡាយសន្ទនាគ្នាថា “ រហូតមកដល់ពេលនេះ ព្រះសារីបុត្រនៅមានតណ្ហាជាប្រាកដ, ត្បិតថា ព្រះថេរៈបាន

ផ្តាំភិក្ខុទាំងឡាយថា     កាលពួកមនុស្សប្រគេនសំពត់ចំណាំ វស្សាហើយ,  ពួកអ្នកគប្បីបញ្ជូនសំពត់ចំណាំវស្សានោះទៅ ឲ្យពួកសទ្ធិវិហារិករបស់ខ្ញុំ,  ឬរក្សាទុកហើយគប្បីបញ្ជូនដំណឹង ទៅឲ្យខ្ញុំ ដូច្នេះហើយ ទើបមក " ។

ព្រះសាស្តាដោះការយល់ខុសរបស់ពួកភិក្ខុ

ព្រះសាស្តាស្តេចមកហើយ ត្រាស់សួរថា " ម្នាលភិក្ខុ ទាំងឡាយ  អ្នកទាំងឡាយសន្ទនាគ្នាអំពីកថាអ្វីហ្ន៎ ?" កាល ភិក្ខុទាំងនោះទូលថា    អំពីកថាឈ្មោះនេះ,    ទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ   តណ្ហារមែងមិនមានដល់បុត្រតថាគត, ប៉ុន្តែបុត្ររបស់តថាគតពោលយ៉ាងនោះ ដោយធ្វើទុកក្នុងចិត្ត ថា ការសោបសូន្យចាកបុណ្យរបស់ពួកមនុស្ស និងការសោប សូន្យចាកលាភដ៏ប្រពៃតាមធម៌របស់ភិក្ខុកំលោះ និងសាមណេរ ទាំងឡាយកុំបីមានឡើយ"ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**២៧ អាសា យស្ស ន វិជ្ជន្តិ អស្មឹ លោកេ បរម្ហិ ច**
**និរាសយំ វិសំយុត្តំ     តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា  មិនមានសេចក្តីប្រាថ្នាក្នុងលោក

នេះផង ក្នុងលោកខាងមុខផង តថាគតហៅបុគ្គល
នោះ ដែលមិនមានសេចក្តីប្រាថ្នា ដែលផុតស្រឡះ
ចាកកិលេស ថាជាព្រាហ្មណ៍ ។

## អធិប្បាយគាថា

តណ្ហា ឈ្មោះថា **អាសា** ក្នុងព្រះគាថានោះ ។

បទថា **និរាសាសំ** បានដល់ មិនមានតណ្ហា ។

បទថា **វិសំយុត្តំ** សេចក្តីថា តថាគតហៅអ្នកដែលផុត
ស្រឡះចាកកិលេសទាំងពួងនោះថា ជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនសម្រេចអរិយផល
ទាំងឡាយ មានសោតាបត្តិផលជាដើម ៕

( រឿងព្រះសារីបុត្រ ចប់ )

## ២៨ រឿងព្រះមហាមោគ្គល្លានត្ថេរ

# សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះមហាមោគ្គល្លាន ត្រាស់ព្រះធម្មទេសនានេះថា “**យស្សា-លយា**” ជាដើម ។

## ព្រះសាស្តាទ្រង់សម្តែងលក្ខណៈរបស់ព្រាហ្មណ៍

រឿងនេះក៏ដូចរឿងមុននោះដែរ ។ ប៉ុន្តែក្នុងរឿងនេះព្រះសាស្តាថា ព្រះមហាមោគ្គល្លាន ជាអ្នកមិនមានតណ្ហា ហើយត្រាស់ព្រះគាថានេះថា :-

**២៨ យស្សាលយា ន វិជ្ជន្តិ អញ្ញាយ អកថង្កថី**
**អមតោគធំ អនុប្បត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។**

អ្នកណា មិនមានសេចក្តីអាល័យ គឺតណ្ហា
មិនមានសេចក្តីសង្ស័យក្នុងអ្វីសោះ ព្រោះដឹង
ច្បាស់ធម៌ តថាគតហៅបុគ្គលនោះ ដែលមាន
ចិត្តចុះស៊ប់កាន់ព្រះនិព្វាន ដែលមានព្រះអរហត្ត-
ផលដល់ហើយ ដោយលំដាប់ ថាជាព្រាហ្មណ៍ ។

## អធិប្បាយគាថា

តណ្ហា ឈ្មោះថា **អាល័យ** ក្នុងព្រះគាថានោះ ។

បាទព្រះគាថាថា **អញ្ញាយ អកថង្កថី** សេចក្ដីថា អ្នកដឹងវត្ថុ ៨ តាមការពិតហើយ ជាអ្នកមិនមានសេចក្ដីសង្ស័យ ដោយសេចក្ដីសង្ស័យដែលមានវត្ថុ ៨ យ៉ាង ។

បាទព្រះគាថាថា **អមតោគធំ អនុប្បត្តំ** សេចក្ដីថា តថាគតហៅបុគ្គលនោះ ដែលមានចិត្តចុះស៊ប់កាន់ព្រះនិព្វានឈ្មោះអមតៈ ដែលមានព្រះអរហត្តផលដល់ហើយ ដោយលំដាប់ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយ-ផលទាំងឡាយ មានសោតាបត្តិផលជាដើម ។៚

( រឿងព្រះមហាមោគ្គល្លាន ចប់ )

## ២៩ រឿងព្រះរេវតត្ថេរ

## សេចក្ដីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តបុព្វារាម ទ្រង់ប្រារព្ធព្រះរេវតត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា “**យោ បុញ្ញញ្ច** ” ជាដើម ។

## ព្រះខីណាស្រពមិនមានបុណ្យនិងបាប

រឿងខ្ញុំម្ចាស់បានឲ្យពិស្តារហើយ ក្នុងអដ្ឋកថានៃព្រះគាថាថា “ **គាមេ វា យទិ វា រញ្ញេ** ” ជាដើម ។

ពិតណាស់ ក្នុងរឿងនោះខ្ញុំម្ចាស់បានពោលថា “ ថ្ងៃស្អែកឡើង ភិក្ខុទាំងឡាយសន្ទនាគ្នាថា “ អស្ចារ្យណាស់ សាមណេរអ្នកមានលាភ អស្ចារ្យណាស់ សាមណេរអ្នកមានបុណ្យ, តែម្នាក់ឯង អាចសាងផ្ទះកំពូល ៥០០ សម្រាប់ភិក្ខុ ៥០០ រូបបាន ”, ។

ព្រះសាស្តាស្តេចមកហើយ ត្រាស់សួរថា “ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយកថាអ្វីហ្ន៎ ?” កាលភិក្ខុទាំងនោះក្រាបទូលថា “ដោយកថាឈ្មោះនេះ ព្រះអង្គ” ក៏ទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ បុណ្យរមែងមិនមានដល់បុត្តរបស់តថាគត, បាបក៏មិនមានដែរ, បុណ្យបាប

ទាំងពីរបុគ្គរបស់តថាគតលះបង់អស់ហើយ”  ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា ៖-

**២៩ យោធ បុញ្ញញ្ច បាបញ្ច ឧភោ សង្គំ ឧបច្ចគា**
**អសោកំ វិរជំ សុទ្ធំ  តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា ក្នុងលោកនេះ លះបង់បុណ្យ
និងបាបទាំង ២ និងកិលេសជាគ្រឿងចំពាក់
( មានរាគៈជាដើម ) ចេញហើយ តថាគត
ហៅបុគ្គលនោះ ដែលជាអ្នកមិនមានសេចក្តី
សោក មានធូលី គឺកិលេសអស់ហើយ ជា
អ្នកបរិសុទ្ធ ថាជាព្រាហ្មណ៍ ។

**អធិប្បាយគាថា**

បណ្តាបទទាំងនោះ បទថា **ឧភោ** សេចក្តីថា លះបង់បុណ្យនិងបាបសូម្បីទាំងពីរ ។

បទថា **សង្គំ** បានដល់ កិលេសជាគ្រឿងចំពាក់ មានរាគៈជាដើម ។

បទថា **ឧបច្ចគា** បានដល់ ឈានកន្លងហើយ ។ អធិប្បាយថា តថាគតហៅបុគ្គលដែលមិនមានសេចក្តីសោក ព្រោះមិនមានសេចក្តីសោកដែលមានវដ្តៈជាមូល បុគ្គល ដែលឈ្មោះថាមានធុលីទៅប្រាសហើយ ព្រោះមិនមានធុលី គឺរាគៈជាដើមខាងក្នុង បុគ្គលដែលឈ្មោះថាបរិសុទ្ធហើយ ព្រោះជាអ្នកមិនមានឧបក្កិលេសនោះថា ជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

រឿងព្រះរេវតត្ថេរ ចប់

## ៣០ រឿងព្រះចន្ទាភត្ថេរ

### សេចក្តីខាងដើម

*ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះចន្ទាភត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា “**ចន្ទំវ**” ជាដើម*

### ព្រះចន្ទាភៈធ្លាប់ជាឈ្មួញខ្លឹមច័ន្ទក្រហម

*អនុបុព្វីកថាក្នុងរឿងព្រះចន្ទាភត្ថេរ មានដូចតទៅនេះ*

*“បានឮថា ក្នុងអតីតកាល ឈ្មួញក្នុងក្រុងពារាណសីម្នាក់គិតថា “យើងនឹងទៅកាន់បច្ចន្តជនបទហើយ នាំខ្លឹមច័ន្ទក្រហមមក” យកវត្ថុជាច្រើនមានសំពត់និងគ្រឿងអាភរណ៍ជាដើម ទៅកាន់បច្ចន្តជនបទដោយរទេះ ៥០០ បញ្ឈប់រទេះនៅជិតទ្វារស្រុកហើយ សួរពួកក្មេងគង្វាលគោក្នុងព្រៃថា “មនុស្សណាមួយក្នុងស្រុកនេះ ដែលមកប្រកបការងារនាជើងភ្នំនេះមានដែរឬ ?”*

*ពួកក្មេងគង្វាលគោ. បាទ មាន ។*

ឈ្មួញ. មនុស្សនោះឈ្មោះអ្វី ?

ពួកក្មេងក្មៀល. មនុស្សនោះឈ្មោះឯណោះ ។

ឈ្មួញ. ក៏កិរិយាឬបុត្តទាំងឡាយរបស់គេ មានឈ្មោះអ្វីដែរ ?

ពួកក្មេងក្មៀលគោ. ពួកគេមានឈ្មោះយ៉ាងនេះ ៗ ។

ឈ្មួញ. ក៏ផ្ទះរបស់ពួកគេនៅឯណា ?

ពួកក្មេងក្មៀលគោ. ផ្ទះរបស់ពួកគេនៅឯណោះ ។

ឈ្មួញអង្គុយលើយានតូចដ៏ជាទីសប្បាយ បរទៅកាន់ទ្វារផ្ទះរបស់ពួកគេ តាមសញ្ញាដែលពួកក្មេងក្មៀលគោឲ្យហើយ ចុះអំពីយាន ចូលទៅកាន់ផ្ទះហើយហៅស្ត្រីនោះថា "ម្នាលស្ត្រីឈ្មោះឯណោះ" ស្ត្រីនោះគិតថា "បុគ្គលនេះនឹងជាញាតិរបស់យើង" ក៏មកយ៉ាងរហ័ស ក្រាលអាសនៈទទួល។

ឈ្មួញនោះ អង្គុយលើអាសនៈនោះហើយ សួរថា "សម្លាញ់របស់ខ្ញុំទៅណា ?"

ស្ត្រី. បពិត្រនាយ គេទៅព្រៃហើយ ។

ឈ្មួញបញ្ចាក់ឈ្មោះរបស់មនុស្សទាំងពួងហើយ សួរថា "បុត្តរបស់ខ្ញុំឈ្មោះឯណោះ ធិតារបស់ខ្ញុំឈ្មោះឯណោះទៅណា ? ដូច្នេះហើយ ពោលថា "នាងគប្បីឲ្យសំពត់ និងគ្រឿងអាភរណ៍ទាំងនេះដល់ជនទាំងនោះ, ហើយនៅពេលដែលសម្លាញ់របស់ខ្ញុំគេត្រឡប់មកអំពីព្រៃ នាងគប្បីឲ្យសំពត់និងគ្រឿងអាភរណ៍នេះ" ហើយឲ្យ ( វត្ថុទាំងនោះ ) ។ នាងបានសក្ការៈយ៉ាងក្រៃលែងចំពោះឈ្មួញនោះ ហើយនៅដែលស្វាមីមក ក៏ពោលថា "បពិត្រនាយ បុរសនេះ មកដល់ផ្ទះរបស់យើងពេលណា គេបញ្ចាក់ឈ្មោះរបស់ជនទាំងពួងហើយ ឲ្យវត្ថុនេះនិងវត្ថុនេះ" ចំណែកស្វាមីរបស់ស្ត្រីនោះក៏ធ្វើកិច្ចដែលគួរធ្វើចំពោះឈ្មួញនោះ ។

លុះដល់ពេលល្ងាច ឈ្មួញនោះអង្គុយលើទីដេកសួរថា "នែសម្លាញ់ សម្លាញ់ឯងតែងតែត្រាច់ទៅកាន់ជើងភ្នំជានិច្ច តើសម្លាញ់ឯងធ្លាប់ឃើញអ្វីច្រើនជាងគេ ?"

បុរសម្ចាស់ផ្ទះ. ខ្ញុំមិនឃើញអ្វីដទៃទេ, ប៉ុន្តែខ្ញុំឃើញដើមឈើមួយប្រភេទមានមែកក្រហម ។

ឈ្មួញ. ដើមឈើប្រភេទនោះមានច្រើនឬ ?

បុរសម្ចាស់ផ្ទះ. បាទ ដើមឈើប្រភេទនោះមានច្រើនៗ

ឈ្មួញពោលថា "បើដូច្នោះ លោកចូរបង្ហាញឈើប្រភេទនោះដល់ខ្ញុំ" ដូច្នេះហើយ ទៅជាមួយនិងបុរសនោះកាត់ដើមចន្ទន៍ក្រហមដាក់ឲ្យពេញរទេះ ៥០០ ហើយ មុននឹងធ្វើដំណើរមកវិញ បានពោលទៅបុរសនោះថា " ម្នាលសម្លាញ់ ផ្ទះរបស់ខ្ញុំនៅឯក្រុងពារាណសី, លោកគប្បីទៅកាន់សម្នាក់របស់ខ្ញុំអស់កាលតាមកាលចុះ, ខ្ញុំមិនត្រូវការអ្វីដទៃទេ, លោកគប្បីនាំយកតែឈើដែលមានមែកក្រហមបានហើយ ។ បុរសនោះយល់ព្រមថា "ប្រពៃហើយ" ហើយនៅដែលមកកាន់ផ្ទះរបស់ឈ្មួញនោះ តែងតែនាំយកឈើដែលមានមែកក្រហមមកជាមួយជានិច្ច ។ ចំណែកឈ្មួញនោះក៏បានឲ្យយ៉ាងច្រើនដល់បុរសនោះ ។

ក្រោយមក កាលព្រះកស្សបទសពលបរិនិព្វានហើយ កាលមហាជនប្រតិស្ឋានព្រះស្តូបមាសឡើងហើយ,

បុរសនោះបាននាំយកដើមចន្ទន៍ក្រហមជាច្រើន ទៅកាន់ក្រុងពារាណសី ។

គ្រានោះ ឈ្មួញដែលជាសម្លាញ់របស់បុរសនោះ ឲ្យគេកិនដើមចន្ទន៍ក្រហមជាច្រើនដាក់ពេញថាសហើយ ពោលថា "នែសម្លាញ់ ចូរមក, ពួកយើងនឹងទៅកាន់កន្លែងដែលគេកសាងព្រះចេតិយ ចាំកត្តុង្គិន ពួកយើងសឹមត្រឡប់មកវិញ" បាននាំបុរសនោះទៅកាន់ទីនោះ បូជាព្រះចេតិយដោយខ្លឹមចន្ទន៍ក្រហម ។

បុរសអ្នកមានប្រក្រតីនៅក្នុងបច្ចន្តជនបទ ជាសម្លាញ់របស់បុរសនោះ បានកសាងមណ្ឌលព្រះច័ន្ទដោយដើមចន្ទន៍ក្រហម ក្នុងផ្ទៃនៃព្រះចេតិយ, បុព្វកម្មរបស់បុរសនោះមានត្រឹមតែប៉ុណ្ណោះ ។

## អានិសង្សនៃការបូជាព្រះចេតិយដោយដើមចន្ទន៍ក្រហម

បុរសនោះចុតិចាកអត្តភាពនោះហើយ បដិសន្ធិក្នុងទេវលោក ញុំាងពុទ្ធន្តរមួយឲ្យអស់ទៅក្នុងទេវលោកនោះ ក្នុងពុទ្ធុប្បាទកាលនេះ បដិសន្ធិក្នុងត្រកូលព្រាហ្មណ៍មហា

សាល ក្នុងក្រុងរាជគ្រឹះ ។ រស្មីដូចមណ្ឌលព្រះច័ន្ទតាំងឡើង អំពីមណ្ឌលផ្ចិតនៃទារកនោះ ។ ព្រោះហេតុនោះ ទើបពួក ញាតិដាក់ឈ្មោះឲ្យទារកនោះថា "ចន្ទាភៈ" បានឮថា នោះជា ផលនៃការធ្វើមណ្ឌលព្រះច័ន្ទ ក្នុងផ្ទៃនៃព្រះចេតិយរបស់ ទារកនោះ ។

ព្រាហ្មណ៍ទាំងឡាយប្រឹក្សាគ្នាថា "ពួកយើងនាំយក ទារកនេះទៅហើយ អាចនឹងស្វែងរកលាភបាន" ដូច្នេះហើយ ឲ្យទារកនោះអង្គុយលើយានតូច នាំទៅដោយពោលពាក្យថា "អ្នកណា យកដៃពាល់ត្រូវសរីរៈរបស់ចន្ទាភៈព្រាហ្មណ៍នេះ, អ្នកនោះនឹងបានឥស្សរិយសម្បត្តិបែបនេះ" ។

លុះត្រាតែ ឲ្យទ្រព្យមួយរយខ្វះ មួយពាន់ខ្វះ មួយ សែនខ្វះដល់ព្រាហ្មណ៍ទាំងនោះ ទើបអាចពាល់ទារកនោះ ដោយដៃបាន ។

ព្រាហ្មណ៍ទាំងនោះ ត្រាច់ទៅយ៉ាងនេះ ក៏ដល់ក្រុង សាវត្ថីដោយលំដាប់ បានសំណាក់អាស្រ័យនៅចន្លោះព្រះ នគរនិងវិហារ ។

អរិយសាវកប្រមាណ ៥ កោដិនៅក្នុងក្រុងសាវត្ថីនោះ ថ្វាយទានក្នុងកាលមុនភត្តហើយ ខាងក្រោយភត្ត មានដៃកាន់គ្រឿងក្រអូបកម្រងផ្កាសំពត់និងភេសជ្ជៈជាដើម ទៅកាន់វិហារដើម្បីស្តាប់ធម៌ ។ ព្រាហ្មណ៍ទាំងនោះឃើញអរិយសាវកទាំងនោះហើយ សួរថា "អ្នកទាំងឡាយទៅណា ?"

អរិយសាវក. ពួកយើងទៅសម្នាក់ព្រះសាស្តា ដើម្បីស្តាប់ធម៌ ។

ពួកព្រាហ្មណ៍. អ្នកទាំងឡាយចូរមក, អ្នកទាំងឡាយទៅកាន់សម្នាក់ព្រះសាស្តាធ្វើអ្វី ? អានុភាពដូចអានុភាពនៃចន្ទាភៈព្រាហ្មណ៍របស់ពួកយើងមិនមាន, ព្រោះថា ជនទាំងឡាយណាពាល់ត្រូវសរីរៈរបស់ចន្ទាភៈព្រាហ្មណ៍នេះ ហើយ ជនទាំងនោះ រមែងបានសម្បត្តិឈ្មោះនេះ, ដូច្នេះអ្នកទាំងឡាយចូរមក, ចូរមកមើលចន្ទាភៈព្រាហ្មណ៍នោះ ។

អរិយសាវកទាំងនោះពោលថា " ឈ្មោះថាអានុភាពនៃព្រាហ្មណ៍ឈ្មោះចន្ទាភៈរបស់ពួកលោកជាយ៉ាងណា ? ព្រះសាស្តារបស់ពួកយើងប៉ុណ្ណោះ មានអានុភាពច្រើន" ។

អរិយសាវកនិងព្រាហ្មណ៍ទាំងនោះ មិនអាចញ៉ាំងគ្នានិងគ្នាឲ្យយល់ព្រមបាន ទើបពោលថា "ពួកយើងទៅកាន់វិហារហើយ នឹងដឹងអានុភាពរបស់ចន្ទាភៈព្រាហ្មណ៍ ឬរបស់ព្រះសាស្តារបស់ពួកយើង" ដូច្នេះហើយបាននាំចន្ទាភៈព្រាហ្មណ៍នោះទៅកាន់វិហារ ។

## ចន្ទាភៈព្រាហ្មណ៍ស្រអាប់ក្នុងសំណាក់ព្រះសាស្តា

ព្រះសាស្តា កាលចន្ទាភៈព្រាហ្មណ៍នោះ ចូលទៅដល់សំណាក់របស់ព្រះអង្គភ្លាម, ក៏ទ្រង់ធ្វើរស្មីដូចរស្មីព្រះច័ន្ទឲ្យអស់ទៅ ។ ចន្ទាភៈព្រាហ្មណ៍នោះ មានឧបមាដូចជាសត្វក្អែកក្នុងកញ្ច្រែងធ្យូង ក្នុងសម្នាក់ព្រះសាស្តា ។

គ្រានោះ ព្រាហ្មណ៍ទាំងឡាយក៏នាំចន្ទាភៈនោះទៅកាន់ចំណែកម្ខាង ។ រស្មីក៏ជាធម្មជាតិតាំងនៅដូចដើមវិញ ។

ព្រាហ្មណ៍ទាំងនោះ ក៏នាំមកកាន់សម្នាក់ព្រះសាស្តាម្តងទៀត ។ រស្មីក៏អស់ទៅដូចមុនទៀត ។ ចន្ទាភៈព្រាហ្មណ៍ទៅហើយត្រឡប់មកវិញដោយអាការយ៉ាងនេះរហូតអស់ ៣ដង ឃើញរស្មីរបស់ខ្លួនបាត់ទៅ អស់ទៅយ៉ាងនោះ ក៏គិតថា

“ សមណៈនេះ ប្រហែលជាចេះមន្តដែលជាគ្រឿងធ្វើរស្មីឲ្យអស់ទៅហើយមើលទៅ ” លុះគិតដូច្នេះហើយ ក៏ទូលសួរព្រះសាស្តាថា “ បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់ជ្រាបមន្តជាគ្រឿងវិនាសទៅនៃរស្មីឬ ?” ។

ព្រះសាស្តា. អើ តថាគតជ្រាប ។

ចន្ទាភៈ. បើដូច្នោះ សូមព្រះអង្គទ្រង់ប្រទានឲ្យខ្ញុំព្រះអង្គខ្លះផង ។

ព្រះសាស្តា. តថាគតមិនអាចឲ្យដល់បុគ្គលដែលមិនបួសបានទេ ។

ចន្ទាភៈពោលទៅកាន់ព្រាហ្មណ៍ទាំងនោះថា “ កាលខ្ញុំរៀនមន្តនោះហើយ ខ្ញុំនឹងជាអ្នកប្រសើរក្នុងជម្ពូទ្វីបទាំងមូល, ដូច្នេះ ពួកលោកចូររង់ចាំខ្ញុំនៅទីនេះសិន, ខ្ញុំនឹងបួសរៀនមន្តតែ ២-៣ ថ្ងៃប៉ុណ្ណោះ ” ។ លុះប្រាប់ព្រាហ្មណ៍ទាំងនោះដូច្នោះហើយ ក៏ទូលសូមព្រះសាស្តាដើម្បីបព្វជ្ជា ហើយក៏បានឧបសម្បទាក្នុងសម្នាក់ព្រះសាស្តា ។

គ្រានោះ ព្រះសាស្តាក៏ទ្រង់ត្រាស់ប្រាប់អាការ ៣២ ដល់ចន្ទាភៈភិក្ខុនោះ ។

ចន្ទាភៈនោះទូលសួរព្រះសាស្តា “ បពិត្រព្រះអង្គដ៏ចម្រើន តើព្រះតម្រាស់ដែលព្រះអង្គត្រាស់ប្រាប់ខ្ញុំព្រះអង្គនេះ ជាអ្វី ?”

ព្រះសាស្តា. នេះជាបរិកម្មនៃមន្ត, អ្នកគួរស្វាធ្យាយ ។

ចំណែកពួកព្រាហ្មណ៍មកក្នុងចន្លោះ ៗ ហើយ ទូលសួរថា “ អ្នករៀនមន្តបានហើយឬ ?”

ចន្ទាភៈ. នៅឡើយទេ, ខ្ញុំកំពុងរៀន ។

ចន្ទាភៈភិក្ខុនោះ បានសម្រេចព្រះអរហត្តដោយកាល ២-៣ ថ្ងៃប៉ុណ្ណោះ ក្នុងពេលដែលពួកព្រាហ្មណ៍មកសួរ ក៏ពោលថា “ អ្នកទាំងឡាយចូរទៅចុះ, ឥឡូវនេះ ខ្ញុំមិនមានធម៌ជាគ្រឿងទៅទេ គឺអស់ធម៌ដែលជាគ្រឿងទៅហើយ ” ។

ភិក្ខុទាំងឡាយក្រាបទូលព្រះសាស្តាថា “ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះពោលពាក្យមិនពិត ព្យាករព្រះអរហត្តផល ” ។

## ព្រះទីណាស្រេចពោលតែពាក្យពិត

ព្រះសាស្តាត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ចន្ទាភៈបុត្តរបស់តថាគតមានអាសវៈអស់ហើយ ពោលតែពាក្យពិតប៉ុណ្ណោះ " ដូច្នេះហើយត្រាស់ព្រះគាថានេះថាៈ-

**៣០ ចន្ទំវ វិមលំ សុទ្ធំ វិប្បសន្នមនាវិលំ**
**នន្ទិភវបរិក្ខីណំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគតហៅបុគ្គល ដែលមិនមានសេចក្តី
សៅហ្មង ដូចព្រះចន្ទប្រាសចាកមន្ទិល ជាអ្នក
បរិសុទ្ធ មានចិត្តជ្រះថ្លា មិនកករល្អក់ អស់
សេចក្តីត្រេកអរក្នុងភពហើយនោះ ថាជាព្រាហ្មណ៍ ។

**អធិប្បាយគាថា**

បណ្តាបទទាំងនោះ បទថា **វិមលំ** បានដល់ ប្រាសចាកមន្ទិលមានពពកជាដើម ។

បទថា **សុទ្ធំ** បានដល់ មិនមានឧបក្កិលេស ។

បទថា **វិប្បសន្នំ** បានដល់ មានចិត្តផូរផង់ មានចិត្តជ្រះថ្លាហើយ ។

បទថា **អនាវិលំ** បានដល់ ប្រាសចាកមន្ទិល មានកិលេសជាដើម ។

បទថា **នន្ទិភវបរិក្ខីណំ** សេចក្តីថា តថាគតហៅបុគ្គលអ្នកមានតណ្ហាក្នុងភពអស់ហើយនោះថា ជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

រឿងចន្ទាភៈភិក្ខុ ចប់

## ៣០ រឿងព្រះសីវលិត្ថេរ

### សេចក្តីខាងដើម

ព្រះសាស្តា កាលទ្រង់អាស្រ័យក្រុងកុណ្ឌិកោលិយៈ ទ្រង់គង់នៅក្នុងព្រៃឈ្មោះកុណ្ឌធាន ទ្រង់ប្រារព្ធព្រះសីវលី ត្រាស់ព្រះធម្មទេសនានេះថា “**យោ ឥមំ**” ជាដើម ។

## ព្រះនាងសុប្បវាសាទ្រង់គ្របសង្កត់ សេចក្តីទុក្ខបានដោយវិតក្ក ៣ ប្រការ

សេចក្តីពិស្តារថា សម័យមួយ ព្រះធិតារបស់ព្រះកោលិយវង្ស ព្រះនាងសុប្បវាសា ទ្រង់ព្រះគភ៌អស់ ៧ ឆ្នាំ មានព្រះគភ៌ដ៏វង្វេង ៧ ថ្ងៃទៀត ត្រូវទុក្ខវេទនាដ៏ខ្លាំងក្លាពាល់ត្រូវហើយ, ទ្រង់គ្របសង្កត់ទុក្ខវេទនានោះ ដោយវិតក្ក ៣ ប្រការគឺ “ ព្រះមានព្រះភាគអង្គណា ទ្រង់សម្តែងធម៌ដើម្បីលះបង់ទុក្ខនៃរូបនេះ ព្រះមានព្រះភាគអង្គនោះ ជាអ្នកបដិបត្តិដ៏ប្រពៃហើយហ្ន៎ ១, ព្រះសង្ឃសាវកឯណា ជាអ្នកបដិបត្តិដើម្បីលះបង់ទុក្ខនៃរូបនេះ, ព្រះសង្ឃសាវកនោះរបស់ព្រះមានព្រះភាគអង្គនោះ ជាអ្នកបដិបត្តិប្រពៃហើយហ្ន៎ ១, ទុក្ខបែបនេះ មិនមានក្នុងព្រះនិព្វានណា, ព្រះនិព្វាននោះជាសុខពិតមែនហ្ន៎ ១” , ដូច្នេះហើយ ទ្រង់បញ្ជូនព្រះស្វាមី

ទៅកាន់សម្នាក់ព្រះសាស្តា, កាលព្រះស្វាមីនោះ ក្រាបទូលការថ្វាយបង្គំចំពោះព្រះសាស្តា តាមពាក្យរបស់ព្រះនាងហើយ, ដំណាលគ្នានិងព្រះសាស្តាត្រាស់ថា “ ព្រះធិតាព្រះកោលិយវង្ស ព្រះនាមថាសុប្បវាសាចូរជាអ្នកមានសេចក្តីសុខ មិនមានរោគ, ប្រសូតិព្រះឱរសដោយមិនមានរោគចុះ” ក៏ជាអ្នកមានសេចក្តីសុខ មិនមានរោគ ប្រសូតិព្រះឱរសអ្នកមិនមានរោគដោយសិរីសួស្តីហើយ ទ្រង់និមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ថ្វាយមហាទានអស់ ៧ ថ្ងៃ ។

## ព្រះឱរសបានសម្រេចព្រះអរហត្ត

ចំណែកព្រះឱរសរបស់ព្រះនាង កាន់យកធម្មក្រកត្រងទឹកប្រគេនភិក្ខុសង្ឃបាន ចាប់តាំងអំពីថ្ងៃប្រសូតិនោះឯង ។ ក្រោយមក ព្រះឱរសនោះស្តេចទៅបព្វជ្ជាហើយបានសម្រេចព្រះអរហត្ត ។

ក្រោយមកទៀត ពួកភិក្ខុសន្ទនាគ្នាក្នុងធម្មសភាថា “អ្នកមានអាយុទាំងឡាយ អ្នកទាំងឡាយចូរមើលចុះ ភិក្ខុអ្នកដល់ព្រមដោយធម៌ដែលជាឧបនិស្ស័យបែបនេះ នៅ

សោយទុក្ខក្នុងផ្ទៃមាតាអស់កាលប្រមាណប៉ុណ្ណេះ, ចាំបាច់ពោលទៅថ្វីដល់ជនដទៃនោះ, ទុក្ខយ៉ាងច្រើន ត្រូវភិក្ខុនេះដកឡើងហើយ"

ព្រះសាស្ដាស្ដេចមកហើយ ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយកថាអ្វី ?" កាលភិក្ខុទាំងនោះក្រាបទូលថា "ដោយកថាឈ្មោះនេះ ព្រះអង្គ" ទើបត្រាស់ថា "អើភិក្ខុទាំងឡាយ បុត្តតថាគតផុតចាកទុក្ខប្រមាណប៉ុណ្ណេះហើយ ឥឡូវនេះ ធ្វើព្រះនិព្វានឲ្យជាក់ច្បាស់ហើយ" ដូច្នេះហើយ ត្រាស់ព្រះគថានេះថា ៖-

**៣ យោមំ បលិបថំ ទុគ្គំ សំសារំ មោហមច្ចគា**
**តិណ្ណោ បារគតោ ឈាយី អនេជោ អកថង្កថី**
**អនុបាទាយ និព្វុតោ តមហំ ព្រូមិ ព្រាហ្មណំ**

បុគ្គលណា កន្លងផ្លូវ គឺរាគៈ និងភក់ដែលគេឆ្លងបានដោយកម្រ គឺកិលេស និងសង្សារវដ្ដ និងមោហៈទាំងនេះបាន ជាអ្នកឆ្លងអន្លង់ទាំង ៤ បានដល់ត្រើយ គឺព្រះនិព្វាន ជាអ្នកមានឈាន មិន

ញាប់ញ័រដោយតណ្ហា មិនមានសេចក្ដីសង្ស័យ
មិនប្រកាន់មាំ ជាអ្នករលត់កិលេសហើយ តថា-
គតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

## អធិប្បាយគាថា

គប្បីជ្រាបសេចក្ដីនៃព្រះគាថានោះ ( ដូច្នេះ ) ៖-

សេចក្ដីថា ភិក្ខុណា កន្លងផ្លូវគឺរាគៈ ភក់គឺកិលេស សង្សារវដ្ដ និងមោហៈដែលមិនឲ្យចាក់ធ្លុះអរិយសច្ចទាំង ៤ មានប្រក្រតីសម្លឹងដោយឈាន ២ យ៉ាង, ឈ្មោះថាមិនមានកិលេសជាគ្រឿងញាប់ញ័រ ព្រោះមិនមានតណ្ហា, ឈ្មោះថាមិនមានសេចក្ដីសង្ស័យ ដែលជាហេតុពោលថាយ៉ាងណា ព្រោះមិនមានវាចាជាគ្រឿងពោលយ៉ាងណា, ឈ្មោះថាមិនប្រកាន់មាំ ព្រោះមិនមានឧបាទាន, ឈ្មោះរលត់ហើយ ព្រោះជាអ្នករលត់កិលេស, តថាគតហៅភិក្ខុនោះថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

រឿងព្រះសីវលិត្ថេរ ចប់

## ៣២ រឿងព្រះសុន្ទរសមុទរត្ថេរ

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសុន្ទរសមុទរត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា “**យោធ កាមេ**” ជាដើម ។

## កុលបុត្តចេញបួស

បានឮថា ក្នុងក្រុងសាវត្ថី មានកុលបុត្តម្នាក់ឈ្មោះសុន្ទរសមុទរកុមារ កើតក្នុងត្រកូលធំដែលមានសម្បត្តិ ៤០ កោដិ ។

ថ្ងៃមួយ កុមារនោះឃើញមហាជនមានគ្រឿងក្រអូបនិងកម្រងផ្កាក្នុងដៃទៅកាន់វត្តជេតពនដើម្បីស្តាប់ធម៌ ក៏សួរថា “ពួកលោកទៅណា ?” កាលមហាជនប្រាប់ថា “ពួកយើងទៅកាន់សំណាក់ព្រះសាស្តាដើម្បីស្តាប់ព្រះធម៌”, ក៏ពោលថា “ខ្ញុំទៅដែរ” ហើយទៅជាមួយមហាជនអង្គុយខាងចុងបរិស័ទ ។

ព្រះសាស្តា ទ្រង់ជ្រាបអធ្យាស្រ័យរបស់កុមារនោះ ទើបទ្រង់សម្តែងអនុបុព្វីកថា ។ កុមារនោះគិតថា "បុគ្គលអ្នកនៅគ្រប់គ្រងផ្ទះ មិនអាចប្រព្រឹត្តព្រហ្មចរិយឲ្យបរិសុទ្ធបរិបូរណ៍ ដូចជាស័ង្ខដែលគេខាតហើយបានទេ" ។ កើតសេចក្តីជ្រះថ្លា និងឧស្សាហ៍ក្នុងបព្វជ្ជា ដោយអាស្រ័យព្រះធម្មកថារបស់ព្រះសាស្តា, កាលបរិស័ទចៀសចេញទៅ ក៏ទូលសូមព្រះសាស្តាបព្វជ្ជា បានស្តាប់ថា "ព្រះតថាគតទាំងឡាយ មិនញុំាងកុលបុត្តដែលមាតាបិតាមិនទាន់អនុញ្ញាតឲ្យបព្វជ្ជាទេ" ទើបទៅផ្ទះ លុះទៅដល់ផ្ទះហើយ ក៏ញុំាងមាតាបិតាឲ្យអនុញ្ញាតដោយសេចក្តីព្យាយាមដ៏ធំ ដូចកុលបុត្តឈ្មោះរដ្ឋបាលជាដើម បានបព្វជ្ជាឧបសម្បទាក្នុងសម្នាក់ព្រះសាស្តាហើយ គិតថា "ប្រយោជន៍អ្វីដល់យើង ដោយការនៅទីនេះ" ទើបចេញចាកក្រុងសាវត្ថីទៅកាន់ក្រុងរាជគ្រឹះ ញុំាងកាលឲ្យកន្លងទៅនៅទីនោះ ។

## ស្រីពេស្យាធានាថានឹងធ្វើឲ្យព្រះថេរៈសឹកទាល់តែបាន

ក្រោយមក នៅថ្ងៃមួយ មាតាបិតារបស់ព្រះសុន្ទរ-សមុទរត្ថេរនោះ ឃើញពួកកុមារដែលជាសម្លាញ់របស់ព្រះសុន្ទរសមុទរត្ថេរ កំពុងលេងដោយសិរីសោភាគ្យដ៏ធំក្នុងថ្ងៃមហោស្រពមួយ ក្នុងក្រុងសាវត្ថី សោកខ្សឹកខ្សួល យំរៀបរាប់ថា "ការលេងបែបនេះ បុត្តរបស់យើងបានដោយក្រ" ។

ក្នុងខណៈនោះ ស្រីពេស្យាម្នាក់ទៅកាន់ត្រកូលនោះ ឃើញមាតារបស់ព្រះសុន្ទរសមុទរត្ថេរនោះ កំពុងយំរៀប-រាប់ ក៏សួរថា "បពិត្រម៉ែម្ចាស់ ហេតុដូចម្តេច ទើបម៉ែយំ"។

មាតាព្រះសុន្ទរសមុទរ. ខ្ញុំគិតដល់កូន ទើបខ្ញុំយំ ។

ស្រីពេស្យា. ក៏បុត្តនោះទៅទីណា ?

មាតាព្រះសុន្ទរសមុទរ. បួសក្នុង ( សម្នាក់ ) ភិក្ខុទាំងឡាយ ។

ស្រីពេស្យា. ការធ្វើឲ្យលោកសឹក មិនគួរឬ ?

មាតាព្រះសុន្ទរសមុទរ. គួរ ប៉ុន្តែកូនរបស់ខ្ញុំមិនព្រមសឹក, គេចេញចាកក្រុងសាវត្ថីនេះ ទៅកាន់ក្រុងរាជគ្រឹះ ។

ស្រីពេស្យា. ប្រសិនបើខ្ញុំធ្វើឲ្យកូនរបស់ម៉ែសឹកបាន, តើម៉ែម្ចាស់គប្បីធ្វើអ្វីចំពោះ ? ។

មាតាព្រះសុន្ទរសមុទរ. ពួកខ្ញុំនឹងធ្វើនាងឲ្យជាម្ចាស់នៃទ្រព្យក្នុងត្រកូននេះ ។

ស្រីពេស្យាពោលថា “បើដូច្នេះ សូមម៉ែម្ចាស់ឲ្យថ្លៃឈ្នួលដល់ខ្ញុំ” កាន់យកថ្លៃឈ្នួលហើយ ទៅកាន់ក្រុងរាជគ្រឹះដោយបរិវារមួយពួកធំ កំណត់ផ្លូវដែលជាទីត្រាច់បិណ្ឌបាតរបស់ព្រះថេរៈនោះបានហើយ កាន់យកផ្ទះដែលជាទីសម្រាក់មួយក្នុងទីនោះ តាក់តែងអាហារដ៏ប្រណីតតាំងអំពីព្រលឹមហើយប្រគេនភិក្ខុក្នុងពេលព្រះថេរៈចូលទៅបិណ្ឌបាត ។

ដោយកាលកន្លងទៅ ២-៣ ថ្ងៃ និមន្តព្រះថេរៈថា “បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់គង់ក្នុងទីនេះធ្វើភត្តកិច្ចចុះ” ហើយទទួលយកបាត្រ ។ ព្រះថេរៈក៏បានឲ្យបាត្រទៅនាង ។

## ស្រីពេស្យាប្រើឧបាយទាក់ទាញព្រះថេរៈ

គ្រានោះ ស្រីពេស្យានោះអង្គាសព្រះថេរៈនោះដោយអាហារដ៏ប្រណីតហើយ ប្រាប់ព្រះថេរៈថា “ បពិត្រលោកម្ចាស់ដ៏ចម្រើន ការត្រាច់បិណ្ឌបាតក្នុងទីនេះស្រួល ” និមន្តព្រះថេរៈឲ្យគង់ឆាន់ក្នុងយ៉ផ្ទះ ២-៣ ថ្ងៃហើយ យកនំឲ្យពួកក្មេងស៊ី ហើយនិយាយប្រាប់ថា “ ពួកឯងចូរមក, ក្នុងវេលាព្រះថេរៈមកហើយ ទោះបីយើងហាមឃាត់ពួកឯងយ៉ាងណាក៏ដោយ ពួកឯងកុំឈប់មកកាន់ទីនេះ ហើយប្រឡែងគ្នាលេងធ្វើឲ្យដីហុយឡើង ” ។

ថ្ងៃស្អែកឡើង វេលាដែលព្រះថេរៈឆាន់ ពួកក្មេងទាំងនោះ សូម្បីត្រូវស្រីពេស្យានោះហាមឃាត់យ៉ាងណាក៏ដោយ ក៏នៅតែមិនស្ដាប់ ប្រលែងគ្នាលេងធ្វើដីឲ្យហុយទ្រលោម ។

ថ្ងៃស្អែកឡើង ស្រីពេស្យានោះប្រាប់ព្រះថេរៈនោះថា ក្មេងទាំងនេះ សូម្បីខ្ញុំហាមឃាត់យ៉ាងណាក៏ដោយ ក៏នៅតែមិនស្ដាប់ខ្ញុំ ប្រលែងគ្នាធ្វើដីឲ្យហុយដដែល, សូមលោកម្ចាស់និមន្តទៅគង់ខាងក្នុងផ្ទះចុះ ” ឲ្យព្រះថេរៈគង់ខាងក្នុងហើយនិមន្តឲ្យឆាន់អស់ ២-៣ ថ្ងៃ , ស្រីពេស្យានោះយកនំឲ្យពួក

ក្មេងស៊ីហើយ និយាយប្រាប់ក្មេងទាំងនោះទៀតថា “ ពួកឯង សូម្បីត្រូវយើងហាមយ៉ាងណាក៏ដោយ ក៏កុំឈប់ធ្វើសំឡេង គឹកកងក្នុងវេលាព្រះថេរៈឆាន់ ” ។ ក្មេងទាំងនោះក៏ធ្វើយ៉ាង នោះ ។

ថ្ងៃស្អែកឡើង នាងពោលថា “ បពិត្រលោកម្ចាស់ដ៏ចម្រើន ទីនេះមានសំឡេងគឹកកងខ្លាំងណាស់, ពួកក្មេងទាំងនេះ សូម្បីខ្ញុំហាមឃាត់យ៉ាណាក៏ដោយ ក៏នៅតែមិនស្ដាប់ពាក្យរបស់ខ្ញុំ, លោកម្ចាស់និមន្តទៅគង់ក្នុងប្រាសាទខាងលើចុះ ”, កាលព្រះថេរៈទទួលនិមិត្តហើយ ក៏ឲ្យព្រះថេរៈនិមន្តទៅមុន កាលនឹងឡើងទៅកាន់ប្រាសាទ បិទទ្វារទាំងឡាយហើយ ទើបឡើងទៅជាខាងក្រោយ ។

ព្រះថេរៈនោះ សូម្បីជាអ្នកសមាទានការត្រាច់បិណ្ឌបាតតាមលំដាប់ផ្ទះជាវត្តយ៉ាងឧក្រិដ្ឋក៏ដោយ ប៉ុន្តែត្រូវចំណង់ក្នុងរសរួបរឹតហើយ ទើបឡើងទៅកាន់ប្រាសាទ ៧ ជាន់តាមពាក្យរបស់ស្រីពេស្យា ។

# ស្រីពេស្យាសម្ដែងអាការ ៤០ យ៉ាង ទាក់ទាញព្រះថេរៈ

ស្រីពេស្យានោះ និមន្តព្រះថេរៈឲ្យគង់ហើយ សម្ដែងមាយារបស់ស្ត្រី លីលារបស់ស្ត្រី ដែលមកហើយយ៉ាងនេះថា “ បានឮថា ស្ត្រីរមែងចែចង់ ( លួងលោម ) បុរសដោយមាយារបស់ស្ត្រី ៤០ គឺបួញមាត់ ១ មិតពត់ ១ កែក្រាយ ១ ម្រិកម្រ៉ុក ( អិមអៀន ) ១ ផ្ទាត់ក្រចក ១ ជាន់ជើងដោយជើង ១ គូសដីដោយឈើ ១ ជ្រោងទារកឡើង ១ ធ្វើទារកឲ្យលោត ១ ប្រឡែងជាមួយនិងក្មេង ១ ថើបក្មេង ១ ឲ្យក្មេងថើប ១ បរិភោគ ១ ឲ្យក្មេងបរិភោគ ១ ឲ្យ ១ សូម ១ ធ្វើត្រាប់ ១ ពោលខ្ពស់ ( ពោលខ្លាំង ) ១ ពោលទាប (ខ្សឹប) ១ ពោលចំហ ១ ពោលបិទបាំង ១ ស្ទឹមចង្កេះដោយការរាំ ដោយច្រៀង ដោយការប្រគំ ដោយដំណើរកែក្រាយ ដោយការស្អិតស្អាង ១ សម្លក់ ១ ញ៉ាំងចង្កេះឲ្យកម្រើក ១ ធ្វើរបស់កំបាំងឲ្យកម្រើក ១ បើកភ្លៅ ១ បិទភ្លៅ ១ សំដែងនូវដោះ ១ សំដែងនូវថ្ពក់ ១ សំដែងផ្ចិត ១ បិទភ្នែក ១

ញាក់ចិញ្ចើម ១ លិតបបូរមាត់ ១លៀនអណ្តាត់ ១ ស្រាយសំពត់ ១ សៀតសំពត់ ១ រំសាយសក់ ១ ចងសក់ ១ ។

## ព្រះថេរៈឈ្នះស្រីពេស្យាដោយសារព្រះសាស្តា

គ្រានោះ មហាសង្វេគបានកើតឡើងដល់ព្រះថេរៈថា " ឱហ្ន៎ ! កម្មដែលយើងមិនបានពិចារណា ហើយធ្វើ ធ្ងន់ណាស់ហ្ន៎ " ។ ក្នុងខណៈនោះ ព្រះសាស្តាទ្រង់គង់នៅឯវត្តជេតពន ចម្ងាយ ៤៥ យោជន៍ ទ្រង់ឃើញហេតុនោះហើយ ទ្រង់ធ្វើការញញឹមឲ្យប្រាកដ ។

គ្រានោះ ព្រះអានន្ទត្ថេរទូលសួរព្រះអង្គថា " បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ជាហេតុ អ្វីហ្ន៎ជាបច្ច័យ នៃការញញឹមរបស់ព្រះអង្គ ?" ។

ព្រះសាស្តាត្រាស់ថា " ម្នាលអានន្ទ សង្គ្រាមរវាងភិក្ខុឈ្មោះសុន្ទរសមុទ្រ និងស្រីពេស្យា កំពុងតែប្រព្រឹត្តទៅនៅប្រាសាទ ៧ ជាន់ ក្នុងក្រុងសាវត្ថី ។

ព្រះអានន្ទទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ការឈ្នះនឹងមានដល់អ្នកណា ? ការចាញ់នឹងមានដល់អ្នកណា?

ព្រះសាស្ដាត្រាស់ថា "ម្នាលអានន្ទ ការឈ្នះនឹងមានដល់សុន្ទរសមុទ្រ, ការចាញ់នឹងមានដល់ស្រីពេស្យា" ដូច្នេះហើយ ទ្រង់ប្រកាសការឈ្នះរបស់ព្រះថេរៈ ទ្រង់គង់នៅក្នុងវត្តជេតពននោះឯង ទ្រង់ផ្សាយព្រះរស្មីទៅ ហើយត្រាស់ថា "ម្នាលភិក្ខុ អ្នកចូរអស់អាល័យ លះបង់កាមសួម្បីទាំងពីរចេញ" ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា ៖-

**៣២ យោធ កាមេ បហន្ត្វាន អនាគារោ បរិព្វជេ**
**កាមភវបរិក្ខីណំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា ក្នុងលោកនេះ បានលះបង់កាម
ទាំងឡាយ ជាអ្នកមិនមានផ្ទះ គេចចេញចាក
កាមបាន តថាគតហៅបុគ្គលនោះ ដែលអស់
កាមភពហើយ ថាជាព្រាហ្មណ៍ ។

**អធិប្បាយគាថា**

គប្បីជ្រាបសេចក្ដីនៃព្រះគាថានោះ ( ដូច្នេះ ) ៖-

សេចក្ដីថា បុគ្គលណា លះបង់កាមសួម្បីទាំងពីរក្នុងលោកនេះហើយ ជាអ្នកមិនមានផ្ទះ គេចចេញចាកកាមបាន,

តថាគតហៅបុគ្គលនោះ ដែលមានកាមអស់ហើយ និងអ្នកមានភពអស់ហើយ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ព្រះថេរៈបានសម្រេចព្រះអរហត្តហើយ ហោះឡើងទៅកាន់វេហាស៍ដោយកម្លាំងឫទ្ធិ ទម្លុះមណ្ឌលពពកចេញហើយ សរសើរព្រះសរីរៈព្រះសាស្តាហើយ មកថ្វាយបង្គំព្រះសាស្តា ។

## ព្រះសាស្តាជាទីពឹងរបស់ព្រះថេរៈ

ភិក្ខុទាំងឡាយ សន្ទនាគ្នាក្នុងធម្មសភាថា "អ្នកមានអាយុទាំងឡាយ ព្រះសុន្ទរសមុទ្រត្រេអាស្រ័យរសដែលគប្បីដឹងដោយអណ្តាត់ ស្ទើតែវិនាស ។ ប៉ុន្តែព្រះសាស្តាជាទីពឹងនៃលោក" ។

ព្រះសាស្តាទ្រង់ព្រះសណ្តាប់កថានោះហើយ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ តថាគតជាទីពឹងនៃសុន្ទរសមុទ្រនោះ តែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏ទេ, សូម្បីក្នុងកាលមុន តថាគតក៏ជាទីពឹងនៃសុន្ទរសមុទ្រនោះ ដែលជាអ្នកជាប់ក្នុងរសតណ្ហាហើយដែរ" កាលភិក្ខុទាំងនោះទូលអារាធនាហើយ

ក៏ទ្រង់នាំអតីតនិទានមក ដើម្បីនឹងទ្រង់ប្រកាសសេចក្តីនោះ ទើបទ្រង់ញ៉ាំងវាតមិគជាតកនេះឲ្យពិស្តារថា ៈ-

បានឮថា សភាវៈដទៃដែលលាមកជាងរសទាំងឡាយ គឺអាសវៈទាំងឡាយ ឬការស្និទ្ធស្នាលគ្នារមែងមិនមាន, អ្នករក្សាឧទ្យានឈ្មោះសញ្ជ័យបាននាំសត្វឈ្លូលដែលអាស្រ័យព្រៃស្បាត មកកាន់អំណាចរបស់ខ្លួនបាន ព្រោះតែរសទាំងឡាយ ។

ដូច្នេះហើយ ទ្រង់ប្រជុំជាតកថា "សុន្ទរសមុទ្រក្នុងកាលនោះជាសត្វឈ្លូល, ចំណែកមហាអាមាត្យរបស់ព្រះរាជាដែលជាអ្នកពោលគាថានេះហើយ ឲ្យប្រលែងម្រឹះនោះទៅ គឺតថាគតនេះឯង" ។

រឿងព្រះសុន្ទរសមុទ្រត្ថេរ ចប់

## ៣៣ រឿងព្រះជោតិកត្ថេរ

### សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រះជោតិកត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា "**យោធ តណ្ហិ** ជាដើម ។

### បុព្វកម្មរបស់បងប្អូនទាំងពីរនាក់

អនុបុព្វីកថាក្នុងរឿងនោះ មានដូចតទៅនេះ ៖-

បានឮថា ក្នុងអតីតកាល កុដុម្ពិកៈ ២ នាក់បងប្អូនក្នុងក្រុងពារាណសីញុំាំងមហាជនឲ្យធ្វើចំការអំពៅជាច្រើន ។

ថ្ងៃមួយ ប្អូនប្រុសទៅចំការអំពៅហើយ គិតថា "យើងនឹងឲ្យអំពៅមួយដើមដល់បងប្រុស មួយដើមសម្រាប់យើង" ដូច្នេះហើយ ចងអំពៅទាំងពីរដើមត្រង់កន្លែងកាប់ ដើម្បីមិនឲ្យរសហូរចេញ ហើយកាន់យកទៅផ្ទះ ។

បានឮថា ក្នុងគ្រានោះ កិច្ចដោយការកាបអំពៅដោយគ្រឿងយន្ត មិនមាន, អំពៅពេលដែលគេកាប់ចុងឮគល់ ហើយលើកឡើង រស ( អំពៅ ) រមែងហូរចេញឯង ដូចទឹកហូរចេញអំពីធម្មក្រកដូច្នោះ ។ ក៏វេលាដែលកុដុម្ពិក៏ជាប្អូននោះកាន់យកអំពៅចេញអំពីចំការដើរមក ព្រះបច្ចេកពុទ្ធដែលមានប្រក្រតីនៅឯភ្នំគន្ធមាទន៍ចេញអំពីសមាបត្តិ ហើយពិចារណាថា "ថ្ងៃនេះ យើងគួរសង្គ្រោះអ្នកណាហ្ន៎ ? ឃើញកុដុម្ពិក៏នោះចូលទៅក្នុងសំណាញ់គឺញាណរបស់ខ្លួន ហើយដឹងថាកុដុម្ពិក៏នោះអាចសង្គ្រោះបាន ក៏កាន់បាត្រនិងចីវរ ហើយ មកដោយឫទ្ធិ ឈរខាងមុខកុដុម្ពិក៏នោះ ។

## ប្អូនប្រុសប្រគេនអំពៅចំពោះព្រះបច្ចេកពុទ្ធ

កុដុម្ពិក៏នោះគ្រាន់តែឃើញព្រះបច្ចេកភ្លាម ក៏មានចិត្តជ្រះថ្លា ក្រាលសំពត់ដណ្តប់លើទីដែលខ្ពង់ជាង ហើយនិមន្តព្រះបច្ចេកពុទ្ធឲ្យគង់លើកម្រាលនោះដោយពាក្យថា "បពិត្រលោកម្ចាស់ដ៏ចម្រើន និមន្តគង់ទីនេះចុះ" ហើយក៏ពោលថា "សូមលោកម្ចាស់បង្អោនបាត្រមក" ស្រាយចំណងចេញហើយ ដាក់លើបាត្រព្រះបច្ចេកពុទ្ធ ទឹកអំពៅក៏ហូរចូលពេញបាត្រ ។ កាលព្រះបច្ចេកពុទ្ធឆាន់ទឹកអំពៅនោះហើយកុដុម្ពិក៏នោះគិតថា "ល្អពិតមែនហ្ន៎ លោកម្ចាស់ដ៏ចម្រើនរបស់យើងឆាន់ទឹកអំពៅហើយ, ប្រសិនបើបងប្រុសរបស់យើងឲ្យនាំមូលតម្លៃមក, យើងក៏ឲ្យមូលតម្លៃ, បើឲ្យយើងនាំចំណែកបុណ្យមក, យើងក៏ឲ្យចំណែកបុណ្យដល់គាត់" ហើយពោលថា "បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់បង្អោនបាត្រមក" ហើយបានស្រាយចំណងដើមអំពៅទី ២ ប្រគេនទឹកអំពៅដល់ព្រះបច្ចេកពុទ្ធម្តងទៀត ។

បានឮថា កុដុម្ពិក៏នោះមិនបានគិតល្មើសសូម្បីមានប្រមាណប៉ុណ្ណោះថា "បងប្រុសរបស់យើងនឹងនាំអំពៅដទៃ

មកបរិភោគ" ចំណែកព្រះបច្ចេកពុទ្ធមានបំណងនឹងប្រគេនទឹកអំពៅនោះដល់ព្រះបច្ចេកពុទ្ធដទៃ ព្រោះព្រះអង្គឆាន់ទឹកអំពៅដើមដំបូងហើយ ទើបទទួលទុកប៉ុណ្ណោះ ហើយក៏គង់ៗ កុដុម្ពិក៍នោះដឹងអាការរបស់ព្រះបច្ចេកពុទ្ធហើយ ទើបថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន តាំងសេចក្តីប្រាថ្នាថា " បពិត្រលោកម្ចាស់ដ៏ចម្រើន ដោយអំណាចផលនៃរសដ៏ប្រណីតដែលខ្ញុំព្រះករុណាប្រគេនហើយនេះ, សូមឲ្យខ្ញុំបានសោយសម្បត្តិក្នុងទេវលោកនិងមនុស្សលោក ទីបំផុតសូមឲ្យបានសម្រេចធម៌ ដែលលោកម្ចាស់បានសម្រេចហើយផងចុះ ។ ព្រះបច្ចេកពុទ្ធក៏ពោលថា " សូមឲ្យសេចក្តីប្រាថ្នារបស់អ្នកសម្រេចតាមសេចក្តីប្រាថ្នាចុះ " ហើយធ្វើអនុមោទនាដល់កុដុម្ពិកនោះដោយគាថា ២ គាថាថា " **ឥច្ឆិតំ បត្ថិតំ តុម្ហំ** " ជាដើម, ហើយក៏អធិដ្ឋានឲ្យកុដុម្ពិកអាចឃើញបាន ហោះទៅកាន់ភ្នំគន្ធមាទន៍តាមអាកាស ហើយបានប្រគេនទឹកអំពៅដល់ព្រះបច្ចេកពុទ្ធ ៥០០ អង្គ ។ កុដុម្ពិកឃើញបាដិហារិយ៍នោះហើយ ទៅកាន់សម្នាក់បងប្រុស, កាលបងប្រុសសួរថា "ឯង

ទើបតែមកពីណា ?" ក៏ប្រាប់ថា " ខ្ញុំទៅមើលចម្ការអំពៅ " ត្រូវបងប្រុសពោលថា " នឹងមានប្រយោជន៍អ្វីដល់មនុស្ស ដូចជាឯង ទៅចម្ការអំពៅនោះ, ឯងគួរតែកាន់យកអំពៅមក ១ ដើម ឬក៏ ២ ដើមមិនមែនឬ ?" ក៏ពោលថា " ត្រូវហើយ បងប្រុស, ខ្ញុំបានយកអំពៅមក ២ ដើមដែរ, ប៉ុន្តែខ្ញុំឃើញព្រះ បច្ចេកពុទ្ធមួយអង្គ ខ្ញុំក៏ប្រគេនអំពៅរបស់ខ្ញុំ ហើយប្រគេន អំពៅរបស់បង ដោយគិតថា យើងនឹងឲ្យតម្លៃ ឬចំណែក បុណ្យ, តើបងនឹងទទួលយកតម្លៃអំពៅនោះ ឬក៏ទទួលយក ចំណែកបុណ្យ ?" ។

បងប្រុស. ក៏ព្រះបច្ចេកពុទ្ធនោះ ធ្វើអ្វី ?

ប្អូនប្រុស. ព្រះបច្ចេកពុទ្ធនោះ ឆាន់ទឹកអំពៅរបស់ខ្ញុំ ហើយ ក៏កាន់យកទឹកអំពៅរបស់បងទៅកាន់ភ្នំគន្ធមាទន៍តាម អាកាស ប្រគេនទឹកអំពៅនោះដល់ព្រះបច្ចេកពុទ្ធ ៥០០ រូប ។

## បងប្រុសជ្រះថ្លាសុំអនុមោទនាចំណែកបុណ្យ

បងប្រុសនោះ កាលកុដុម្ពិកជាប្អូនកំពុងពោលនោះឯង ជាអ្នកមានសរីរៈដែលបីតិពាល់ត្រូវហើយ ដោយមិនមាន

ចន្ទោះ បានធ្វើសេចក្តីប្រាថ្នាថា “ ការសម្រេចធម៌ដែលព្រះ-បច្ចេកពុទ្ធនោះមានហើយ គប្បីមានដល់យើងផងចុះ ” ។

ប្អូនប្រុសប្រាថ្នាសម្បត្តិ ៣ យ៉ាង, ចំណែកបងប្រុសប្រាថ្នាព្រះអរហត្ត ដោយប្រការដូច្នេះ ។

នេះជាបុព្វកម្មរបស់បងប្អូនទាំង ២ នោះ

## ពីរនាក់បងប្អូនបានកើតរួមគ្នាទៀតក្នុងជាតិតមក

ពីរនាក់បងប្អូននោះ រស់នៅរហូតអស់ជីវិត, ចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោក ញុំាងពុទ្ធន្តរមួយឲ្យអស់ទៅ ។ ក្នុងកាលដែលបងប្អូនទាំងពីរនាក់នោះទៅកាន់ទេវលោកនោះ ព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមថាវិបស្សីស្តេចឧប្បត្តិឡើងក្នុងលោក ។

បងប្អូនទាំងពីរនាក់នោះ ចុតិចាកទេវលោកនោះហើយ បងប្រុសក៏នៅជាបងប្រុស ប្អូនប្រុសក៏នៅជាប្អូនប្រុស បដិ-សន្ធិក្នុងត្រកូលមួយក្នុងពន្ធុមតីនគរ ។

បណ្តាក្មេងទាំងពីរនាក់នោះ មាតាបិតាបានដាក់ឈ្មោះឲ្យកូនច្បងថា “ **សេនៈ** ” ឲ្យកូនប្អូនថា “ **អបរាជិត** ” ។

កាលបងប្អូនទាំង ២ នាក់នោះ កំពុងគ្រប់គ្រងទ្រព្យសម្បត្តិក្នុងវេលាធំពេញវ័យ, សេនកុដុម្ពិក បានស្ដាប់ការប្រកាសក្នុងពន្ធមតីនគរ របស់ឧបាសកអ្នកឃោសនាធម៌ថា “ ពុទ្ធរតនៈកើតឡើងហើយក្នុងលោក, ធម្មរតនៈកើតឡើងហើយក្នុងលោក, សង្ឃរតនៈកើតឡើងហើយក្នុងលោក, អ្នកទាំងឡាយចូរឲ្យទាន, ចូរធ្វើបុណ្យទាំងឡាយ, ថ្ងៃនេះជាតិថីទី ១៤ ថ្ងៃនេះជាតិថីទី ១៥, អ្នកទាំងឡាយចូររក្សាឧបោសថចូរស្ដាប់ធម៌ ” ឃើញមហាជនថ្វាយទាន ក្នុងកាលមុនកត្តហើយ ទៅស្ដាប់ធម៌ក្នុងកាលក្រោយកត្ត ក៏សួរថា “ នែអ្នកទាំងឡាយ អ្នកទាំងឡាយទៅណា ? កាលមហាជនប្រាប់ថាពួកយើងទៅកាន់សម្នាក់ព្រះសាស្ដាដើម្បីស្ដាប់ធម៌ ” ពោលថា “ ខ្ញុំទៅដែរ ” ហើយក៏ទៅជាមួយនឹងមហាជន អង្គុយក្នុងទីបំផុតបរិស័ទ ។

ព្រះសាស្ដា ទ្រង់ជ្រាបអធ្យាស្រ័យរបស់គាត់ ទើបត្រាស់អនុបុព្វីកថា ។ លុះគាត់បានស្ដាប់ធម្មកថារបស់ព្រះ-

សាស្ដាហើយ កើតសេចក្ដីជ្រះថ្លាក្នុងបព្វជ្ជា ទើបសូមព្រះសាស្ដាបព្វជ្ជា ។

គ្រានោះ ព្រះសាស្ដាត្រាស់សួរគាត់ថា “ ក៏ពួកញាតិដែលអ្នកគប្បីលា មានដែរឬទេ ?” ។

សេនកុដុម្ពិក. មាន ព្រះអង្គ ។

ព្រះសាស្ដា. បើដូច្នោះ អ្នកទៅលាហើយ ចូរមក ។

## បងប្រុសលាប្អូនប្រុសចេញបួសហើយ បានសម្រេចព្រះអរហត្ត

សេនកុដុម្ពិកនោះ ទៅកាន់សម្នាក់ប្អូនប្រុសហើយពោលថា “ ទ្រព្យសម្បត្តិណា មាននៅក្នុងត្រកូលនេះ ទ្រព្យសម្បត្តិទាំងអស់នោះ ចូរជារបស់ឯងចុះ ” ។

ប្អូនប្រុស. ចុះបងឯងទៅណា ?

សេនកុដុម្ពិក. បងនឹងទៅបួសក្នុងសម្នាក់ព្រះសាស្ដា ។

ប្អូនប្រុស. បងនិយាយអ្វី ? ខ្ញុំកាលមាតាស្លាប់ហើយ បានបងដូចជាមាតា, កាលបិតាស្លាប់ហើយ ក៏បានបងដូចជា

បិតា, ត្រកូលនេះមានភោគៈច្រើន, បងនៅក្នុងផ្ទះនេះ ក៏អាចធ្វើបុណ្យបាន, បងកុំធ្វើដូច្នោះ ។

សេនកុដុម្ពិក. បងស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តាហើយ, កាលបើបងនៅគ្រប់គ្រងផ្ទះ បងមិនអាចបំពេញធម៌នោះបានទេ, ដូច្នេះ បងត្រូវតែបួស ឯងចូរត្រឡប់ទៅវិញចុះ ។

សេនកុដុម្ពិកញ៉ាំងប្អូនប្រុសឲ្យត្រឡប់ទៅដោយអាការយ៉ាងនោះហើយ បានបព្វជ្ជាឧបសម្បទាក្នុងសម្នាក់ព្រះសាស្តាមិនយូរប៉ុន្មានក៏បានសម្រេចព្រះអរហត្ត ។

ចំណែកប្អូនប្រុសគិតថា " យើងនឹងធ្វើសក្ការបូជាចំពោះបព្វជិតដែលជាបងប្រុស " លុះគិតដូច្នេះហើយ ក៏ថ្វាយទានចំពោះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ថ្វាយបង្គំបងប្រុសហើយ ពោលថា " បពិត្របងប្រុស បងធ្វើការរលាស់ចេញចាកភពបានហើយ, ចំណែកខ្ញុំនៅជាប់ជំពាក់ដោយកាមគុណ ៥, មិនអាចចេញបួសបាន, សូមបងប្រាប់បុញ្ញកម្មដ៏ធំដែលសមគួរដល់ខ្ញុំ ដែលជាអ្នកនៅគ្រប់គ្រងផ្ទះ " ។

គ្រានោះ ព្រះថេរៈពោលទៅកាន់ប្អូនប្រុសនោះថា "ប្រពៃហើយ ប្អូនប្រុស, ឯងចូរជាបណ្ឌិត ចូរឲ្យគេកសាងព្រះគន្ធកុដិ សម្រាប់ព្រះសាស្តាចុះ ។

## ប្អូនប្រុសកសាងព្រះគន្ធកុដិថ្វាយព្រះសាស្តា

ប្អូនប្រុសនោះទទួលថា "សាធុ សាធុ សាធុ" ហើយញុំាងជនឲ្យនាំឈើផ្សេង ៗ មកហើយប្រើឲ្យឈូសដើម្បីប្រយោជន៍ដល់ទព្វសម្ភារៈទាំងឡាយមានសសរជាដើម ឲ្យធ្វើសសរទាំងអស់វិចិត្រដោយកែវ ៧ ប្រការ គឺមួយដើមវិចិត្រដោយមាស មួយដើមវិចិត្រដោយប្រាក់ មួយដើមវិចិត្រដោយកែវមណីជាដើម ហើយឲ្យកសាងព្រះគន្ធកុដិដោយសសរទាំងនោះ ឲ្យប្រក់ដោយក្បឿងសម្រាប់ប្រក់ដែលវិចិត្រដោយកែវ ៧ ប្រការដែរ ។

ក៏ក្នុងពេលកសាងព្រះគន្ធកុដិនោះ ក្មួយប្រុសឈ្មោះអបរាជិត អ្នកមានឈ្មោះដូចខ្លួននោះ ចូលទៅរកអបរាជិត-កុដុម្ពិកនោះហើយ ពោលថា "បពិត្រពូ ខ្ញុំចង់កសាងដែរ សូមពូឲ្យខ្ញុំកសាងដើម្បីបានចំណែកបុណ្យជាមួយនិងពូផង"

អបរាជិតកុដុម្ពិកនោះពោលថា “នែបា យើងមិនឲ្យទេ, យើងនឹងកសាងដោយមិនឲ្យទូទៅដល់ជនដទៃ” ។

ក្មួយប្រុសនោះ អង្វរអស់ច្រើនដង កាលមិនបានចំណែកបុណ្យ ក៏គិតថា “ការដែលយើងបានសាលាមានរូបដូចដំរីនៅខាងមុខព្រះគន្ធកុដិ រមែងគួរ” ដូច្នេះហើយ ទើបឲ្យកសាងសាលាដែលមានរូបដូចដំរីដោយកែវ ៩ ប្រការ ។

ក្មួយប្រុសនោះ បានជាមេណ្ឌកសេដ្ឋីក្នុងពុទ្ធុប្បាទកាលនេះ ។

ក៏សន្ទឹកបង្អួចធំ ៗ ៣ សន្ទឹក ដែលសម្រេចដោយកែវ ៧ ប្រការ បានមានហើយក្នុងព្រះគន្ធកុដិ ។

អបរាជិតគហបតីឲ្យគេកសាងស្រះបោក្ខរណី ៣ ក្នុងទីដែលគេបូកដោយបាយអខាងក្រោម ក្នុងទីចំពោះមុខបង្អួចទាំងនោះ ឲ្យបំពេញដោយទឹកក្រអូបដែលកើតអំពីជាតិទាំង ៤ ហើយប្រើបម្រើឲ្យដាំផ្កាប្រាំពណ៌, អបរាជិតគហបតីនោះឲ្យគេជំរតនៈ ៧ ប្រការ ជារតនៈដែលគួរដល់ភាពជារបស់ដែលខ្ជួនគប្បីជំ ហើយកាន់យករតនៈក្រៅនេះទាំងអស់

រោយជុំវិញព្រះគន្ធកុដិដោយស្រទាប់ត្រឹមជង្គង់ ញុំាង បរិវេណឲ្យពេញដោយលំអិតរតនៈ ៧ ប្រការ ។

គហបតីឈ្មោះអបរាជិត ញុំាងព្រះគន្ធកុដិឲ្យសម្រេចដោយអាការយ៉ាងនេះហើយ ទើបចូលទៅរកព្រះថេរៈអ្នកជាបងប្រុសហើយ ប្រាប់ថា "បពិត្រលោកម្ចាស់ ព្រះគន្ធកុដិសម្រេចហើយ ខ្ញុំព្រះករុណាចង់បានការប្រើប្រាស់ព្រះគន្ធ-កុដិនោះ, ព្រោះខ្ញុំបានឮថា បុណ្យជាច្រើន រមែងមានព្រោះការប្រើប្រាស់" ។

ព្រះថេរៈនោះ ចូលទៅគាល់ព្រះសាស្ដាក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន កុដុម្ពិកនេះឲ្យសាងព្រះគន្ធកុដិថ្វាយព្រះអង្គ, ឥឡូវនេះ គេប្រាថ្នាការប្រើប្រាស់ " ។

ព្រះសាស្ដាស្ដេចក្រោកចាកអាសនៈហើយ ស្ដេចទៅកាន់ព្រះគន្ធកុដិ ទ្រង់ឃើញគំនររតនៈដែលគេដាក់ព័ទ្ធជុំវិញព្រះគន្ធកុដិ ក៏ទ្រង់ឈរត្រង់ខ្លោងទ្វារ, កាលកុដុម្ពិកនោះក្រាបទូលថា " បពិត្រព្រះអង្គដ៏ចម្រើន ការរក្សានឹងមានដល់ខ្ញុំ

ព្រះអង្គ, សូមព្រះអង្គស្តេចចូលទៅចុះ ” ។ ព្រះសាស្តាស្តេចចូលទៅ ។

## កុដុម្ពិកបាត់ឲ្យគេរក្សារតនៈ ដែលដាក់ជុំវិញព្រះគន្ធកុដិ

ចំណែកកុដុម្ពិក ក៏ចាត់ចែងការរក្សាទុកដោយជុំវិញ ផ្តាំងអ្នកបម្រើទាំងឡាយថា “ នែអ្នកទាំងឡាយ ពួកឯងចូរហាមជនទាំងឡាយអ្នកកាន់យករតនៈដោយថ្នក់ ឬដោយប្រេង និងដោយការុង, ប៉ុន្តែចូរកុំហាមជនអ្នកកាន់យកដោយដៃ ”។ មិនត្រឹមតែប៉ុណ្ណោះ ប្រើបម្រើឲ្យដើរប្រាប់ក្នុងនគរថា “ រតនៈ ៧ ប្រការ ដែលយើងរោយក្នុងបរិវេណនៃព្រះគន្ធកុដិ, មនុស្សទាល់ក្រទាំងឡាយ ដែលមកស្តាប់ធម៌ក្នុងសម្នាក់ព្រះសាស្តាហើទៅ ចូរកាន់យកឲ្យពេញដៃទាំងពីរចុះ, មនុស្សទាំងឡាយសូម្បីអ្នកមានសេចក្តីសុខហើយក៏ដោយ ក៏នៅតែកាន់យកដោយដៃទៀត ។

បានឮថា កុដុម្ពិកនោះមានគំនិតយ៉ាងនេះថា “ ជនទាំងឡាយអ្នកមានសទ្ធាប្រាថ្នានឹងស្តាប់ធម៌ ទើបទៅកាន់ទីនោះ,

ចំណែកអ្នកមិនមានសទ្ធា ទៅដោយសេចក្ដីលោភក្នុងទ្រព្យ ស្ដាប់ធម៌ហើយ ក៏នឹងផុតចាកទុក្ខបាន ", ព្រោះហេតុនោះ ទើបគាត់ឲ្យប្រាប់យ៉ាងនោះ ដើម្បីសង្គ្រោះមហាជន ។

មហាជន កាន់យករតនៈទាំងឡាយតាមកំណត់ដូចដែលកុដុម្ពិកបានប្រាប់ហើយនោះឯង ។ កាលរតនៈដែលកុដុម្ពិករោយលើកដំបូងនោះអស់ទៅ គាត់ក៏ឲ្យរោយបន្តទៀតដោយស្រទាប់ប្រមាណត្រឹមជង្គង់ ដរាបអស់វារៈ ៣ ដង ។

មិនត្រឹមតែប៉ុណ្ណោះ គាត់បានដាក់កែវមណីដែលកាត់ថ្លៃពុំបាន ប្រមាណប៉ុនផ្លែឪឡឹកទៀបបាទមូលព្រះសាស្ដា ។

បានឮថា គាត់មានគំនិតយ៉ាងនេះថា " ដែលឈ្មោះថាការឆ្អែត នឹងមិនមានដល់ជនទាំងឡាយអ្នកសម្លឹងមើលរស្មីនៃកែវមណី ព្រមទាំងរស្មីដែលមានពណ៌ដូចមាសផ្សាយចេញអំពីព្រះសរីរៈរបស់ព្រះសាស្ដា ", ព្រោះដូច្នោះ ទើបគាត់ធ្វើយ៉ាងនោះ ។ សូម្បីមហាជនក៏សម្លឹងមើលមិនចេះឆ្អែត ព្រាហ្មណ៍មិច្ឆាទិដ្ឋិលួចកែវមណី

ក្រោយមក នៅថ្ងៃមួយ ព្រាហ្មណ៍មិច្ឆាទិដ្ឋិម្នាក់គិតថា " បានឮថា កែវមណីដែលមានតម្លៃកាត់ថ្លៃពុំបាន កុដុម្ពិកបាន ដាក់ទុកទៀបបាទមូលព្រះសាស្តា, យើងនឹងលួចកែវមណី នោះ " ទើបទៅកាន់វិហារ ចូលទៅចន្លោះមហាជនអ្នកមក ដើម្បីថ្វាយបង្គំព្រះសាស្តា ។

កុដុម្ពិកដឹងថា " ព្រាហ្មណ៍នេះមានបំណងនឹងកាន់យក កែវមណី " ដោយអាការនៃការចូលទៅរបស់ព្រាហ្មណ៍នោះ គិតថា " ឱហ្ន៎ ! ព្រាហ្មណ៍មិនគួរកាន់យក " ។

ចំណែកព្រាហ្មណ៍នោះ ដាក់ដៃទៀបបាទមូលធ្វើដូចជា ថ្វាយបង្គំព្រះសាស្តា យកកែវមណីលាក់ទុកក្នុងសំពត់ហើយ ចៀសចេញទៅ ។ កុដុម្ពិក មិនអាចញុំាងចិត្តឲ្យជ្រះថ្លាក្នុង ព្រាហ្មណ៍នោះបាន ។

ក្នុងកាលចប់ធម្មកថា កុដុម្ពិកនោះចូលទៅគាល់ព្រះ-សាស្តា ក្រាបទូលថា " បពិត្រព្រះអង្គដ៏ចម្រើន រតនៈ ៧ ប្រការដែលខ្ញុំព្រះអង្គរោយជុំវិញព្រះគន្ធកុដិអស់វារៈ ៣ ដង ដោយស្រេទាប់ត្រឹមជង្គង់, កាលជនទាំងឡាយកាន់យករតនៈ

ទាំងនោះ ឈ្មោះថា អាឃាតមិនបានមានហើយដល់ខ្ញុំព្រះអង្គ, ចិត្តខ្ញុំព្រះអង្គជ្រះថ្លាក្រៃលែងឡើងៗ ប៉ុន្តែថ្ងៃនេះ ខ្ញុំព្រះអង្គគិតថា " ឱហ្ន៎! ព្រាហ្មណ៍នេះ មិនគួរកាន់យកកែវមណីទេ ", កាលព្រាហ្មណ៍នោះកាន់យកកែវមណីទៅ ទើបខ្ញុំព្រះអង្គមិនអាចញុំាងចិត្តឲ្យជ្រះថ្លាបាន " ។

ព្រះសាស្តា ទ្រង់ព្រះសណ្តាប់ពាក្យរបស់កុដុម្ពិកនោះហើយ ត្រាស់ថា " ម្នាលឧបាសក អ្នកមិនអាចធ្វើទ្រព្យរបស់ខ្លួន ឲ្យជារបស់ដែលបុគ្គលដទៃមិនគប្បីនាំទៅបាន មិនដូច្នោះឬ ?" ដូច្នេះហើយ បានប្រទានន័យ ។

កុដុម្ពិកនោះ តាំងនៅក្នុងន័យដែលព្រះសាស្តាទ្រង់ប្រទានហើយ ថ្វាយបង្គំព្រះសាស្តា ធ្វើសេចក្តីប្រាថ្នាថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះរាជា ឬចោរសូម្បីច្រើនរយឈ្មោះថា ជាអ្នកអាចសង្កត់សង្កិនខ្ញុំព្រះអង្គ ហើយកាន់យកសូម្បីចេសជាយសំពត់ដ៏ជាទ្រព្យរបស់ខ្ញុំព្រះអង្គ ចូរកុំមានចាប់តាំងពីថ្ងៃនេះតទៅ, សូម្បីភ្លើងក៏កុំឆេះទ្រព្យរបស់ខ្ញុំព្រះអង្គសូម្បីទឹកក៏កុំបន្សាត់ទៅ " ។

ចំណែកព្រះសាស្តា ក៏ទ្រង់ធ្វើអនុមោទនាដល់កុដុម្ពិក នោះថា “ ផលដែលអ្នកប្រាថ្នាហើយនោះ ចូរសម្រេចតាម សេចក្តីប្រាថ្នាចុះ ” ។

កុដុម្ពិកនោះ កាលធ្វើបុណ្យឆ្លងព្រះគន្ធកុដិ បានថ្វាយ មហាទានចំពោះភិក្ខុ ៦៨ សែន ក្នុងវិហារនោះអស់ ៩ ខែ ក្នុងកាលជាទីបំផុត បានប្រគេនត្រៃចីវរដល់ភិក្ខុគ្រប់រូប ។

សំពត់សាដក សម្រាប់ធ្វើចីវររបស់ភិក្ខុអ្នកទើបបួសថ្មី ក្នុងសង្ឃ មានតម្លៃ ១០០០ ។

## អបរាជិតកុដុម្ពិកកើតជាជោតិកសេដ្ឋី

កុដុម្ពិកនោះ ធ្វើបុណ្យទាំងឡាយរហូតអស់អាយុយ៉ាង នោះហើយ ចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោក បន្ទោលទៅមកក្នុងទេវលោក និងមនុស្សលោក រហូតអស់ កាលប្រមាណប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទកាលនេះ បដិសន្ធិក្នុង ត្រកូលសេដ្ឋីមួយ ក្នុងក្រុងរាជគ្រឹះ នៅក្នុងផ្ទៃរបស់មាតា អស់ ៩ ខែកន្លះ ។

ក៏ក្នុងថ្ងៃដែលកុដុម្ពិកនោះកើត សព្វាវុធទាំងឡាយក្នុងព្រះនគរទាំងមូលរុងរោចន៍ដោយរស្មី ។ សុប្បីអាភរណៈទាំងឡាយដែលមហាជនពាក់ហើយ ដូចជារុងរឿងបញ្ចេញរស្មី ។ ព្រះនគរមានពន្លឺជាមួយគ្នា ។ សុប្បីសេដ្ឋីក៏ទៅកាន់ទីបម្រើព្រះរាជាអំពីព្រលឹម ។

គ្រានោះ ព្រះរាជាត្រាស់សួរសេដ្ឋីនោះថា " ថ្ងៃនេះ សព្វាវុធទាំងឡាយបញ្ចេញរស្មីដ៏ភ្លឺចិញ្ចាចចិញ្ចែង ព្រះនគរក៏រុងរោចន៍ដោយរស្មី អ្នកដឹងហេតុក្នុងរឿងនេះទេ ?" ។

សេដ្ឋី. បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គដឹង ។

ព្រះរាជា. ម្នាលសេដ្ឋី តើមានហេតុ ?

សេដ្ឋី. ទាសៈរបស់ព្រះអង្គ កើតក្នុងផ្ទះនៃខ្ញុំព្រះអង្គ, ពន្លឺភ្លឺស្វាងនោះ កើតឡើងហើយដោយតេជៈនៃបុណ្យរបស់គេ ។

ព្រះរាជាត្រាស់សួរថា ក្មេងនោះនឹងជាចោរទេដឹង ?

សេដ្ឋីទូលថា បពិត្រព្រះសម្មតិទេព ការៈនៃបុត្ររបស់ខ្ញុំព្រះអង្គជាចោរនោះ មិនមានឡើយ, បុត្ររបស់ខ្ញុំព្រះអង្គជាសត្វមានបុណ្យ មានអភិនីហារបានធ្វើទុកហើយ ។

ព្រះរាជា ព្រះរាជទានទ្រព្យថ្លៃមើលថែរក្សា មួយថ្ងៃមួយពាន់ ដោយព្រះតម្រាស់ថា " បើដូច្នោះ អ្នកចិញ្ចឹមក្មេងនោះឲ្យល្អ ទើបគួរ, នេះចូរជាថ្លៃទឹកដោះសម្រាប់បុត្ររបស់អ្នក " ក៏ក្នុងថ្ងៃដាក់ឈ្មោះឲ្យក្មេងនោះ ជនទាំងឡាយក៏ដាក់ឈ្មោះឲ្យក្មេងនោះថា " **ជោតិកៈ** " ព្រោះព្រះនគរទាំងមូលមានពន្លឺភ្លឺស្វាងដោយរស្មីក្នុងថ្ងៃដែលក្មេងនោះកើត ។

ក្រោយមក ក្នុងវេលាដែលជោតិកកុមារនោះធំពេញវ័យហើយ កាលផ្ទៃដីដែលគេជម្រះដើម្បីប្រយោជន៍ដល់ការធ្វើផ្ទះសម្រាប់ជោតិកកុមារនោះ ភពនៃសក្កទេវរាជសម្តែងអាការក្តៅ ។

## សក្កទេវរាជស្តេចមកនិម្មិតសម្បត្តិឲ្យជោតិកសេដ្ឋី

សក្កទេវរាជទ្រង់ពិចារណាមើលថា " នេះជាហេតុអ្វីហ្ន៎ ?" ទ្រង់ជ្រាបថា " ជនទាំងឡាយកំពុងចាត់ចែងធ្វើផ្ទះ

ដើម្បីជោតិកកុមារ ” ទ្រង់ព្រះតម្រិះទៀតថា “ជោតិកកុមារនេះ នឹងមិននៅក្នុងផ្ទះដែលជនទាំងនោះធ្វើទេ, ការដែលយើងទៅកាន់ទីនោះ គួរ” ហើយស្ដេចទៅកាន់ទីនោះដោយភេទជាជាងឈើ ត្រាស់សួរថា “នែអ្នកទាំងឡាយ អ្នកទាំងឡាយកំពុងធ្វើអ្វី ?”

ពួកជន. ពួកខ្ញុំចាត់ចែងធ្វើផ្ទះសម្រាប់ជោតិកៈ ។

សក្កទេវរាជត្រាស់ថា “ពួកអ្នកចូរចៀសចេញ, ជោតិកៈនេះនឹងមិននៅផ្ទះដែលពួកអ្នកធ្វើទេ, ហើយទ្រង់ទតមើលភូមិប្រទេសប្រមាណ ១៦ ករីស ។ ភូមិប្រទេសដែលសក្កទេវរាជទ្រង់រមិលមើលហើយនោះ ជាប្រទេសដ៏រាបស្មើដូចមណ្ឌលកសិណ ។ សក្កទេវរាជទ្រង់មានព្រះតម្រិះបន្តទៅទៀតថា “ សូមប្រាសាទ ៧ ជាន់ដែលសម្រេចដោយកែវ ៧ ប្រការ ចូរទម្លាយផែនដីផុសឡើងនៅទីនេះ ” ហើយទ្រង់ទតមើល ។ ប្រាសាទ ( បែបនោះ ) ផុសឡើងក្នុងខណៈនោះឯង ។ សក្កទេវរាជទ្រង់ត្រិះរិះទៀតថា “សូមកំផែង ៧ ជាន់ ដែលសម្រេចដោយកែវ ៧ ប្រការ ចូរផុស

ឡើងព័ទ្ធជុំវិញប្រាសាទនេះ” ហើយទ្រង់ទតមើល ។ កំផែងបែបនោះក៏ផុសឡើង ។ គ្រានោះ សក្កទេវរាជទ្រង់ត្រិះរិះថា សូមដើមកកល្បព្រឹក្សទាំងឡាយ ចូរផុសឡើងក្នុងទីបំផុតជុំវិញកំផែងទាំងនោះ” ហើយទ្រង់ទតមើល ដើមកល្បព្រឹក្សទាំងឡាយបែបនោះផុសឡើងជុំវិញកំផែងទាំងនោះ ។ សក្កទេវរាជទ្រង់ត្រិះរិះទៀតថា “កំណាប់ទ្រព្យបួនរណ្ដៅ ចូរផុសឡើងត្រង់ជ្រុងទាំង ៤ នៃប្រាសាទ” ហើយទ្រង់ទតមើល ។ វត្ថុគ្រប់យ៉ាងបានមានយ៉ាងនោះដូចគ្នា ។

បណ្ដាកំណាប់ទ្រព្យទាំងនោះ កំណាប់ទ្រព្យមួយរណ្ដៅមានប្រមាណមួយយោជន៍, មួយរណ្ដៅប្រមាណ ៣ គាវុត, កំណាប់មួយរណ្ដៅមានប្រមាណកន្លះយោជន៍, មួយរណ្ដៅមានប្រមាណមួយគាវុត, ត្រង់ខ្លោងទ្វារទាំង ៧ យក្ស ៧ ឈរចាំយាម, យក្សឈ្មោះយមមោលិព្រមទាំងយក្សដែលជាបរិវារមួយពាន់ យាមខ្លោងទ្វារទីមួយ, យក្សឈ្មោះឧប្បលៈ ព្រមទាំងយក្សដែលជាបរិវាររបស់ខ្លួនពីរពាន់យាមខ្លោងទ្វារទីពីរ ។ យក្សឈ្មោះវជិរៈព្រមទាំងយក្សដែលជា

បរិវាររបស់ខ្លួន ៣ ពាន់ យាមខ្លោងទ្វារទី ៣, យក្សឈ្មោះវជីរពាហុ ព្រមទាំងយក្សដែលជាបរិវាររបស់ខ្លួនបួនពាន់ យាមខ្លោងទ្វារទីបួន, យក្សឈ្មោះសកដៈព្រមទាំងបរិវារនៃខ្លួនប្រាំពាន់ យាមខ្លោងទ្វារនោះ, យក្សឈ្មោះសកជត្តៈ ព្រមទាំងយក្សដែលជាបរិវាររបស់ខ្លួន ៦ ពាន់ យាមខ្លោងទ្វារទី ៦, យក្សឈ្មោះទិសាមុខៈព្រមទាំងយក្សដែលជាបរិវាររបស់ខ្លួន ៧ ពាន់ យាមខ្លោងទ្វារទី ៧ ។ ទាំងខាងក្នុង ទាំងខាងក្រៅប្រាសាទ មានការយាមយ៉ាងមាំដោយអាការយ៉ាងនេះ។

## ព្រះបាទពិម្ពិសារព្រះរាជទានឆត្រតែងតាំងឲ្យជាសេដ្ឋី

ព្រះរាជាទ្រង់ព្រះនាមថាពិម្ពិសារ ទ្រង់ព្រះសណ្ដាប់ថា "ប្រាសាទ ៧ ជាន់ ដែលសម្រេចដោយកែវ ៧ ប្រការ ផុសឡើងដើម្បីជោតិកៈ, កំផែង ៧ ជាន់ ខ្លោងទ្វារ ៧ កំណប់ទ្រព្យ ៧ រណ្ដៅក៏ផុសឡើងហើយ ( ដើម្បីជោតិកៈដែរ )" ក៏ទ្រង់បញ្ជូនឆត្រតំណែងសេដ្ឋីទៅ ( ឲ្យ ), ជោតិកៈនោះបានជាអ្នកមានឈ្មោះថា ជោតិកសេដ្ឋី ។ ក៏ស្ត្រីអ្នកមានបុញ្ញ

កម្មដែលបានធ្វើទុកហើយជាមួយនិងជោតិកសេដ្ឋីនោះ កើតហើយក្នុងឧត្តរកុរុទ្វីប ។

គ្រានោះ ទេវតានាំនាងមកអំពីឧត្តរកុរុទ្វីបនោះហើយឲ្យនាងអង្គុយក្នុងបន្ទប់ដ៏មានសិរី ។

ស្ត្រីនោះកាលមក បានកាន់យកនាឡិអង្ករមួយ និងផែនថ្មជាគ្រៀងឆេះ ៣ ដុំមកជាមួយ, កត្តានៃជនទាំងពីរនោះបានមានហើយដោយនាឡិអង្ករនោះឯង រហូតអស់ជីវិត ។

បានឮថា ប្រសិនបើជនទាំងនោះប្រាថ្នានឹងញ៉ាំងរទេះសូម្បី ១០០ ឲ្យពេញដោយអង្ករ, នាឡិនោះឯងក៏គង់ប្រាកដជានាឡិដែលពេញដោយអង្ករដដែល ។ ក្នុងវេលាចំអិនកត្តពួកគាត់ដាក់អង្ករក្នុងឆ្នាំង ហើយតម្កល់លើថ្មាំងសិលាទាំងនោះ, ភ្លើងក៏ឆេះឡើងក្នុងខណៈនោះភ្លាម កាលកត្តឆ្អិន ភ្លើងនោះក៏រលត់ទៅដែរ ពួកគាត់ក៏ដឹងថាភត្តឆ្អិនហើយ ដោយសញ្ញានោះឯង ។ សូម្បីក្នុងវេលាស្ងោជាដើម ក៏ន័យនេះដែរ។ ជោតិកសេដ្ឋី និងកិរិយារបស់គាត់តែងតែចំអិនអាហារដោយថ្មាំងសិលាដែលឆេះដោយអាការយ៉ាងនេះ ។

ជនទាំងនោះ រស់នៅដោយពន្លឺកែវមណី, មិនបានដឹងថាជាពន្លឺភ្លើង ឬថាពន្លឺប្រទីបឡើយ ។

បានឮថា សម្បត្តិរបស់ជោតិកសេដ្ឋីបែបនោះ បានប្រាកដទូទៅជម្ពូទ្វីបទាំងមូល ។ មហាជនទឹមរទេះជាដើមមកដើម្បីមើលសម្បត្តិរបស់សេដ្ឋី ។

ជោតិកសេដ្ឋី បញ្ជាឲ្យចំអិនកត្តដោយអង្ករ ដែលនាំមកអំពីឧត្តរកុរុទ្វីប ហើយឲ្យៗដល់ជនទាំងឡាយដែលមកហើយៗ, ប្រាប់មហាជនថា "អ្នកទាំងឡាយ ចូរកាន់យកសំពត់, ចូរកាន់យកគ្រឿងប្រដាប់ អំពីដើមកល្បព្រឹក្សទាំងឡាយ" ហើយឲ្យបើកមាត់ឃ្លាំងកំណប់ទ្រព្យ ដែលមានប្រមាណមួយគាវុត ហើយប្រាប់ថា "អ្នកទាំងឡាយចូរកាន់យកទ្រព្យល្មមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបានចុះ" ។

កាលជនទាំងឡាយអ្នកនៅក្នុងជម្ពូទ្វីបទាំងអស់ កាន់យកទ្រព្យហើយទៅ មាត់ឃ្លាំងនៃកំណប់ទ្រព្យមិនបានរលស់សូម្បីតែមួយអង្គុលី ។

បានឮថា នោះជាផលនៃរតនៈដែលគាត់រោយ ធ្វើឲ្យជាស្រទាប់ក្នុងបរិវេណព្រះគន្ធកុដិ ។

## ព្រះបាទពិម្ពិសារមានព្រះបំណងនឹងទតប្រាសាទ

កាលមហាជន កាន់យកសំពត់អាភរណ៍ និងទ្រព្យតាមសេចក្ដីត្រូវការហើយទៅយ៉ាងនោះ, ព្រះបាទពិម្ពិសារមានព្រះបំណង់នឹងទតប្រាសាទរបស់ជោតិកសេដ្ឋីដែរ ប៉ុន្តែដោយមហាជនមកច្រើនពេក ទើបព្រះអង្គមិនមានឱកាស ។

ក្រោយមក កាលមហាជនតិចទៅៗ ព្រោះកាន់យកវត្ថាភរណ៍និងទ្រព្យតាមសេចក្ដីត្រូវការហើយទៅ ទើបព្រះរាជាត្រាស់ទៅកាន់បិតារបស់ជោតិកសេដ្ឋីថា "ខ្ញុំមានបំណងនឹងមើលប្រាសាទនៃបុត្ររបស់អ្នក" បិតារបស់ជោតិកៈនោះក្រាបទូលថា "ប្រសើរណាស់ ព្រះសម្មតិទេព" ហើយទៅប្រាប់បុត្ររបស់ខ្លួនថា "នែបា ព្រះរាជាមានព្រះបំណងនឹងទតប្រាសាទរបស់អ្នក" ជោតិកៈពោលថា "ប្រសើរណាស់បិតា, សូមឲ្យព្រះអង្គស្ដេចយាងមកចុះ" ។

ព្រះរាជា ស្ដេចទៅកាន់ទីនោះ មួយអន្ទើដោយរាជបរិវារជាច្រើន ។ ទាសីអ្នកបោសសំអាត់ខ្លោងទ្វារជំបូងបានថ្វាយដៃចំពោះព្រះរាជា ។ ព្រះរាជាទ្រង់អៀន ដោយសំគាល់ថា "កិរិយារបស់សេដ្ឋី" ទើបមិនទ្រង់ដាក់ព្រះហស្ដលើដៃរបស់នាង ។ ព្រះរាជាទ្រង់សម្គាល់ទាសីដែលបោសសំអាត់ខ្លោងទ្វារដ៏សេសថា "ជាកិរិយារបស់សេដ្ឋី" យ៉ាងនោះ ទើបមិនទ្រង់ដាក់ព្រះហស្ដលើដៃនៃទាសីទាំងនោះ ។

ជោតិកសេដ្ឋី មកទទួលព្រះរាជា ថ្វាយបង្គំហើយ នៅអំពីក្រោយ ក្រាបទូលថា "បពិត្រព្រះសម្មតិទេព សូមស្ដេចយាងចូលទៅខាងក្នុង" ផែនដីដែលប្រដាប់ដោយកែវ ហាក់ដូចជាជ្រោះមានជម្រៅមួយរយជួរបុរស ប្រាកដចំពោះព្រះ-រាជា ។ ព្រះរាជាទ្រង់សម្គាល់ថា "ជោតិកសេដ្ឋីនេះ ជីករណ្ដៅទុកដើម្បីចាប់អញ" ទើបមិនហ៊ានដាក់ព្រះបាទចុះ" ។

ជោតិកសេដ្ឋីក្រាបទូលថា "បពិត្រព្រះសម្មតិទេពនេះមិនមែនជារណ្ដៅទេ, សូមព្រះអង្គស្ដេចមកតាមក្រោយខ្ញុំព្រះអង្គ" ហើយបាននាំព្រះរាជាចូលទៅខាងក្នុង ។

ព្រះរាជា ទ្រង់ជាន់ផែនដីក្នុងកាលដែលជាតិកសេដ្ឋីនោះជាន់ហើយ ស្តេចយាងទតប្រាសាទតាំងអំពីជាន់ក្រោមរហូតដល់ជាន់លើ ។

## ព្រះបាទអជាតសត្រូវទ្រង់តូចព្រះទ័យ

គ្រានោះ ព្រះរាជកុមារទ្រង់ព្រះនាមថាអជាតសត្រូវទ្រង់ចាប់ព្រះអង្គុលីនៃព្រះរាជាបិតា ស្តេចត្រាច់ទៅ ទ្រង់ព្រះតម្រិះថា "ឱ បិតារបស់អញជាមនុស្សអន្ធពាល, ជាតិកៈនេះមានឋានៈត្រឹមតែគហបតិ ប៉ុន្តែរស់នៅក្នុងប្រាសាទដែលសម្រេចដោយកែវ ៧ ប្រការ, ចំណែកបិតារបស់យើងជាព្រះរាជា ប៉ុន្តែទ្រង់ប្រថាប់នៅក្នុងផ្ទះដែលធ្វើអំពីឈើ, ពេលដែលយើងបានជាព្រះរាជា យើងនឹងលើកកងទ័ពមកដណ្តើមយកប្រាសាទរបស់សេដ្ឋីនេះ នឹងមិនឲ្យគហបតីនេះនៅក្នុងប្រាសាទនេះ" កាលព្រះរាជាកំពុងតែស្តេចឡើងកាន់ប្រាសាទជាន់លើនោះឯង ពេលវេលានៃការសោយព្រះក្រយាហាររបស់ព្រះរាជាក៏បានមកដល់, ព្រះរាជាត្រាស់ហៅ

សេដ្ឋីមកហើយ ត្រាស់ថា “មហាសេដ្ឋី ពួកយើងនឹង បរិភោគអាហារពេលព្រឹកនៅទីនេះ” ។

សេដ្ឋី. បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គក៏ជ្រាប, ព្រះក្រយាហារសម្រាប់ព្រះអង្គ ខ្ញុំព្រះអង្គត្រៀមទុកហើយ ។

ព្រះរាជាទ្រង់ស្រង់ទឹកក្រអូប ១៦ ថ្នាំង ហើយទ្រង់គង់លើបល្ល័ង្កដែលជាទីអង្គុយរបស់សេដ្ឋីនោះ ដែលគេតាក់តែងទុកក្នុងមណ្ឌបជាទីអង្គុយរបស់សេដ្ឋី ដែលសម្រេចដោយកែវ ។

## ព្រះរាជាទ្រង់គង់សោយក្នុងផ្ទះជោតិកសេដ្ឋី

គ្រានោះ ពួកអ្នកបម្រើថ្វាយទឹកសម្រាប់លាងព្រះ-ហស្តចំពោះព្រះរាជា ហើយដួសបាយាសដ៏សៅហ្មងដាក់អំពីភាជនៈមាសដែលមានតម្លៃមួយសែន តម្កល់ទុកខាងមុខព្រះភក្រ្តព្រះរាជា ។ ព្រះរាជាទ្រង់ផ្តើមនឹងសោយដោយសម្គាល់ថា “ជាភោជន” ។

សេដ្ឋីក្រាបទូលថា “បពិត្រព្រះសម្មតិទេព នេះមិនមែនជាភាជនៈ, នេះជាបាយាសសៅហ្មងទេ ។ ពួកអ្នកបម្រើ

ដួសភោជនដាក់ក្នុងភាជនៈមាសដទៃ ហើយដាក់ទុកក្នុងថាសមាសមុន" ។

បានឮថា ការបរិភោគភោជនដោយចំហាយដែលតាំងឡើងអំពីភាជនៈបាយាសសៅហ្មងនោះ រមែងជាហេតុនាំមកនូវសេចក្ដីសុខ ។ ព្រះរាជាកាលសោយភោជនដ៏ថ្លៃ ក៏មិនទ្រង់ស្គាល់ប្រមាណ ។

គ្រានោះ សេដ្ឋីថ្វាយបង្គំព្រះរាជាហើយ ផ្គងអញ្ជលីក្រាបទូលថា បពិត្រព្រះសម្មតិទេព ល្មមហើយ, ការសោយតែត្រឹមប៉ុណ្ណឹង ចូរមានព្រះអង្គចុះ, ព្រោះព្រះអង្គមិនអាចនឹងទ្រង់ធ្វើអាហារដ៏ក្រៃលែងជាងនេះ ឲ្យរលួយបានទេ" ។

គ្រានោះ ព្រះរាជាត្រាស់សួរសេដ្ឋីថា "ម្នាលគហបតីអ្នកធ្វើការធ្ងន់ចិត្តឬ ទើបពោលដល់កត្តរបស់ខ្លួន ?"

សេដ្ឋី. បពិត្រព្រះសម្មតិ ការណ៍នុ៎ះ មិនមែនដូច្នោះទេ ត្បិតថា កត្តសម្រាប់កងពលរបស់ព្រះអង្គសូម្បីទាំងអស់ ក៏នេះ, សម្ងក៏នេះ, ក៏ប៉ុន្តែខ្ញុំព្រះអង្គខ្លាចអំពីការសាបសូន្យបាកយស ។

ព្រះរាជា. ព្រោះហេតុអ្វី ?

សេដ្ឋី. ប្រសិនបើ ហេតុត្រឹមតែការខ្ជិលប្រអូសនៃព្រះកាយ នឹងគប្បីមានដល់ព្រះសម្មតិទេពនោះ, ខ្ញុំព្រះអង្គខ្លាចចំពោះពាក្យថា ពីថ្ងៃម្សិល ព្រះរាជាសោយ (ភត្ត) នៅផ្ទះរបស់សេដ្ឋី ។ សេដ្ឋីពិតជាធ្វើអ្វី ( ថ្វាយជាប្រាជក ) ។

ព្រះរាជា. បើដូច្នោះ អ្នកចូរនាំភត្តទៅ, ចូរនាំទឹកមក។

ក្នុងទីបំផុតនៃភត្តកិច្ចរបស់ព្រះរាជា រាជបរិពារទាំងអស់ក៏បរិភោគភត្តនោះឯង ។

## ព្រះរាជាទ្រង់សន្ទនាជាមួយនិងសេដ្ឋី

ព្រះរាជា ទ្រង់គង់ដោយព្រះវាចាជាគ្រឿងពោលប្រារព្ធសេចក្ដីសុខ ត្រាស់ហៅសេដ្ឋីមកហើយ ទ្រង់សួរថាម្នាលសេដ្ឋី អ្នកមិនមានភរិយាទេឬ ?”

សេដ្ឋី. មាន ព្រះសម្មតិទេព ។

ព្រះរាជា. នាងនៅឯណា ?

សេដ្ឋីក្រាបទូលថា នាងអង្គុយនៅក្នុងបន្ទប់ដ៏មានសិរីមិនបានដឹងថាព្រះអង្គស្ដេចយាងមក ។

ក៏ព្រះរាជាព្រមទាំងរាជបរិពារ ស្តេចមកតាំងអំពីព្រឹកក៏ពិត, ប៉ុន្តែនាងមិនដឹងថាព្រះរាជាស្តេចយាងមក ។

គ្រានោះ សេដ្ឋីដឹងថា "ព្រះរាជាមានព្រះបំណងនឹងទតកិរិយារបស់ខ្លួន" ទើបទៅកាន់សំណាក់នាងហើយ ប្រាប់ថា "ព្រះរាជាស្តេចយាងមកហើយ ការដែលនាងចូលទៅគាល់ព្រះអង្គ មិនគួរឬ ?"

## កិរិយាសេដ្ឋីតូចចិត្តដែលនៅមានអ្នកធំជាងខ្លួន

ចំណែកកិរិយារបស់សេដ្ឋីនោះ ទាំងដែលនៅដេកនោះឯង បានសួរថា "បពិត្រអ្នកជាម្ចាស់ ឈ្មោះថាព្រះរាជានោះជាអ្វី ?" កាលសេដ្ឋីប្រាប់ថា "បុគ្គលដែលជាធំរបស់ពួកយើង ឈ្មោះថាព្រះរាជា", ក៏បង្ហាញនូវការៈនៃខ្លួនជាអ្នកមានចិត្តមិនរីករាយ ពោលថា "ពួកយើងនៅមានបុគ្គលជាធំជាង ( របថា ) ធ្វើបុញ្ញកម្មទាំងឡាយទុកមិនល្អហើយហ្ន៎, ពួកយើងធ្វើបុញ្ញកម្មទាំងឡាយដោយមិនមានសទ្ធា ទើបកើតក្នុងទីជាតាំងនៃឥស្សរភាពនៃបុគ្គលដទៃ, ទាននឹងជាទាន

ដែលយើងទាំងពីរមិនជឿហើយឲ្យ, នេះជាផលនៃទាននោះ” ហើយពោលថា “បពិត្រនាយ តើខ្ញុំគួរធ្វើយ៉ាងណា ?”

សេដ្ឋី. នាងចូរយកផ្ចិតជាងត្នោតបក់ថ្វាយព្រះរាជា ។

កាលកិរិយាជោតិកសេដ្ឋី យកផ្ចិតជាងត្នោតបក់ថ្វាយព្រះរាជានោះ ខ្យល់លាយដោយក្លិនឈ្នួតព្រះរាជាប៉ះត្រូវភ្នែករបស់នាង ។

## កិរិយាសេដ្ឋីហូរទឹកភ្នែក

គ្រានោះ ទទឹកភ្នែកហូរចេញចាកភ្នែករបស់នាង, ព្រះរាជាទ្រង់ទតឃើញអាការនោះ ក៏ត្រាស់ទៅកាន់សេដ្ឋីថា “មហាសេដ្ឋី ធម្មតាមាតុគ្រាម មានការចេះដឹងតិច ប្រហែលជានាងយំ ព្រោះខ្លាចថា “ព្រះរាជានឹងដណ្ដើមយកសម្បត្តិស្វាមីរបស់យើង, អ្នកចូរលួងលោមនាង, យើងមិនត្រូវការសម្បត្តិរបស់អ្នកទេ” ។

សេដ្ឋី. បពិត្រព្រះសម្មតិទេព មិនមែននាងយំទេ ។

ព្រះរាជា. កាលបើដូច្នោះ នោះជាអ្វីទៅ ?

សេដ្ឋី. ទឹកភ្នែករបស់នាងហូរចេញមក ព្រោះក្លិននៃព្រះកូសារបស់ព្រះអង្គ, ត្បិតថា កិរិយារបស់ខ្ញុំព្រះអង្គនេះមិនធ្លាប់ឃើញពន្លឺប្រទីប ឬពន្លឺភ្លើង តែងតែបរិភោគ អង្គុយនិងដេកក្រោមពន្លឺកែវមណីប៉ុណ្ណោះ, ចំណែកព្រះសម្មតិទេពប្រហែលជាទ្រង់គង់ដោយពន្លឺប្រទីប ។

ព្រះរាជា. ត្រឹមត្រូវ សេដ្ឋី ។

សេដ្ឋីក្រាបទូលថា បពិត្រព្រះសម្មតិទេព បើដូច្នោះចាប់ពីថ្ងៃនេះទៅ សូមព្រះអង្គទ្រង់គង់ដោយពន្លឺកែវមណីចុះ, លុះពោលដូច្នោះហើយ ក៏បានថ្វាយកែវមណីដែលមានតម្លៃកាត់ថ្លៃពុំបាន ប្រមាណប៉ុនផ្លែឪឡឹក ។

ព្រះរាជា ទ្រង់ទតផ្ទះសេដ្ឋីហើយ ត្រាស់ថា "សម្បត្តិរបស់ជោតិកៈច្រើនពិតមែន" ហើយស្តេចយាងទៅវិញ ។

រឿងរបស់ជោតិកត្ថេរនេះស្ទះទុកសិន

**កុមារជដិលត្រូវមាតាយកទៅអណ្តែតទឹក**

ឥឡូវនេះ គប្បីជ្រាបការកើតឡើងនៃជដិលសេដ្ឋី ៖-

សេចក្ដីពិស្ដារថា នៅក្នុងពារាណសី មានធីតារបស់សេដ្ឋីម្នាក់ ជាស្រីមានរូបស្រស់ស្អាត ។ មាតាបិតាឲ្យស្រីបម្រើម្នាក់ទុកដើម្បីមើលថែនាង ពេលនាងមានអាយុ ១៥-១៦ ឆ្នាំង ឲ្យនាងនៅក្នុងបន្ទប់ដ៏មានសិរីលើផ្ទៃប្រាសាទជាន់ទី ៧ ។

ថ្ងៃមួយ វិទ្យាធរម្នាក់ហោះនៅលើអាកាស ឃើញនាងកំពុងបើកបង្អួចមើលខាងក្រៅ កើតសេចក្ដីស្រឡាញ់ ក៏ចូលទៅតាមបង្អួចហើយ ធ្វើសេចក្ដីស្និទ្ធស្នាលជាមួយនាង។ អាស្រ័យការនៅរួមជាមួយនិងវិទ្យាធរនោះ នាងក៏តាំងគភ៌អស់កាលមិនយូរ ។

គ្រានោះ ទាសីនោះឃើញហេតុនោះហើយ ក៏ពោល "បពិត្រនាងម្ចាស់ ការណនេះ ដូចម្ដេច ? នាងប្រាប់ថា "រឿងនោះចូរលើកទុក, នាងកុំប្រាប់អ្នកណាឲ្យសោះ", ទើបនៅស្ងៀមព្រោះខ្លាច ។ ដោយកាលកន្លងទៅ ១០ ខែ នាងក៏ប្រសូតិបុត្ត ហើយឲ្យទាសីនោះយកភាជនៈថ្មីមក ឲ្យទារកនោះដេកក្នុងភាជនៈនោះហើយ បិទភាជនៈនោះ ដាក់កម្រង

ផ្កាខាងលើ ប្រើទាសីថា "នាងចូរយកសីរសៈទូលកាជនៈនេះទៅអណ្តែតក្នុងស្ទឹងគង្គាចុះ, បើមានអ្នកណាសួរថា នេះជាអ្វី ? នាងគប្បីប្រាប់ថា ពលីកម្មរបស់នាងម្ចាស់ខ្ញុំ ។ ទាសីនោះក៏បានធ្វើយ៉ាងនោះ ។

## ស្ត្រី ២ នាក់ឈ្លោះគ្នាទារកជដិល

ស្ត្រីពីរនាក់កំពុងងូតទឹក ផ្នែកខាងក្រោមនៃស្ទឹងគង្គា ឃើញកាជនៈនោះ ត្រូវទឹកបន្សាត់មក, ស្ត្រីម្នាក់ពោលថា "កាជនៈនោះជារបស់ខ្ញុំ" ម្នាក់ទៀតពោលថា "វត្ថុដែលនៅក្នុងកាជនៈនោះ ជារបស់ខ្ញុំ" កាលកាជនៈ ( អណ្តែតមក ) ដល់ ក៏ចាប់កាជនៈនោះដាក់លើគោក បើកមើលឃើញទារក ស្ត្រីម្នាក់និយាយថា "ទារកជារបស់ខ្ញុំ ព្រោះខ្ញុំបានពោលថា កាជនៈជារបស់ខ្ញុំ" ។ ម្នាក់ទៀតនិយាយថា "ទារកជារបស់ខ្ញុំ ព្រោះខ្ញុំពោលថា វត្ថុដែលនៅក្នុងកាជនៈនោះជារបស់ខ្ញុំ" ។

ស្ត្រីទាំងពីរនាក់នោះឈ្លោះគ្នា ទៅកាន់សាលាវិនិច្ឆ័យ ហើយ ប្រាប់សេចក្តីនោះ កាលពួកអាមាត្យវិនិច្ឆ័យមិនបាន ក៏ទៅកាន់សម្នាក់ព្រះរាជា ។

ព្រះរាជា ទ្រង់ព្រះសណ្ដាប់ពាក្យរបស់ស្ត្រីទាំងពីរនាក់នោះ ទើបត្រាស់ថា "នាងចូរយកទារក, នាងចូរយកភាជនៈ" ។

ក៏ស្ត្រីដែលបានទារកនោះ ជាឧបដ្ឋាយិការបស់ព្រះមហាកច្ចាយនត្ថេរ, ព្រោះហេតុនោះ ទើបស្ត្រីនោះចិញ្ចឹមទារកនោះ ដោយគិតថា "នឹងឲ្យទារកនេះបួសក្នុងសម្នាក់ព្រះថេរៈ" ។

## ហេតុដែលទារកនោះមានឈ្មោះថាជដិលៈ

សក់របស់ទារកនោះ ជារបស់កណ្ដាញ់ ដោយសារមន្ទិលនៃគភ៌ដែលសេដ្ឋីធីតាមិនលាងសំអាត់ ក្នុងថ្ងៃដែលទារកនោះកើត ។ ព្រោះហេតុនោះ ទើបជនទាំងឡាយដាក់ឈ្មោះឲ្យទារកនោះថា "ជដិល" ។

នៅពេលដែលក្មេងនោះដើរបាន ព្រះថេរៈចូលទៅកាន់ផ្ទះនោះដើម្បីបិណ្ឌបាត ។ ឧបាសិកានិមន្តព្រះថេរៈឲ្យគង់ហើយ ប្រគេនអាហារ ។

ព្រះថេរៈឃើញក្មេងនោះ ក៏សួរថា "ឧបាសិកា នាង បានក្មេងឬ ?"

ឧបាសិកាប្រាប់ថា "ព្រះករុណា លោកម្ចាស់, ខ្ញុំព្រះករុណាចិញ្ចឹមក្មេងនេះ ដោយសង្ឃឹមថា នឹងឲ្យបួសក្នុងសម្នាក់លោកម្ចាស់, សូមលោកម្ចាស់បំបួសក្មេងនេះផង" ដូច្នោះហើយ បានប្រគេនក្មេងនោះទៅព្រះថេរៈ ។

## ព្រះមហាកច្ចាយនទទួលក្មេងយកទៅប្រគល់ឲ្យឧបដ្ឋាក

ព្រះថេរៈទទួលថា "ប្រពៃហើយ" ហើយនាំក្មេងនោះទៅ ពិចារណាមើលថា បុញ្ញកម្មដែលជាហេតុឲ្យបានសោយសម្បត្តិសម្រាប់គ្រហស្ថរបស់ក្មេងនេះ មានដែរឬហ្ន៎ ? គិតថា សត្វអ្នកមានបុណ្យច្រើន នឹងសោយសម្បត្តិធំ, ក្មេងនេះនៅក្មេងនៅឡើយ, សូម្បីញាណរបស់គេក៏មិនទាន់ចាស់ក្លាដែរ" ទើបនាំក្មេងនោះទៅកាន់ផ្ទះឧបដ្ឋាកម្នាក់ ក្នុងក្រុងតក្កសិលា ។ ឧបដ្ឋាកនោះថ្វាយបង្គំព្រះថេរៈហើយ ឈរក្នុងទីសមគួរ, ឃើញក្មេងនោះហើយ សួរព្រះថេរៈថា "បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់បានក្មេងឬ ?"

ព្រះថេរៈឆ្លើយតបថា “អើ ឧបាសក, ក្មេងនេះគេនឹងបួស, ប៉ុន្តែគេនៅក្មេងពេក, ទើបអាត្មាយកមកឲ្យនៅជាមួយឧបាសកសិន” ។

ឧបាសកនោះយល់ព្រមថា ប្រពៃហើយ លោកម្ចាស ហើយទុកដាក់ក្មេងនោះក្នុងឋានៈជាបុត្តចិញ្ចឹម ។

ក៏កណ្ដុះក្នុងផ្ទះរបស់ឧបាសកនោះ ជារបស់ដុះដាលឡើងអស់ ១២ ឆ្នាំហើយ ។ ឧបាសកនោះទៅកាន់ចន្លោះស្រុក នាំយកកណ្ដុះនោះទាំងអស់ទៅកាន់ផ្សារ ឲ្យក្មេងនោះក្នុងផ្សារហើយ ប្រាប់តម្លៃនៃកណ្ដុះនោះ ៗ ហើយពោលថា “ឯងគប្បីកាន់យកទ្រព្យប្រមាណប៉ុណ្ណេះ ហើយទើបឲ្យវត្ថុនេះ និងវត្ថុនេះ” ដូច្នោះហើយ ចៀសចេញទៅ ។

## ទេវតាជួយឲ្យក្មេងលក់របស់អស់

ថ្ងៃនោះ ទេវតាដែលរក្សាព្រះនគរ ធ្វើជនអ្នកមានសេចក្ដីត្រូវការ ( វត្ថុ ) ដោយហោចទៅសូម្បីតែអ្នកត្រូវការម្រេចនិងស្លឹកជីរជាដើម ឲ្យមានមុខឆ្ពោះទៅកាន់រានផ្សាររបស់ក្មេងនោះទាំងអស់ ។ ក្មេងនោះលក់វត្ថុដែលសន្សំទុក

អស់ ១២ ឆ្នាំ ( អស់ ) តែមួយថ្ងៃប៉ុណ្ណោះ ។ កុដុម្ពិកមក មិនឃើញអ្វីៗ ក្នុងរានផ្សារ ក៏សួរថា "នែបា ឯងធ្វើវត្ថុទាំងអស់ឲ្យវិនាសហើយឬ" ។

ក្មេងឆ្លើយថា "ខ្ញុំមិនបានធ្វើទ្រព្យឲ្យវិនាសទេ, ខ្ញុំលក់វត្ថុទាំងអស់នោះតាមន័យដែលអ្នកប្រាប់នោះ, នេះជាតម្លៃនៃវត្ថុឈ្មោះនោះ, នេះជាតម្លៃវត្ថុឈ្មោះនោះ" កុដុម្ពិកសប្បាយចិត្ត គិតថា "បុរសមានតម្លៃកាត់ថ្លៃមិនបាន អាចរស់នៅទីណាក៏បាន" ទើបលើកកូនស្រីដែលទើបតែពេញវ័យឲ្យក្មេងនោះ ប្រើអ្នកបម្រើថា "ពួកឯងចូរសាងផ្ទះឲ្យកូនប្រសារបស់យើង" កាលផ្ទះធ្វើហើយ ក៏ប្រាប់ថា "នែបា ពួកឯងចូរទៅនៅក្នុងផ្ទះរបស់ខ្លួនចុះ" ។

## ជដិលកុមារបានជាសេដ្ឋីដោយសារភ្នំមាសផុសនៅជិតផ្ទះ

គ្រានោះ គ្រាន់តែជដិលកុមារនោះជាន់ដោយជើងម្ខាងក្នុងកាលជាទីចូលទៅកាន់ផ្ទះ ភ្នំមាសប្រមាណ ៨០ ហត្ថទំលាយផែនដីផុសឡើងខាងក្រោយផ្ទះ ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់ថា "ក្នុំមាសផុសឡើងនៅជិតផ្ទះជដិលកុមារក្លាម" ក៏ទ្រង់បញ្ជូនឆត្រសម្រាប់សេដ្ឋីទៅព្រះរាជទានឲ្យក្លាមដែរ ។ ជដិលកុមារនោះមានឈ្មោះថា ជដិលសេដ្ឋី ។ ជដិលសេដ្ឋីនោះមានបុត្ត ៣ នាក់ ។

## ជដិលសេដ្ឋីឲ្យបុត្តដើរស៊ើបសួររកសេដ្ឋីដែលស្មើនិងខ្លួន

សេដ្ឋីនោះញុំាងចិត្តឲ្យកើតឡើងក្នុងបព្វជ្ជា ក្នុងកាលដែលបុត្រទាំងនោះធំពេញវ័យថា "ប្រសិនបើត្រកូលសេដ្ឋីដែលមានភោគៈសម្បត្តិស្មើ និងភោគៈសម្បត្តិរបស់យើងមាននោះ, បុត្តទាំងឡាយក៏នឹងឲ្យយើងបួសបាន, បើមិនមានទេ បុត្តទាំងឡាយនឹងមិនឲ្យយើងបួសឡើយ, ក្នុងជម្ពូទ្វីបនេះត្រកូលដែលមានសម្បត្តិស្មើនិងសម្បត្តិរបស់យើង មានឬហ្ន៎ ?" លុះគិតដូច្នោះហើយ ក៏ឲ្យជាងធ្វើឥដ្ឋមាស ដងជន្លួញមាស និងទ្រនាប់ជើងមាស រួចហើយឲ្យទៅអ្នកបម្រើទាំងឡាយ ដើម្បីល្បងមើល បញ្ជូនទៅដោយពាក្យថា "ពួកឯងចូរទៅ, ចូរកាន់ឥដ្ឋមាសជាដើមនេះ ធ្វើដូចជារកមើលអ្វីមួយ

ត្រាច់ទៅកាន់ជម្ពូទ្វីបហើយ សុំបឲ្យដឹងថាត្រកូលសេដ្ឋី ដែលមានសម្បត្តិស្មើនិងសម្បត្តិរបស់យើង មានដែរឬអត់ ហើយ ចូរមក” អ្នកបម្រើទាំងនោះត្រាច់ទៅកាន់ទីចារិក បាន ទៅដល់កទ្ទិយនគរ ។

## ពួកអ្នកបម្រើជួបមេណ្ឌសេដ្ឋី

គ្រានោះ មេណ្ឌសេដ្ឋីឃើញអ្នកបម្រើទាំងនោះហើយ ក៏សួរថា “នៃអ្នកដ៏ចម្រើន អ្នកទាំងឡាយត្រាច់ទៅធ្វើអ្វី ?” កាលពួកអ្នកបម្រើប្រាប់ថា “ពួកខ្ញុំដើររកមើលវត្ថុមួយ” ដឹង ថា “កិច្ចដោយការកាន់ឥដ្ឋមាសជាដើមត្រាច់ទៅ ដើម្បីរក មើលវត្ថុអ្វី ៗ របស់អ្នកបម្រើទាំងនេះ រមែងមិនមាន, អ្នក បម្រើទាំងនេះដើរសុំបសួររកមើលសេដ្ឋី” ទើបពោលថា “ម្នាលអ្នកដ៏ចម្រើនទាំងឡាយ អ្នកចូរមក ចូរចូលទៅមើល ផ្ទះរបស់យើង” ។

អ្នកបម្រើទាំងនោះ ឃើញពពែមាសទាំងឡាយ មាន ប្រមាណប៉ុនដំរី សេះ និងគោឧសភៈដែលយកខ្នងទល់គ្នា

ផុសឡើងក្នុងទីប្រមាណ ៨ ករីស ខាងក្រោយផ្ទះនោះហើយ ដើរទៅក្នុងចន្លោះ ៗ ពាំពែទាំងនោះហើយ ចៀសចេញទៅ ។

គ្រានោះ សេដ្ឋីសួរអ្នកបម្រើទាំងនោះថា "នៃអ្នកទាំងឡាយ អ្នកទាំងឡាយត្រាច់ទៅដើម្បីស៊ើបរកមើលអ្នកណា, អ្នកនោះ អ្នកទាំងឡាយបានឃើញហើយឬ ?" កាលអ្នកបម្រើប្រាប់ថា "បពិត្រសេដ្ឋី ពួកខ្ញុំបានឃើញហើយ" ទើបបញ្ជូនអ្នកបម្រើទាំងនោះទៅដោយពោលថា "អ្នកទាំងឡាយចូរទៅ"

អ្នកបម្រើទាំងនោះទៅអំពីទីនោះហើយ, កាលសេដ្ឋីរបស់ខ្លួនសួរថា "នៃអ្នកទាំងឡាយ ត្រកូលសេដ្ឋីដែលមានទ្រព្យសម្បត្តិនិងយើង ពួកឯងឃើញហើយឬ ?" ក៏ប្រាប់ថា បពិត្រសេដ្ឋី ទ្រព្យសម្បត្តិរបស់លោកនេះ ហៅថាមានអ្វី ? មេណ្ឌកសេដ្ឋីនៅក្នុងភទ្ទិយឯណោះ ទើបឈ្មោះថាជាអ្នកមានទ្រព្យសម្បត្តិច្រើនពិតមែន" ហើយប្រាប់រឿងរាវនោះទាំងអស់ដល់សេដ្ឋី ។

## ជដិលសេដ្ឋីឲ្យស៊ើបសួរជាលើកទី ២

សេដ្ឋីស្ដាប់ពាក្យនោះហើយ មានចិត្តត្រេកអរ គិតថា "ត្រកូលសេដ្ឋី យើងបានស្វែងរកឃើញមួយត្រកូលហើយ, ត្រកូលសេដ្ឋីដទៃទៀត មានដែរឬហ្ន៎ ?" ហើយឲ្យសំពត់កម្ពលមានតម្លៃមួយសែន បញ្ជូនទៅថា "នែអ្នកទាំងឡាយ អ្នកទាំងឡាយចូរទៅ, ចូរស្វែងរកត្រកូលសេដ្ឋីដទៃទៀត" ។ អ្នកបម្រើទៅកាន់ក្រុងរាជគ្រឹះហើយ ធ្វើគំនរឧសក្នុងទីមិនឆ្ងាយអំពីផ្ទះជោតិកសេដ្ឋី ដុតឲ្យឆេះហើយឈរជុំវិញគំនរភ្លើងនោះ ។

ពេលដែលមហាជនមកសួរថា "មានរឿងអ្វី ?" ក៏ប្រាប់ថា "កាលពួកខ្ញុំលក់សំពត់កម្ពលដែលមានតម្លៃច្រើនមួយផ្ទាំងនេះ គ្មានអ្នកណាទិញ, បើពួកខ្ញុំកាន់ដើរទៅ ខ្លាចចោរ, ព្រោះហេតុនេះ ពួកខ្ញុំប្រាថ្នានឹងដុតវាចោលហើយទើបចៀសចេញទៅ"

## ពួកអ្នកបម្រើជួបជោតិកសេដ្ឋី

គ្រានោះ ជោតិកសេដ្ឋីឃើញពួកអ្នកបម្រើទាំងនោះ ក៏សួរថា "ពួកនេះធ្វើអ្វី ?" កាលដឹងរឿងនោះហើយ ក៏ឲ្យគេ

ទៅហៅអ្នកបម្រើទាំងនោះមកសួរថា "សំពត់កម្ពលមានតម្លៃប៉ុន្មាន ?" កាលពួកអ្នកបម្រើប្រាប់ថា "មានតម្លៃមួយសែន" ក៏ប្រើអ្នកបម្រើរបស់ខ្លួនឲ្យៗ សំពត់កម្ពលមានតម្លៃមួយសែន ដោយប្រាប់ថា "អ្នកទាំងឡាយ ចូរឲ្យសំពត់មួយផ្ទាំងនោះដល់ទាសីអ្នកបោសសំអាត់ខ្លោងទ្វារចុះ" ហើយបញ្ជូនទៅឲ្យអ្នកបម្រើទាំងនោះ ។ ទាសីនោះទទួលយកសំពត់នោះហើយ យំដើរទៅកាន់សំណាក់ជោតិកសេដ្ឋីប្រាប់ថា "បពិត្រអ្នកជាម្ចាស់ កាលកំហុសរបស់ខ្ញុំមាន ប្រហារនាងខ្ញុំ មិនគួរឬ ? ព្រោះហេតុអ្វី ទើបបញ្ជូនសំពត់កម្ពលសាច់គ្រោតគ្រាតយ៉ាងនេះទៅឲ្យខ្ញុំ ? ខ្ញុំនឹងស្លៀកឬដណ្តប់សំពត់កម្ពលបែបនេះដោយប្រការដូចម្តេច ?"

ជោតិកសេដ្ឋី . ខ្ញុំមិនបានបញ្ជូនទៅឲ្យនាងដើម្បីប្រយោជន៍ដល់ការស្លៀកឬដណ្តប់នោះទេ ប៉ុន្តែបញ្ជូនសំពត់កម្ពលមួយផ្ទាំងនោះទៅឲ្យនាង ដើម្បីប្រយោជន៍ដល់ការមូរសំពត់កម្ពលនុ៎ះ ហើយតម្កល់ទុកក្នុងទីជិតដំណេករបស់នាងសម្រាប់ជូតជើង នៅពេលដែលនាងលាងដោយទឹកប្រអប

ក្នុងកាលចូលដេក, សូម្បីកិច្ចមានប្រមាណប៉ុណ្ណោះនាងមិនអាចបានឬ ?

ទាសីនោះពោលថា បើដូច្នោះ ខ្ញុំអាចធ្វើកិច្ចនោះបាន ទើបទទួលយកសំពត់នោះទៅ ។

ចំណែកអ្នកបម្រើទាំងនោះ ឃើញហេតុនោះហើយ ក៏ទៅកាន់សំណាក់សេដ្ឋីរបស់ខ្លួន កាលសេដ្ឋីសួរថា នែអ្នកទាំងឡាយ ត្រកូលសេដ្ឋី អ្នកទាំងឡាយបានឃើញហើយឬ ? ក៏ប្រាប់ថា "បពិត្រសេដ្ឋី លោកនឹងមានអ្វី, សម្បត្តិបែបនេះរបស់សេដ្ឋីឈ្មោះជោតិកៈ មាននៅក្នុងក្រុងរាជគ្រឹះ" ទើបពណ៌នាអំពីសម្បត្តិទាំងពួងក្នុងផ្ទះ ហើយប្រាប់រឿងរ៉ាវទាំងអស់ដល់សេដ្ឋី ។

សេដ្ឋីស្ដាប់ពាក្យរបស់អ្នកបម្រើទាំងនោះហើយ មានចិត្តសោមនស្សស្រស់ប្បាយរីករាយ គិតថា "ឥឡូវនេះ យើងអាចបួសបានហើយ" លុះគិតដូច្នោះហើយ ក៏ទៅកាន់សម្នាក់ព្រះរាជាក្រាបទូលថា "បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គមានបំណងនឹងបួស" ។

ព្រះរាជាត្រាស់ថា "ប្រពៃហើយ មហាសេដ្ឋី អ្នកចូរ បួសចុះ" ។

សេដ្ឋីនោះទៅផ្ទះហើយ ឲ្យហៅបុត្តទាំងឡាយមក ហើយ ដាក់ចបជងមាស ផ្ទៃពេជ្រ ក្នុងដៃបុត្តច្បងហើយ ពោលថា "នែកូន កូនឯងចូរគាស់យកដុំមាសអំពីក្នុំដែលនៅ ខាងក្រោយផ្ទះរបស់យើងចុះ" បុត្តច្បងនោះយកចបទៅ គាល់ក្នុំមាស, កាលបុត្តច្បងរបស់សេដ្ឋីនោះកាប់ក្នុំនោះ ដូច ជាកាប់ផ្ទាំងថ្មដាដូច្នោះ ។

សេដ្ឋីយកចបអំពីដៃកូនប្រុសច្បង ឲ្យទៅកូនប្រុស កណ្តាល ។ សូម្បីកូនប្រុសកណ្តាលនោះគាល់ក្នុំមាស, កាលគេកាប់នោះ ហាក់ដូចជាកាប់ផ្ទាំងថ្មដាដូច្នោះដែរ ។

គ្រានោះ សេដ្ឋីក៏យកចបអំពីដៃកូនប្រុសកណ្តាលឲ្យ ទៅកូនប្រុសពៅ ។ កាលកូនប្រុសពៅនោះ ទទួលយកចប ទៅដើម្បីគាស់ក្នុំ ពេលដែលគេកាប់នោះឯង ហាក់ដូចជា កាប់ដីស្អិតដែលគេគរទុកដូច្នោះ ។

គ្រានោះ សេដ្ឋីក៏ពោលទៅកាន់កូនប្រុសពៅនោះថា នែកូន ចូរមក លួមហើយដោយទ្រព្យមានប្រមាណប៉ុណ្ណោះ ហើយឲ្យហៅកូនប្រុស ២ នាក់ក្រៅនេះមកហើយ ប្រាប់ថា "ក្អមមាសនេះ មិនមែនកើតឡើងដើម្បីពួកឯងទេ, កើតឡើងដើម្បីពុកនិងប្អូនប្រុសរបស់ពួកឯងប៉ុណ្ណោះ, ពួកឯងចូរប្រើប្រាស់រួមជាមួយនិងប្អូនពៅនេះចុះ" ។

សួរថា "ព្រោះហេតុអ្វី ? ទើបក្អមមាសនោះកើតឡើងដើម្បីបិតានិងកូនប្រុសពៅប៉ុណ្ណោះ ? ព្រោះហេតុអ្វី ទើបជដិលសេដ្ឋីត្រូវគេយកទៅទម្លាក់ទឹកក្នុងវេលាកើតហើយ ?"

ឆ្លើយថា ព្រោះកម្មដែលខ្លួនធ្វើទុកហើយនោះឯង ។

## បុព្វកម្មរបស់ជដិលសេដ្ឋី

**សេចក្តីពិស្តារថា កាលមហាជនកំពុងកសាងព្រះចេតិយរបស់ព្រះកស្សបសម្មាសម្ពុទ្ធ ព្រះខីណាស្រពមួយអង្គទៅកាន់ចេតិយដ្ឋាន ពិនិត្យមើលហើយសួរថា "នែអ្នក**ទាំងឡាយ ព្រោះហេតុអ្វី មុខខាងទិសឧត្តរនៃចេតិយ មិនទាន់សាងឡើង ?"

មហាជន. បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្វះមាស ។

ព្រះទីណាស្រេព. អាត្មាភាពនឹងចូលទៅកាន់ស្រុក ហើយបបួលមហាជន, អ្នកទាំងឡាយ ចូរធ្វើកម្មដោយអើពើចុះ ។

ព្រះទីណាស្រេពនោះ ពោលយ៉ាងនោះហើយ ចូរទៅកាន់ព្រះនគរ បបួលមហាជនថា "នែអ្នកទាំងឡាយ មាសសម្រាប់ធ្វើមុខចេតិយខាងទិសឧត្តរមិនគ្រប់គ្រាន់, អ្នកទាំងឡាយចូរដឹងមាសនោះចុះ" បានទៅកាន់ត្រកូលជាងមាសចំណែកជាងមាសកំពុងឈ្លោះប្រកែកជាមួយនិងភរិយា ។

គ្រានោះ ព្រះថេរៈពោលទៅកាន់ជាងនោះថា "មាសសម្រាប់មុខព្រះចេតិយ ដែលអ្នកទាំងឡាយទទួលមិនទាន់គ្រប់គ្រាន់, ការដែលអ្នកដឹងនូវមាសនោះ រមែងគួរ ។

ដោយអំណាចសេចក្ដីក្រោធចំពោះភរិយា ជាងនោះក៏ទៅកាន់ព្រះថេរៈថា "លោកចូរបោះព្រះសាស្ដារបស់លោកចុះក្នុងទឹកហើយទៅចុះ" ។

គ្រានោះ កិរិយារបស់ជាងមាសនោះក៏ពោលថា "លោកធ្វើកម្មធុតតាប់ក្រៃលែងណាស់ លោកខឹងខ្ញុំ គួរជេរ ឬវាយខ្ញុំប៉ុណ្ណោះ, ហេតុដូចម្តេច ទើបចងពៀរជាមួយនិងព្រះពុទ្ធទាំងឡាយ ទាំងជាអតីតអនាគតនិងបច្ចុប្បន្នទៅវិញ ?" ក្នុងនោះឯង ជាងមាសនោះក៏តក់ស្លុតហើយ ពោលថា "បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់អត់ទោសឲ្យខ្ញុំព្រះករុណាផង" ហើយក្រាបចុះទៀបជើងព្រះថេរៈ ។

ព្រះថេរៈ. ញោម អាត្មាមិនត្រូវញោមពោលស្តីអ្វីទេ, ញោមចូរសូមទោសព្រះសាស្តាចុះ" ។

ជាងមាស. បពិត្រលោកម្ចាស់ ខ្ញុំព្រះករុណាធ្វើដូចម្តេចទៅ ទើបសូមទោសព្រះសាស្តាបាន ។

ព្រះថេរៈ. ញោមចូរធ្វើកុម្ភផ្កាឈូកបីកុម្ភ ហើយចូរដាក់ក្នុងទីបញ្ចុះព្រះធាតុ រួចហើយជាអ្នកមានសំពត់ទទឹកមានសក់ទទឹក ញុំាងព្រះសាស្តាឲ្យអត់ទោសចុះ ។

ជាងមាសទទួលថា "ប្រពៃហើយ លោកម្ចាស់" ហើយមុននឹងធ្វើផ្កាឈូកមាស បានហៅកូនប្រុសច្បងមក

ហើយ ពោលថា "នែកូន ចូរមក, ពុកបានពោលទៅកាន់ព្រះសាស្តាដោយពាក្យដ៏ជាពៀរ, ព្រោះដូច្នោះ ពុកនឹងធ្វើផ្កាឈូកទាំងនេះ តម្កល់ក្នុងទីបញ្ចុះព្រះធាតុ ដើម្បីឲ្យព្រះសាស្តាអត់ទោស, ដូច្នេះ សូម្បីកូនឯង ក៏ចូរជាសម្លាញ់របស់ពុកដែរ" ។

កូនប្រុសច្បងនោះឆ្លើយថា " ខ្ញុំមិនបានប្រើពុកឯងឲ្យពោលពាក្យដ៏ជាពៀរចំពោះព្រះសាស្តាឯណា, ដូច្នេះពុកឯងធ្វើតែម្នាក់ឯងចុះ " ហើយមិនប្រាថ្នានឹងធ្វើ ។

ជាងមាស ឲ្យហៅកូនប្រុសកណ្តាលមកហើយ ពោលដូចមុន ។ សូម្បីកូនប្រុសកណ្តាលនោះក៏ពោលដូចបងប្រុសរបស់ខ្លួនដែរ ហើយមិនព្រមជួយធ្វើ ។ ជាងមាសក៏ឲ្យហៅកូនប្រុសពៅមកហើយ ពោល ( ដូចមុន ) ។

កូនប្រុសនោះ គិតថា "ធម្មតាកិច្ចដែលកើតឡើងដល់បិតា រមែងជាភារៈរបស់បុត្រ " លុះគិតដូច្នេះហើយ ក៏ជួយធ្វើផ្កាឈូកបិតា ។ ជាងមាសធ្វើផ្កាំងផ្កាឈូកប្រមាណ ១ ចំអាម ៣ ឲ្យសម្រេចហើយ ដាក់ក្នុងទីបញ្ចុះព្រះធាតុ មាន

សំពត់ទទឹក សក់ទទឹក ញុំាងព្រះសាស្តាឲ្យអត់ទោស ។ ជាង មាសនោះត្រូវគេយកទៅបោះចោលក្នុងទឹកក្នុងកាលដែលខ្លួន កើតហើយអស់ ៧ ដងដោយប្រការដូច្នេះ ។

ក៏អត្តភាពរបស់គាត់ដែលតាំងនៅក្នុងទីបំផុត សូម្បី ក្នុងកាឥឡូវនេះ ក៏ត្រូវគេយកទៅបណ្តែតទឹក ដោយផលនៃ កម្មនោះដែរ ។ ចំណែកបុត្ររបស់គាត់ ២ នាក់ មិនព្រមធ្វើ ជាសម្លាញ់នឹងគាត់ក្នុងកាលធ្វើផ្កាឈូកមាស,ព្រោះហេតុនោះ ទើបផ្កាមាសមិនកើតដើម្បីបុត្រទាំង ២ នោះ, ប៉ុន្តែកើតឡើង ដើម្បីកូនប្រុសពៅរបស់គាត់ ព្រោះកូននោះបានធ្វើផ្កាឈូក មាសរួមជាមួយនឹងបិតា ។

## ជដិលសេដ្ឋីចេញបួសបានសម្រេចអរហត្ត

សេដ្ឋីនោះ ប្រៀនប្រដៅបុត្រដោយប្រការដូច្នេះហើយ បួសក្នុងសម្នាក់ព្រះសាស្តា បានសម្រេចព្រះអរហត្ត ដោយ កាល ២-៣ ថ្ងៃប៉ុណ្ណោះ ដោយប្រការដូច្នេះ ។

ក្នុងសម័យដទៃទៀត ព្រះសាស្តាត្រាច់ទៅដើម្បីបិណ្ឌ- បាតជាមួយនឹងភិក្ខុ ៥០០ រូប ស្តេចទៅកាន់ទ្វារផ្ទះនៃបុត្រទាំង

ឡាយរបស់សេដ្ឋីនោះ ។ បុត្រទាំងនោះ បានប្រគេនភិក្ខាហារ ចំពោះភិក្ខុអស់កន្ទះខែ ។

ភិក្ខុទាំងឡាយ សន្ទនាគ្នាក្នុងធម្មសភាថា “ ម្នាល អាវុសោជដិល ឥឡូវនេះ តណ្ហាក្នុងក្អមមាសប្រមាណ ៨០ ហត្ថ ក្នុងបុត្រទាំងឡាយរបស់អ្នកមានឬ ?” ។

ព្រះជដិល. ម្នាលអាវុសោ តណ្ហា ឬមានះក្នុងក្អមមាស និងក្នុងបុត្រទាំងឡាយរបស់ខ្ញុំ អស់ហើយ ។

ភិក្ខុទាំងនោះក៏ពោលថា ព្រះជដិលត្ថេរនេះពោលពាក្យ មិនពិត ព្យាករព្រះអរហត្តផល ។

ព្រះសាស្តា ទ្រង់ព្រះសណ្តាប់ពាក្យរបស់ភិក្ខុទាំងនោះ ហើយ ត្រាស់ថា “ ម្នាលភិក្ខុទាំងឡាយ តណ្ហា ឬមានះក្នុង ក្អមមាស និងបុត្រទាំងឡាយនៃបុត្រតថាគតអស់ហើយ មិន មានទៀតទេ ” ដូច្នេះហើយ កាលនឹងទ្រង់សម្តែងធម៌ ទើប ត្រាស់ព្រះគាថានេះថា :-

**៣៣ យោធ តណ្ហំ បហន្ត្វាន អនាគារោ បរិព្វជេ**
**តណ្ហាភវបរិក្ខីណំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា ក្នុងលោកនេះ បានលះបង់តណ្ហា
ហើយ ជាអ្នកមិនមានផ្ទះ គេចចេញចាកតណ្ហា
បាន តថាគតហៅបុគ្គល ដែលអស់តណ្ហា និង
ភពហើយនោះ ថាជាព្រាហ្មណ៍ ។

អធិប្បាយគាថា

គប្បីជ្រាបសេចក្ដីនៃព្រះគាថានោះថា :-

បុគ្គលណាលះតណ្ហាដែលប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ ក្នុងលោកនេះបាន ជាអ្នកមិនមានសេចក្ដីត្រូវការនៅគ្រប់គ្រងផ្ទះ ឈ្មោះថា ជាអ្នកមិនមានផ្ទះ គេចចេញចាកតណ្ហាបានហើយ តថាគតហៅបុគ្គលនោះថា អ្នកមានតណ្ហា និងភពអស់ហើយ ព្រោះភាវៈនៃតណ្ហា និងភពអស់ទៅដោយជុំវិញហើយនោះ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

ព្រះបាទអជាតសត្តុប្រាថ្នានឹងជណ្ដើមយកផ្ទះសេដ្ឋី

ចំណែកព្រះបាទអជាតសត្តុកុមារ សពគប់នឹងព្រះ-ទេវទត្ត ធ្វើឃាតព្រះបិតា តាំងនៅក្នុងរាជសម្បត្តិហើយ ទ្រង់ព្រះតម្រិះថា " យើងនឹងដណ្តើមយកប្រាសាទជោតិកសេដ្ឋី " ទើបទ្រង់ត្រៀមចម្បាំង ហើយស្តេចចេញទៅ លុះទតឃើញស្រមោលរបស់ព្រះអង្គ មួយអន្លើដោយបរិវារត្រង់កំពែងកែវភ្លាម ក៏ទ្រង់យល់ព្រះទ័យថា "គហបតីលើកពលមកហើយ" ទើបមិនអាចស្តេចចូលទៅបាន ។

ថ្ងៃនោះ សេដ្ឋីរក្សាឧបោសថ បរិភោគអាហារពេលព្រឹកអំពីព្រលឹម ហើយទៅកាន់វិហារ អង្គុយស្តាប់ធម៌ក្នុងសម្នាក់ព្រះសាស្តា ។

ចំណែកយក្ខឈ្មោះយមមោលី ដែលរក្សាខ្លោងទ្វារទី ១ ឃើញព្រះបាទអជាតសត្តុ ក៏សួរថា " បពិត្រមហារាជព្រះអង្គយាងទៅណា ?" ហើយកម្ចាត់ព្រះបាទអជាតសត្តុមួយអន្លើដោបរិវារ ដេញតាមទៅក្នុងទិសតូច និងទិសធំទាំងឡាយ ។ ព្រះរាជាក៏ស្តេចទៅកាន់វិហារដែរ ។

គ្រានោះ សេដ្ឋីគ្រាន់តែឃើញព្រះរាជាភ្ញាម ក៏ក្រោកឡើងចាកអាសនៈ ទូលសួរថា " បពិត្រមហារាជ មានរឿងអ្វី ?" ។

ព្រះរាជា.ម្នាលគហបតី អ្នកបង្គាប់ពួកបុរសរបស់អ្នកថា ចូរច្បាំងជាមួយនឹងយើង, ហើយមកកាន់ទីនេះ អង្គុយធ្វើដូចជាស្តាប់ធម៌ឬ ?

សេដ្ឋី. បពិត្រព្រះសម្មតិទេព ព្រះអង្គស្តេចទៅដើម្បីដណ្តើមយកផ្ទះទូលព្រះបង្គំ ពិតមែនឬ ?

ព្រះរាជា. អើ យើងទៅ ។

សេដ្ឋី. បពិត្រព្រះសម្មតិទេព សូម្បីព្រះរាជាទាំងពាន់ក៏មិនអាចនឹងដណ្តើមយកផ្ទះខ្ញុំព្រះអង្គបាន ប្រសិនបើទូលបង្គំមិនប្រាថ្នានឹងថ្វាយ ។

ព្រះរាជាទ្រង់ត្រាស់ថា "ក៏អ្នកនឹងជាព្រះរាជាឬ ?"

សេដ្ឋី. បពិត្រសម្មតិទេព ទូលព្រះបង្គំមិនជាព្រះរាជាទេ, ប៉ុន្តែព្រះរាជាឬចោរមិនអាចនឹងកាន់យកសូម្បីតែចេស

ពួដ៏ជាយសំពត់ដែលជារបស់ទូលព្រះបង្គំបាន ព្រោះទូលព្រះបង្គំមិនប្រាថ្នា ។

ព្រះរាជា. ក៏យើងនឹងកាន់យកតាមការពេញចិត្តរបស់អ្នកបានយ៉ាងណា ?

សេដ្ឋី. បពិត្រសម្មតិទេព បើដូច្នោះ ចិញ្ចៀន ២០ ពួដ៏ម្រាមដៃទាំងដប់របស់ខ្ញុំព្រះអង្គ, ខ្ញុំព្រះអង្គមិនថ្វាយចិញ្ចៀនទាំងនេះចំពោះព្រះអង្គទេ ប្រសិនបើព្រះអង្គអាចកាន់យកបាននោះ សូមព្រះអង្គទ្រង់កាន់យកចុះ ។

ក៏ព្រះរាជាអង្គនោះ កាលទ្រង់គង់ប្រហោងលើផែនដីព្រះអង្គអាចលោតឡើងទៅលើបាន ១៨ ហត្ថ, កាលទ្រង់ប្រថាប់ឈរ ព្រះអង្គអាចលោតកម្ពស់បាន ៨០ ហត្ថ ។

ព្រះរាជា សូម្បីទ្រង់ជាអ្នកមានកម្លាំងច្រើនយ៉ាងនេះ ទ្រង់លោតទៅមកខាងនោះ និងខាងនេះ ក៏មិនអាចនឹងដកសូម្បីតែចិញ្ចៀនមួយបាន ។

## សេដ្ឋីស្មុតចិត្តប្រាថ្នានឹងបួស

គ្រានោះ សេដ្ឋីក្រាបទូលព្រះរាជាថា "បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់ក្រាលសំពត់សាជក" ហើយធ្វើម្រាមដៃទាំងដប់ឲ្យត្រង់ ចិញ្ចៀនសូម្បីទាំង ២០ វង់ របូតចេញមក ។

គ្រានោះ សេដ្ឋីក្រាបទូលព្រះរាជាថា "បពិត្រព្រះសម្មតិទេព ប្រសិនបើខ្ញុំព្រះអង្គមិនឲ្យទេ អ្នកណា ៗ ក៏មិនអាចនឹងកាន់យកទ្រព្យសម្បត្តិ ដែលជារបស់ខ្ញុំព្រះអង្គដោយអាការយ៉ាងនោះបានដែរ" ដូច្នេះហើយ កើតការស្លុតចិត្តដោយសារកិរិយារបស់ព្រះរាជា ទើបក្រាបទូលថា "បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់អនុញ្ញាតការដល់ខ្ញុំព្រះអង្គ" ព្រះរាជាទ្រង់ព្រះតម្រិះថា "កាលសេដ្ឋីនេះបួស, យើងនឹងយកប្រាសាទនេះបានស្រួល" ទើបត្រាស់ថា "ម្នាលសេដ្ឋីអ្នកចូរបួសចុះ" ដោយព្រះតម្រាស់តែមួយព្រះឱស្ឋប៉ុណ្ណោះ។

សេដ្ឋីនោះបួសក្នុងសម្នាក់ព្រះសាស្ដាហើយ មិនយូរប៉ុន្មានក៏បានសម្រេចព្រះអរហត្ត មានឈ្មោះថា ព្រះជោតិកត្ថេរ ។

ក្នុងខណៈ ដែលលោកបានសម្រេចព្រះអរហត្តហើយ នោះឯង ទ្រព្យសម្បត្តិទាំងអស់នោះក៏អន្តរធានទៅ ។ ពួកទេវតាក៏នាំកិរិយារបស់សេដ្ឋី ឈ្មោះសតុលកាយានោះ ទៅកាន់ឧត្តរកុរុទ្វីបវិញ ។

## ពួកភិក្ខុយល់ថាព្រះថេរៈពោលអួតឧត្តរិមនុស្សធម៌

ក្រោយមក ភិក្ខុទាំងឡាយហៅព្រះជោតិកត្ថេរមកហើយ សួរថា "ម្នាលអាវុសោជោតិកៈ ក៏តណ្ហាក្នុងប្រាសាទឬក្នុងស្ត្រីនោះរបស់អ្នកនៅមានឬ ? កាលលោកប្រាប់ថា មិនមានទេ អ្នកមានអាយុទាំងឡាយ" ក៏ក្រាបទូលព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុឈ្មោះជោតិកៈនេះ ពោលពាក្យមិនពិត ព្យាករព្រះអរហត្តផល" ។

ព្រះសាស្តាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ បុត្តរបស់តថាគតមិនមានតណ្ហាក្នុងប្រាសាទឬក្នុងស្ត្រីនោះទេ" ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា ៈ-

បុគ្គលណា ក្នុងលោកនេះ បានលះបង់តណ្ហា
ហើយ ជាអ្នកមិនមានផ្ទះ គេចចេញចាកតណ្ហា

បាន តថាគតហៅបុគ្គល ដែលអស់តណ្ហា និង
ភពហើយនោះ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

រឿងព្រះជោតិកត្ថេរ ចប់

៣៤

## ៣៤ រឿងភិក្ខុអ្នកធ្លាប់ជាអ្នករបាំទីមួយ

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវន ទ្រង់ប្រារព្ធភិក្ខុអ្នកធ្លាប់ជាអ្នករបាំមួយរូប ត្រាស់ព្រះធម្មទេសនានេះថា **“ហិត្វា មានុសកំ”** ជាដើម ។

## អ្នករបាំចេញបួសបានសម្រេចព្រះអរហត្ត

បានឮថា អ្នករបាំនោះដើរលេងកីឡាគឺការរាំមួយបែប ស្តាប់ធម្មកថារបស់ព្រះសាស្តា បួសហើយបានសម្រេចព្រះអរហត្ត ។ កាលភិក្ខុនោះកំពុងចូលទៅបិណ្ឌបាតជាមួយនឹងភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ភិក្ខុទាំងឡាយឃើញបុត្តអ្នករបាំម្នាក់កំពុងរាំ ក៏សួរថា “ម្នាលអាវុសោ បុត្តរបស់អ្នករបាំនោះ លេងកីឡាដែលអ្នកធ្លាប់លេងហើយ, អ្នកនៅមានតណ្ហាក្នុងកីឡាបែបនេះឬ ?” កាលភិក្ខុនោះឆ្លើយប្រាប់ថា “មិនមានទេ” ក៏ពោលថា “អ្នកមានអាយុទាំងឡាយ ភិក្ខុនេះពោលពាក្យមិនពិត ព្យាករព្រះអរហត្តផល” ។

ព្រះសាស្តា ទ្រង់ព្រះសណ្តាប់ពាក្យរបស់ភិក្ខុទាំងនោះហើយ ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ បុត្តតថាគតឈាន

កន្ទងកិលេសជាគ្រឿងប្រកបទាំងពួងបានហើយ"  ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា ៖-

**៣៤ ហិត្វា មានុសកំ យោគំ ទិព្វំ យោគំ ឧបច្ចគា**
**សព្វយោគវិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា លះកិលេសជាគ្រឿងប្រកប
ដែលជារបស់មនុស្ស កន្ទងកិលេសជាគ្រឿង
ប្រកប ដែលជារបស់ទិព្វបានហើយ តថាគត
ហៅបុគ្គល ដែលផុតស្រឡះ ចាកកិលេសជា
គ្រឿងប្រកបទាំងពួងនោះ ថាជាព្រាហ្មណ៍ ។

**អធិប្បាយគាថា**

បណ្ដាបទទាំងនោះ ពីរបទថា **មានុសកំ យោគំ** បានដល់ អាយុនិងកាមគុណទាំង ៥ ដែលជារបស់មនុស្ស ។ សូម្បីកិលេសជាគ្រឿងដែលជាទិព្វ ក៏មានន័យដូច្នេះដែរ ។

បទថា **ឧបច្ចគា** ជាដើម សេចក្ដីថា បុគ្គលណាលះកិលេសគ្រឿងប្រកប ដែលជារបស់មនុស្ស ឈានកន្លងកិលេសគ្រឿងប្រកបដែលជាទិព្វបានហើយ, តថាគតហៅ

បុគ្គលនោះ ដែលប្រាសចាកកិលេសគ្រឿងប្រកបទាំងអស់ សូម្បី ៤ យ៉ាងបានហើយថា ជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

រឿងភិក្ខុអ្នកធ្លាប់ជាអ្នករបាំរូបទីមួយ

## ៣៥ រឿងភិក្ខុអ្នកធ្លាប់ជាអ្នករបាំរូបទីពីរ

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវន ទ្រង់ប្រារព្ធភិក្ខុអ្នកធ្លាប់ជាអ្នករបាំមួយរូប ត្រាស់ព្រះធម្មទេសនានេះថា "**ហិត្វា រតិញ្ច**" ជាដើម

## ព្រាហ្មណ៍លះសេចក្តីត្រេកអរនិងសេចក្តីមិនត្រេកអរ

រឿងដូចគ្នារឿងមុននោះឯង ។ ប៉ុន្តែក្នុងរឿងនេះ ព្រះសាស្តាត្រាស់ថា "ភិក្ខុទាំងឡាយ បុត្ររបស់តថាគតលះបង់សេចក្តីត្រេកអរ និងសេចក្តីមិនត្រេកអរបានហើយ" ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា ៖-

**៣៥ ហិត្វា រតឹ អរតិញ្ច  សីតិភូតំ និរូបធឹ**
**សព្វលោកាភិភុំ វីរំ  តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគតហៅបុគ្គល ដែលលះបង់សេចក្តី
ត្រេកអរក្នុងកាមគុណ  និងមិនត្រេកអរក្នុង
កិរិយានៅក្នុងព្រៃ  ជាអ្នកមានចិត្តត្រជាក់ មិន

មានឧបក្កិលេស     គ្របសង្កត់លោកទាំងពួង
មានសេចក្តីព្យាយាមនោះ ថាជាព្រាហ្មណ៍ ។

**អធិប្បាយគាថា**

បណ្តាបទទាំងនោះ បទថា **រតឹ** បានដល់ សេចក្តីត្រេកអរក្នុងកាមគុណ ៥ ។

បទថា **អរតឹ** បានដល់ អ្នកអផ្សុកក្នុងការនៅក្នុងព្រៃ។

បទថា **សីតិភូតំ** បានដល់ អ្នករលត់ហើយ ។

បទថា **និរូបធឹ** បានដល់ អ្នកមិនមានឧបក្កិលេស ។

បទថា **វីរំ** សេចក្តីថា តថាគតហៅបុគ្គលអ្នកគ្របសង្កត់ខន្ធលោកទាំងអស់បានហើយ អ្នកមានសេចក្តីព្យាយាមនោះ គឺបែបនោះថា ជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

រឿងភិក្ខុអ្នកធ្លាប់ជាអ្នករបាំរូបទីពីរ ចប់

# ៣៦ រឿងព្រះវង្គីសត្ថេរ

## សេចក្តីខាងដើម

បានឮថា ព្រាហ្មណ៍ដែលមានប្រក្រតីនៅក្នុងក្រុងរាជគ្រឹះមួយរូបឈ្មោះវង្គីសៈ គោះក្បាលមនុស្សដែលស្លាប់ហើយ ក៏ដឹងបានថា “នេះជាក្បាលអ្នកកើតក្នុងនរក, នេះជាក្បាលអ្នកកើតក្នុងកំណើតសត្វតិរច្ឆាន, នេះជាក្បាលអ្នកកើតក្នុងបេតវិស័យ, នេះជាក្បាលអ្នកកើតក្នុងមនុស្សលោក, នេះជាក្បាលអ្នកកើតក្នុងទេវលោក” ។

ពួកព្រាហ្មណ៍គិតថា “ពួកយើងអាស្រ័យព្រាហ្មណ៍ឈ្មោះវង្គីសៈនេះ អាចរកទ្រព្យបាន” ទើបឲ្យវង្គីសៈស្លៀកសំពត់ក្រហម ២ ផ្ទាំងហើយនាំទៅកាន់ជនបទ ពោលទៅកាន់មនុស្សទាំងឡាយថា “ព្រាហ្មណ៍ឈ្មោះវង្គីសៈនេះ គោះ

ក្បាលមនុស្សដែលស្លាប់ហើយ អាចដឹងទីកើតបាន, អ្នកទាំងឡាយចូរសួរអំពីទីកើតនៃញាតិរបស់អ្នកទាំងឡាយចុះ”

មនុស្សទាំងនោះឲ្យទ្រព្យ ១០ កហាបណៈខ្លះ ២០ ខ្លះ ១០០ ខ្លះ តាមកម្លាំងហើយ ទើបសួរអំពីទីកើតនៃញាតិរបស់ខ្លួន ។ ព្រាហ្មណ៍ទាំងនោះទៅដល់ក្រុងសាវត្ថីដោយលំដាប់ហើយ សំណាក់នៅក្នុងទីជិតវត្តជេតពន, ពួកគេឃើញមហាជនដែលបរិភោគអាហារព្រឹកហើយ មានដៃកាន់គ្រឿងក្រអូបនិងកម្រងផ្កាជាដើម ដើរទៅដើម្បីស្តាប់ធម៌ ក៏សួរថា “អ្នកទាំងឡាយទៅណា ?” កាលមហាជនប្រាប់ថា “ទៅវិហារស្តាប់ធម៌” ក៏ពោលថា “អ្នកទាំងឡាយទៅទីនោះធ្វើអ្វី ? អ្នកដែលប្រាជកស្មើនិងវង្គីសព្រាហ្មណ៍របស់ពួកយើង មិនមានឡើយ, គេគោះក្បាលមនុស្សដែលស្លាប់ហើយ ក៏ដឹងទីកើតបាន, អ្នកទាំងឡាយចូរសួរអំពីទីកើតនៃញាតិរបស់អ្នកទាំងឡាយចុះ” ។

មនុស្សទាំងនោះពោលថា “វង្គីសៈនឹងដឹងអ្វី ? បុគ្គលដែលប្រាជកស្មើនិងព្រះសាស្តារបស់ពួកយើង មិនមាន

ឡើយ” ។ ប្រកែកគ្នាហើយពោលថា “មកចុះ ឥឡូវនេះ ពួកយើងនឹងដឹងថាវង្គីសៈរបស់ពួកអ្នក ឬព្រះសាស្ដារបស់ពួកយើងមានការចេះដឹង” ហើយបាននាំព្រាហ្មណ៍ទាំងនោះទៅកាន់វិហារ ។

ព្រះសាស្ដាទ្រង់ជ្រាបថា ជនទាំងនោះមក ទើបត្រាស់ឲ្យនាំ ( លលាដ៍ ) ក្បាលខ្មោចមក ៤ គឺ “ក្បាលរបស់សត្វអ្នកកើតក្នុងឋានៈទាំង ៤ គឺ ក្នុងនរក ក្នុងកំណើតសត្វតិរច្ឆាន ក្នុងមនុស្សលោក ក្នុងទេវលោក និង ( លលាដ៍ ) សីសៈរបស់ព្រះខីណាស្រព” ត្រាស់ឲ្យដាក់តាមលំដាប់ ក្នុងពេលដែលវង្គីសៈមកដល់ហើយ ទើបត្រាស់សួរវង្គីសៈថា “ម្នាលវង្គីសៈ បានឮថា អ្នកគោះក្បាលមនុស្សដែលស្លាប់ហើយ ដឹងទីកើតរបស់សត្វទាំងឡាយដែលស្លាប់ហើយ ពិតមែនឬ ?” ។

វង្គីសៈ. ព្រះករុណា ព្រះអង្គ ខ្ញុំព្រះអង្គអាចដឹង ។

ព្រះសាស្ដា. នេះជា ( លលាដ៍ ) ក្បាលអ្នកណា ?

វង្គីសៈគោះក្បាលនោះហើយ ក្រាបទូលថា “ បពិត្រព្រះអង្គដ៏ចម្រើន របស់សត្វអ្នកកើតក្នុងនរក ” ។ លំដាប់នោះ ព្រះសាស្តាទ្រង់ប្រទានសាធុការថា “ ប្រពៃហើយ ” ទើបត្រាស់សួរសីសៈទាំង ៣ ក្រៅនេះ ក្នុងខណៈដែលវង្គីសៈក្រាបទូលហើយៗ មិនខុស ក៏ទ្រង់ប្រទានសាធុការដូចលើកមុន ទើបទ្រង់បង្ហាញសីសៈទី ៥ ហើយត្រាស់សួរថា “ នេះជា ( លលាដ៍ ) សីសៈរបស់អ្នកណា ?” វង្គីសៈគោះសីសៈនោះហើយ មិនដឹងទីកើត ។ ពេលនោះ ព្រះសាស្តាត្រាស់សួរថា “ ម្នាលវង្គីសៈ អ្នកមិនដឹងឬ ?” កាលវង្គីសៈក្រាបទូលថា “ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនដឹង ” ទើបត្រាស់ថា “ តថាគតដឹង ” ។

វង្គីសៈ. ព្រះអង្គទ្រង់ជ្រាបដោយពិធីណា ?

ព្រះសាស្តា. ជ្រាបដោយកម្លាំងមន្ត ។

គ្រានោះ វង្គីសៈទូលសូមមន្តអំពីព្រះអង្គថា “ សូមព្រះអង្គទ្រង់ប្រទានមន្តនេះដល់ខ្ញុំព្រះអង្គ ” ព្រះសាស្តាត្រាស់

ថា “ តថាគតមិនអាចឲ្យមន្តដល់បុគ្គល ដែលមិនមែនជាបព្វជិតបានទេ ”។

## វង្គីសៈបួសដើម្បីរៀនមន្ត

វង្គីសៈគិតថា “ កាលយើងរៀនមន្តហើយ យើងក៏ជាអ្នកប្រសើរក្នុងជម្ពូទ្វីបទាំងមូល ” ទើបបញ្ជូនព្រាហ្មណ៍ទាំងនោះទៅដោយពាក្យថា “ ពួកអ្នកចូរនៅទីនេះ ២-៣ ថ្ងៃសិន ខ្ញុំនឹងបួស ” ហើយបានបព្វជ្ជាឧបសម្បទាក្នុងសម្នាក់ព្រះសាស្តា មានឈ្មោះថា វង្គីសត្ថេរ ។

គ្រានោះ ព្រះសាស្តាប្រទានកម្មដ្ឋាន មានអាការ ៣២ ជាអារម្មណ៍ដល់លោកហើយ ត្រាស់ថា “ អ្នកចូរស្វាធ្យាយមន្តនេះ ” ។

## ព្រះថេរៈសម្រេចព្រះអរហត្ត

ព្រះវង្គីសត្ថេរនោះស្វាធ្យាយមន្ត ត្រូវពួកព្រាហ្មណ៍សួរក្នុងចន្លោះៗ ថា “ លោករៀនចប់មន្តហើយឬនៅ ?” ក៏ប្រាប់ថា “ ពួកអ្នកចូររង់ចាំសិន ខ្ញុំកំពុងរៀន ” អស់កាល ២-៣ ថ្ងៃប៉ុណ្ណោះ ក៏បានសម្រេចព្រះអរហត្ត ត្រូវព្រាហ្មណ៍ទាំង

នោះសួរទៀត ក៏ពោលថា " អ្នកមានអាយុទាំងឡាយ ឥឡូវនេះ អាត្មាមិនគួរទៅទេ " ។

ភិក្ខុទាំងឡាយបានឮពាក្យនោះហើយ ក៏ក្រាបទូលព្រះសាស្ដាថា " បពិត្រព្រះអង្គដ៏ចម្រើន ព្រះវង្គីសត្ថេរនេះព្យាករព្រះអរហត្តផល ដោយពាក្យមិនពិត " ។

ព្រះសាស្ដាត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំពោលយ៉ាងនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ បុត្ររបស់តថាគត ឈ្លាសវៃក្នុងការចុតិ និងបដិសន្ធិហើយ " ដូច្នេះហើយ បានត្រាស់ព្រះគាថានេះថា :-

**៣៦ ចុតឹ យោ វេទិ សត្តានំ ឧបបត្តិញ្ច សព្វសោ**
**អសត្តំ សុគតំ ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។**
**យស្ស គតឹ ន ជានន្តិ ទេវា គន្ធព្វមានុសា**
**ខីណាសវំ អរហន្តំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា ដឹងច្បាស់ចុតិ និងបដិសន្ធិរបស់ពួកសត្វ ដោយអាការទាំងពួងបាន តថាគតហៅបុគ្គល ដែលជាអ្នកមិនជាប់នៅក្នុងកាម

អ្នកមានដំណើរល្អ ដោយសេចក្ដីប្រតិបត្តិ អ្នកត្រាស់ដឹងនូវសច្ចៈ ៤ នោះ ថាជាព្រាហ្មណ៍ ។

ទេវតា គន្ធព្វ និងពួងមនុស្សទាំងឡាយ មិនដឹងគតិរបស់បុគ្គលណា តថាគតហៅបុគ្គល ដែលជាអ្នកមានអាសវៈអស់ហើយ ជាព្រះអរហន្តនោះ ថាជាព្រាហ្មណ៍ ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ ពីរបទថា **យោ វេទិ** ជាដើម សេចក្ដីថា បុគ្គលណាដឹងចុតិ និងបដិសន្ធិរបស់សត្វទាំង-ឡាយ ដោយប្រការទាំងពួងយ៉ាងច្បាស់, តថាគតហៅបុគ្គលនោះ គឺបុគ្គលដែលមិនជាប់ក្នុងកាម ព្រោះជាអ្នកមិនជាប់ជំពាក់ ឈ្មោះថា អ្នកមានដំណើរល្អ ព្រោះជាអ្នកដើរទៅហើយដោយការបដិបត្តិ ឈ្មោះថាអ្នកត្រាស់ដឹងហើយ ព្រោះជាអ្នកត្រាស់ដឹងសច្ចៈទាំង ៤ ថា ជាព្រាហ្មណ៍ ។

បទថា **យស្ស** ជាដើម សេចក្ដីថា ទេវតាជាដើម មិនដឹងគតិរបស់បុគ្គលណា, តថាគតហៅបុគ្គលអ្នកមានអាសវៈ

អស់ហើយ ព្រោះអាសវៈទាំងឡាយអស់ហើយ ឈ្មោះថា អ្នកឆ្ងាយចាកកិលេស ព្រោះជាអ្នកនៅឆ្ងាយអំពីកិលេសទាំងឡាយ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់គាថា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិជាដើម ៕ល៚

( រឿងព្រះវង្គីសត្ថេរ ចប់ )

## ៣៧ រឿងព្រះធម្មទិន្នាថេរី

### សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធភិក្ខុនីឈ្មោះធម្មទិន្នា ត្រាស់ព្រះធម្មទេសនានេះថា "**យស្ស បុរេ ច** " ជាដើម ។

## វិសាខឧបាសកសម្រេចអនាគាមិផល

សេចក្ដីពិស្ដារថា ថ្ងៃមួយ ក្នុងវេលានាងនៅជាគ្រហស្ថ វិសាខឧបាសកអ្នកជាស្វាមី ស្ដាប់ធម៌ក្នុងសម្នាក់ព្រះសាស្ដា សម្រេចអនាគាមិផលហើយ គិតថា " ការដែលយើងឲ្យនាង ធម្មទិន្នាទទួលទ្រព្យសម្បត្តិទាំងពួង គួរ ", ពេលមុនៗ ឧបា-សកនោះ កាលមកដល់ផ្ទះ ឃើញនាងធម្មទិន្នាអង្គុយមើលផ្លូវក្បែរបង្អួច តែងធ្វើការញញឹម ។ ប៉ុន្តែថ្ងៃនោះ មិនសម្លឹងមើលនាងដែលឈរនៅក្បែរបង្អួច បានដើរហួសទៅ ។

នាងគិតថា " តើមានរឿងអ្វីហ្ន៎ គិតថា រឿងនោះចូរលើកទុកសិនចុះ, យើងនឹងដឹងក្នុងវេលាបរិភោគ " ហើយនាំភត្តចូលទៅក្នុងវេលាបរិភោគ ។

ក្នុងថ្ងៃមុនៗ ឧបាសកនោះ និយាយថា មកចុះនាង យើងនឹងបរិភោគជាមួយគ្នា ។ ប៉ុន្តែថ្ងៃនោះ អង្គុយស្ងៀមធ្វើព្រងើយ បរិភោគយ៉ាងស្ងៀមស្ងាត់ ។ នាងគិតថា " ស្វាមីរបស់យើង ប្រហែលជាក្រោធខឹងដោយសារហេតុអ្វីមួយជាប្រាកដ " ។

គ្រានោះ វិសាខឧបាសក ហៅនាងក្នុងវេលាអង្គុយតាមសប្បាយមកហើយ ពោលប្រាប់នាងថា " ម្នាលធម្មទិន្នា នាងចូរទទួលយកទ្រព្យសម្បត្តិទាំងពួងក្នុងផ្ទះនេះចុះ " ។ នាងគិតថា " តើមានរឿងអ្វីហ្ន៎ ?" ក៏ពោលថា " បពិត្រនាយចុះអ្នក " ។

ឧបាសក. ចាប់ពីពេលនេះទៅ ខ្ញុំមិនអាចនឹងចាត់ចែងការងារអ្វីៗ បានឡើយ ។

ធម្មទិន្នា. នរណាទៅនឹងទទួលទឹកមាត់ដែលអ្នកស្តោះចោលហើយនោះ, កាលបើដូច្នោះ លោកចូរអនុញ្ញាតការបួសដល់ខ្ញុំផងចុះ ។

ឧបាសកនោះទទួលថា " ប្រពៃហើយ នាង " ហើយនាំនាងទៅកាន់សម្នាក់ភិក្ខុនី ដោយសក្ការៈដ៏ធំ ។ នាងបានបព្វជ្ជាឧបសម្បទាហើយ មានឈ្មោះថា ធម្មទិន្នាថេរី ។

វិសាខឧបាសកសួរបញ្ហាក្នុងមគ្គនឹងព្រះថេរី

នាងទៅកាន់ជនបទជាមួយនឹងភិក្ខុនីទាំងឡាយ ព្រោះជាអ្នកប្រាថ្នាវិវេក នៅក្នុងជនបទនោះមិនយូរប៉ុន្មាន ក៏បាន

សម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយ ត្រឡប់មកកាន់ក្រុងរាជគ្រឹះវិញ ដោយគិតថា " ឥឡូវនេះ ពួកជនជាញាតិអាស្រ័យយើងហើយ នឹងធ្វើបុណ្យទាំងឡាយ " ។

ឧបាសកបានដឹងថា ព្រះថេរីមក ក៏គិតថា " ព្រះថេរីមកដោយហេតុអ្វីហ្ន៎ " ទើបទៅកាន់សម្នាក់ភិក្ខុនី ថ្វាយបង្គំព្រះថេរីហើយ អង្គុយក្នុងទីដ៏សមគួរមួយ គិតថា កាលបើយើងសួរថា " ម្នាលនាងដ៏ចម្រើន នាងអផ្សុកឬ ក៏ជាការមិនសមគួរ, យើងនឹងសួរបញ្ហាមួយខចំពោះនាង " ។ ហើយសួរបញ្ហាក្នុងសោតាបត្តិមគ្គ ។ ព្រះថេរីឆ្លើយបញ្ហានោះបាន ។ ឧបាសកក៏សួរបញ្ហាក្នុងមគ្គដ៏សេសទៀត កាលព្រះថេរីនោះពោលក្នុងវេលាដែលឧបាសកនោះសួរហួសបញ្ហាថា វិសាខអ្នកមានអាយុ អ្នកសួរហួសបញ្ហាហើយ " ហើយពោលថា " ប្រសិនបើអ្នកមានបំណងចង់សួរបញ្ហានេះទៀត អ្នកគប្បីចូលទៅគាល់ព្រះសាស្ដាហើយទូលសួរបញ្ហានេះចុះ " ថ្វាយបង្គំព្រះថេរីហើយ ក្រោកចាកអាសនៈ ទៅកាន់សម្នាក់ព្រះ-

សាស្តា ក្រាបទូលការសន្ទនាទាំងអស់នោះចំពោះព្រះមានព្រះភាគ ។

ព្រះសាស្តាទ្រង់សរសើរព្រះធម្មទិន្នាថេរី

ព្រះសាស្តា ត្រាស់ថា “ ធម្មទិន្នាធីតារបស់តថាគតពោលត្រឹមត្រូវហើយ, ប្រសិនបើតថាគតដោះស្រាយបញ្ហានោះ ក៏តថាគតដោះស្រាយដូច្នោះដែរ ” ដូច្នេះហើយ កាលនឹងទ្រង់សម្ដែងធម៌ បានត្រាស់ព្រះគាថានេះថា :-

**៣៧ យស្ស បុរេ ច បច្ឆា ច មជ្ឈេ ច នត្ថិ កិញ្ចនំ**
**អកិញ្ចនំ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា មិនមានសេចក្ដីកង្វល់ ក្នុងកាលមុនផង ក្នុងកាលជាខាងក្រោយផង ក្នុងកាលជាកណ្ដាលផង តថាគតហៅបុគ្គល ដែលជាអ្នកមិនមានកង្វល់ មិនមានសេចក្ដីប្រកាន់នោះ ថាជាព្រាហ្មណ៍ ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **បុរេ** សេចក្ដីថា ខន្ធទាំងឡាយដែលជាអតីត ។

បទថា **បច្ឆា** គឺខន្ធទាំងឡាយដែលជាអនាគត ។

បទថា **មជ្ឈេ** បានដល់ ខន្ធទាំងឡាយ ដែលជាបច្ចុប្បន្ន ។

ពីរបទថា **នត្ថិ កិញ្ចនំ** ជាដើម សេចក្តីថា សេចក្តីកង្វល់ ពោលគឺការប្រកាន់ដោយតណ្ហាក្នុងឋានៈ ៣ ប្រការ របស់បុគ្គលណាមិនមាន, តថាគតហៅបុគ្គលនោះ ដែលមិនមានកង្វល់ដោយកិលេសគ្រឿងកង្វល់ គឺរាគៈជាដើម បុគ្គលដែលឈ្មោះថា មិនប្រកាន់មាំ ព្រោះមិនប្រកាន់អ្វីៗ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។៚

## ៣៨ រឿងព្រះអង្គុលិមាលត្ថេរ

### សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអង្គុលិមាលត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **“ឧសភំ”** ជាដើម

# ព្រះអង្គុលិមាលមិនខ្លាចដំរី

រឿងខ្ញុំពោលទុកក្នុងគាថាវណ្ណនាថា " **នវេកទរិយា ទេវលោកំ វជន្តិ** " ជាដើម ។

ពិតណាស់ ក្នុងទីនោះខ្ញុំពោលទុកថា " ភិក្ខុទាំងឡាយសួរព្រះអង្គុមាលត្ថេរថា " ម្នាលអ្នកដ៏មានអាយុ អ្នកឃើញដំរីកាចឈរបាំងឆត្រហើយ មិនខ្លាចទេឬ ?" អង្គុលិមាលឆ្លើយតបថា " ម្នាលអ្នកមានអាយុ ខ្ញុំមិនខ្លាចទេ " ។

ភិក្ខុទាំងនោះ ក្រាបទូលព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន អង្គុលិមាលព្យាករព្រះអរហត្តដោយពាក្យមិនពិត។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អង្គុលិមាលបុត្ររបស់តថាគតមិនខ្លាចទេ, ព្រោះថា ភិក្ខុទាំងឡាយដូចជាបុត្ររបស់តថាគត អ្នកដ៏ឆ្នើមក្នុងចំណោមនៃព្រះខីណាស្រពដ៏ឆ្នើមទាំងឡាយ រមែងមិនខ្លាចឡើយ " ដូច្នេះហើយ ត្រាស់ព្រះគាថានេះ ក្នុងព្រាហ្មណវគ្គថា :-

**៣៨ ឧសភំ បវរំ វីរំ មហេសឹ វិជិតាវិនំ**
**អនេជំ ន្ហាតកំ ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគតហៅវីរបុរស អ្នកអង់អាច អ្នក
ប្រសើរ អ្នកស្វែងរកគុណដ៏ធំ ឈ្នះមារ មិន
មានកិលេសជាគ្រឿងញាប់ញ័រ ងូតលាង
កិលេស ត្រាស់ដឹងសច្ចៈនោះ ថាជាព្រាហ្មណ៍ ។

អធិប្បាយគាថា

គប្បីជ្រាបសេចក្ដីនៃព្រះគាថានោះថា :-

តថាគតហៅបុគ្គលនោះ គឺបុគ្គលបែបនោះ បុគ្គលដែលឈ្មោះថា អង់អាច ព្រោះដូចជាគោឧសភៈ ដោយអត្ថថាមិនតក់ស្លុត ឈ្មោះថាប្រសើរ ព្រោះអត្ថថាខ្ពង់ខ្ពស់ ឈ្មោះថាក្លៀវក្លា ព្រោះអត្ថថាដល់ព្រមដោយសេចក្ដីព្យាយាម ឈ្មោះថា អ្នកស្វែងរកគុណដ៏ធំ ព្រោះភាពជាអ្នកស្វែងរកគុណដ៏ធំ មានសីលគុណជាដើម ឈ្មោះថា អ្នកឈ្នះហើយដោយវិសេស ព្រោះមារទាំង ៣ ខ្ទង់បានឈ្នះហើយ ឈ្មោះថា អ្នកងូតលាងហើយ ព្រោះជាអ្នកមានកិលេសលាងហើយ ឈ្មោះថា ត្រាស់ដឹង ព្រោះជាអ្នកត្រាស់ដឹងសច្ចៈទាំង ៤ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយ-
ផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

( រឿងព្រះអង្គុលិមាលត្ថេរ ចប់ )

# ៣៩ រឿងទេវហិតព្រាហ្មណ៍

## សេចក្ដីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបញ្ហាទេវហិតព្រាហ្មណ៍ ត្រាស់ព្រះធម្មទេសនានេះថា “**ឧសភំ**” ជាដើម ។

## ព្រាហ្មណ៍ទូលសួរទក្ខិណាដែលមានផលច្រើន

សេចក្តីពិស្តារថា សម័យមួយ ព្រះមានព្រះភាគទ្រង់អាពាធដោយព្រះវាយោ ( កម្រើក ) ទ្រង់បញ្ជូនព្រះឧបវាន:ទៅកាន់សម្នាក់ទេវហិតព្រាហ្មណ៍ដើម្បីត្រូវការទឹកក្តៅ ។

ព្រះឧបវាន:នោះទៅប្រាប់ទេវហិតព្រាហ្មណ៍ថា ម្នាលព្រាហ្មណ៍ ព្រះមានព្រះភាគទ្រង់អាពាធ ហើយសុំទឹកក្តៅ ។

ព្រាហ្មណ៍ស្តាប់ពាក្យនោះហើយ មានចិត្តត្រេកអរគិតថា “ ការដែលព្រះសម្មាសម្ពុទ្ធទ្រង់បញ្ជូន ( ព្រះឧបវាន: ) មកកាន់សម្នាក់យើង ដើម្បីត្រូវការទឹកក្តៅ ជាលាភរបស់យើងហ្ន៎ ” ទើបប្រើបុរសឲ្យយកអំរែករែកទឹកក្តៅ និងទឹកអំពៅមកប្រគេនព្រះឧបវាន: ។

ព្រះថេរៈ ឲ្យជនកាន់ទឹកក្តៅជាដើមនោះទៅកាន់វិហារ ក្រាបទូលព្រះសាស្តាឲ្យទ្រង់ស្រង់ទឹកក្តៅហើយ លាយទឹកអំពៅនឹងទឹកក្តៅថ្វាយព្រះមានព្រះភាគ ។

ក្នុងខណៈនោះឯង អាពាធរបស់ព្រះអង្គក៏ស្ងប់រម្ងាប់ទៅ ។ ព្រាហ្មណ៍គិតថា " ទេយ្យធម៌យើងឲ្យដល់បុគ្គលណាហ្ន៎ ? ទើបមានផលច្រើន, យើងនឹងទូលសួរព្រះសាស្តា "។

ព្រាហ្មណ៍នោះទៅកាន់សម្នាក់ព្រះសាស្តាហើយ មុននឹងទូលសួរសេចក្តីនោះ បានពោលគាថានេះថា :-

បុគ្គលគួរឲ្យទេយ្យធម៌ដល់បុគ្គលណា ? ទេយ្យធម៌
ដែលបុគ្គលឲ្យដល់បុគ្គលណា ទើបមានផលច្រើន ?
ទក្ខិណារបស់បុគ្គលអ្នកបូជាយ៉ាងណា នឹងសម្រេច
បានយ៉ាងណា ។

## ព្រះសាស្តាទ្រង់ដោះស្រាយបញ្ហារបស់ព្រាហ្មណ៍

គ្រានោះ ព្រះសាស្តាត្រាស់ថា " ទេយ្យវត្ថុដែលបុគ្គលឲ្យហើយដល់ព្រាហ្មណ៍ដូច្នេះ រមែងមានផលច្រើន " ដូច្នេះ

ហើយ កាលទឹងទ្រង់ប្រកាសបុគ្គលអ្នកជាព្រាហ្មណ៍ ដល់ព្រាហ្មណ៍នោះ បានត្រាស់ព្រះគាថានេះថា :-

៣៩ ពុព្វេនិវាសំ យោ វេទិ សគ្គាបាយញ្ច បស្សតិ
អថោ ជាតិក្ខយំ បត្តោ អភិញ្ញា វោសិតោ មុនិ
សព្វវោសិតវោសានំ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា ដឹងច្បាស់ខន្ធបញ្ចកៈ ដែលខ្លួនធ្លាប់នៅអាស្រ័យ ក្នុងកាលមុនផង ឃើញច្បាស់ឋានសួគ៌ និងអបាយភូមិផង មួយទៀត បានសម្រេចធម៌ជាគ្រឿងអស់ជាតិ ជាអ្នកប្រាជ្ញ ស្រេចកិច្ចហើយ ព្រោះអភិញ្ញា តថាគតហៅបុគ្គល ដែលជាអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ ចប់សព្វគ្រប់ហើយនោះ ថាជាព្រាហ្មណ៍ ។

## អធិប្បាយគាថា

គប្បីជ្រាបសេចក្ដីនៃព្រះគាថានោះថា :-

បុគ្គលណា ដឹងច្បាស់ខន្ធដែលខ្លួនធ្លាប់នៅអាស្រ័យ ឃើញឋានសួគ៌ ១៦ ជាន់ និងអបាយភូមិ ៤ ដោយទិព្វចក្ខុ

ពុំនោះ បានសម្រេចព្រះអរហត្ត ដែលបណ្ឌិតទាំងឡាយរាប់ថា ធម៌ជាគ្រឿងអស់ទៅនៃជាតិ សម្រេចកិច្ចហើយ ព្រោះដឹងយ៉ាងក្រៃលែងនូវធម៌ដែលគួរដឹងយ៉ាងក្រៃលែង កំណត់ដឹងធម៌ដែលគួរកំណត់ដឹង លះបង់ធម៌ដែលគួរលះបង់ ធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ គឺសម្រេចព្រះ-និព្វាន ឬសម្រេចព្រហ្មចរិយៈដែលខ្លួនអប់រំហើយ ឈ្មោះថាមុនី ព្រោះការៈជាអ្នកដល់នូវភាពជាមុនី ដោយបញ្ញាជាគ្រឿងអស់ទៅនៃអាសវៈ, តថាគតហៅបុគ្គលដែលប្រព្រឹត្តព្រហ្មចរិយធម៌ចប់សព្វគ្រប់ហើយ ព្រោះជាអ្នកនៅចប់ព្រហ្ម-ចរិយៈ ដែលជាទីបំផុតនៃកិលេសទាំងឡាយ គឺព្រះអរហត្ត-មគ្គញ្ញាណនោះ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយ-ផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

ចំណែកព្រាហ្មណ៍ មានចិត្តជ្រះថ្លាហើយ តាំងនៅក្នុងសរណៈទាំងឡាយ ប្រកាសភាពជាឧបាសក ។

( រឿងរេវតព្រាហ្មណ៍ ចប់ )

ព្រាហ្មណវគ្គវណ្ណនា ចប់

វគ្គទី ២៦ ចប់

រួមវគ្គដែលមានក្នុងគាថាធម្មបទគឺ

យមកវគ្គ អប្បមាទវគ្គ ចិត្តវគ្គ បុប្ផវគ្គ ពាលវគ្គ បណ្ឌិតវគ្គ អរហន្តវគ្គ សហស្សវគ្គ បាបវគ្គ ទណ្ឌ-វគ្គ ជរាវគ្គ អត្តវគ្គ លោកវគ្គ ពុទ្ធវគ្គ សុខវគ្គ បិយ-វគ្គ កោធវគ្គ មលវគ្គ ធម្មដ្ឋវគ្គ មគ្គវគ្គ រួមជា ២០-វគ្គ បកិណ្ណកវគ្គ និរយវគ្គ នាគវគ្គ តណ្ហាវគ្គ ភិក្ខុ-វគ្គ ព្រាហ្មណវគ្គ រួមទាំងអស់នេះជា ២៦ វគ្គដែលព្រះពុទ្ធជាផៅពង្សនៃព្រះអាទិត្យ ទ្រង់សម្តែងហើយ ក្នុងយមកវគ្គមាន ២០ គាថា ក្នុងអប្បមាទវគ្គ មាន ១២ គាថា ក្នុងចិត្តវគ្គ មាន ១១ គាថា ក្នុងបុប្ផវគ្គ-មាន ១៦ គាថា ក្នុងពាលវគ្គមាន ១៧ គាថា ក្នុង-បណ្ឌិតវគ្គមាន ១៤ គាថា ក្នុងអរហន្តវគ្គមាន ១០ គាថា ក្នុងសហស្សវគ្គមាន ១៦ គាថា ក្នុងបាបវគ្គ មាន ១៣ គាថា ក្នុងទណ្ឌវគ្គមាន ១៧ គាថា ក្នុង-ជរាវគ្គមាន ១១ គាថា ក្នុងអត្តវគ្គមាន ១២ គាថា ក្នុងលោកវគ្គមាន ១២ គាថា ក្នុងពុទ្ធវគ្គមាន ១៦

គាថា ក្នុងសុខវគ្គមាន ១២ គាថា ក្នុងបិយវគ្គមាន ១២ គាថា ក្នុងកោធវគ្គមាន ១៤ គាថា ក្នុងមលវគ្គមាន ២១ គាថា ក្នុងធម្មដ្ឋវគ្គមាន ១៧ គាថា ក្នុងមគ្គវគ្គមាន ១៦ គាថា ក្នុងបកិណ្ណកវគ្គមាន ១៦ គាថា និរយវគ្គនិងនាគវគ្គក្នុងនីមួយៗ មាន ១៤ គាថា ក្នុងតណ្ហាវគ្គមាន ២៦ គាថា ក្នុងភិក្ខុវគ្គមាន ២៣ គាថា ក្នុងព្រាហ្មណវគ្គដែលជាវគ្គទីបំផុតមាន ៤០ គាថា គាថា ៤២៣ គាថា ដែល ព្រះពុទ្ធអ្នកជាផៅពង់នៃព្រះអាទិត្យ ទ្រង់សម្តែង ហើយទុកក្នុងនិបាតក្នុងធម្មបទ ។

ចប់គាថាធម្មបទ

## អដ្ឋកថា
## រួមរឿងទាំងអស់

អដ្ឋកថានៃព្រះធម្មបទ មានប្រមាណ ៧២ ភាណវារៈ ដែលខ្ញុំម្ចាស់ប្រកាសរឿង ២៩៩ រឿងគឺ “ ក្នុងយមកវគ្គ ដែលជាវគ្គដំបូងនៃវគ្គទាំងអស់ ១៤ រឿង, ក្នុងអប្បមាទវគ្គ មាន ៩ រឿង, ក្នុងចិត្តវគ្គមាន ៩ រឿង, ក្នុង បុប្ផវគ្គមាន ១២ រឿង, ក្នុងពាលវគ្គមាន រឿង, ក្នុងបណ្ឌិតវគ្គមាន ១១ រឿង, ក្នុងអរហន្តវគ្គមាន ១០ រឿង, ក្នុងសហស្សវគ្គមាន ១៤ រឿង, ក្នុងបាបវគ្គមាន ១២ រឿង, ក្នុងទណ្ឌវគ្គមាន ១១ រឿង, ក្នុងជរាវគ្គមាន ៩ រឿង, ក្នុងអត្តវគ្គមាន ១០ រឿង, ក្នុងលោកវគ្គមាន ១១ រឿង, ក្នុងពុទ្ធវគ្គមាន ៩ រឿង, ក្នុង សុខវគ្គមាន ៨ រឿង, ក្នុងបិយវគ្គមាន ៩ រឿង, ក្នុងកោធវគ្គ មាន ៨ រឿង, ក្នុងមលវគ្គមាន ១២ រឿង, ក្នុងធម្មដ្ឋវគ្គមាន ១០ រឿង, ក្នុងមគ្គវគ្គ ១០ រឿង ក្នុងបកិណ្ណកវគ ៩ រឿង,

ក្នុងនិរយវគ្គ ៩ រឿង, ក្នុងនាគវគ្គ ៨ រឿង, ក្នុងតណ្ហាវគ្គ ១២ រឿង, ក្នុងភិក្ខុវគ្គ ១២ រឿង, ក្នុងព្រាហ្មណវគ្គ ៣៩រឿង, រួចនាទុកសមល្មម ដោយមិនសង្ខេបពេក មិនពិស្តារពេក ចប់ហើយដោយពាក្យមានប្រមាណប៉ុណ្ណេះ ។

ចប់អដ្ឋកថាធម្មបទ

# នាមពុទ្ធបរិសទ្យចូលបោះពុម្ពសៀវភៅ

*ពុទ្ធបរិសទ្យក្រុងព្រះសីហនុ តាមរយៈឧបាសក ង៉ែត សុផាន់*

*ឧ.សិ ជិន សាវេត និងស្វាមី ព្រមទាំងបុត្រ .......... ៥០ $*

*ឧ.ស ជា សុខុម និងឧ.សិ ងួន គឹមអ៊ីវ ............. ២០ $*

*ឧបាសិកា ស៊ូ មួយ .................................... ១០ $*

*ឧបាសិកា លាន សុខទី ព្រមទាំងបុត្រ ............... ១០ $*

*ឧបាសិកា ហ៊ុន សុផល ......................... ៥ $*

*ប្រាក់ទេសនាសង្ឃទានផ្ទះឧ.សិ ស៊ូ មួយ ដោយភិក្ខុ ហាមមុនី-សុបហាន លោកគ្រូ រៀម រដ្ឋា លោកគ្រូ ង៉ែត សុផាន់ .... ១៥០០០០ ៛*

*ឧបាសិកា តាំង អៀងស៊ុយ ..................... ៤០០០០ ៛*

*ឧបាសិកា សុខ ណៃ ..................... ៣០០០០ ៛*

*ឧ.ស ទន់ កាណែល និងភរិយា +បុត្រ ........... ៤៣០០០ ៛*

*ឧបាសិកា លឹម វួចសេង ..................... ២០០០០ ៛*

*លោក ម៉េង ថានី និងភរិយា +បុត្រ ............... ២០០០០ ៛*

| | | |
|---|---|---|
| ឧបាសិកា គីម សុង និងស្វាមី +បុត្រ | ............ | ២០០០០ ៛ |
| ឧបាសិកា អ៊ុក ស៊ីនី | .................... | ២០០០០ ៛ |
| ឧបាសិកា អ៊ុក ស៊ីណា +បុត្រ | .................... | ២០០០០ ៛ |
| ភិក្ខុ ណាន នីម | .................... | ២០០០០ ៛ |
| ឧបាសក ព្រំ ប៊ុក និងភរិយា | .................... | ២០០០០ ៛ |
| ឧ.ស ឃី សៀ និងឧ.សិ ងួន គីមលី | ............... | ២០០០០ ៛ |
| ឧ.សិ ជៀម អ៊ីវ និងស្វាមី +បុត្រ | ............... | ២០០០០ ៛ |
| ឧ.សិ ទូច សិរីគុណា និងស្វាមី | ................ | ១៥០០០ ៛ |
| ឧ.ស គុំ គង់ និងភរិយា +បុត្រ | ................ | ១៥០០០ ៛ |
| ឧ.សិ តឹប សារ៉ាក់ និងស្វាមី +បុត្រ | .............. | ១០០០០ ៛ |
| ឧ.ស ហ៊ីម ពន្ធី និងភរិយា +បុត្រ | ............... | ១០០០០ ៛ |
| ភិក្ខុ សេង ណារិទ្ធ | .................... | ១០០០០ ៛ |
| យុវជន វ៉ិត សុខា | .................... | ១០០០០ ៛ |
| ឧបាសិកា នៅ ម៉េត | .................... | ៥០០០ ៛ |
| ឧបាសិកា ងន ស៊ីម | .................... | ៥០០០ ៛ |
| ឧបាសិកា កង ម៉ាន | .................... | ៥០០០ ៛ |
| ឧ.ស អៀ សំភី និងភរិយា +បុត្រ | ............... | ៥០០០ ៛ |
| ឧបាសក យ៉ាង ប្រឹង និងភរិយា | ................ | ៥០០០ ៛ |
| ឧបាសិកា គីម មន | .................... | ៥០០០ ៛ |

ឧបាសិកា ង៉ែត នន ..................... ២០០០ ៛

បាត់ដំបង តាមរយៈឧបាសក ង៉ែត សុផាន់

ឧបាសក អ៊ូច សុវណ្ណ ..................... ៥ $

ប្រាក់សម្តែងធម៌ផ្ទះឧ.សិ នួន សួង .....

ដោយឧ.ស ង៉ែត សុផាន់ ..................... ១៦០០០ ៛

ឧបាសិកា នេត សន ..................... ១០០០០ ៛

ឧបាសិកា គី សៀង ..................... ១០០០០ ៛

ឧបាសិកា គី ចន្ទី ..................... ១០០០០ ៛

ឧបាសិកា នួន សួង ..................... ១០០០០ ៛

ឧ.ស ង៉ែត សុផល +ភរិយាសោម ស៊ីនួន ....... ១០០០០ ៛

ឧ.សិ ង៉ែត ចាន់ណា +ស្វាមីនួប សុផុន ........ ៥០០០ ៛

ឧបាសិកា ង៉ែត សុភា ..................... ៥០០០ ៛

ឧបាសិកា ង៉ែត រីម ..................... ៥០០០ ៛

ឧបាសក កែវ ង៉ាន់ ..................... ៥០០០ ៛

ឧបាសិកា ប្រាក់ សុខខឿន ............... ១០០០០ ៛

ឧបាសិកា អ៊ុន សារ៉ុម ..................... ៥០០០ ៛

ឧបាសិកា ប៉ាង វណ្ណា ..................... ៥០០០ ៛

យុវតី ភន ស្មី ..................... ៥០០០ ៛

យុវជន សន សុជា ..................... ៥០០០ ៛

ឧ.សិ សោម ផល្លី និងស្វាមី +បុត្រ ............. ៥០០០ ៛

យុវតី សន ស្រីនុច ..................... ១០០០ ៛

យុវសិស្ស កន ម៉ីម៉ី ..................... ១០០០ ៛

ឧបាសិកា ហេង លាត (វត្តគល់ទទឹង) ........... ១០ $

ឧបាសក ហ៊ិន ថលចិត្រា (វត្តគល់ទទឹង) ...... ១០០០០ ៛

.......................

## ពុទ្ធបរិស័ទឡូទៅ

ឧបាសិកា តាំង លីគាង (ផ្សារណាត់) ......... ១០ $

ឧបាសិកា ទូច សុម៉ាលី ..................... ៥ $

ឧ.សិ ជិប ឱរត្ន័ និងកូនចៅ ..................... ៤០០០០ ៛

ឧបាសិកា ឈើវ ចាំង ..................... ៣០០០០ ៛

ឧ.សិ ឯម សីថន ឧ.សិ កៅ នួន ................ ២៥០០០ ៛

ភិក្ខុ លី ចាន់ណោន ..................... ២០០០០ ៛

ស្រី រ័ត្ន សោ លាង ..................... ១០០០០ ៛

ឧបាសិកា ដួង សាមៀន ..................... ១០០០០ ៛

បងស្រី មាយ ចាន់លី និងបុត្រ ................... ១០០០០ ៛

អ្នកគ្រូ ជូ រេវត្តី និងបុត្រ លី មេត្តាឧត្តម ........ ៤ ក.

អ្នកគ្រូ ភិន ផល្លា ស្វាមី +បុត្រ .................. ៣ ក.

ឧ.ស ភិន កែវ ឧ.សិ ឡុង ហុង .................. ២ ក.

| | | |
|---|---|---|
| ឧបាសិកា លី គី និងកូនចៅ | .................... | ១ ក. |
| ឧបាសិកា ភិន ចន្ទា និងបុត្រ | .................... | ១ ក. |
| ប្អូន ចាន់ណា និងប្អូន កញ្ញា | .................... | ១ ក. |
| លោកគ្រូ អ៊ឹម អុល អ្នកស្រី ផូ សុផាត | ......... | ២ ក. |
| អៀម ប៊ុនធឿន និងភរិយា | .................... | ១ ក. |
| ឧបាសិកា សៀក ឡាង | .................... | ២០០០០ ៛ |
| ឧបាសិកា នុម វ៉ាត់ | ................... | ២០០០០ ៛ |
| ឧបាសិកា អ៊ី ផេង | ................... | ១០០០០ ៛ |
| ឧបាសិកា ឆាង វីន | ................... | ១០០០០ ៛ |
| ឧបាសិកា មោង ណី | ................... | ១០០០០ ៛ |